# កម្ពុជា

# ការផ្សារភ្ជាប់ប្រជាពលរដ្ឋនិងរដ្ឋាភិបាល



## ការវាយតំលៃទៅលើការរួមចំណែករបស់ សង្គមស៊ីវិលចំពោះអភិបាលកិច្ចល្អនៅកម្ពុជា

ខែ កុម្ភៈ ឆ្នាំ ២០០៩

ធនាគារពិភពលោក

# ការផ្សារភ្ជាប់ប្រជាពលរដ្ឋនិងរដ្ឋាភិបាល

## ការវាយតំលៃទៅលើការរួមចំណែករបស់សង្គមស៊ីវិល ចំពោះអភិបាលកិច្ចល្អនៅកម្ពុជា

**ធនាគារពិភពលោក**


**និពន្ធរបាយការណ៍ : ខាមិន ម៉ាលិណា និង គ្រីស្ទីនណា ឈឹម**

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងដោយ

មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់

ភ្នំពេញ

**ក្រុមស្រាវជ្រាវ**

គ្រីស្ទីនណា ឈឹម (អ្នកសំរបសំរួល)

| | |
|---|---|
| ហ៊ាង ផាត | ហាក់ សុចន្ទី |
| ស្វូ កិត្យា | ឈត ប៊ុនថង |
| ហេង គឹមវណ្ណ | ជេន សុជឿន |

ប្រែសំរួលអត្ថបទជាភាសាខ្មែរដោយ

**ហ៊ាង ផាត & លឹម រ៉ាមី**

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានរៀបរៀងឡើងក្រោមការដឹកនាំចាត់ចែងរបស់ លោក John Clark (អ្នកឯកទេសជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍សង្គមប្រចាំតំបន់អាស៊ីអាគ្នេយ៍) ។ ឯការស្រាវជ្រាវត្រូវបានធ្វើឡើងដោយ មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ដែលមានទីស្នាក់ការនៅភ្នំពេញ ។ របាយការណ៍នេះត្រូវបានសរសេររួមគ្នាដោយ លោកស្រី Carmen Malena (ទីប្រឹក្សាជាន់ខ្ពស់នៃធនាគារពិភពលោក) និងលោកស្រី Kristina Chhim (អ្នកសំរបសំរួលការស្រាវជ្រាវជាន់ខ្ពស់នៃមជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់) ។ ចំពោះការសិក្សាស្រាវជ្រាវត្រូវបានដឹកនាំដោយ លោកស្រី Kristina Chhim និងធ្វើឡើងដោយក្រុមអ្នកស្រាវជ្រាវមួយក្រុមដែលរួមមាន លោកស្រី ហាក់ សុចន្ទី, លោក ហ៊ាង ផាត, លោក ឈុត ប៊ុនថង, លោក ស៊ូ កិត្យា, លោក ជេន សុជឿន, និង លោក ហេង គឹមវណ្ណ ។ លោកស្រី Kristina Chhim ក៏ជាអ្នកដែលបានធ្វើការសិក្សាតាមឯកសារផងដែរ ដែលនេះគឺជាផ្នែកមួយបានរួមចំណែកដល់របាយការណ៍នេះ ។ ធនាគារពិភពលោក សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ការរួមចំណែកដ៏សំខាន់របស់សមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងប្រទេសដូចខាងក្រោម ដែលបានចូលរួមក្នុងការរៀបចំទំរង់នៃការសិក្សាស្រាវជ្រាវ និងផ្តល់មតិយោបល់ទៅលើរបកគំហើញ និងការវិភាគលទ្ធផលស្រាវជ្រាវ ។ ក្នុងនោះរួមមានលោក ឱក សេរីសោភក្តិ, លោក ឈិត សំអាត, លោកបណ្ឌិត មាស នី, លោក ច័ន្ទ សុផល, លោក យេង វីរៈ, លោក យ៉ង សាំងកុមារ, លោកស្រី Jenny Pearson, លោកស្រី Carol Strickler និង លោក Gijs Koop ។ ការសិក្សាស្រាវជ្រាវនេះក៏ទទួលបានការរួមចំណែកយ៉ាងធំធេងតាមរយៈការត្រួតពិនិត្យ និងការផ្តល់យោបល់ពី លោក Ian Porter, លោក Raja Iyer, លោកស្រី Nisha Agrawal, លោក Stephane Guimbert, លោក ឱក សេរីសោភក្តិ, លោក Andy Norton, លោក Jeff Thindwa, លោកស្រី Loty Salazar, លោក Petrarca Karetji, លោក Scott Guggenheim, លោក Bhuvan Bhatnagar, លោក Janmejay Singh, លោកស្រី Corazon (Dinky) Juliano-Soliman, លោកស្រី និល វណ្ណា , លោក Daniel Adler, លោក Luis Benveniste, លោក Tim Conway, លោកស្រី Mia Hyun, លោក ប៊ូ សារឿន និង លោក ព្រាប កុល (ដែលអ្នកទាំងអស់គ្នានេះសុទ្ធសឹងជាបុគ្គលិករបស់ធនាគារពិភពលោក) ក៏ដូចជា លោក Roger Henke, លោកស្រី Caroline Hughes, លោក ធន សារាយ និង លោកស្រី Eva Mysliwiec ។ ការពិភាក្សាជាក្រុមជាច្រើន ដែលត្រូវបានធ្វើឡើងនៅក្នុងខែ មេសា ឆ្នាំ២០០៨ បានផ្តល់នូវព័ត៌មានត្រលប់ និងយោបល់ដ៏មានតំលៃជាច្រើនទៅលើសេចក្តីព្រាងនៃរបាយ-ការណ៍នេះ ។ ធនាគារពិភពលោកសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់អ្នកតំណាងគ្រប់រូប (ជាង ៨០ នាក់) មកពីភាគីរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ ក្រុមអ្នកឯកទេស សមាគមវិជ្ជាជីវៈ និងសមាគមពាណិជ្ជកម្ម សហជីព សមាគមប្រព័ន្ធផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល បណ្តាញអង្គការក្រៅរដ្ឋាភិបាល និងម្ចាស់ជំនួយអន្តរជាតិ ដែលបានចូលរួមនៅក្នុងការពិភាក្សាទាំងនេះ ។ សូមថ្លែងអំណរគុណដល់បុគ្គលិក និងដៃគូរបស់អង្គការសេដាក ខេត្តតាកែវ ដែលបានជួយរៀបចំអោយមានការពិភាក្សាប្រកបដោយផ្លែផ្កាជាមួយអ្នកតំណាងក្រុមកសិករក្នុងមូលដ្ឋាន មេដឹកនាំសហគមន៍ អាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិលនៅក្នុងខេត្តតាកែវ ។ ក្រុមអ្នកស្រាវជ្រាវសូមថ្លែងអំណរគុណជាពិសេសដល់លោកស្រី Nisha Agrawal (ប្រធានធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា) ចំពោះការដឹកនាំ និងការគាំទ្រពេញទំហឹងរបស់លោកស្រី នៅក្នុងការសិក្សាស្រាវជ្រាវនេះ ។ ក្រុមអ្នកស្រាវជ្រាវក៏សូមថ្លែងអំណរគុណដល់ លោកស្រី អ៊ូ ណារីយ៉ា, កញ្ញា ជា លីណា (ការិយាល័យធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា) និង

លោកស្រី Nona Sachdeva (ធនាគារពិភពលោកប្រចាំតំបន់អាស៊ីអាគ្នេយ៍, ទីក្រុងវ៉ាស៊ីនតោនឌីស៊ី) សំរាប់ការគាំទ្រផ្នែករដ្ឋបាល និងភស្តុភារដ៏ប៉ិនប្រសប់ ការថតចម្លង ពិនិត្យកែសំរួល និងការចាត់ចែងត្រួតពិនិត្យការបកប្រែរបាយការណ៍ជាភាសាខ្មែរ។ ជាចុងក្រោយ ការសិក្សាស្រាវជ្រាវនេះពុំអាចនឹងសំរេចបានឡើយប្រសិនបើគ្មានកិច្ចសហការពីរដ្ឋាភិបាលកម្ពុជា និងឆន្ទៈនៃការចូលរួមពីអ្នកផ្តល់បទសំភាសន៏ អ្នកចូលរួមនៅក្នុងការស្ទាបស្ទង់មតិ និងអ្នកចូលរួមនៅក្នុងក្រុមពិភាក្សា ដែលបានចំណាយពេលវេលាដ៏មានតំលៃរបស់ខ្លួន ដើម្បីជួយដល់ការសិក្សាស្រាវជ្រាវនេះអោយសំរេចទៅបានប្រកបដោយជោគជ័យ ។

# ពាក្យសរសេរកាត់

| | |
|---|---|
| ADHOC | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា |
| BSO | អង្គការពន្លឺសង្គម |
| CAS | មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ |
| CBO | អង្គការសហគមន៍ |
| CCC | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា |
| CCHR | មជ្ឈមណ្ឌលកម្ពុជាដើម្បីសិទ្ធិមនុស្ស |
| CCSP | គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CEDAC | មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CIC | មជ្ឈមណ្ឌលព័ត៌មានសហគមន៍ |
| CIDA | ភ្នាក់ងារសំរាប់ការអភិវឌ្ឍន៍អន្តរជាតិកាណាដា |
| CLEC | មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ |
| COMFREL | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា |
| COPCEL | យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា |
| CSD | មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម |
| CSO | អង្គការសង្គមស៊ីវិល |
| CTSWF | សហព័ន្ធទេសចរណ៍ និង បុគ្គលិកបំរើសេវានៅកម្ពុជា |
| DP | ដៃគូអភិវឌ្ឍន៍ |
| DMC | ដែប៉ាតេម៉ង់ផ្សព្វផ្សាយ និងទំនាក់ទំនង |
| FA | សមាគមកសិករ |
| FGD | ក្រុមពិភាក្សា |
| GTZ | សហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ |
| IEC | ព័ត៌មាន-ការអប់រំ-ទំនាក់ទំនង |
| INGO | អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ |
| J4P | គំរោងយុត្តិធម៌សំរាប់ជនក្រីក្រ |
| KAP | ក្រុមអភិវឌ្ឍន៍ភូមិ |
| KID | វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ |
| K-NAN | បណ្តាញតស៊ូមតិនៃអង្គការក្រៅរដ្ឋាភិបាលខេត្តកំពង់ចាម |
| MC&D | ក្រុមហ៊ុនប្រឹក្សា អភិវឌ្ឍន៍ និងព័ត៌មាន |

| | |
|---|---|
| MEDiCAM | ( បណ្តាញអង្គការសុខភាពក្នុងប្រទេសកម្ពុជា) |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MONASRI | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MP | សមាជិកសភា |
| NDI | វិទ្យាស្ថានជាតិប្រជាធិបតេយ្យ |
| NEP | ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| ODA | ជំនួយអភិវឌ្ឍន៍ក្រៅប្រទេស |
| OWSO | ការិយាល័យច្រកចេញចូលតែមួយ |
| PACOCO | គណៈកម្មាធិការវត្តសំរាប់ការសំរបសំរួល |
| PACT | អង្គការ Pact កម្ពុជា |
| PAP | កម្មវិធីសកម្មភាពអាទិភាព |
| PECSA | កម្មវិធីពង្រឹងសមត្ថភាពដើម្បីការទទួលខុសត្រូវសង្គម |
| PETS | ការអង្កេតពីការតាមដានចំណាយសាធារណៈ |
| RUPP | សកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| RNK | វិទ្យុជាតិកម្ពុជា |
| SAc | ការទទួលខុសត្រូវសង្គម |
| SIDA | ភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត |
| SSC | គណៈកម្មាធិការទ្រទ្រង់សាលារៀន |
| TAF | មូលនិធិអាស៊ី |
| TI | តម្លាភាពអន្តរជាតិ |
| UNTAC | អាជ្ញាធរបណ្តោះអាសន្នសហប្រជាជាតិប្រចាំប្រទេសកម្ពុជា |
| USAID | ភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ |
| WB | ធនាគារពិភពលោក |
| WMC | មណ្ឌលព័ត៌មានស្ត្រីកម្ពុជា |
| YCC | ក្រុមប្រឹក្សាយុវជនកម្ពុជា |

# មាតិកា


**សេចក្តីសង្ខេបប្រតិបត្តិ**......i

១. ការរួមចំណែករបស់សង្គមស៊ីវិលចំពោះអភិបាលកិច្ចល្អនៅកម្ពុជា......i

២. ការវិភាគទៅលើលក្ខខ័ណ្ឌ និងសមត្ថភាពដើម្បីការទទួលខុសត្រូវសង្គមនៅកម្ពុជា...... iv

៣. ការពង្រឹងការទទួលខុសត្រូវសង្គមនៅកម្ពុជា......xvi

**១. ការរួមចំណែករបស់សង្គមស៊ីវិលចំពោះអភិបាលកិច្ចល្អនៅកម្ពុជា......១**

១.ក. សេចក្តីផ្តើម......១

១.ក.១. ទិដ្ឋភាពរួមនៃរបាយការណ៍......៣

១.ក.២. វិធីសាស្ត្រស្រាវជ្រាវ......៤

១.ខ. ទិដ្ឋភាពសំខាន់ៗនៃបរិបទកម្ពុជា......៥

១.ខ.១. ដំណាក់កាលក្រោយសង្គ្រាម......៥

១.ខ.២. កត្តានយោបាយ......៦

១.ខ.៣. កត្តាវប្បធម៌-សង្គម......៩

១.ខ.៤. ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល......១០

១.ខ.៥. សង្គមស៊ីវិល......១២

១.ខ.៦. ទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល......១៦

១.គ. រូបភាពនៃការទទួលខុសត្រូវសង្គមនៅកម្ពុជា......១៧

១.គ.១. ការរួមចំណែកដល់គោលនយោបាយ និង ផែនការសាធារណៈ......១៨

១.គ.២. ការឃ្លាំមើលចំណូលសាធារណៈ......២០

១.គ.៣. ការចូលរួមយោបល់អំពីថវិកាសាធារណៈ......២០

១.គ.៤. ការឃ្លាំមើលចំណាយសាធារណៈ...... ២១

១.គ.៥. ការកែលំអសេវាសាធារណៈ......២៣

១.គ.៦. ការត្រួតពិនិត្យវិស័យសាធារណៈ......២៥

**២. ការវិភាគទៅលើលក្ខខ័ណ្ឌ និងសមត្ថភាពដើម្បីការទទួលខុសត្រូវសង្គមនៅកម្ពុជា......២៦**

២.ក. អំពីព័ត៌មាន......២៦

២.ក.១. ប្រភពនៃព័ត៌មានសាធារណៈ......២៦

២.ក.២. ចំណាប់អារម្មណ៍ជាអាទិភាពរបស់ប្រជាពលរដ្ឋ......២៨

២.ក.៣. កង្វះការទាមទាររកព័ត៌មាន...........................................................................................................២៩
២.ក.៤. កង្វះតម្លាភាព និងលទ្ធភាពទទួលបានព័ត៌មានសាធារណៈ...................................................................៣០
២.ក.៥. ប្រជាពលរដ្ឋមានព័ត៌មាន និងចំណេះដឹងតិច........................................................................................៣២
២.ក.៦. តួនាទីអង្គការសង្គមស៊ីវិលអំពីបញ្ហាព័ត៌មាន.........................................................................................៣៤
២.ក.៧. អនុសាសន៍ និងសកម្មភាពដែលគួរអនុវត្ត..........................................................................................៣៩
២.ខ. ការបញ្ចេញមតិ............................................................................................................................៤២
២.ខ.១. ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ.....................................................................................................៤២
២.ខ.២ ការផ្តល់អំណាចដល់ប្រជាពលរដ្ឋ.....................................................................................................៤៨
២.ខ.៣. ការពឹងផ្អែកយ៉ាងធំធេងទៅលើអ្នកដឹកនាំនៅមូលដ្ឋាន..........................................................................៤៩
២.ខ.៤. កង្វះយន្តការសំរាប់ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ...........................................................................៥១
២.ខ.៥. អនុសាសន៍ និងសកម្មភាពដែលគួរអនុវត្ត.........................................................................................៥៩
២.គ. ការរួបរួមជាសមាគម.....................................................................................................................៦២
២.គ.១. សមាគម និងការរួបរួមរបស់ប្រជាពលរដ្ឋ..............................................................................................៦២
២.គ.២. បញ្ហាប្រឈមផ្ទៃក្នុងផ្នែកអភិបាលកិច្ចរបស់សង្គមស៊ីវិល..............................................................................៦៧
២.គ.៣. ការកសាងបណ្តាញ និងសម្ព័ន្ធភាពរបស់សង្គមស៊ីវិល .............................................................................៧១
២.គ.៤. អនុសាសន៍ និងសកម្មភាពដែលគួរអនុវត្ត..........................................................................................៧៤
២.ឃ. ការចូលរួមនិងការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា...............................................................................៧៧
២.ឃ.១. ការបង្កើតបរិយាកាសអំណោយផល និងស្ថាប័ននីយកម្មនៃសិទ្ធិរបស់ប្រជាពលរដ្ឋ-អង្គការសង្គមស៊ីវិល.......៧៨
២.ឃ.២. ពី "ការតស៊ូមតិ" ទៅជាការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា...........................................................៧៩
២.ឃ.៣. ការលើកកំពស់ប្រសិទ្ធិភាពយន្តការទទួលខុសត្រូវដែលមានស្រាប់តាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ ...៨៤
២.ឃ.៤. ការពង្រីកឱកាស និងយន្តការសំរាប់ការពិភាក្សា និងការចូលរួម.................................................................៩២
២.ឃ.៥. អនុសាសន៍ និងសកម្មភាពដែលគួរអនុវត្ត........................................................................................៩៣
**៣. ការពង្រឹងការទទួលខុសត្រូវសង្គមនៅកម្ពុជា**.........................................................................................៩៨
៣.ក. សេចក្តីសន្និដ្ឋាន.........................................................................................................................៩៨
៣.ខ. សកម្មភាពជាអាទិភាព.....................................................................................................................៩៩
៣.ខ.១. សកម្មភាពអាទិភាពសំរាប់រាជរដ្ឋាភិបាលកម្ពុជា..................................................................................៩៩
៣.ខ.២. សកម្មភាពអាទិភាពសំរាប់អង្គការសង្គមស៊ីវិល....................................................................................១០០
៣.ខ.៣. សកម្មភាពអាទិភាពសំរាប់ដៃគូអភិវឌ្ឍន៍...........................................................................................១០១
**ឯកសារយោង**...............................................................................................................................១០៣
**សន្ទានុក្រម**...................................................................................................................................១០៩

## តារាងប្រអប់


ប្រអប់ទី ១ ទិដ្ឋភាពរួមនៃអង្គការសង្គមស៊ីវិលនៅកម្ពុជា ---------------------------------------- ១៣

ប្រអប់ទី ២ ការលើកកំពស់ភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំ-សង្កាត់ និងអង្គការសហគមន៍ - កម្មវិធីLAAR ------- ១៩

ប្រអប់ទី ៣ គំរោងឃ្លាំមើលថវិកាជាតិរបស់អង្គការ NGO Forum ---------------------------------- ២២

ប្រអប់ទី ៤ សមាគមសុខភាពភូមិ - ក្រុមអភិវឌ្ឍន៍ភូមិ ------------------------------------------------ ២៤

ប្រអប់ទី ៥ រូបភាពនៃ "ទីប្រឹក្សាប្រជាពលរដ្ឋ" ដែលមានប្រជាប្រិយភាព ------------------------------------- ៣៨

ប្រអប់ទី ៦ ឧទាហរណ៍នៃការពង្រឹងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ នៅក្នុងបរិបទវិមជ្ឈការ ---------------- ៤៧

ប្រអប់ទី ៧ ឧទាហរណ៍នៃការបោះពុម្ពផ្សាយតាមតំបន់ដើម្បីជាយន្តការបញ្ចេញមតិរបស់ប្រជាពលរដ្ឋមូលដ្ឋាន ----- ៥៤

ប្រអប់ទី ៨ សមាគមកសិកររបស់អង្គការសេដាក ------------------------------------------------------- ៦៦

ប្រអប់ទី ៩ បណ្តាញតស៊ូមតិនៃអង្គការក្រៅរដ្ឋាភិបាលប្រចាំខេត្តកំពង់ចាម (K-NAN) ---------------------- ៧២

ប្រអប់ទី១០ គំរោង "បណ្តាញអ្នកភូមិ" ដែលគាំទ្រដោយអង្គការ GTZ --------------------------------- ៧៣

ប្រអប់ទី១១ ការលំបាកនៅក្នុងការផ្លាស់ប្តូរពី "ស្ថានភាពសង្គមបច្ចុប្បន្ន" អោយទៅជា "ចលនាសង្គម" ------------ ៨១

ប្រអប់ទី១២ គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ ----------------------------------------------------- ៨៦

ប្រអប់ទី១៣ បទពិសោធន៍របស់សមាគមទ្រទ្រង់សាលារៀន និងគណៈកម្មការទ្រទ្រង់សាលារៀនខេត្តកំពង់ធំ ------- ៨៩


## តារាងរូបភាព


រូបភាពទី ១ ឧទាហរណ៍នៃការទទួលខុសត្រូវសង្គមនៅកម្ពុជា ------------------------------------- ១៧

រូបភាពទី ២ ប្រភពសំខាន់ៗនៃព័ត៌មានសាធារណៈ---------------------------------------------------- ២៧

រូបភាពទី ៣ ប្រភពសំខាន់ៗនៃព័ត៌មានសាធារណៈសំរាប់ប្រជាពលរដ្ឋដែល "ក្រីក្របំផុត" -------------------- ២៨

រូបភាពទី ៤ ចំណាប់អារម្មណ៍ជាអាទិភាពរបស់ប្រជាពលរដ្ឋ ទាក់ទងទៅនឹងព័ត៌មានសាធារណៈ ---------------- ២៩

រូបភាពទី ៥ ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីច្បាប់ (បែងចែកទៅតាមភេទ) ---------------------------- ៣៣

រូបភាពទី ៦ ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីថវិកាជាតិ ------------------------------------------ ៣៣

រូបភាពទី ៧ ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីថវិកាក្រុមប្រឹក្សាឃុំ-សង្កាត់ ------------------------------ ៣៤

រូបភាពទី ៨ កំរិតនៃសកម្មភាព សមត្ថភាព និងភាពសំខាន់របស់អង្គការសង្គមស៊ីវិលអំពីព័ត៌មានសាធារណៈ- ការងារផ្សព្វផ្សាយ ---------------------------------------------------------------------- ៣៥

រូបភាពទី ៩ ស្ទ័យវាយតំលៃលើសមត្ថភាពរបស់អង្គការក្រៅរដ្ឋាភិបាលទាក់ទងទៅនឹងការទទួលខុសត្រូវសង្គម------ ៣៦

រូបភាពទី ១០ ភាគរយនៃប្រជាពលរដ្ឋដែលបានចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ -------------------- ៤៣

រូបភាពទី ១១ ហេតុផលរបស់ប្រជាពលរដ្ឋក្នុងការមិនចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ ------------------- ៤៤

រូបភាពទី ១២ ហេតុផលរបស់ប្រជាពលរដ្ឋក្នុងការមិនចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ (តាមអាយុ) ------ ៤៤

រូបភាពទី ១៣  ចរិតលក្ខណៈនៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ ------------------៤៥

រូបភាពទី ១៤  ទស្សនៈប្រជាពលរដ្ឋអំពីអ្នកដែលអាចការពារពួកគេពីការបង់ថ្លៃឈ្នួលក្រៅផ្លូវការទៅអោយអាជ្ញាធរ ---៤៩

រូបភាពទី ១៥  ឥទ្ធិពលរបស់ប្រជាពលរដ្ឋទៅលើការសំរេចចិត្តអំពីថវិកាជាតិ ---------------------------------៤៩

រូបភាពទី ១៦  តើប្រជាពលរដ្ឋត្រូវប្តឹងទៅនរណាអំពីបញ្ហាសេវាសាធារណៈ? --------------------------------៥០

រូបភាពទី ១៧  កំរិតសមាជិកភាពនៅក្នុងអង្គការសង្គមស៊ីវិល ---------------------------------------------៦២

រូបភាពទី ១៨  សមាជិកភាពរបស់អង្គការសង្គមស៊ីវិលតាមអាយុ ------------------------------------------៦៣

រូបភាពទី ១៩  សមាជិកភាពរបស់អង្គការសង្គមស៊ីវិលតាមតំបន់ --------------------------------------------៦៣

រូបភាពទី ២០  សមាជិកភាពរបស់អង្គការសង្គមស៊ីវិលតាមប្រភេទអង្គការ និងអាយុ --------------------------៦៤

រូបភាពទី ២១  ស្វ័យវាយតំលៃរបស់អង្គការក្រៅរដ្ឋាភិបាលអំពីការគ្រប់គ្រងផ្ទៃក្នុង ---------------------------៧០

រូបភាពទី ២២  ឥទ្ធិពលរបស់អង្គការក្រៅរដ្ឋាភិបាលតាមការយល់ឃើញរបស់ខ្លួនទៅលើដំណើរការអភិបាលកិច្ច -------៨០

រូបភាពទី ២៣  ការយល់ឃើញរបស់អង្គការក្រៅរដ្ឋាភិបាលអំពីឧបសគ្គចំពោះគំនិតផ្តួចផ្តើមផ្នែកទទួលខុសត្រូវសង្គម --- ៨២

រូបភាពទី ២៤  ប្រភេទគំនិតផ្តួចផ្តើមផ្នែកការទទួលខុសត្រូវសង្គមនៅកម្ពុជានាពេលបច្ចុប្បន្ន--------------------៨៣

រូបភាពទី ២៥  តំរូវការសមត្ថភាពរបស់អង្គការក្រៅរដ្ឋាភិបាលដើម្បីកែលំអសកម្មភាពទទួលខុសត្រូវសង្គម ---------៨៤

រូបភាពទី ២៦  ការរីកចំរើនជុំវិញការឆ្លើយតបរបស់អាជ្ញាធរឃុំ-សង្កាត់ ----------------------------------៨៦

រូបភាពទី ២៧  ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីគណៈកម្មាធិការគាំទ្រសាលារៀន --------------------------៨៨

# សង្ខេបប្រតិបត្តិ

## ១. ការរួមចំណែករបស់សង្គមស៊ីវិលចំពោះអភិបាលកិច្ចល្អនៅកម្ពុជា

### ១.ក. សេចក្តីផ្តើម

១. អភិបាលកិច្ចត្រូវបានទទួលស្គាល់ថាជាបញ្ហាប្រឈមយ៉ាងធ្ងន់ធ្ងរបំផុតចំពោះការអភិវឌ្ឍន៍នៅកម្ពុជា ។ កិច្ចការអភិបាលកិច្ចល្អតំរូវអោយមានមិនត្រឹមតែការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏តំរូវអោយមានផងដែរនូវការទាមទារយ៉ាងសកម្មពីប្រជាពលរដ្ឋ និងសង្គមស៊ីវិល ។ បច្ចុប្បន្ននេះរាជរដ្ឋាភិបាលមានគំនិតផ្តួចផ្តើមផ្សេងៗ ដើម្បីកែលំអអភិបាលកិច្ច ដោយផ្តើមចេញពី “ផ្នែកខាងក្នុង” ។ ការសិក្សានេះផ្តោតជាសំខាន់ទៅលើតួនាទី (សិទ្ធិ និងករណីយកិច្ច) របស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល ក្នុងការជំរុញនូវ *ការទាមទារ* ប្រកបដោយប្រសិទ្ធិភាព *អោយមានអភិបាលកិច្ចល្អ* ។

២. *ការទទួលខុសត្រូវសង្គម* សំដៅដល់បណ្តុំសកម្មភាព និងយន្តការទាំងឡាយ (លើសពីការបោះឆ្នោត) ដែលប្រជាពលរដ្ឋអាចយកមកប្រើប្រាស់ដើម្បីជួយអោយរដ្ឋាភិបាលកាន់តែមានប្រសិទ្ធិភាព និងមានការទទួលខុសត្រូវ ហើយក៏សំដៅដល់សកម្មភាពនានារបស់រដ្ឋាភិបាល សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងតួអង្គដទៃទៀតក្នុងសង្គម ដែលលើកកំពស់ ឬបង្កលក្ខណៈងាយស្រួលអោយមានកិច្ចខិតខំប្រឹងប្រែងបែបនេះដែរ ។ តួយ៉ាងនៃការទទួលខុសត្រូវសង្គមរួមមាន កិច្ចខិតខំរបស់ប្រជាពលរដ្ឋ ឬអង្គការសង្គមស៊ីវិលក្នុងការ :

- ទទួលព័ត៌មានគ្រប់គ្រាន់អំពីកម្មវិធី សកម្មភាព និងគំរោងថវិការបស់រដ្ឋាភិបាល (ដូចជាតាមរយៈការទទួលបានឯកសារ ឬចូលរួមក្នុងកិច្ចប្រជុំសាធារណៈ)
- សំដែងចេញជាសាធារណៈនូវមតិយោបល់ និងតំរូវការរបស់ខ្លួន (ដូចជាតាមរយៈការស្ទាបស្ទង់មតិជាសាធារណៈ វេទិកាសាធារណៈ ឬកម្មវិធី "ជជែកពិភាក្សា" តាមវិទ្យុ)
- វិភាគ និងផ្តល់យោបល់ទៅលើឯកសារសាធារណៈសំខាន់ៗ (ដូចជាការវិភាគដោយឯករាជ្យទៅលើគោលនយោបាយ ឬគំរោងថវិកា)
- ឃ្លាំមើលការចំណាយសាធារណៈ (ដូចជាថវិកាសំរាប់សាលារៀន ឬមូលនិធិក្រុមប្រឹក្សាឃុំ-សង្កាត់)
- ឃ្លាំមើល និងវាយតំលៃទៅលើសេវាកម្មនានារបស់រដ្ឋ (ដូចជាការធ្វើសវនកម្មសង្គម ប័ណ្ណរាយការណ៏របស់ប្រជាពលរដ្ឋ ឬប័ណ្ណដាក់ពិន្ទុរបស់សហគមន៏)
- ពិនិត្យមើលទៅលើសកម្មភាពរបស់រដ្ឋាភិបាល (ដូចជា តាមរយៈការយកព័ត៌មានបែបស៊ើបអង្កេត ឬការស្ទាបស្ទង់មតិអំពីអំពើពុករលួយ)
- រួមចំណែកក្នុងដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តជាសាធារណៈ (ដូចជា ការចូលរួមរបស់ប្រជាពលរដ្ឋ ឬអង្គការសង្គមស៊ីវិល នៅក្នុងក្រុមប្រឹក្សាសាធារណៈ ឬក្រុមការងារផ្សេងៗ) ។

៣. វិធីសាស្ត្រដូចរៀបរាប់ខាងលើនេះ ពុំមែនដើរតួនាទីជំនួសយន្តការផ្លូវការនៃការទទួលខុសត្រូវនោះទេ ប៉ុន្តែផ្ទុយទៅវិញគឺជាការបំពេញបន្ថែម និងពង្រឹងដល់យន្តការផ្លូវការទាំងនោះ ។ ដូច្នេះហើយ ការសិក្សានេះគឺធ្វើការវាយតំលៃទៅលើការអនុវត្តន៏ការទទួលខុសត្រូវសង្គមនាពេលបច្ចុប្បន្ននៅកម្ពុជា ដោយកំណត់រកឧបសគ្គ និងឱកាសចំបងៗ ព្រមទាំងផ្តល់ជាយោបល់ពីការកែតំរូវ និងសកម្មភាពជាអាទិភាពដែលគួរអនុវត្តន៏ ។

## ១.២. ទិដ្ឋភាពសំខាន់ៗនៃបរិបទកម្ពុជា

៤. ស្ថានភាពនៃការចូលរួមរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវសង្គមនៅកម្ពុជា បានទទួលរងនូវឥទ្ធិពលពីកត្តាបរិបទសំខាន់ៗមួយចំនួន ។ *សង្គ្រាមដែលទើបបញ្ចប់នាពេលថ្មីៗ* បានធ្វើអោយសេចក្តីទុកចិត្ត និងសាមគ្គីភាពសង្គមធ្លាក់ចុះ ព្រមទាំងធ្វើអោយសកម្មភាពរួមរបស់សហគមន៏ ជាពិសេសនៅតំបន់ជនបទ មានការថយចុះ ។ សង្គ្រាមដ៏រ៉ាំរ៉ៃនោះក៏បានបំបាក់ស្មារតីប្រជាពលរដ្ឋអោយមានការខ្លាចរអារចំពោះអាជ្ញាធរ និងធ្វើអោយពួកគេមានសេចក្តីប្រាថ្នាយ៉ាងជ្រាលជ្រៅចង់បានសន្តិភាព និងភាពសុខុដុមក្នុងសង្គម ។

៥. *កត្តានយោបាយ* ក៏មានឥទ្ធិពលយ៉ាងធំធេងទៅលើការចូលរួមរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវសង្គមផងដែរ ។ លទ្ធិប្រជាធិបតេយ្យពហុបក្សបានលេចជារូបរាងឡើងហើយមែន ប៉ុន្តែនៅមានលក្ខណៈក្មេងខ្ចីនិងដោយអន្លើនៅឡើយ ។ បើទោះបីជារចនាសម្ព័ន្ធនយោបាយកំពុងតែមានការផ្លាស់ប្តូរគួរអោយកត់សំគាល់ក្តី ក៏រដ្ឋបាលរបស់កម្ពុជានៅតែបន្តទទួលរងឥទ្ធិពលពីការគ្រប់គ្រងតាមបែបប្រពៃណី និងតាមបែបទំនាក់ទំនងចៅហ្វាយនាយ-កូនចៅនៅឡើយ ។ អំណាចច្រើនតែត្រូវបានប្រមូលផ្តុំនៅក្នុងដៃបុគ្គល ជាជាងនៅក្នុងស្ថាប័ន ដែលកត្តានេះបង្កអោយប្រជាពលរដ្ឋមានការលំបាកក្នុងការពឹងផ្អែកទៅលើយន្តការការិយាធិបតេយ្យ ។ ប្រពៃណីនៃការទទួលខុសត្រូវ "ពីថ្នាក់ក្រោមចំពោះថ្នាក់លើ" ជាជាង "ពីថ្នាក់លើចំពោះថ្នាក់ក្រោម" ដ៏តឹងរ៉ឹងបានបង្កអោយមាននូវបញ្ហាប្រឈមមួយ ។ ប៉ុន្តែដំណើរការវិមជ្ឈការ និងវិសហមជ្ឈការនាពេលបច្ចុប្បន្នបានផ្តល់នូវឱកាសដ៏សំខាន់មួយដើម្បីធ្វើអោយរដ្ឋាភិបាល "កាន់តែបានខិតជិតប្រជាជន" ។

៦. *កត្តាសង្គម និងវប្បធម៌* មានឥទ្ធិពលយ៉ាងសំខាន់ ហើយបច្ចុប្បន្ននេះក៏កំពុងស្ថិតក្នុងសភាពប្រែប្រួលផងដែរ ។ ប្រពៃណីនៃសង្គមកម្ពុជា មានឋានានុក្រមច្បាស់លាស់ ដោយសង្កត់ធ្ងន់ទៅលើការគោរពចំពោះអាជ្ញាធរ ហើយពុំសូវរាប់ស្ត្រី និងក្រុមដទៃទៀតដែលពុំសូវមានអំណាចបញ្ចូលទៅក្នុងដំណើរការសំរេចចិត្តជាសាធារណៈឡើយ ។ បើទោះបីជាសព្វថ្ងៃនេះមានការផ្លាស់ប្តូរខ្លះនៅក្នុងចំណោមយុវជនផ្នែកឥរិយាបថ និងគុណតំលៃក្តី ក៏វិធីសាស្ត្រនានាសំរាប់លើកកំពស់ការត្រួតពិនិត្យ និងឃ្លាំមើលយ៉ាងសកម្មរបស់ប្រជាជនទៅលើសកម្មភាពរបស់រដ្ឋាភិបាល នឹងជួបប្រទះបញ្ហាប្រឈមស្រួចស្រាល់ ។

៧. *ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល* ក៏កំពុងតែវិវត្តន៏គួរអោយកត់សំគាល់ផងដែរ ប៉ុន្តែប្រជាពលរដ្ឋកម្ពុជាជាច្រើន ជាពិសេសអ្នកដែលមានវ័យចំណាស់ និងប្រជាពលរដ្ឋដែលរស់នៅតំបន់ជនបទ ច្រើនតែមានទស្សនៈបែបបិតុនិយមយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល ពោលគឺផ្តល់ការទុកចិត្តអោយរដ្ឋាភិបាលជាអ្នកធ្វើការសំរេចចិត្តជំនួសខ្លួន ។ ហេតុដូច្នេះហើយពួកគាត់ពុំសូវគិតគូរច្រើនពីបញ្ហាសិទ្ធិប្រជាពលរដ្ឋ ការផ្តល់អំណាចដល់ប្រជាពលរដ្ឋ ឬអំពីកាតព្វកិច្ចរបស់មន្ត្រីរដ្ឋាភិបាលដែលជាអ្នកបំពេញភារកិច្ចនោះទេ ។

៨. *សង្គមស៊ីវិល* នៅកម្ពុជាក៏ជាផលមួយនៃប្រវត្តិសាស្ត្រដ៏ពិសេសផ្នែកនយោបាយ និងសង្គមរបស់ប្រទេសនេះដែរ ។ អង្គការក្រៅរដ្ឋាភិបាលដែលមានលក្ខណៈជាអាជីពភាគច្រើននៅកម្ពុជាសព្វថ្ងៃនេះ មួយចំណែកធំកើតឡើងដោយសារឥទ្ធិពល និងជំនួយផ្នែកហិរញ្ញវត្ថុពីម្ចាស់ជំនួយអន្តរជាតិ ជាជាងដោយសារការបើកចំហបន្តិចម្តងៗនៃឱកាសបែបប្រជាធិបតេយ្យ ការរីកដុះដាលដោយឯកឯងនៃអង្គការសហគមន៍ ការកកើតមាននូវវប្បធម៌ស្ម័គ្រចិត្តនិងសកម្មជនសង្គម ឬសមាគមសប្បុរសធម៌របស់មនុស្សក្នុងវណ្ណៈកណ្តាល ។ អង្គការក្រៅរដ្ឋាភិបាលមានការពឹងផ្អែកយ៉ាងខ្លាំងទៅលើម្ចាស់ជំនួយ ហើយភាគច្រើនមិនសូវមានការផ្សារភ្ជាប់ជាមួយសហគមន៍មូលដ្ឋានឡើយ ។ ប្រសិនបើសង្គមស៊ីវិល ត្រូវបានចាត់ទុកថាជា "ដែនសាធារណៈដែលប្រជាពលរដ្ឋអាចប្រាស្រ័យទាក់ទងគ្នាដោយសេរីដើម្បីលើកកំពស់ផលប្រយោជន៍រួម" នោះ អញ្ចឹងសង្គមស៊ីវិលនៅកម្ពុជានៅមានភាពទន់ខ្សោយនៅឡើយ ។ ការប្រាស្រ័យទាក់ទងគ្នាជាលក្ខណៈស្ថាប័នរវាងអង្គការសង្គមស៊ីវិលកម្ពុជាជាមួយនឹងរដ្ឋាភិបាល នៅមានកំរិតតិចតួចណាស់ ។

## ១.គ. រូបភាពនៃការទទួលខុសត្រូវសង្គមនៅកម្ពុជា

៩. អង្គការក្រៅរដ្ឋាភិបាលបានរួមចំណែកយ៉ាងសំខាន់ដល់ការកើតមាននៃវប្បធម៌ប្រជាធិបតេយ្យនៅកម្ពុជា ជាពិសេសតាមរយៈការលើកកំពស់ការយល់ដឹង និងសកម្មភាពបណ្តុះបណ្តាល ប៉ុន្តែបើនិយាយពី*ការរួមចំណែករបស់អង្គការសង្គមស៊ីវិលចំពោះអភិបាលកិច្ចល្អ* តាមរយៈការស្វែងរក និងផ្សព្វផ្សាយព័ត៌មានអំពីរដ្ឋាភិបាល ការចូលរួមនៅក្នុងដំណើរការពិភាក្សា និងការសំរេចចិត្ត ក៏ដូចជាការធ្វើអោយរដ្ឋាភិបាលមានការទទួលខុសត្រូវនោះ គឺនៅមានលក្ខណៈថ្មីថ្មោងនៅឡើយ ហើយមានបញ្ហាប្រឈមច្រើន ។

១០. បើទោះបីគំនិតផ្តួចផ្តើមផ្នែកការទទួលខុសត្រូវសង្គម ទើបតែកើតមាននៅកម្ពុជាក្តី ក៏ការសិក្សាស្រាវជ្រាវនេះបានរកឃើញសកម្មភាពការងារផ្នែកទទួលខុសត្រូវសង្គម (ក្នុងទ្រង់ទ្រាយតូចៗ) ជាច្រើនទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដែលមានគោលបំណង :

- រួមចំណែកដល់គោលនយោបាយ និងផែនការសាធារណៈ (ឧទាហរណ៍ : កិច្ចខិតខំរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការផ្តល់មតិយោបល់ដល់ការរៀបចំគោលនយោបាយថ្នាក់ជាតិ ឬសំរបសំរួលអោយប្រជាពលរដ្ឋបានចូលរួមនៅក្នុងការរៀបចំផែនការរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់) ។
- ឃ្លាំមើលចំណូលសាធារណៈ (ឧទាហរណ៍ : យុទ្ធនាការ "បោះពុម្ពផ្សាយនូវអ្វីដែលអ្នកបានចំណាយ" ដែលទើបដំណើរការថ្មីៗ) ។
- មានឥទ្ធិពលទៅលើគំរោងថវិកាសាធារណៈ (ឧទាហរណ៍ : នាពេលថ្មីៗនេះ *វេទិកាអង្គការមិនមែនរដ្ឋាភិបាល* បានបង្កើតអោយមានគំរោងឃ្លាំមើលថវិកាជាតិ) ។
- ឃ្លាំមើលចំណាយសាធារណៈ (ឧទាហរណ៍ : *កិច្ចខិតខំរបស់* បណ្តាញភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ក្នុងការឃ្លាំមើលការចំណាយសាធារណៈនៅក្នុងវិស័យអប់រំ) ។
- កែលំអសេវាសាធារណៈ (ឧទាហរណ៍ : ក្រុមអភិវឌ្ឍន៍ភូមិបានបង្កើតគណៈកម្មាធិការសមាគមសុខភាពភូមិ) ។

- ផ្តល់ការត្រួតពិនិត្យជាសាធារណៈ (ដូចជា គណៈកម្មាធិការត្រួតពិនិត្យឃុំ-សង្កាត់ ដែលឧបត្ថម្ភដោយអង្គការ PACT ការណែនាំអោយប្រើប្រាស់នូវ *របាយការណ៍ចំណាត់ថ្នាក់របស់ប្រជាពលរដ្ឋ* ដោយគំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ និងការឃ្លាំមើលសភា ព្រមទាំងការសិក្សាពីអំពើពុករលួយ ដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម) ។

១១. គិតមកដល់បច្ចុប្បន្ននេះការអនុវត្តន៍គំនិតផ្តួចផ្តើមស្តីពីការទទួលខុសត្រូវសង្គមនៅកម្ពុជា នៅមានប្រសិទ្ធិភាពតិចតួចនៅឡើយ ។ តែទោះជាយ៉ាងណាក្តី ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា មានការចាប់អារម្មណ៍ និងឆន្ទៈច្រើនក្នុងការពង្រីក និងជំរុញសកម្មភាពរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល ហើយនិងប្រសិទ្ធិភាពក្នុងវិស័យនេះ ។

## ២. ការវិភាគទៅលើលក្ខខ័ណ្ឌ និងសមត្ថភាពដើម្បីការទទួលខុសត្រូវសង្គមនៅកម្ពុជា

១២. ការសិក្សាបានកំណត់នូវផ្នែកសំខាន់ៗនៃការទទួលខុសត្រូវសង្គម ហើយបានរកឃើញនូវកត្តាអំណោយផល និងកត្តារាំងស្ទះ ព្រមជាមួយនឹងចំណុចខ្លាំង និងបញ្ហាប្រឈម នៅក្នុងផ្នែកនីមួយៗដូចខាងក្រោម :

- *ព័ត៌មាន* - តើប្រជាពលរដ្ឋអាចទទួលបាន និងបង្កើតនូវព័ត៌មានដែលពាក់ព័ន្ធនឹងខ្លួនគេបានដែរឬទេ?
- *ការបញ្ចេញមតិ* — តើប្រជាពលរដ្ឋអាចសំដែងពីកង្វល់ និងបង្ហាញពីអាទិភាពរបស់ខ្លួនបានដែរឬទេ (ដោយមានការជ្រោមជ្រែងពីអង្គការសង្គមស៊ីវិល)?
- *ការរួបរួមជាសមាគម* - តើប្រជាពលរដ្ឋអាចបង្កើតជាសមាគម ហើយប្រើប្រាស់សមាគមនោះដើម្បីប្រមូលផ្តុំមតិ និងសំដែងចេញនូវមតិយោបល់ទាំងនោះបានដែរឬទេ?
- *ការចូលរួម និងការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា* - តើប្រជាពលរដ្ឋអាចផ្សារភ្ជាប់ទំនាក់ទំនង និងចូលរួមក្នុងដំណើរការសំរេចចិត្តជាសាធារណៈបានដែរឬទេ?

### ២.ក. អំពីព័ត៌មាន

១៣. កត្តាអំណោយផលដ៏សំខាន់មួយសំរាប់ការទទួលខុសត្រូវសង្គម គឺការដែលប្រជាពលរដ្ឋមាននូវ *ព័ត៌មានសាធារណៈ* ដែលត្រឹមត្រូវ និងពាក់ព័ន្ធដល់ពួកគេ ។ កាលបើប្រជាពលរដ្ឋពុំមានលទ្ធភាពទទួលបាន ឬបង្កើតព័ត៌មានអំពីគោលនយោបាយ និងនីតិវិធី គំរោងថវិកា ការចំណាយ កម្មវិធីនិងសេវាសាធារណៈទេ នោះពួកគេពុំមានគំនិតយោបល់សំរាប់ចូលរួមក្នុងការពិភាក្សាជាសាធារណៈ ឬឃ្លាំមើលសកម្មភាពរបស់រដ្ឋាភិបាល ឬចរចាជាមួយមន្ត្រីសាធារណៈអោយមានប្រសិទ្ធិភាពឡើយ ។ បទពិសោធន៍ជាទូទៅបង្ហាញថា បើទោះបីនៅគ្រាដំបូងរដ្ឋាភិបាលតែងមានភាពស្ទាក់ស្ទើរក្នុងការចែករំលែកព័ត៌មានក៏ដោយ ក៏ទីបំផុតភាពជឿជាក់ និងទំនុកចិត្តពីសាធារណៈដែលទទួលបានពីការចែករំលែកព័ត៌មាន បានធ្វើអោយរដ្ឋាភិបាលស្ងប់ចិត្តដោយសារតែអត្ថប្រយោជន៍នៃតម្លាភាពបែបនោះ ។

១៤. ទាក់ទងនឹងបញ្ហាព័ត៌មានសំរាប់ប្រជាពលរដ្ឋ ការស្រាវជ្រាវនេះបានរកឃើញទាំងឱកាស និងបញ្ហាប្រឈមសំខាន់ៗមួយចំនួននៅក្នុងបរិបទកម្ពុជា ។ ឱកាសសំខាន់ៗរួមមានការផ្សាយនៃវិទ្យុ និងទូរទស្សន៍ដែលគ្របដណ្តប់នូវវិសាលភាពធំទូលាយ ហើយនិងប្រការដែលប្រជាពលរដ្ឋបានបង្ហាញពីការអារម្មណ៍របស់គេចំពោះព័ត៌មានសាធារណៈ (ជាពិសេសព័ត៌មានស្តីពីបញ្ហានៅមូលដ្ឋាន

ដែលផលប៉ះពាល់ផ្ទាល់ដល់សុខុមាលភាពរូបវ័ន្តរបស់ពួកគេ) ។ ក្រៅពីនេះប្រជាពលរដ្ឋក៏គិតថា វាជាការសំខាន់ណាស់ដែលពួកគេ គួរទទួលបានព័ត៌មាន ។រីឯ*បញ្ហាប្រឈមចំបងៗ*រួមមាន :

១៥. *កង្វះការទាមទាររកព័ត៌មាន* - បើទោះបីប្រជាពលរដ្ឋមានការចាប់អារម្មណ៍ និងអោយតំលៃទៅលើព័ត៌មានសាធារណៈក៏ដោយ ក៏ការទាមទាររកព័ត៌មានសារធារណៈទាំងនោះពីសំណាក់ប្រជាពលរដ្ឋ នៅមានកំរិតតិចតួចនៅឡើយ ។ បញ្ហានេះកើតឡើងដោយសារកង្វះការយល់ដឹងអំពីសិទ្ធិក្នុងការទទួលបានព័ត៌មាន ភាពស្ទាក់ស្ទើរក្នុងការស្នើសុំព័ត៌មានដែលមានលក្ខណៈ "រសើប" និងកង្វះការយល់ដឹងអំពីវិធីស្វែងរកព័ត៌មាន ឬវិធីប្រើប្រាស់ព័ត៌មានដើម្បីនាំអោយមានការផ្លាស់ប្តូរ ។ ការស្រាវជ្រាវបានរកឃើញនូវការយល់ឃើញជាទូទៅថា បញ្ហាអភិបាលកិច្ចគឺពុំមែនជារឿងដែលប្រជាពលរដ្ឋសាមញ្ញត្រូវខ្វល់ខ្វាយឡើយហើយបញ្ហាបែបនេះ រួមជាមួយនឹងបញ្ហាផ្នែកសេវាសាធារណៈផង គឺមានតែថ្នាក់លើទេដែលអាចដោះស្រាយបាន ។

១៦. *កង្វះនូវតម្លាភាព និងលទ្ធភាពទទួលបានព័ត៌មានសាធារណៈ* - នៅកម្ពុជា បញ្ហាកង្វះនូវការទាមទារដ៏សកម្មរកព័ត៌មាន គឺត្រូវបានធ្វើអោយធ្ងន់ធ្ងរថែមទៀត ដោយសាររដ្ឋាភិបាលពុំសូវមានតម្លាភាព ហើយលទ្ធភាពទទួលបានព័ត៌មានសាធារណៈក៏នៅមានកំរិតទាបដែរ ។ នៅក្នុងសង្គមកម្ពុជា ពុំមានទំលាប់ក្នុងការចែករំលែកព័ត៌មានសាធារណៈជាលក្ខណៈប្រព័ន្ធ ឬជាលក្ខណៈផ្លូវការឡើយ ឯច្បាប់ស្តីពីការទទួលបានព័ត៌មានក៏ពុំទាន់ត្រូវបានអនុម័តដែរ ។ ហេតុដូច្នេះហើយ មន្ត្រីរដ្ឋាភិបាលពុំមានទំលាប់ក្នុងការចែករំលែកព័ត៌មានឡើយ ហើយពួកគេពុំមានអារម្មណ៍ថាមានសុវត្ថិភាពទេ ក្នុងការសំរេចចិត្តថាព័ត៌មានបែបណាដែលអាច ឬគួរចែករំលែកទៅខាងក្រៅ ជាពិសេសចំពោះមន្ត្រីរាជការនៅថ្នាក់ក្រោម ។ ជាងនេះទៀត ពួកគេតែងមានការស្ទាក់ស្ទើរក្នុងការបញ្ចេញព័ត៌មានដែលមានលក្ខណៈ "រសើប" ។ ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា លទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានផ្នែកហិរញ្ញវត្ថុសាធារណៈ (ដូចជាអំពី ចំណូល គំរោងថវិកា និងចំណាយរបស់រដ្ឋាភិបាលកម្ពុជា) គឺកាន់តែមានតិចតួចទៅទៀត ។

១៧. *ប្រជាពលរដ្ឋមានព័ត៌មាន និងចំណេះដឹងតិច* - ដោយសារមូលហេតុដូចខាងលើនេះហើយ ការស្រាវជ្រាវបានរកឃើញថា ជាទូទៅប្រជាពលរដ្ឋមានព័ត៌មាន និងចំណេះដឹងតិចតួចអំពីវិស័យសាធារណៈ ហើយការយល់ដឹងរបស់ពួកគេអំពីផ្នែកហិរញ្ញវត្ថុសាធារណៈរឹតតែមានកំរិតទាបទៅទៀត ។ ចំណែកឯនៅថ្នាក់មូលដ្ឋាន បើទោះបីជាជាទូទៅប្រជាពលរដ្ឋមានការយល់ដឹងល្អបង្គួរអំពីក្រុមប្រឹក្សាឃុំ-សង្កាត់ក៏ដោយ ក៏ពួកគេនៅតែមិនសូវដឹងអំពីថវិកា និងការចំណាយរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ដែរ ។ ជាងនេះទៀត បើទោះបីអ្នកដែលក្រុមស្រាវជ្រាវបានជួបនៅក្នុងក្រុមពិភាក្សា បានបង្ហាញពីការចាប់អារម្មណ៍របស់គេចំពោះព័ត៌មានអំពីថវិកាឃុំ-សង្កាត់ និងរបៀបចំណាយធនធានយ៉ាងណាក្តី ក៏ពួកគេបានអោយដឹងថាព័ត៌មានបែបនេះពិបាកនឹងរកបានណាស់ ហើយក៏ពុំមែនសំរាប់ផ្តល់ជូនប្រជាពលរដ្ឋសាមញ្ញដែរ ។ ការដែលប្រជាពលរដ្ឋពុំសូវមានសេចក្តីក្លាហាន និងអំណាច ក៏ជាកត្តាមួយបន្ថែមបង្អាក់ដល់ការទាមទាររកព័ត៌មានដែរ ។

១៨. *ភាពទន់ខ្សោយនៃតួនាទីរបស់អង្គការសង្គមស៊ីវិលផ្នែកព័ត៌មាន* - ការរួមចំណែកក្នុងការផ្សព្វផ្សាយព័ត៌មានសាធារណៈដែលពាក់ព័ន្ធហើយនិងការអប់រំប្រជាពលរដ្ឋអំពីបញ្ហាចំបងៗក្នុងផ្នែកសាធារណៈគឺជាតួនាទីស្នូលរបស់សង្គមស៊ីវិល ។ តែទោះជាយ៉ាងណាក្តី នៅក្នុងប្រទេសកម្ពុជា តួនាទីរបស់អង្គការសង្គមស៊ីវិលដែលធ្វើការផ្នែកអភិបាលកិច្ច ក្នុងការស្វែងរក បង្កើត ប្រើប្រាស់ និងចែក

រំលែកព័ត៌មាន គឺកំពុងលេចឡើងយ៉ាងសន្សឹមៗ ហើយស្ថិតក្នុងសភាពទន់ខ្សោយនៅឡើយ ។ មានអង្គការសង្គមស៊ីវិលតែមួយចំនួនតូចប៉ុណ្ណោះ ដែលបានអភិវឌ្ឍជំនាញឯកទេសផ្នែក *ព័ត៌មាន-ការអប់រំ-ទំនាក់ទំនង* (IEC) និងផ្នែកផ្សព្វផ្សាយទាក់ទងទៅនឹងប្រធានបទអភិបាលកិច្ច ឬការទទួលខុសត្រូវសង្គម ។ រីឯកិច្ចខិតខំជាលក្ខណៈប្រព័ន្ធក្នុងការស្វែងរក និងវិភាគព័ត៌មានទាក់ទងនឹងរដ្ឋាភិបាល ឬបង្កើត និងផ្សព្វផ្សាយព័ត៌មានដែលទទួលបានពីការស្រាវជ្រាវឯករាជ្យ ឬមតិយោបល់របស់ប្រជាពលរដ្ឋ គឺកំរនឹងឃើញមានណាស់ ។ ការសិក្សានេះបានរកឃើញថា បើសូម្បីនៅក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលអាជីពក្តី ក៏អង្គការទាំងនេះមានព័ត៌មាន និងចំណេះដឹងពីវិស័យសាធារណៈក្នុងកំរិតដ៏តិចតួចដែរ ។ បុគ្គលិកនៃអង្គការក្រៅរដ្ឋាភិបាលអាជីពដែលត្រូវបានធ្វើការស្ទាបស្ទង់មតិបានបង្ហាញថាពួកគេមានព័ត៌មាន-ចំណេះដឹងតិចតួចអំពីគោលនយោបាយ នីតិវិធី និងថវិកាសាធារណៈ ។

១៩. *អនុសាសន៍*ចំនួន៣ត្រូវបានស្នើឡើងដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ

*អនុសាសន៍ ក.១-* ជំរុញអោយប្រជាពលរដ្ឋអោយមានការទាមទារជំរុញសកម្មនូវព័ត៌មានសាធារណៈ
ឧទាហរណ៍ តាមរយៈ

- ការលើកទឹកចិត្តអង្គការសង្គមស៊ីវិលដែលធ្វើការនៅតាមសហគមន៍ (ក្នុងវិស័យផ្សេងៗ) អោយបញ្ចូលនូវផ្នែក "ព័ត៌មានសាធារណៈ" ទៅក្នុងកម្មវិធីរបស់ខ្លួន (ដូចជាចែករំលែកជាមួយសមាជិក និងក្រុមគោលដៅ នូវព័ត៌មានស្តីពីច្បាប់ គោលនយោបាយ ផែនការ និងថវិកាសាធារណៈ ដែលពាក់ព័ន្ធទៅនឹងសកម្មភាពបច្ចុប្បន្ន) ។
- ការលើកកំពស់ការចាប់អារម្មណ៍នៅក្នុងចំណោមប្រជាពលរដ្ឋសាមញ្ញ អំពីបញ្ហាអភិបាលកិច្ច តាមរយៈយុទ្ធនាការ IEC ដែលមានព័ត៌មានអំពីស្ថាប័ន និងដំណើរការអភិបាលកិច្ចមូលដ្ឋាន ក៏ដូចជាអំពីគោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជាធិប-តេយ្យ សិទ្ធិ ព្រមទាំងករណីយកិច្ចរបស់ប្រជាពលរដ្ឋ ។
- ការជំរុញសកម្មភាពនានាឈានទៅអនុម័តច្បាប់ស្តីពីការទទួលបានព័ត៌មានសាធារណៈ និងផ្សព្វផ្សាយជូនប្រជាពលរដ្ឋអំពីសិទ្ធិរបស់ពួកគេចំពោះព័ត៌មាន ។

*អនុសាសន៍ ក.២-* លើកកំពស់លទ្ធភាពទទួលបានព័ត៌មានដែលពាក់ព័ន្ធផ្ទាល់នឹងសុខមាលភាពរបស់ប្រជាពលរដ្ឋ ជាពិសេសនៅថ្នាក់ក្រោមជាតិ (ថ្នាក់ឃុំ ស្រុក និងខេត្ត)។
ឧទាហរណ៍ តាមរយៈ

- ការណែនាំអោយប្រើប្រាស់នូវក្រមនៃការអនុវត្តន៍ស្តីពីលទ្ធភាពទទួលបានព័ត៌មានអំពីរដ្ឋាភិបាល ។
- ការណែនាំដល់អ្នកផ្តល់សេវានៅថ្នាក់មូលដ្ឋាន (ដូចជា សាលារៀន និងមណ្ឌលសុខភាព) អោយចែករំលែកជាសាធារណៈនូវព័ត៌មានអំពីថវិកា និងការចំណាយ ។
- ការឃ្លាំមើល និងការគាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ទាក់ទងនឹងការប្រតិបត្តិតាមនូវគោលការណ៍នៃការធ្វើផែនការដែលមានការចូលរួម និងតម្លាភាពនៃការគ្រប់គ្រងថវិកា ។

*អនុសាសន៍ ក.៣-* លើកកំពស់ចំណេះដឹងរបស់អង្គការសង្គមស៊ីវិលលើវិស័យសាធារណៈ/រដ្ឋាភិបាល និងកសាងសមត្ថភាពពួកគេក្នុងការធ្វើការសិក្សាស្រាវជ្រាវដោយឯករាជ្យ វិភាគ និងរៀបចំសំភារៈIEC សំរាប់គោលបំណងការងារទទួលខុសត្រូវសង្គម ។

ឧទាហរណ៍ តាមរយៈ

- ការរៀបចំសិក្ខាសាលាចែករំលែកព័ត៌មាន ដើម្បីជួយលើកកំពស់ចំណេះដឹងរបស់អង្គការសង្គមស៊ីវិលដែលជាប្រតិបត្តិករទាំងអស់អំពីច្បាប់ គោលនយោបាយ និងនីតិវិធីរដ្ឋបាលសាធារណៈដែលពាក់ព័ន្ធ ។ល។
- ការលើកកំពស់ និងគាំទ្រភាពជាដៃគូ ដែលក្នុងនោះអង្គការសង្គមស៊ីវិលអាចសហការជាមួយបណ្ដាក្រសួង ដើម្បីកែសំរួលព័ត៌មានសាធារណៈ អោយមានខ្លឹមសារសាមញ្ញសំរាប់ផ្សព្វផ្សាយ ។
- ការបណ្ដុះបណ្ដាលដល់អង្គការសង្គមស៊ីវិលផ្នែកសិក្សាស្រាវជ្រាវ វិភាគ ទំនាក់ទំនង និងសកម្មភាពអប់រំសាធារណៈ ។
- ការលើកកំពស់ និងគាំទ្រអោយមានទំនាក់ទំនងកាន់តែល្អប្រសើររវាងអង្គការសង្គមស៊ីវិល និងតួអង្គនានានៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ។

## ២.២. អំពីការបញ្ចេញមតិ

២០. សមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងការ *បញ្ចេញមតិ* អំពីទស្សនៈ សេចក្ដីត្រូវការ និងការព្រួយបារម្ភរបស់ពួកគេ ដើម្បីអោយអាជ្ញាធររដ្ឋាភិបាលបានដឹងកាន់តែច្បាស់អំពីអាទិភាពរបស់ពួកគេនោះ គឺជាផ្នែកសំខាន់មួយទៀតនៃការទទួលខុសត្រូវសង្គម ។ ប្រសិនបើប្រជាពលរដ្ឋមិនពេញចិត្តចំពោះសេវាសាធារណៈ ឬគិតថាសិទ្ធិរបស់ពួកគេត្រូវបានបំពាន ប៉ុន្តែពួកគេគ្មានមធ្យោបាយ "សំដែងចេញ" នូវបទពិសោធន៍ និងក្ដីបារម្ភទាំងនោះទេ អញ្ចឹងលទ្ធភាពឈានទៅរកការផ្លាស់ប្ដូរជាវិជ្ជមានដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋគឺមានតិចតួចណាស់ ។ ជាថ្មីម្ដងទៀត នៅក្នុងបរិបទប្រទេសកម្ពុជាការសិក្សាស្រាវជ្រាវនេះបានរកឃើញថាមានឱកាសផង និងបញ្ហាប្រឈមផង ទាក់ទងទៅនឹងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋនេះ ។

២១. *ការសំដែងមតិរបស់ប្រជាពលរដ្ឋ* - ប្រជាពលរដ្ឋកម្ពុជាបានសំដែងនូវចំណាប់អារម្មណ៍ និងឆន្ទៈក្នុងការប្រើប្រាស់សំលេងរបស់ខ្លួនដូចជាតាមរយៈការចូលរួមនៅក្នុងការបោះឆ្នោត និងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។ តែទោះជាយ៉ាងណាក្ដី ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ប្រជាពលរដ្ឋអាចនឹងចូលរួមបានច្រើនប្រសិនបើពួកគេត្រូវបានអញ្ជើញជាផ្លូវការ និងច្បាស់លាស់ ហើយពួកគេនៅមានភាពស្ទាក់ស្ទើរក្នុងការសួរសំណួរ ឬរិះគន់សកម្មភាពរបស់រដ្ឋាភិបាល ឬអាជ្ញាធរដោយចំហ ។ បើទោះបីជាមានប្រជាពលរដ្ឋច្រើនបង្គួរបានចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ក្ដី ក៏ការចូលរួមរបស់គេគឺភាគច្រើនគ្រាន់តែទៅអង្គុយស្ដាប់ប៉ុណ្ណោះ ហើយពុំមានលក្ខណៈរៀបរយល្អទេ (ចូលរួមក្នុងនាមជាបុគ្គល គឺពុំមែនតំណាងអោយក្រុម ឬសមាគមណាមួយឡើយ) ។ កង្វះសេចក្ដីក្លាហាន (គិតថាអ្វីដែលពួកគាត់និយាយនឹងពុំត្រូវបានគេទទួលស្ដាប់ ឬអនុវត្តតាម) និងការភ័យខ្លាចចំពោះការសងសឹកណាមួយ ត្រូវបានរកឃើញថាជាឧបសគ្គដ៏ចំបងចំពោះការសំដែងមតិរបស់ប្រជាពលរដ្ឋ ។ មន្ត្រីសាធារណៈពុំមានទម្លាប់ទទួលយកការពិនិត្យពិច័យ ឬការសួរដេញដោលពីប្រជាពលរដ្ឋ ឬអង្គការសង្គមស៊ីវិលនោះទេ ហើយជាញឹកញាប់គេពុំសុខចិត្តទទួលស្ដាប់ការចោទសួរ ឬមតិយោបល់រិះគន់ឡើយ ។ តែទោះជាយ៉ាងនេះក្ដី ការស្រាវជ្រាវនេះក៏បានរកឃើញដែរថា

ដំណើរការវិមជ្ឈការនាពេលបច្ចុប្បន្ន ប្រសិនបើចាត់ចែងអោយបានសមស្រប នឹងបានជាសក្តានុពលដ៏ពិសេសសំរាប់ការលើកកំពស់ការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយារបស់ប្រជាពលរដ្ឋ និងអាជ្ញាធរ ។

២២. *ការផ្តល់អំណាចដល់ប្រជាពលរដ្ឋ* - អាស្រ័យដោយបទដ្ឋានវប្បធម៌ និងតថភាពសង្គមនយោបាយ ប្រជាពលរដ្ឋបានបាត់បង់នូវអំណាច ហើយពុំសូវមានទំនុកចិត្តលើសមត្ថភាពរបស់ខ្លួន (ជាលក្ខណៈបុគ្គល ឬសមូហភាព) ក្នុងការធ្វើអោយមានឥទ្ធិពលលើការសំរេចចិត្ត ឬធ្វើអោយមានការផ្លាស់ប្តូរណាមួយនោះទេ ។ ឥរិយាបថបិតុនិយម ហេតុផលនៃទំនាក់ទំនងបែបចៅហ្វាយនាយ-កូនចៅ និងការភ័យខ្លាចចំពោះការតបតណាមួយ គឺជាកត្តារួមចំណែកធ្វើអោយប្រជាពលរដ្ឋមិនមានអំណាច និងគិតថាខ្លួនមិនអាចធ្វើអ្វីបានឡើយ ។ ស្ត្រី យុវជន និងប្រជាពលរដ្ឋក្រីក្រ ប្រឈមនឹងការលំបាកជាងគេក្នុងការទទួលបានព័ត៌មាន ការបញ្ចេញមតិយោបល់ និងការជះឥទ្ធិពលដល់ការផ្លាស់ប្តូរណាមួយ ។ ហេតុដូច្នេះ ជាចាំបាច់គប្បីមានកិច្ចខិតខំប្រឹងប្រែងច្បាស់លាស់ និងជាក់លាក់ ដើម្បីផ្តល់អំណាច និងគាំទ្រដល់ក្រុមដែលពុំសូវមានអំណាចទាំងនេះ ។ បើទោះបីនាពេលបច្ចុប្បន្ននេះ មានអង្គការក្រៅរដ្ឋាភិបាលតែ មួយចំនួនតូចកំពុងមានកិច្ចខិតខំប្រឹងប្រែងនៅថ្នាក់មូលដ្ឋានដើម្បីពង្រឹងអំណាចដល់ប្រជាពលរដ្ឋ និងពង្រឹងសំលេងរបស់ពួកគេយ៉ាងណាក្តី ការសិក្សានេះបានរកឃើញនូវឧទាហរណ៍ល្អៗមួយចំនួនដែលគួររៀនសូត្រតាម ។

២៣. *ការពឹងផ្អែកយ៉ាងធំធេងទៅលើអ្នកដឹកនាំនៅមូលដ្ឋាន* - ដោយសារប្រជាពលរដ្ឋមិនសូវមានអំណាច ហើយច្រើនតែពឹងផ្អែកលើទំនាក់ទំនងផ្ទាល់ខ្លួនបែបចៅហ្វាយនាយ-កូនចៅ ម្ល៉ោះហើយប្រជាពលរដ្ឋសាមញ្ញពឹងផ្អែកយ៉ាងធំធេងទៅលើអ្នកដឹកនាំនៅមូលដ្ឋាន ក្នុងការលើកឡើងនូវបញ្ហា ថ្លែងពីសេចក្តីត្រូវការ និងទស្សនៈផ្សេងៗជំនួសខ្លួន ។ អ្នកដឹកនាំនៅតាមសហគមន៍ និងថ្នាក់មូលដ្ឋានមានសក្តានុពលយ៉ាងធំធេងក្នុងការពង្រឹងអំណាច និងគៀងគរប្រជាពលរដ្ឋ កែប្រែឥរិយាបថ និងអាកប្បកិរិយា សំរបសំរួលការទំនាក់ ទំនងជាមួយអាជ្ញាធរសាធារណៈ ពាំនាំក្តីបារម្ភរបស់មូលដ្ឋានទៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ព្រមទាំងផ្តល់នូវគំរូដឹកនាំជាប្រចាំមួយនៃការដឹកនាំដែលប្រកបទៅដោយការទទួលខុសត្រូវ ។ ជាអកុសល ការស្រាវជ្រាវនេះបានរកឃើញថាអ្នកដឹកនាំជាច្រើន (ទាំងនៅក្នុងជួររដ្ឋាភិបាលនិងសង្គមស៊ីវិលនៅគ្រប់កំរិតថ្នាក់) ប្រកាន់ឥរិយាបថបែបឋានានុក្រមផ្តាច់ការថ្នាក់លើ-ថ្នាក់ក្រោម ហើយមិនសូវគិតថា "ការដឹកនាំជាការផ្តល់សេវា" ឬ "ការទទួលខុសត្រូវចំពោះថ្នាក់ក្រោម" ឡើយ ។

២៤. *កង្វះយន្តការសំរាប់អោយប្រជាពលរដ្ឋបញ្ចេញមតិ* - ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ក្រៅពីការបោះឆ្នោត និងការចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលមានឱកាស និងយន្តការតិចតួចណាស់ សំរាប់បញ្ចេញទស្សនៈ និងក្តីបារម្ភរបស់ខ្លួនជាសាធារណៈនោះ ។ វេទិកាសាធារណៈដែលជាឱកាសដ៏ល្អបំផុត ក្នុងការបញ្ចេញមតិយោបល់ និងលើកឡើងពីបញ្ហានានាដោយចំហនៅចំពោះវត្តមានរបស់តំណាងរដ្ឋាភិបាលនោះ ជាអកុសលត្រូវបានរៀបចំឡើងតិចតួចបំផុតនៅថ្នាក់មូលដ្ឋាន ។ ប្រព័ន្ធផ្សព្វផ្សាយតាមមូលដ្ឋាន (ឧទាហរណ៍: វិទ្យុសហគមន៍ជាដើម) អាចជាឧបករណ៍មួយដ៏មានឥទ្ធិពលក្នុងការផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានអំពីបញ្ហាដែលទាក់ទងនឹងការអភិវឌ្ឍន៍ឃុំ-ស្រុក និងផ្តល់ជាវេទិកាមួយសំរាប់ទាំងបុគ្គល និងក្រុមនានាដើម្បីចែករំលែកមតិយោបល់ និងក្តីព្រួយបារម្ភរបស់ផ្សេងៗជាសាធារណៈ ។ បើទោះបីវិស័យផ្សព្វផ្សាយនៅកម្ពុជាត្រូវបានពង្រីកគួរអោយកត់សំគាល់ក្នុងរយៈពេលមួយទសវត្សកន្លងមកនេះក្តី ក៏ប្រព័ន្ធផ្សព្វផ្សាយស្ទើរតែទាំងអស់ប្រមូលផ្តុំគ្នាតែនៅក្នុងទីក្រុងភ្នំពេញ ហើយផ្តោតការផ្សព្វផ្សាយរបស់ខ្លួនតែលើបញ្ហាថ្នាក់ជាតិ និងបញ្ហាក្នុងទីក្រុងប៉ុណ្ណោះ ។ ដោយសារកង្វះប្រព័ន្ធផ្សព្វផ្សាយនៅថ្នាក់មូលដ្ឋានបែបនេះហើយទើបប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលនៅតំបន់

ជនបទ និងសូម្បីតែអ្នកដែលរស់នៅទីប្រជុំជនស្រុក និងខេត្ត ស្ទើរតែពុំមានមធ្យោបាយដើម្បីទទួលបានព័ត៌មានអំពីមូលដ្ឋាន ឬ បញ្ចេញមតិរបស់ខ្លួនអោយគេលឺជាសាធារណៈឡើយ ។ ក្រៅពីកម្មវិធីជជែកកំសាន្តតាមវិទ្យុឯករាជ្យមួយចំនួនតូច នៅកម្ពុជាមានកម្មវិធីឆ្លើយឆ្លងតាមវិទ្យុ (ដែលប្រជាពលរដ្ឋសាមញ្ញអាចបញ្ចេញពីទស្សនៈរបស់ខ្លួន ចោទជាសំណួរ និងធ្វើការឆ្លើយឆ្លងជាមួយវិស័យសាធារណៈ) បែបនេះតិចតួចណាស់ ។

២៥. *អនុសាសន៍* ចំនួនបីត្រូវបានស្នើឡើងដើម្បីដោះស្រាយបញ្ហាទាំងនេះ និងពង្រឹងការសំដែងមតិរបស់ប្រជាពលរដ្ឋនៅកម្ពុជា

*អនុសាសន៍ ខ.១* — គាំទ្រដល់គំនិតផ្តួចផ្តើមពង្រឹងអំណាច និងកសាងសេចក្តីក្លាហានរបស់ប្រជាពលរដ្ឋ

ឧទាហរណ៍ តាមរយៈ

- ការសិក្សា និងការផ្សព្វផ្សាយជាសាធារណៈនូវឧទាហរណ៍នានា ដែលការចូលរួមរបស់ប្រជាពលរដ្ឋបាននាំមកនូវការផ្លាស់ប្តូរដ៏ពិតប្រាកដ និងអត្ថប្រយោជន៍ជាក់ស្តែង ។
- ការកសាងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល (ជាពិសេសអង្គការដែលកំពុងធ្វើសកម្មភាពនៅតាមសហគមន៍) ដើម្បីអោយអង្គការទាំងនោះអនុវត្តវិធីសាស្រ្តស៊ូមតិដែលផ្តោតទៅលើប្រជាជន និងសិទ្ធិ ។
- ការធ្វើអោយប្រាកដថា វេទិកាសំរាប់ការសំដែងមតិរបស់ប្រជាពលរដ្ឋនិងសំរាប់កិច្ចសន្ទនារវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល (ដូចជាកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ កិច្ចប្រជុំរបស់គណៈកម្មការទ្រទ្រង់សាលារៀន វេទិកាសាធារណៈ) បានបញ្ចូលនូវប្រការ និងយន្តការច្បាស់លាស់សំរាប់ការឆ្លើយតប និងការតាមដាន ។
- ការគាំទ្រដល់កម្មវិធី និងសកម្មភាពទាំងឡាយណាដែលខិតខំកសាងចំណេះដឹង សេចក្តីក្លាហាន និងសមត្ថភាពរបស់ក្រុមដែលជាទូទៅគេ"ពុំសូវយកចិត្តទុកដាក់" ដូចជា ក្រុមស្រ្តី យុវជន និង ប្រជាពលរដ្ឋក្រីក្រ ។

*អនុសាសន៍ ខ.២* - ផ្តល់ការបណ្តុះបណ្តាល និងគាំទ្រដល់អ្នកដឹកនាំបច្ចុប្បន្ន និងអនាគតអ្នកដឹកនាំនៅថ្នាក់មូលដ្ឋាន

ឧទាហរណ៍ តាមរយៈ

- ការកំណត់រក និងគាំទ្រអ្នកដឹកនាំបច្ចុប្បន្ន និងអនាគតអ្នកដឹកនាំ ព្រមទាំងអ្នកជំនាញផ្នែកគំនិត (ជាពិសេសនៅថ្នាក់ភូមិ ឃុំ និង ស្រុក) ។
- ការណែនាំអោយអនុវត្តប្រព័ន្ធបោះឆ្នោតជ្រើសរើសប្រធានភូមិតាមបែបប្រជាធិបតេយ្យ (ដើម្បីជំនួសការអនុវត្តន៍នាពេលបច្ចុប្បន្នដែលប្រធានភូមិត្រូវបានតែងតាំងអាស្រ័យទៅតាមកូតារបស់គណៈបក្សនយោបាយ) ។

*អនុសាសន៍ ខ.៣* - ពង្រីក និងលើកកំពស់យន្តការសំរាប់ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន

ឧទាហរណ៍ តាមរយៈ

- ការធ្វើអោយប្រាកដថា វេទិកាដែលរៀបចំឡើងក្នុងបំណងលើកកំពស់ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ និងពិភាក្សារវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល មានរៀបចំអោយមានការអញ្ជើញច្បាស់លាស់អោយប្រជាពលរដ្ឋចូលរួម ការអញ្ជើញអោយប្រជាពលរដ្ឋឡើងបញ្ចេញមតិ ហើយបរិយាកាសនោះគប្បីពោរពេញដោយការគាំទ្រ និងលើកទឹកចិត្ត (ជាពិសេសសំរាប់ប្រជាពលរដ្ឋដែលពុំសូវមានសេចក្តីក្លាហាន ឬពុំសូវទទួលបានការអប់រំ) ។
- ការគាំទ្រដល់ការបង្កើតឡើងនូវប្រព័ន្ធផ្សព្វផ្សាយបែបឆ្លើយឆ្លងនៅថ្នាក់មូលដ្ឋាន និង ជាពិសេសវិទ្យុសហគមន៍ ។
- ការបង្កើត និងគាំទ្រដល់យន្តការសំរាប់សំដែងមតិដែលសម្របទៅតាមលក្ខណៈពិសេស និងសេចក្តីត្រូវការរបស់ស្ត្រី យុវជន និងក្រុមដទៃទៀតដែលជាទូទៅគេពុំសូវយកចិត្តទុកដាក់ជាមួយ ។

## ២.គ. ការរួបរួមជាសមាគម

២៦. វិធីសាស្ត្រនៃការទទួលខុសត្រូវសង្គម គឺផ្អែកលើសកម្មភាពរួមរបស់ប្រជាពលរដ្ឋ និងសមត្ថភាពរបស់ពួកគេក្នុងការ *ប្រាស្រ័យទាក់ទង* ជាមួយគ្នាដើម្បីលើកកំពស់ផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ខ្លួន ។ ភាពខ្លាំងរបស់សង្គមស៊ីវិល គឺមួយភាគធំអាស្រ័យដោយវិសាលភាព ភាពស៊ីជំរៅ និងគុណភាពនៃភាពជាសមាគម ។ ទំហំ វិសាលភាព និងកំរិតថ្នាក់នៃអង្គការសហគមន៍ និងអង្គការសង្គមស៊ីវិល ភាពស្របច្បាប់ ភាពជាតំណាង និងការទទួលខុសត្រូវរបស់អង្គការទាំងនោះចំពោះសមាជិករបស់ពួកគេ ព្រមទាំងសមត្ថភាពរបស់ពួកគេក្នុងការកសាងបណ្តាញ និងសម្ព័ន្ធភាព សុទ្ធសឹងជាចំណុចសំខាន់ ចំពោះជោគជ័យនៃការងារទទួលខុសត្រូវសង្គម ។

២៧. *ការរួបរួមរបស់ប្រជាពលរដ្ឋ ឬសមាគមប្រជាពលរដ្ឋ* -ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ការរួបរួមរបស់ប្រជាពលរដ្ឋ ឬសមាគមរបស់ប្រជាពលរដ្ឋ នៅមានកំរិតទាបនៅឡើយហើយនេះជាចំណុចខ្សោយដ៏ចំបងមួយនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ។ ការសិក្សាក៏បានកំណត់ដែរថា ការធ្លាក់ចុះនូវការជឿទុកចិត្តគ្នា និងការបាត់បង់នូវធនធានសង្គម គឺជាកត្តាមួយដែលជះឥទ្ធិពលមិនល្អ ។ ក្នុងចំណោមប្រជាពលរដ្ឋមួយចំនួនតូច (២៣%) ដែលជាសមាជិកនៃអង្គការណាមួយនោះ មួយភាគធំ (៦៦.២%) គឺជាសមាជិករបស់សមាគមប្រពៃណី (ដូចជាសមាគមពាក់ព័ន្ធនឹងវត្តអារាម) ។ បើទោះបីជាធម្មតា សមាគមប្រពៃណីបែបនេះពុំមានពាក់ព័ន្ធដោយផ្ទាល់នៅក្នុងបញ្ហាអភិបាលកិច្ចសាធារណៈ និងការទទួលខុសត្រូវក្តី ក៏ដំណើរការនៃវិមជ្ឈការនាពេលបច្ចុប្បន្ន បានបង្កើតអោយមាននូវឱកាសដ៏មានសក្តានុពល សំរាប់ការអភិវឌ្ឍន៍តួនាទីរបស់សមាគមទាំងនោះ អោយទៅជាអ្នកប្រមូលផ្តុំនៃសំលេងរបស់ប្រជាពលរដ្ឋ និងជាអ្នកសំរបសំរួលទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ការសិក្សាស្រាវជ្រាវបានរកឃើញថា វិសាលភាពនិងប្រសិទ្ធិភាពនៃអង្គការសហគមន៍ "បែបទំនើប" (ដូចជាសមាគមកសិករ និងក្រុមស្ត្រី) នៅមានកំរិតទាបនៅឡើយ ដោយក្នុងនោះមានអ្នកឆ្លើយសំណួរនៅក្នុងការស្ទាបស្ទង់មតិប្រជាពលរដ្ឋប្រមាណតែ ១២.៣% ប៉ុណ្ណោះដែលបាននិយាយថា ជាសមាជិករបស់ក្រុមបែបនេះ ហើយភាគច្រើននៃក្រុមនេះមានទំហំតូចៗ (ដោយសារមានធនធានសង្គមតិច និងចេតនាចង់រក្សាសមាគមនោះអោយមានលក្ខណៈបុគ្គល និងមិនផ្លូវការ) ។ ទើបតែមកដល់ពេលថ្មីៗនេះទេដែលម្ចាស់ជំនួយចាប់ផ្តើមផ្តល់ជំនួយទៅសមាគមនៅមូលដ្ឋានបែបនេះ ហើយការផ្តល់នេះគឺធ្វើឡើងតាមរយៈអង្គការក្រៅរដ្ឋាភិបាលដែលជាអន្តរការីស្ទើរតែទាំងអស់ ។ ប៉ុន្តែក្នុងនោះមានតែអង្គការក្រៅរដ្ឋាភិបាលមួយចំនួនតូចប៉ុណ្ណោះដែលមានការផ្សារភ្ជាប់ទៅនឹងមូលដ្ឋានស្រាប់ ពោលគឺមានទាំងវត្តមាននិងជំនាញ ។ គំនិតផ្តួចផ្តើមខ្លះ (ដូចជាសមាគមកសិករអង្គការសេដាក) សំរេចបាន

លទ្ធផលគួរជាទីចាប់អារម្មណ៍ និងបានផ្តល់នូវឱកាសដ៏ល្អសំរាប់រៀនសូត្រ ការពង្រីកបន្ថែម និងយកទៅអនុវត្តនៅកន្លែងផ្សេងទៀត ។

២៨. *បញ្ហាប្រឈមផ្ទៃក្នុងផ្នែកអភិបាលកិច្ចរបស់សង្គមស៊ីវិល* - ដើម្បីអោយសង្គមស៊ីវិលដើរតួនាទីបានកាន់តែល្អប្រសើរក្នុងការជួយដល់រដ្ឋាភិបាលអោយមានតម្លាភាព មានការទទួលខុសត្រូវ និងមានការឆ្លើយតបបានល្អ អង្គការសង្គមស៊ីវិលខ្លួនឯងផ្ទាល់ត្រូវខិតខំធ្វើជាគំរូគេទាំងផ្នែកគុណតំលៃ និងការអនុវត្តន៍ជាក់ស្តែងនូវអ្វីដែលខ្លួនឯងចង់អោយគេធ្វើ ។ ជាអកុសល ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា អង្គការសង្គមស៊ីវិលជាច្រើននៅគ្រប់កំរិតថ្នាក់នៅកម្ពុជា ពុំសូវប្រកាន់យកលទ្ធិប្រជាធិបតេយ្យ ការចូលរួម និងការទទួលខុសត្រូវចំពោះ"ថ្នាក់ក្រោម" នៅក្នុងផ្ទៃក្នុងរបស់ខ្លួនទេ ។ ខណៈដែលគំរូដឹកនាំបែប"ថ្នាក់លើ-ថ្នាក់ក្រោម" និងឥរិយាបថបែបបិតុនិយម កើតមានព្រោងព្រាតនៅកម្ពុជា អ្នកដឹកនាំក្នុងសង្គមស៊ីវិល (រួមទាំងសមាជិកផង) ជាញឹកញាប់តែងបែរទៅប្រកាន់យកគំរូអភិបាលកិច្ចម្យ៉ាងដែលបង្កអោយមានការពឹងផ្អែកលើអ្នកដទៃដោយមិនដឹងខ្លួន ហើយលើសពីនេះទៀតខកខានមិនបានលើកទឹកចិត្ត និងផ្តល់អំណាចដល់សមាជិកខ្លួន អោយហ៊ាននិយាយ និងធ្វើអ្វីៗជំនួសខ្លួន ឬចូលរួមនៅក្នុងការសំរេចចិត្ត និងទាមទារអោយមានការទទួលខុសត្រូវឡើយ ។ ទំនាក់ទំនងជាមួយស្ថាប័នម្ចាស់ជំនួយក៏ស្តែងអោយឃើញនូវបញ្ហាប្រឈមដែរដោយសារជាញឹកញយអង្គការសង្គមស៊ីវិលបង្ហាញអោយឃើញនូវទំនាក់ទំនងបែប "ថ្នាក់លើ-ថ្នាក់ក្រោម" និងផ្តោតការយកចិត្តទុកដាក់ច្រើនទៅលើការទទួលខុសត្រូវចំពោះ "ថ្នាក់លើ" (ចំពោះម្ចាស់ជំនួយ)ច្រើនជាង "ការទទួលខុសត្រូវចំពោះថ្នាក់ក្រោម" (អតិថិជន សមាជិក ប្រជាពរលដ្ឋគោលដៅ) ។ តែទោះជាយ៉ាងណាក្តី ការសិក្សាស្រាវជ្រាវនេះបានរកឃើញឧទាហរណ៍មួយចំនួនគួរជាទីពេញចិត្ត ទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដែលនោះគឺជាកិច្ចខិតខំប្រឹងប្រែងបង្កើតនូវគំរូដឹកនាំដែលមានលក្ខណៈឆ្លើយតប មានការចូលរួម និងការទទួលខុសត្រូវ ។

២៩. *បណ្តាញសង្គមស៊ីវិល* — បើទោះបីជាក្នុងទសវត្សកន្លងមក មានកិច្ចខិតខំប្រឹងប្រែងគួរអោយចាប់អារម្មណ៍ ក្នុងការការបង្កើតបណ្តាញ និងការចែករំលែកព័ត៌មានក្នុងចំណោមអង្គការសង្គមស៊ីវិលនៅគ្រប់កំរិតថ្នាក់យ៉ាងណាក្តី ក៏ការស្រាវជ្រាវនេះបានរកឃើញថា ប្រសិទ្ធិភាព និងឥទ្ធិពលនៃបណ្តាញទាំងនេះនៅមានកំរិតទាបនៅឡើយ (ជាពិសេសនៅថ្នាក់ក្រោមជាតិ) ។ មានបណ្តាញតែមួយចំនួនតូចប៉ុណ្ណោះដែលកំពុងប្រតិបត្តិនៅថ្នាក់ជាតិ (ដូចជាអង្គការ CCC អង្គការNGO Forum អង្គការស្តារកម្ពុជា អង្គការ MediCam និង NEP) ដែលបានបង្កើតនូវប្រព័ន្ធ និងរចនាសម្ព័ន្ធរៀបរយល្អ សំរាប់ការសំរបសំរួល និងការចែករំលែកព័ត៌មានបានទៀងទាត់ ។ ឯបណ្តាញថ្នាក់ខេត្តទើបត្រូវបានបង្កើតឡើង ហើយច្រើនតែជួបប្រទះការលំបាកដោយសារមានជំនួយ (ថវិកា និងបច្ចេកទេស) ដ៏ស្តួចស្តើងពេក ។ នៅថ្នាក់ឃុំ ការផ្សារភ្ជាប់រវាង និងក្នុងចំណោមអង្គការសហគមន៍ និងអង្គការសង្គមស៊ីវិល ក៏នៅមានកំរិតតិចតួចដែរ ហើយក្រុមទាំងនេះក៏ប្រឈមនឹងបញ្ហាកង្វះសមត្ថភាព និងធនធានកាន់តែធ្ងន់ធ្ងរថែមទៀត ។ តែទោះជាយ៉ាងណាក្តី ការស្រាវជ្រាវបានរកឃើញនូវឧទាហរណ៍ជោគជ័យមួយចំនួន ដែលទាក់ទងនឹងការកសាងបណ្តាញនៅថ្នាក់មូលដ្ឋានបែបនេះ ។

៣០. អនុសាសន៍ចំនួនបីត្រូវបានស្នើឡើងដើម្បីដោះស្រាយបញ្ហាទាំងនេះ

*អនុសាសន៍ គ.១ - ឧបត្ថម្ភ*គាំទ្រដល់ការកើតមានឡើងនៃសមាគមប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន

ឧទាហរណ៍, តាមរយៈ

- រៀបចំអោយអ្នកដឹកនាំ និងតំណាងប្រជាពលរដ្ឋនៅមូលដ្ឋានបានជួបគ្នាជាមួយប្រតិបត្តិករ និងអ្នកឯកទេសដែលពាក់ព័ន្ធ ដើម្បីបានឆ្លុះបញ្ចាំងទៅលើមូលហេតុដែលនាំអោយពុំសូវមានសមាគមមូលដ្ឋាននៅកម្ពុជា រួចហើយបំផុសគំនិតរកវិធីជំរុញអោយមានការរួបរួមជាសមាគមនៅក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា ។
- ធ្វើការសិក្សាទៅលើគំនិតផ្តួចផ្តើមដែលមានស្រាប់ (ដូចជាសមាគមកសិកររបស់សេដាក សហគមន៍អាដហុក សហជីពកម្មករ និងបណ្តាញអ្នកភូមិ) ដើម្បីស្វែងយល់ ថាតើវិធីសាស្រ្តណាខ្លះដែលមានជោគជ័យ ឬមាននិរន្តរភាពបំផុត (ដូចជាជោគជ័យនៃវិធីសាស្រ្ត "ផ្តោតលើផលប្រយោជន៍" ជាជាង "ផ្តោតទៅលើទស្សនាទាន" អត្ថប្រយោជន៍ ឬភាពចាំបាច់នៃការផ្សារភ្ជាប់ការផ្តល់អំណាចផ្នែកសេដ្ឋកិច្ចនិងនយោបាយទៅនឹងគំរូការអោយមានការចូលរួម និងការនៅជាមួយគ្នាយូរអង្វែង)។
- ផ្តល់ការគាំទ្រ និងធនធានបន្ថែមទៀតដល់អង្គការសហគមន៍ និងអង្គការសង្គមស៊ីវិលដែលធ្វើការងារនៅមូលដ្ឋានផ្ទាល់ ។

*អនុសាសន៍ គ.២* - គាំទ្រអង្គការសង្គមស៊ីវិលអោយក្លាយជាគំរូផ្នែកអភិបាលកិច្ចដែលប្រកបដោយតម្លាភាព មានការឆ្លើយតប និងការទទួលខុសត្រូវ

ឧទាហរណ៍, តាមរយៈ

- ការគាំទ្រកិច្ចខិតខំប្រឹងប្រែងដែលមានស្រាប់របស់អង្គការសង្គមស៊ីវិលកម្ពុជា (ដូចជាកិច្ចខិតខំដែលដឹកនាំដោយអង្គការ CCC) ក្នុងការបង្កើតក្រមសីលធម៌រួម និងប្រព័ន្ធស្វ័យនិយ័តកម្មជាដើម ។
- ការគាំទ្រគំនិតផ្តួចផ្តើមដើម្បីអភិវឌ្ឍន៍អង្គការ និងការកសាងសមត្ថភាពដើមម្បីឈានទៅកែលំអអភិបាលកិច្ច និងការគ្រប់គ្រងផ្ទៃក្នុងរបស់អង្គការសង្គមស៊ីវិល ។
- ម្ចាស់ជំនួយត្រូវ "ធ្វើនូវអ្វីដែលខ្លួននិយាយ" និង "ធ្វើខ្លួនជាគំរូ" តាមរយៈការលើកកំពស់តម្លាភាព និងអនុវត្តនូវ "ការទទួលខុសត្រូវចំពោះថ្នាក់ក្រោម" របស់ខ្លួន ។

*អនុសាសន៍ គ.៣* - គាំទ្រនិងសំរបសំរួលអោយមានការចែករំលែកព័ត៌មាន ការចងក្រងបណ្តាញ និងការកសាងសម្ព័ន្ធភាពកាន់តែមានប្រសិទ្ធិភាពក្នុងចំណោមអង្គការសង្គមស៊ីវិល

ឧទាហរណ៍, តាមរយៈ

- ការផ្តល់ឱកាសដល់អ្នកដឹកនាំ និងបុគ្គលិកអង្គការសង្គមស៊ីវិល (ជាពិសេសអង្គការនៅថ្នាក់ក្រោមជាតិ) បានរៀនសូត្រអំពីបទពិសោធន៍ល្អៗផ្នែកចែករំលែកព័ត៌មាន ការចងក្រងបណ្តាញ និងការកសាងសម្ព័ន្ធភាពនេះ រួចហើយអោយគេយកទៅពិសោធន៍អនុវត្តជាមួយនឹងវិធីសាស្រ្ត និងបច្ចេកទេសថ្មីៗ ។
- ការផ្តល់មូលនិធិ និងការគាំទ្រដល់បណ្តាញផ្នែកទទួលខុសត្រូវសង្គម បណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្តដែលទើបកើតឡើងថ្មីៗ ទំនាក់ទំនងក្នុងចំណោមសមាគមថ្នាក់សហគមន៍ ឬមូលដ្ឋាន និងរវាងក្រុមនានានៅថ្នាក់សហគមន៍ ជាមួយនឹងអង្គការសង្គមស៊ីវិលដែលធ្វើការនៅថ្នាក់ខ្ពស់ជាងនេះ (ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ)។

## ២.ឃ. ការចូលរួមនិងការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា

៣១. ទិសដៅចុងក្រោយបំផុតនៃកិច្ចការទទួលខុសត្រូវសង្គម គឺពុំមែនត្រឹមតែលើកកំពស់ការចែករំលែកព័ត៌មាន និងការសំដែងមតិរបស់ប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែគឺជាការឆ្លើយតបពីមន្ត្រីសាធារណៈ និងសកម្មភាពដែលលើកកំពស់ប្រសិទ្ធិភាព និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល ។ ដើម្បីមានឥទ្ធិពលទៅលើការសំរេចចិត្ត និងសកម្មភាពរបស់រដ្ឋាភិបាល អង្គការសង្គមស៊ីវិលច្រើនតែពឹងផ្អែកទៅលើយុទ្ធសាស្ត្រឯកតោភាគី គឺការរិះគន់ ការបញ្ចុះបញ្ចូល និងការដាក់សម្ពាធ ក្រោមរូបភាពការតស៊ូមតិ ការបញ្ចុះបញ្ចូល ការធ្វើបាតុកម្មជាសាធារណៈ ការប្រឆាំងតវ៉ា ឬការបរិហារជាសាធារណៈ ។ តែទោះជាយ៉ាងនេះក្តី ឱកាសដែលអាចធ្វើអោយមានការផ្លាស់ប្តូរពិតប្រាកដអាចមានច្រើនជាងនេះ ប្រសិនបើប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលអាចប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយសមភាគីរដ្ឋាភិបាល និងមានកិច្ចសន្ទនាប្រកបដោយលក្ខណៈស្ថាបនាជាមួយពួកគេ ។ ឱកាស និងយន្តការសំរាប់ *ការពិភាក្សារវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល និងសំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការនៃការពិចារណានិងការសំរេចចិត្តជាសាធារណៈ*កំពុងតែកើតមានច្រើនឡើងៗនៅកម្ពុជាប៉ុន្តែវិសាលភាពនិងប្រសិទ្ធិភាពនៅមានកំរិតទាបនៅឡើយ ។

៣២. *បង្កើតនូវបរិយាកាសអំណោយផល និងធ្វើស្ថាប័ននីយកម្មនូវសិទ្ធិរបស់ប្រជាពលរដ្ឋ/អង្គការសង្គមស៊ីវិល* – ការស្រាវជ្រាវនេះរកឃើញថា មានការយល់ដឹងតិចតួចអំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ (ទាំងក្នុងចំណោមប្រជាពលរដ្ឋ និងតួអង្គនានារបស់រដ្ឋាភិបាល) ហើយក៏បានកត់សំគាល់ឃើញពីការយល់ឃើញផ្សេងគ្នាអំពីតួនាទីស្របច្បាប់ និង "សមស្រប" របស់សង្គមស៊ីវិល ។ ដោយសារបរិយាកាសមិនមានលក្ខណៈអំណោយផល តួអង្គនានាក្នុងសង្គមស៊ីវិលដែលធ្វើសកម្មភាពផ្អែកតស៊ូមតិ (ភាគច្រើនជាឯកតោភាគី និងមានលក្ខណៈតទល់) បានយល់ឃើញថាឥទ្ធិពលរបស់គេ "មានកំរិតតិចតួច" ហើយមានការសោកស្តាយដោយសារជាញឹកញយ គេជួបប្រទះនូវការជំទាស់ពីរដ្ឋាភិបាល (ជាជាងការឆ្លើយតបតាមការចង់បានរបស់ពួកគេ) ។

៣៣. *ពី "ការតស៊ូមតិ" ទៅជាការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា* - ការស្រាវជ្រាវនេះបានរកឃើញនូវគំលាតដ៏ធំរវាងអង្គការមួយប្រភេទដែលមានលក្ខណៈនយោបាយ និងមិនចេះដេញដោល (ធ្វើការផ្អែកផ្តល់សេវា)និងអង្គការបែប "វាយប្រហារ" មួយប្រភេទទៀត (ធ្វើការផ្អែកតស៊ូមតិ) ។ ការសិក្សានេះបានរកឃើញថា វិធីសាស្ត្រនៃកិច្ចការទទួលខុសត្រូវសង្គមបានផ្តល់នូវសក្តានុពលយ៉ាងធំធេងសំរាប់លើកកំពស់សកម្មភាពតស៊ូមតិ និងបំពេញនូវ"ចន្លោះ" (រវាងការតស៊ូមតិនិងការផ្តល់សេវា) ជាមួយនឹងសកម្មភាពដែលជំរុញអោយមានការប្រាស្រ័យទាក់ទង (រួមទាំងការចោទសួរ រិះគន់ និង ដេញដោល) ជាមួយតួអង្គនានារបស់រដ្ឋាភិបាល ប៉ុន្តែត្រូវធ្វើឡើងក្នុងលក្ខណៈមួយដែលមានលក្ខណៈស្ថាបនា ប្រាកដប្រជា ផ្អែកលើភស្តុតាង និងផ្តោតលើដំណោះស្រាយ ។ នៅក្នុងបរិបទកម្ពុជា ការងាកចេញពីវិធីសាស្ត្រតស៊ូមតិជាលក្ខណៈឯកតោភាគី និងបែបតទល់ ទៅជាការបង្កលទ្ធភាពសំរាប់ការពិភាក្សា និងការចូលរួមប្រកបដោយលក្ខណៈស្ថាបនានោះ គឺជាបញ្ហាប្រឈមដ៏ធំបងមួយ ។ ការបង្កើតអោយមានលទ្ធភាពបែបនេះ ជាការលំបាក ទាំងសំរាប់អង្គការសង្គមស៊ីវិល និងមន្ត្រីរដ្ឋាភិបាល ក្នុងការប្តូរមកប្រកាន់នូវឥរិយាបថដែលប្រកបដោយលក្ខណៈស្ថាបនា និងការសុខចិត្តប្តូរមកប្រាស្រ័យទាក់ទងជាមួយគ្នា បើទោះបីជាមានទស្សនៈផ្ទុយគ្នា និងបើទោះបីគេមានការមន្ទិលសង្ស័យ និងមិនទុកចិត្តគ្នាក៏ដោយនោះ ។ វាជាបញ្ហាប្រឈមចំពោះអង្គការសង្គមស៊ីវិលដែលត្រូវតែមានភស្តុតាងសំរាប់ការតវ៉ាណាមួយ ហើយត្រូវស្នើឡើងនូវដំណោះស្រាយបញ្ហា ជាជាងគ្រាន់តែលើកឡើងពីបញ្ហានោះ ។

៣៤. *លើកកំពស់ប្រសិទ្ធិភាពនៃយន្តការទទួលខុសត្រូវសង្គមដែលមានស្រាប់តាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ* — ដំណើរការវិមជ្ឈការ និងវិសហមជ្ឈការនាពេលបច្ចុប្បន្ន បើទោះបីពុំទាន់មានការអភិវឌ្ឍន៍បានល្អក្តី ក៏បានផ្តល់នូវឱកាសដ៏សំខាន់សំរាប់អោយប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលបានចូលរួមពាក់ព័ន្ធជាមួយអាជ្ញាធររដ្ឋាភិបាល និងអ្នកផ្តល់សេវាសាធារណៈនៅថ្នាក់ឃុំ ស្រុក និងខេត្តដែរ ។ យន្តការដែលមានស្រាប់ បង្កើតឡើងក្នុងបំណងសំរបសំរួលអោយមានការចូលរួម របស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវនោះ (ដូចជាការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ គណៈកម្មាធិការទ្រទ្រង់សាលារៀន និង"ប្រអប់គណនេយ្យភាព"ជាដើម) នៅមានឥទ្ធិពលតិចតួចនៅឡើយ និងតំរូវអោយមានការចូលរួមយ៉ាងពិតប្រាកដបន្ថែមទៀត អោយសាធារណៈជនបានមើលឃើញ និងងាយស្រួលប្រើប្រាស់ដើម្បីអោយយន្តការទាំងនេះមានប្រសិទ្ធិភាពខ្ពស់ ។

៣៥. *ពង្រីកឱកាស និងយន្តការសំរាប់ការពិភាក្សា និងការចូលរួម* - ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ពុំសូវមានសញ្ញាណនៃការមានឱកាស ឬយន្តការផ្សេងដែលអាចអោយប្រជាពលរដ្ឋប្រាស្រ័យទាក់ទង និងចូលរួមអោយបានពេញលេញជាមួយអាជ្ញាធររដ្ឋាភិបាលឡើយ ។ នៅថ្នាក់ឃុំ មានឧទាហរណ៍គួរជាទីពេញចិត្តខ្លះជាមួយនឹងការធ្វើវេទិកាសាធារណៈ ប៉ុន្តែគំនិតផ្តួចផ្តើមបែបនេះពុំសូវមានច្រើនទេ ។ នៅថ្នាក់ជាតិ ឱកាសសំរាប់ការពិភាក្សារវាងអង្គការសង្គមស៊ីវិល និងតួអង្គនានាក្នុងរដ្ឋាភិបាល មានកាន់តែច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ (ឧទាហរណ៍ តាមរូបភាពនៃវេទិការួម ឬក្រុមការងារ)។ តែទោះជាយ៉ាងនេះក្តី វេទិកាបែបនេះនៅមានចំនួនតិចតួចនៅឡើយ ហើយអ្នកចូលរួមដែលពុំមែនជាស្ថាប័នរដ្ឋ នៅពុំទាន់បានយល់ច្បាស់ពីលក្ខខ័ណ្ឌនៃការចូលរួមនោះ ហើយក៏នៅខ្វះការតាមដាន រីឯឥទ្ធិពលវិញក៏នៅមានតិចតួចដែរ ។

៣៦. អនុសាសន៍ចំនួនបីត្រូវបានស្នើឡើង ដើម្បីដោះស្រាយបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងដើម្បីប្រើប្រាស់នូវឱកាសដែលបានកំណត់រកឃើញ ។

*អនុសាសន៍ ឃ.១* — បង្កើតនិងគាំទ្រអោយមានបរិយាកាសគោលនយោបាយអំណោយផលមួយសំរាប់ការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា និងសំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល

ឧទាហរណ៍, តាមរយៈ

- បង្កលក្ខណៈអោយតួអង្គសំខាន់ៗពីខាងរដ្ឋាភិបាល និងសង្គមស៊ីវិលបានជួបគ្នាដើម្បីស្វែងរកកុងសង់ស៊ីស (ការឯកភាពគ្នា) ទៅលើគោលការណ៍សំខាន់ៗនៃការទទួលខុសត្រូវសង្គម និងសិទ្ធិ ព្រមទាំងករណីយកិច្ចរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងតួអង្គនានាក្នុងរដ្ឋាភិបាល ។
- បង្កើតក្រុមការងារពិសេសមួយ (ដែលសមាសភាពរួមមាន "អ្នកមានស្នាដៃល្អ" ផ្នែកការទទួលខុសត្រូវសង្គមពីខាងរដ្ឋាភិបាល និងសង្គមស៊ីវិល) ដើម្បីលើកសំណើ និងអនុវត្តការកែទំរង់គោលនយោបាយ និងវិធានរបស់ស្ថាប័ន ក្នុងបំណងលើកកំពស់លទ្ធភាពទទួលបានព័ត៌មាន ការសំដែងមតិ ការរួបរួមជាសមាគម ការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា និងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការអភិបាលកិច្ច ។
- រិះរក និងបង្កើតយន្តការនានាសំរាប់ដោះស្រាយបញ្ហា ឬការត្អូញត្អែរ ឬការមិនឯកភាពធំៗណាមួយដែលតួអង្គនានាក្នុងចំណោមអង្គការសង្គមស៊ីវិលបានលើកឡើង ។

*អនុសាសន៍ ឃ.២* - លើកកំពស់ និងគាំទ្រការប្រើប្រាស់វិធីសាស្ត្រសំរបសំរួល និងឧបករណ៍នៃការទទួលខុសត្រូវសង្គម ដើម្បីធ្វើអោយយន្តការដែលមានស្រាប់សំរាប់ការពិភាក្សានិងការចូលរួម(ដូចជាកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណៈកម្មការទ្រទ្រង់សាលារៀន) កាន់តែមានប្រសិទ្ធិភាព

ឧទាហរណ៍, តាមរយៈ

- ការលើកទឹកចិត្ត និងគាំទ្រអង្គការសហគមន៍ អង្គការសង្គមស៊ីវិល អោយបង្កើតឡើងនូវតួនាទីជា "ស្ពាន " ក្នុងនាមជាអ្នកសំរបសំរួល ឬអន្តរការី រវាងប្រជាពលរដ្ឋ និងអាជ្ញាធរ ។
- ការផ្តល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ផ្នែកវិធីសាស្ត្រ និងឧបករណ៍នៃការទទួលខុសត្រូវសង្គមសំរាប់ប្រតិបត្តិករកម្ពុជា ។
- ការប្រើប្រាស់អ្នកសំរបសំរួលដែលជាភាគីទីបី នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ ការគាំទ្រដល់ការជួបជុំរបស់ប្រជាពលរដ្ឋមុនពេលចូលរួមប្រជុំ និងការប្រើប្រាស់ឧបករណ៍នៃការទទួលខុសត្រូវសង្គម និងវិធីសាស្ត្រនៃការចូលរួម ។ ការបង្កើតឡើងនូវតួនាទីរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ អោយធ្វើជាតំណាង និងនាំនាំសេចក្តីព្រួយបារម្ភរបស់ប្រជាពលរដ្ឋ ទៅដល់រដ្ឋាភិបាលថ្នាក់កណ្តាល ហើយជំនួសមុខអោយប្រជាពលរដ្ឋ ជំរុញអោយរដ្ឋាភិបាលថ្នាក់កណ្តាលទទួលខុសត្រូវ ។
- ការផ្តល់ការបណ្តុះបណ្តាលផ្នែកជំនាញសំរបសំរួល និងបច្ចេកទេសការងារទទួលខុសត្រូវសង្គមដល់សមាជិកសំខាន់ៗ នៃគណៈកម្មការទ្រទ្រង់សាលារៀន (SSCs) និងគាំទ្រកិច្ចខិតខំរបស់ SSCs ក្នុងការប្រើប្រាស់វិធីសាស្ត្រនៃការទទួលខុសត្រូវសង្គម (ដូចជា "ប័ណ្ណដាក់ពិន្ទុសាលារៀន " និង បច្ចេកទេសក្នុងការតាមដានការចំណាយ ជាដើម) ។

*អនុសាសន៍ ឃ.៣*- ណែនាំអោយប្រើប្រាស់នូវឱកាស និងយន្តការថ្មីៗសំរាប់អោយមានការពិភាក្សា និង“ការចរចារ”ដោយផ្ទាល់ និងទៀងទាត់រវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល (នៅគ្រប់កំរិតថ្នាក់)

ឧទាហរណ៍, តាមរយៈ

- ការលើកទឹកចិត្ត(ឬការណែនាំ)អោយក្រុមប្រឹក្សាឃុំ-សង្កាត់រៀបចំការពិភាក្សាជាសាធារណៈអោយបានទៀងទាត់ដោយមានការសំរបសំរួល លើបញ្ហាជាអាទិភាពនានាដែលជាការព្រួយបារម្ភជាសាធារណៈ (ដូចជាសុខភាព ការអប់រំ សន្តិសុខ អំពើហិង្សាក្នុង គ្រួសារ ដីធ្លី ព្រៃឈើ និងនេសាទ) ។
- ការណែនាំអោយប្រើប្រាស់យន្តការថ្មីជាលក្ខណៈស្ថាប័ន សំរាប់ប្រមូលមតិយោបល់ប្រជាពលរដ្ឋ និងការឃ្លាំមើលរបស់ពួកគេទៅលើវិស័យចំបងៗដែលជាប្រយោជន៍សាធារណៈ (ដូចជាការគ្រប់គ្រងចំណូលសាធារណៈពីឧស្សាហកម្មរ៉ែ និងថាមពល) ។
- ការបង្កើតអោយមានឱកាសបន្ថែមទៀតសំរាប់តួអង្គក្នុងរដ្ឋាភិបាល និងសង្គមស៊ីវិលបានជួបគ្នាផ្ទាល់ទាំងនៅក្នុងបរិយាកាសផ្លូវការ និងមិនផ្លូវការដើម្បីកសាងទំនុកចិត្តគ្នាទៅវិញទៅមក ។

## ៣. ការពង្រឹងការទទួលខុសត្រូវសង្គមនៅកម្ពុជា

### ៣.ក សេចក្ដីសន្និដ្ឋាន

៣៧. ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ទំនាក់ទំនងនិងការផ្សារភ្ជាប់រវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាលនៅមានភាពទន់ខ្សោយនៅឡើយ ហើយមានបញ្ហាប្រឈមជាច្រើនដែលពាក់ព័ន្ធទៅនឹងកត្តាបង្កប់ផ្នែកនយោបាយ វប្បធម៌-សង្គម ប៉ុន្តែទន្ទឹមនឹងនេះក៏មានឱកាសល្អៗជាច្រើនផងដែរ ។ ការសិក្សានេះបានស្នើឡើងនូវអនុសាសន៍ជាច្រើន ដែលផ្ដោតទៅលើភាគីពាក់ព័ន្ធដូចជា*រដ្ឋា-ភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍* ។ អនុសាសន៍ទាំងនេះត្រូវបានស្នើឡើងក្នុងបំណងធ្វើអោយបរិយាកាសកាន់តែមានលក្ខណៈអំណោយផលថែមទៀត សំរាប់ការទទួលខុសត្រូវសង្គមនៅកម្ពុជា និងដើម្បីកសាងនូវសមត្ថភាព និងជំនាញដែលចាំបាច់ (ទាំងក្នុងរង្វង់សង្គមស៊ីវិលនិងរដ្ឋាភិបាល) ។ អនុសាសន៍ទាំងនេះក៏ស្នើឡើងដើម្បីពង្រីក និងធ្វើស្ថាប័ននីយកម្មនូវដែន ហើយនិងយន្តការសំរាប់ការពិភាក្សា និងការចរចាររវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល ជាពិសេសនៅថ្នាក់មូលដ្ឋាន ។ របាយការណ៍នេះ ក៏បានសង្កត់ធ្ងន់ផងដែរ អំពីកាលវេលាសំរាប់ជំរុញអោយមានវប្បធម៌នៃ "ការទទួលខុសត្រូវចំពោះថ្នាក់ក្រោម" នៅគ្រប់កំរិតថ្នាក់ព្រមជាមួយនឹងការផ្លាស់ប្ដូរឥរិយាបថ និងអាកប្បកិរិយារបស់ភាគីពាក់ព័ន្ធសំខាន់ៗ ។ ខណៈដែលគ្រប់អនុសាសន៍ទាំងអស់នៅក្នុងរបាយការណ៍នេះត្រូវបានក្រុមសិក្សាស្រាវជ្រាវចាត់ទុកថាមានសារៈសំខាន់ សកម្មភាពដូចខាងក្រោម (ជ្រើសរើសដោយសារមានប្រសិទ្ធិភាពជាលក្ខណៈយុទ្ធសាស្ត្រ) ត្រូវបានចាត់ទុកថាជាអាទិភាពខ្ពស់ ។

### ៣.ខ. សកម្មភាពអាទិភាព

៣៨. សកម្មភាពជាអាទិភាពដែលបានស្នើឡើងសំរាប់ **រាជរដ្ឋាភិបាលកម្ពុជា** រួមមាន ៖

*សំរាប់រយៈពេលខ្លី ៖*

*សកម្មភាពជាអាទិភាពទី១សំរាប់រាជរដ្ឋាភិបាល* - **ណែនាំ (និងគាំទ្រ) ក្រុមប្រឹក្សាឃុំ-សង្កាត់អោយរៀបចំជាវេទិកាសាធារណៈពីរដងក្នុងមួយឆ្នាំ ។** (អនុសាសន៍ ក.២, ខ.៣, និង ឃ.៣)

ការស្រាវជ្រាវនេះបង្ហាញថា ក្រុមប្រឹក្សាឃុំ-សង្កាត់មានសក្ដានុពលយ៉ាងធំធេង (ប៉ុន្តែពុំទាន់អភិវឌ្ឍអោយបានប្រសើរ) សំរាប់រៀបចំវេទិកាដើម្បីការពិភាក្សារវាងប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលគួរណែនាំអោយមានការរៀបចំធ្វើវេទិកាសាធារណៈពីរដងក្នុងមួយឆ្នាំអោយបានទៀងទាត់នៅថ្នាក់ឃុំ-សង្កាត់ សំរាប់ជាឱកាសអោយប្រជាពលរដ្ឋបានចូលរួមជាមួយអាជ្ញាធររដ្ឋាភិបាល លើបញ្ហានានាដែលជាសេចក្ដីព្រួយបារម្ភចំបងរបស់ពួកគេ ។

*សកម្មភាពជាអាទិភាពទី២សំរាប់រាជរដ្ឋាភិបាល*- **ចែងជាបញ្ញត្តិអោយបានច្បាស់លាស់អំពីការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងក្រុមប្រឹក្សាស្រុកនិងក្រុមប្រឹក្សាខេត្តដែលទើបបង្កើតឡើងថ្មីៗ** (អនុសាសន៍ក.២, ខ.៣ និងឃ.៣)

នៅពេលបច្ចុប្បន្ននេះ មានឱកាសតិចតួចណាស់សំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ។ រាជរដ្ឋា-ភិបាលត្រូវបានលើកទឹកចិត្តអោយចេញជាប្រកាសមួយ ដែលមានចែងជាបញ្ញត្តិច្បាស់លាស់ ដើម្បីប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលអាចចូលរួមយ៉ាងមានន័យនៅក្នុងក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខេត្តដែលបង្កើតឡើងថ្មីៗ (បង្កើតឡើងអនុលោមទៅតាមច្បាប់អង្គការដែលទើបត្រូវបានអនុម័តនាពេលថ្មីៗនេះ) ។

*សំរាប់រយៈពេលវែង :*

*សកម្មភាពជាអាទិភាពទី៣សំរាប់រាជរដ្ឋាភិបាល* - **ណែនាំសាលារៀន និងមណ្ឌលសុខភាព និងមន្ទីរពេទ្យទូទាំងប្រទេស អោយចែករំលែកព័ត៌មាន អំពីថវិកាជាសាធារណៈ** (អនុសាសន៍ ក.២)

ការស្រាវជ្រាវនេះបានរកឃើញថា ប្រជាពលរដ្ឋខ្វះលទ្ធភាពទទួលបានព័ត៌មានអំពីសេវាសាធារណៈជាមូលដ្ឋានដែលមានផលប៉ះពាល់ដោយផ្ទាល់ដល់សុខុមាលភាពរបស់ពួកគេ ។ ដើម្បីលើកកំពស់តម្លាភាព និងការទទួលខុសត្រូវសង្គម រាជរដ្ឋាភិបាលត្រូវបានលើកទឹកចិត្តអោយផ្តល់ជាសេចក្តីណែនាំដល់សាលារៀន និងមណ្ឌលសុខភាព និងមន្ទីរពេទ្យនៅទូទាំងប្រទេសអោយចែករំលែកព័ត៌មានអំពីថវិកាជាសាធារណៈ ដើម្បីអោយអ្នកប្រើប្រាស់សេវា ឬប្រជាពលរដ្ឋ បានដឹងអំពីការប្រើប្រាស់ថវិកាសាធារណៈ និងធនធានដទៃទៀតនៅទីកន្លែងទាំងនេះ និងអោយគេបានដឹងថាតើធនធានទាំងនោះត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច ។ ជាអនុសាសន៍ សំរង់ហិរញ្ញវត្ថុប្រចាំឆ្នាំគួរបិតផ្សាយជាសាធារណៈ និងបង្ហាញជូនក្នុងពេលមានវេទិកាសាធារណៈប្រចាំឆ្នាំ ។

*សកម្មភាពជាអាទិភាពទី៤សំរាប់រាជរដ្ឋាភិបាល* - **បង្កើតក្រុមប្រឹក្សាភិបាលអន្តរក្រសួង** (អនុសាសន៍ ឃ.១ និង ឃ.៣)

វេទិកាទៀងទាត់សំរាប់ការចែករំលែកព័ត៌មានរវាងតួអង្គនានាក្នុងសង្គមស៊ីវិល និងរដ្ឋាភិបាលនៅពុំទាន់មាននៅឡើយទេ ។ ជាអនុសាសន៍ រាជរដ្ឋាភិបាលគួរស្នើអោយបណ្តាក្រសួងពាក់ព័ន្ធបង្កើតឡើងនូវក្រុមប្រឹក្សាភិបាលអចិន្ត្រៃយ៍មួយ (ដែលសមាសភាពរួមមានតំណាង ឬទីប្រឹក្សាពាក់ព័ន្ធពីផ្នែកសង្គមស៊ីវិល ផ្នែកសិក្សាធិការ និងវិស័យផ្នែកឯកជន ។ល។) ក្រុមទាំងនេះគួរជួបប្រជុំគ្នាជាទៀងទាត់ (ឧទាហរណ៍ ប្រចាំត្រីមាស) អាស្រ័យទៅតាមលក្ខន្តិកៈច្បាស់លាស់របស់ខ្លួន ដើម្បីជាការរួមចំណែកដល់ការលើកឡើង និងពិភាក្សាអំពីបញ្ហាដែលជាក្តីបារម្ភចំបងៗរបស់សាធារណៈជន ផ្តល់យោបល់ត្រលប់ទៅលើឯកសារសំខាន់ៗ និងសំរបសំរួលដំណើរការពិគ្រោះយោបល់ជាសាធារណៈទៅលើច្បាប់ ឬគោលនយោបាយថ្មីៗ ។

៣៩. សកម្មភាពជាអាទិភាពដែលបានស្នើឡើងសំរាប់ **អង្គការសង្គមស៊ីវិល** រួមមាន :

*សំរាប់រយៈពេលខ្លី :*

*សកម្មភាពជាអាទិភាពទី១សំរាប់អង្គការសង្គមស៊ីវិល*— **ពង្រីកគំនិតផ្តួចផ្តើមថងក្រង និងផ្តល់អំណាចនៅថ្នាក់សហគមន៍** (អនុសាសន៍ ខ.១ និង គ.១)

កិច្ចខិតខំក្នុងការផ្តល់អំណាច គប្បីធ្វើឡើងដោយផ្អែកលើបទពិសោធន៍ និងការរៀនសូត្រពីទំរង់នានា ដូចជាសមាគមកសិករដែលទទួលការគាំទ្រពីអង្គការសេដាក និងសមាគមសុខភាពភូមិរបស់ក្រុមអភិវឌ្ឍន៍ភូមិ ដែលមានបំណងដោះស្រាយសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ហើយដែលក្នុងខណៈជាមួយគ្នានោះ បានជួយពង្រឹងការសំដែងមតិ និងឥទ្ធិពលនយោបាយរបស់ពួកគេផង ។ ការកសាងចំណេះដឹង ទំនុកចិត្ត និងអំណាចរបស់ប្រជាពលរដ្ឋសាមញ្ញៗ (រួមមាន ស្ត្រី យុវជន និងក្រុមដទៃទៀតដែលគេមិនសូវយកចិត្តទុកដាក់) គឺជាផ្នែកមួយដ៏សំខាន់នៃការទទួលខុសត្រូវសង្គម រីឯកង្វះការផ្តល់អំណាច ដល់ប្រជាពលរដ្ឋនៅតាមសហគមន៍ គឺជាមូលហេតុចំបងដែលធ្វើអោយការឧបត្ថម្ភពីម្ចាស់ជំនួយក្នុងទសវត្សកន្លងមកពុំសូវទទួលបានជោគជ័យក្នុងការជំរុញនូវការទាមទារដ៏សកម្មអោយមានអភិបាលកិច្ចល្អ ។

*សកម្មភាពជាអាទិភាពទី២សំរាប់អង្គការសង្គមស៊ីវិល*— **ណែនាំអោយអនុវត្តនូវការធ្វើរបាយការណ៍ និងការប្រកាន់នូវតម្លាភាពចំពោះ "ថ្នាក់ក្រោម"** (អនុសាសន៍ គ.២)

ដើម្បីក្លាយខ្លួនជាភ្នាក់ងារធ្វើការផ្នែកទទួលខុសត្រូវសង្គមដ៏មានប្រសិទ្ធិភាព អង្គការសង្គមស៊ីវិលខ្លួនឯងត្រូវខិតខំធ្វើជាគំរូគេផ្នែកអភិបាលកិច្ចល្អនេះ តាមរយៈការកែលំអអភិបាលកិច្ចផ្ទៃក្នុង និងកែលំអប្រព័ន្ធតម្លាភាពរបស់ខ្លួន និងការទទួលខុសត្រូវចំពោះថ្នាក់ក្រោម ។ ទិដ្ឋភាពចំបងមួយនៃចំណុចនេះ គឺគេត្រូវខ្នះខ្នែងចែករំលែកព័ត៌មានអំពីកម្មវិធី និងថវិកាជាមួយអតិថិជន និងប្រជាពលរដ្ឋគោលដៅ រួចហើយលើកទឹកចិត្តពួកគេអោយចូលរួមឃ្លាំមើលអោយបានសកម្ម ។

*សំរាប់រយៈពេលវែង :*

*សកម្មភាពជាអាទិភាពទី៣សំរាប់អង្គការសង្គមស៊ីវិល* - **អភិវឌ្ឍន៍ជំនាញអំពីវិធីសាស្ត្រតស៊ូមតិបែបចូលរួមដែល "យកប្រជាពលរដ្ឋជាចំបង"** (អនុសាសន៍ ខ.១)

អង្គការសង្គមស៊ីវិលមានតួនាទីដ៏សំខាន់ក្នុងការផ្តល់អំណាចដល់ប្រជាពលរដ្ឋ អោយគេធ្វើសកម្មភាព និងតស៊ូមតិដោយខ្លួនឯង ។ សំរាប់អង្គការសង្គមស៊ីវិលកម្ពុជា ការកសាងសមត្ថភាព និងជំនាញអំពីវិធីសាស្ត្រតស៊ូមតិ និងការអភិវឌ្ឍន៍ដែលមានការចូលរួម និងយកប្រជាពលរដ្ឋជាចំបងនោះ ត្រូវបានចាត់ទុកថាជាកិច្ចការដែលមានអាទិភាពខ្ពស់ ។

*សកម្មភាពជាអាទិភាពទី៤សំរាប់អង្គការសង្គមស៊ីវិល* - **បង្កើតឡើងនូវតួនាទីសំរបសំរួលសំរាប់ការពិភាក្សារវាងប្រជាពល-រដ្ឋ និងរដ្ឋាភិបាល** (អនុសាសន៍ ឃ.២)

បទពិសោធន៍បង្ហាញថា ការពិភាក្សារវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល ទទួលបានផលយ៉ាងធំធេងបើមានការសំរបសំរួលពីភាគីទីបី ។ អង្គការសង្គមស៊ីវិលដើរតួនាទីយ៉ាងសំខាន់ជា "ស្ពាន" រវាងប្រជាពលរដ្ឋ និងអាជ្ញាធររដ្ឋាភិបាល ហើយអង្គការទាំងនោះត្រូវបានលើកទឹកចិត្តអោយបង្កើតឡើង និងពង្រីកតួនាទីទាំងនេះជាអាទិភាពខ្ពស់ (ជាពិសេសនៅថ្នាក់មូលដ្ឋាន) ។

៤០. សកម្មភាពជាអាទិភាពដែលបានស្នើឡើងសំរាប់ **ដៃគូអភិវឌ្ឍន៍** រួមមាន :

*សំរាប់រយៈពេលខ្លី :*

*សកម្មភាពជាអាទិភាពទី១សំរាប់ដៃគូអភិវឌ្ឍន៍* - **គាំទ្រការបណ្តុះបណ្តាល និងការហ្វឹកហ្វឺនដល់អ្នកដឹកនាំបច្ចុប្បន្ន និងអនាគតអ្នកដឹកនាំថ្នាក់មូលដ្ឋាន** (អនុសាសន៍ ខ.២)

សំរាប់ប្រជាពលរដ្ឋសាមញ្ញ អ្នកដឹកនាំសហគមន៍ និងអ្នកដឹកនាំថ្នាក់មូលដ្ឋាន បានដើរតួយ៉ាងសំខាន់ជាអ្នករៀបចំ អ្នកអប់រំ អ្នកគាំទ្រ និងអន្តរការី ។ ហេតុដូច្នេះហើយ ការវិនិយោគទៅលើសមត្ថភាព និងជំនាញរបស់អ្នកដឹកនាំនៅថ្នាក់មូលដ្ឋាននេះ ដើម្បីអោយគេផ្តល់ការឆ្លើយតប និងទទួលខុសត្រូវចំពោះថ្នាក់ក្រោម គឺជាអាទិភាពមួយ ។ ដៃគូអភិវឌ្ឍន៍គួរលើកកំពស់ការគាំទ្រដល់អង្គការសង្គមស៊ីវិល ដែលបច្ចុប្បន្នកំពុងផ្តល់ការបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំក្នុងមូលដ្ឋាន និងគាំទ្រការកសាងសមត្ថភាពនៅក្នុងផ្នែកនេះ ។

*សកម្មភាពជាអាទិភាពទី២របស់ដៃគូអភិវឌ្ឍន៍* - **ណែនាំអោយអនុវត្តនូវការធ្វើរបាយការណ៍ប្រកបដោយតម្លាភាព ទៅ "ថ្នាក់ក្រោម"** (អនុសាសន៍ គ.២)

ដៃគូអភិវឌ្ឍន៍ត្រូវបានលើកទឹកចិត្តអោយ "ធ្វើជាគំរូ" តាមរយៈការអនុវត្តន៍នូវការទទួលខុសត្រូវសង្គម អោយមានលក្ខណៈជាប្រព័ន្ធទៅក្នុងប្រតិបត្តិការរបស់ខ្លួន (ដូចជា ការធានាថាប្រជាពលរដ្ឋត្រូវបានផ្តល់ជូននូវព័ត៌មានអំពីថវិកាដែលបានផ្តល់ និងការប្រើប្រាស់ថវិកាទាំងនោះ ជាពិសេសអោយអ្នកទាំងនោះបានចូលរួមត្រួតពិនិត្យ និងវាយតំលៃទៅលើសកម្មភាពនៃការចំណាយទាំងនោះ) ។ នៅពេលដែលបានក្លាយទៅជាគំរូផ្នែកតម្លាភាព និងការរាយការណ៍ ដៃគូអភិវឌ្ឍន៍មិនត្រឹមតែបានលើកកំពស់ការឃ្លាំមើលជាសាធារណៈចំពោះថវិកានិងកម្មវិធីផ្ទាល់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានជួយប្រជាពលរដ្ឋអោយមើលឃើញជាក់ស្តែងពីរូបភាពនៃការទទួលខុសត្រូវសង្គម ហើយនិងអាចធ្វើអោយប្រជាពលរដ្ឋមានការរំពឹងទុកអំពីតម្លាភាព និងការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលផងដែរ ។

*សំរាប់រយៈពេលវែង :*

*សកម្មភាពជាអាទិភាពទីពារបស់ដៃគូអភិវឌ្ឍន៍* - **ពង្រីកការគាំទ្រដល់គំនិតផ្តួចផ្តើមនៅថ្នាក់សហគមន៍** (អនុសាសន៍ ខ.១ និង គ.១)

ការកៀងគរចងក្រង និងការផ្តល់អំណាចដល់ប្រជាពលរដ្ឋមានសារៈសំខាន់ណាស់ចំពោះការអភិវឌ្ឍន៍របស់សង្គមស៊ីវិល និងការទទួលខុសត្រូវសង្គម ។ រហូតមកដល់ពេលនេះ មានជំនួយពីដៃគូអភិវឌ្ឍន៍តែមួយចំណែកតូចប៉ុណ្ណោះ ដែលត្រូវបានផ្តល់ជូនដោយផ្ទាល់ដើម្បីគាំទ្រការអប់រំ ការចងក្រងនិងការផ្តល់អំណាចដល់ប្រជាពលរដ្ឋនៅថ្នាក់សហគមន៍ ។ ដៃគូអភិវឌ្ឍន៍គួរបង្កើនការឧបត្ថម្ភដល់អង្គការសង្គមស៊ីវិលទាំងឡាយដែលធ្វើការដោយផ្ទាល់នៅតាមសហគមន៍ និងលើកទឹកចិត្ត ព្រមទាំងគាំទ្រអង្គការសង្គមស៊ីវិលថ្នាក់ជាតិអោយអោយប្រកាន់យកនូវវិធីសាស្ត្រពីក្រោមទៅលើ និងផ្សារភ្ជាប់អោយមានប្រសិទ្ធិភាពជាមួយសហគមន៍ ។

*សកម្មភាពជាអាទិភាពទី៤របស់ដៃគូអភិវឌ្ឍន៍* - **ធ្វើការតស៊ូមតិ និងគាំទ្រអោយមានបរិយាកាសគោលនយោបាយអំណោយផលបន្ថែមទៀតសំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល** (អនុសាសន៍ ឃ.១)

លើកទឹកចិត្ត និងគាំទ្ររាជរដ្ឋាភិបាលកម្ពុជាអោយដាក់ចេញនូវគោលនយោបាយ និយ័តកម្ម និងគោលការណ៍ណែនាំ ដែលបង្កើតអោយមាននូវដែនសាធារណៈសំរាប់ការរួបរួមជាសមាគមរបស់ប្រជាពលរដ្ឋ ប្រកាន់យក និងការពារសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ រួចហើយដាក់ចេញនូវវិធានជាមូលដ្ឋានសំរាប់ការពិភាក្សាប្រកបដោយអត្ថន័យរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល ហើយត្រូវចាត់ទុកថាការចូលរួម គឺជាតួនាទីអាទិភាពរបស់ដៃគូអភិវឌ្ឍន៍ ។

## ១. ការរួមចំណែករបស់សង្គមស៊ីវិលចំពោះអភិបាលកិច្ចល្អនៅកម្ពុជា

### ១. ក. សេចក្តីផ្តើម

១. **ចាប់តាំងពីចុងទសវត្សឆ្នាំ ១៩៨០ រហូតមកដល់ដើមទសវត្សឆ្នាំ ១៩៩០ នៅពេលដែលមានដំណើរការសន្តិភាពដែលត្រួតពិនិត្យដោយអង្គការសហប្រជាជាតិ កម្ពុជាបានឆ្លងកាត់នូវដំណាក់កាលអន្តរកាលសំខាន់ៗចំនួនបី គឺពីសង្គ្រាមស៊ីវិលមកសន្តិភាព ពីការដឹកនាំដោយបក្សមួយមកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងពីភាពឯកោផ្នែកសេដ្ឋកិច្ចមកជាសមាហរណកម្ម (ទាំងនៅក្នុងតំបន់ និងសាកលលោក) ។** ក្នុងរយៈពេលមួយទសវត្សកន្លងមកនេះ ការកែទំរង់ដ៏ធំទូលាយ និងពោរពេញដោយបញ្ហាប្រឈមនៅគ្រប់វិស័យ បាននាំមកនូវការរីកចំរើនដ៏សំខាន់ឈានទៅធានានូវសុខសន្តិភាព ការកសាងស្ថាប័នឡើងវិញ និងការបង្កើតនូវបរិយាកាសស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។ បច្ចុប្បន្ននេះកម្ពុជាកំពុងទទួលបាននូវកំណើនសេដ្ឋកិច្ចដ៏ល្អ និងមានលទ្ធភាពក្នុងការបន្តនូវកំណើនបែបនេះនៅពេលអនាគត ។រីឯចំណូលថវិការដ្ឋក៏មានលក្ខណៈវិជ្ជមាន ដោយសារមានការរំពឹងនូវចំណូលពីផ្នែកប្រេង និងរ៉ែនាពេលខាងមុខ និងដោយសារមានការប្តេជ្ញាផ្តល់ជំនួយអភិវឌ្ឍន៍ក្រៅប្រទេស (ODA)(រួមទាំងពីប្រទេសចិនផង) ។ រឿងដែលថាតើសម្បត្តិធនធានដ៏ច្រើននេះ នឹងត្រូវបានប្រែក្លាយអោយទៅជាការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងសមធម៌ និងអាចកាត់បន្ថយភាពក្រីក្របានឬយ៉ាងណានោះ គឺវាអាស្រ័យយ៉ាងសំខាន់ទៅលើបញ្ហាអភិបាលកិច្ច និងយុត្តិធម៌សង្គម ដែលបញ្ហានេះត្រូវបានអ្នកធ្វើអត្ថាធិប្បាយជាច្រើនអំពីការអភិវឌ្ឍន៍ប្រទេសកម្ពុជា រួមទាំងអ្នកនៅក្នុងសហគមន៍ម្ចាស់ជំនួយផង ចាត់ទុកថាជាផ្នែកអាទិភាព ។[១]

២. **អភិបាលកិច្ចត្រូវបានចាត់ទុកជាទូទៅ ថាជាបញ្ហាប្រឈមដ៏ធំបំផុតចំពោះការអភិវឌ្ឍន៍នៅកម្ពុជា ។** បើទោះបីកម្ពុជាសំរេចបាននូវការរីកចំរើនផ្នែកសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្របានល្អបង្គួរក្តី ក៏បញ្ហាអំពើពុករលួយ ភាពទន់ខ្សោយផ្នែកការទទួលខុសត្រូវ និងការព្រួយបារម្ភដទៃទៀតផ្នែកអភិបាលកិច្ច នៅតែបន្តរាំងស្ទះដល់ការអភិវឌ្ឍន៍ (World Bank, *Country Assistance Strategy 2005-2008*:6-7) ។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់អំពីសេចក្តីត្រូវការក្នុងការដោះស្រាយបញ្ហាអភិបាលកិច្ចនេះ ហើយទាំង "យុទ្ធសាស្ត្រចតុកោណ" ឆ្នាំ២០០៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល បានដាក់បញ្ហាអភិបាលកិច្ចល្អជាចំណុចស្នូលនៃរបៀបវារៈអភិវឌ្ឍន៍ប្រទេសកម្ពុជា ។ នៅក្នុងទសវត្សកន្លងមក ក្រុមម្ចាស់ជំនួយ ដោយរាប់បញ្ចូលទាំងធនាគារពិភពលោកផង បានគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការអនុវត្តន៍នូវកំណែទំរង់វិស័យសាធារណៈ ការពង្រឹងស្ថាប័ននិងប្រព័ន្ធគ្រប់គ្រងសាធារណៈ ព្រមទាំងបង្កើតឡើងនូវយន្តការសំរាប់ការត្រួតពិនិត្យផ្ទៃក្នុង ។ បើទោះបីជាមានការរីកចំរើនសំខាន់ៗនៅក្នុងផ្នែកជាច្រើនយ៉ាងណាក្តី ក៏អ្នកធ្វើអត្ថាធិប្បាយភាគច្រើនយល់ឃើញដូចគ្នាថាដំណើរការនេះនឹងនៅវែងឆ្ងាយតទៅទៀត ជាពិសេសក្នុងការផ្លាស់ប្តូរវប្បធម៌នៃការផ្តល់សេវា និងអាជ្ញាធររបស់រដ្ឋ ដែលទាំងនេះជាផ្នែកចំបងនៃកង្វះអភិបាលកិច្ចល្អ ។

៣. **បទពិសោធន៍ជាសាកលបង្ហាញយ៉ាងច្បាស់ថា ដើម្បីសំរេចបាននូវអភិបាលកិច្ចល្អ វាទាមទារអោយមាននូវកិច្ចខិតខំប្រឹងប្រែងមិនត្រឹមតែពីខាងរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែក៏តំរូវអោយមាន*ការទាមទារ* យ៉ាងសកម្មនូវអភិបាលកិច្ចល្អពីប្រជាពលរដ្ឋផងដែរ ។**

---

[១] ឧទាហរណ៍ សូមមើល *Donors' Statements and Commitments at the Consultative Group for Cambodia Meeting*, March 2006.

ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល មានតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់រដ្ឋាភិបាលអោយកាន់តែមានប្រសិទ្ធិភាព និងការទទួលខុសត្រូវ ។ លទ្ធិប្រជាធិបតេយ្យ ដែលមានន័យថា*រដ្ឋាភិបាលកើតឡើងដោយប្រជាជន និងដើម្បីប្រជាជន* តំរូវអោយប្រជាពលរដ្ឋ (និងអង្គការរបស់ពួកគេ) ដើរតួនាទីយ៉ាងសកម្ម ដោយមិនត្រឹមតែបោះឆ្នោតជ្រើសរើសអ្នកតំណាងរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវជំរាបជូនទៅមន្ត្រីសាធារណៈរបស់រដ្ឋនូវមតិយោបល់ សេចក្តីត្រូវការ និងការព្រួយបារម្ភរបស់ខ្លួនផងដែរ ។ លើសពីនេះប្រជាពលរដ្ឋមានតួនាទីជូនយោបល់ពីបញ្ហាគោលនយោបាយនិងផែនការ ត្រួតពិនិត្យ និងផ្តល់យោបល់ត្រលប់អំពីសកម្មភាពរបស់រដ្ឋាភិបាល ព្រមទាំងជំរុញអោយរដ្ឋាភិបាលមានការទទួលខុសត្រូវ ។

៤. **ពាក្យថា "ការទទួលខុសត្រូវសង្គម" សំដៅដល់បណ្តាសកម្មភាព និងយន្តការ (លើសពីការបោះឆ្នោត) ដែលប្រជាពលរដ្ឋអាចប្រើប្រាស់ដើម្បីជួយធ្វើអោយរដ្ឋាភិបាលកាន់តែមានប្រសិទ្ធិភាព និងមានការទទួលខុសត្រូវ ហើយក៏សំដៅផងដែរដល់សកម្មភាពរបស់រដ្ឋាភិបាល សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងតួអង្គក្នុងសង្គមផ្សេងៗទៀត ដែលលើកកំពស់ ឬបង្កលក្ខណៈងាយស្រួលអោយប្រជាពលរដ្ឋធ្វើដូច្នេះបាន**[២] ។ វិធីសាស្ត្រនានាសំរាប់ការទទួលខុសត្រូវសង្គមត្រូវបានគេបន្តចាត់ទុកថា ជាមធ្យោបាយដ៏សំខាន់ក្នុងការកែលំអប្រសិទ្ធិភាពនៃអភិបាលកិច្ច និងការអភិវឌ្ឍន៍តាមរយៈការលើកកំពស់តម្លាភាព ការទទួលខុសត្រូវ និងការឆ្លើយតបនៅក្នុងដំណើរការរៀបចំគោលនយោបាយសាធារណៈ ការរៀបចំផែនការថវិកា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់សេវាសាធារណៈ ។ វិធីសាស្ត្រសំរាប់ការទទួលខុសត្រូវសង្គម ក៏ជួយពង្រឹងអំណាចដល់ប្រជាពលរដ្ឋ និងរួមចំណែកដល់ការកើតឡើងនូវ ស្ថាប័នប្រជាធិបតេយ្យបែបចំរុះ និងបើកចំហ ។ វិធីសាស្ត្រសំរាប់ការទទួលខុសត្រូវសង្គមនេះពុំមែនដើម្បី *ជំនួស* យន្តការធម្មតា ដែលរដ្ឋាភិបាលប្រើប្រាស់ដើម្បីកែលំអបញ្ហាអភិបាលកិច្ច (ពី"ផ្នែកផ្តល់សេវា") នោះទេ តែផ្ទុយទៅវិញវិធីសាស្ត្រទាំងនេះ គឺ*បំពេញបន្ថែម និងពង្រឹង* យន្តការទាំងឡាយរបស់រដ្ឋាភិបាល ។ បទពិសោធន៍ពីអន្តរជាតិបង្ហាញ ថាយន្តការនៃការទទួលខុសត្រូវសង្គមអាចមានប្រសិទ្ធិភាពក្នុងការកំណត់រកអោយឃើញ និងបង្ការអំពើពុករលួយនៅគ្រប់កំរិតថ្នាក់ក្នុងដ្ឋាភិបាល ។ នៅក្នុងន័យនេះយន្តការទាំងនោះគឺជាការបំពេញបន្ថែមដ៏មានឥទ្ធិពលដល់បណ្តាវិធីសាស្ត្រប្រឆាំងអំពើពុករលួយរបស់រដ្ឋាភិបាល ។

៥. **ធនាគារពិភពលោក និងម្ចាស់ជំនួយដទៃៗទៀតទទួលស្គាល់ពីសារៈសំខាន់នៃការបង្កើតនូវផ្នែក "*ទាមទារ" អោយមានអភិបាលកិច្ចល្អ*និងគាំទ្រយ៉ាងខ្លាំងនូវវិធីសាស្ត្រទាំងនេះក្នុងបំណងលើកកំពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវសង្គម ។** គោលបំណងសំខាន់មួយនៃយុទ្ធសាស្ត្រផ្តល់ជំនួយសំរាប់ប្រទេសកម្ពុជានាពេលបច្ចុប្បន្នរបស់ធនាគារពិភពលោក គឺ "គាំទ្រវិមជ្ឈការ និងការលើកកំពស់ភាពជាដៃគូរបស់ប្រជាពលរដ្ឋ ដើម្បីធ្វើអោយប្រសើរដល់អភិបាលកិច្ច "ជាពិសេសតាមរយៈការពង្រឹងនូវវិធីសាស្ត្រ "ទាមទារ" អោយមានអភិបាលកិច្ចល្អ [ដើម្បីបំពេញបន្ថែម] វិធីសាស្ត្រ "ផ្នែកផ្គត់ផ្គង់"ធម្មតា......ដើម្បីធ្វើអោយប្រាកដថាប្រជាពលរដ្ឋកម្ពុជាអាចធ្វើអោយរដ្ឋាភិបាល និងធនាគារពិភពលោកមានការទទួលខុសត្រូវចំពោះជំនួយដែលបានផ្តល់ និងជំរុញអោយរដ្ឋាភិបាលទទួលខុសត្រូវចំពោះប្រជាពលរដ្ឋរបស់ខ្លួនផងដែរ ពោលគឺពុំមែនទទួលខុសត្រូវតែចំពោះម្ចាស់ជំនួយពីខាងក្រៅប៉ុណ្ណោះទេ" ។ យុទ្ធសាស្ត្រផ្តល់ជំនួយសំរាប់ប្រទេស ក៏បានសង្កត់ធ្ងន់ផងដែរពីសារៈសំខាន់នៃការធ្វើអោយមាននូវ

---

[២] របាយការណ៍នេះប្រើប្រាស់នូវទស្សនាទាន និង វាក្យស័ព្ទមួយចំនួនទាក់ទងនឹង "ការទទួលខុសត្រូវសង្គម " និង "អភិបាលកិច្ចល្អផ្តើមចេញពីការទាមទារ " ដែលទាំងនេះមានលក្ខណៈថ្មីស្រឡាងនៅក្នុងបរិបទប្រទេសកម្ពុជា ហើយអ្នកអានប្រហែលជាពុំធ្លាប់ដឹងពីទស្សនាទាន និងវាក្យស័ព្ទទាំងនេះទេ ។ អាស្រ័យហេតុនេះ សទ្ទានុក្រមនៃវាក្យស័ព្ទគន្លឹះៗត្រូវបានជូនភ្ជាប់នៅផ្នែកខាងចុងនៃឯកសារនេះ ។

"បរិយាកាសអំណោយផលសំរាប់ភាពជាដៃគូរបស់ប្រជាពលរដ្ឋ" ក៏ដូចជាការចូលរួមពាក់ព័ន្ធប្រកបដោយលក្ខណៈស្ថាបនា សេរី និងសន្តិភាពរបស់រដ្ឋាភិបាល ម្ចាស់ជំនួយ និងសង្គមស៊ីវិល ។

## ១.ក.១. ទិដ្ឋភាពរួមនៃរបាយការណ៍

៦. **គោលបំណងនៃការសិក្សានេះ គឺដើម្បីស្វែងយល់ពីរូបភាព និងការអនុវត្តន៍នូវការទទួលខុសត្រូវសង្គមនាពេលបច្ចុប្បន្ននៅកម្ពុជា ដោយពិនិត្យរកមើលឱកាស វិភាគទៅលើឧបសគ្គនិងប្រភពរបស់វា ព្រមទាំងផ្តល់យោបល់អំពីដំណោះស្រាយ និងសកម្មភាពអាទិភាព ។** ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងនៅក្នុងបរិបទនៃកិច្ចខិតខំប្រឹងប្រែងទូលំទូលាយរបស់ធនាគារពិភពលោកក្នុងការគាំទ្រ និងលើកកំពស់ការទាមទាររបស់ប្រជាពលរដ្ឋអោយមានអភិបាលកិច្ចល្អនៅកម្ពុជា ដែលក្នុងនោះរួមទាំងកិច្ចខិតខំដើម្បី : ជំរុញអោយមានបរិយាកាសអំណោយផលសំរាប់ការទទួលខុសត្រូវសង្គម ជួយរដ្ឋាភិបាលអោយផ្តល់ការឆ្លើយតប និងទទួលខុសត្រូវចំពោះប្រជាពលរដ្ឋរបស់ខ្លួន ពង្រឹងសមត្ថភាពរបស់ប្រជាពលរដ្ឋ និងសង្គមស៊ីវិលអោយចូលរួមជាមួយអាជ្ញាធរសាធារណៈ និងបង្កើតឡើងនូវយន្តការសំរាប់ការចូលរួមប្រកបដោយលក្ខណៈស្ថាបនារបស់ប្រជាពលរដ្ឋ ។ **របកគំហើញ និងអនុសាសន៍ពីការសិក្សានេះ គឺសំរាប់ក្រុមគោលដៅធំៗបី : រាជរដ្ឋាភិបាលកម្ពុជា តួអង្គនានាក្នុងសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ (DPs) ។**

៧. **ការសិក្សានេះបានរកឃើញនូវបញ្ហាប្រឈម និងឱកាសល្អៗជាច្រើននៅក្នុងបរិបទកម្ពុជា ។** បើធៀបទៅនឹងប្រទេសប្រជាធិប-តេយ្យសេរីដទៃៗទៀត ប្រជាពលរដ្ឋកម្ពុជាមានឥទ្ធិពលតិចតួចណាស់ទៅលើដំណើរការសម្រេចចិត្តជាសាធារណៈ ហើយមានឱកាសតិចតួចក្នុងការទាមទារអោយមន្ត្រីសាធារណៈមានការទទួលខុសត្រូវ ។ កត្តាទាំងនេះមួយភាគធំ គឺដោយសារគោលការណ៍ និងស្ថាប័នប្រជាធិបតេយ្យនៅមានភាពថ្មីថ្មោងនៅឡើយនៅកម្ពុជា ហើយម្យ៉ាងទៀតគឺដោយសារស្លាកស្នាមនៃប្រវត្តិសាស្ត្រដ៏ឃោរឃៅកាលពីពេលថ្មីៗរបស់ប្រទេសនេះ ដែលបានធ្វើអោយបាត់បង់យ៉ាងធ្ងន់ធ្ងរនូវជំនឿទុកចិត្ត "ធនធានសង្គម" ។ បើទោះជាយ៉ាងនេះក្តី ការវិវត្តន៍យ៉ាងឆាប់រហ័សនៃស្ថាប័នប្រជាធិបតេយ្យ និងដំណើរការនៃកំណែទំរង់នយោបាយនាពេលបច្ចុប្បន្ន ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងបំលាស់ប្តូរសង្គម បានផ្តល់នូវឱកាសដ៏សំខាន់ក្នុងការជំរុញអោយមានការចូលរួមរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវសង្គមនៅកម្ពុជា ។

៨. បន្ទាប់ពីបង្ហាញជូននូវវិធីសាស្ត្រស្រាវជ្រាវ ផ្នែកទីមួយនៃរបាយការណ៍នេះនឹងរៀបរាប់អំពីទិដ្ឋភាពសំខាន់ៗមួយចំនួននៃបរិបទរបស់កម្ពុជាដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការទទួលខុសត្រូវសង្គម ហើយនិងពិពណ៌នាត្រួសៗពីអ្វីដែលប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលកំពុងធ្វើ ដើម្បីជួយដល់រាជរដ្ឋាភិបាលអោយកាន់តែមានប្រសិទ្ធិភាព និងមានការទទួលខុសត្រូវ ។ ផ្នែកទីពីរនៃរបាយការណ៍ រៀបរាប់ពីការកំណត់រក និងការវិភាគនូវកត្តាសំខាន់ៗដែលបង្កលក្ខណៈងាយស្រួល ឬរាំងស្ទះដល់ការទទួលខុសត្រូវសង្គមនៅកម្ពុជា ។ នៅក្នុងផ្នែកនេះដែរនឹងមានបង្ហាញជូននូវអនុសាសន៍ទាក់ទងនឹងអ្វីដែលត្រូវធ្វើ ដើម្បីអោយមានការទទួលខុសត្រូវ ។ ផ្នែកនេះត្រូវបានរៀបចំជុំវិញប្រធានបទបួនខាងក្រោម ដែលជាសមាសធាតុចំបងៗ ឬ "ដំណាក់កាលឬជំហាន"

ដើមីអោយមានការទទួលខុសត្រូវសង្គម[៣] : ការសិក្សានេះបានកំណត់រកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយនៅក្នុងផ្នែកនីមួយៗ និងបានដាក់ជាអនុសាសន៍ដើម្បីជំនះឧបសគ្គ និងប្រើប្រាស់ឱកាសដែលមានសំរាប់ផ្នែកនីមួយៗ ។

- *ព័ត៌មាន* - តើប្រជាពលរដ្ឋអាចទទួលបាន និងបង្កើតនូវព័ត៌មានអំពីបញ្ហានានាដែលពាក់ព័ន្ធនឹងការព្រួយបារម្ភរបស់សាធារណៈ ការសំរេចចិត្ត និងសកម្មភាពរបស់ រដ្ឋាភិបាល គោលនយោបាយសាធារណៈ ថវិកា ការចំណាយ និងកម្មវិធីនានាដែរឬទេ?
- *ការបញ្ចេញមតិ* — តើប្រជាពលរដ្ឋអាចសំដែងពីកង្វល់ និងបង្ហាញពីអាទិភាពរបស់ខ្លួនបានដែរឬទេ (ដោយមានការជ្រោមជ្រែងពីអង្គការសង្គមស៊ីវិល)?
- *ការរួបរួមជាសមាគម* - តើប្រជាពលរដ្ឋអាចបង្កើតជាសមាគម ហើយប្រើប្រាស់សមាគមនោះដើម្បីប្រមូលផ្តុំមតិ និងសំដែងចេញនូវមតិយោបល់ទាំងនោះបានដែរឬទេ?
- *ការចូលរួម និងការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា* - តើប្រជាពលរដ្ឋអាចផ្សារភ្ជាប់ទំនាក់ទំនង និងចូលរួមក្នុងដំណើរការសំរេចចិត្តជាសាធារណៈបានដែរឬទេ?

ជាចុងក្រោយ ផ្នែកទីបីនៃរបាយការណ៍នេះ គឺជាសេចក្តីសន្និដ្ឋាន និងការលើកឡើងនូវសកម្មភាពជាអាទិភាពមួយចំនួន សំរាប់ធ្វើសកម្មភាពក្នុងរយៈពេលខ្លី និងមធ្យមដោយក្រុមគោលដៅពាក់ព័ន្ធនីមួយៗ។

### ១.ក.២. វិធីសាស្ត្រស្រាវជ្រាវ

៩. **ការសិក្សាស្រាវជ្រាវនេះបានប្រើប្រាស់រួមគ្នានូវវិធីសាស្ត្រស្រាវជ្រាវបែបគុណភាពផងនិងបរិមាណផង សំរាប់ជាការបំពេញអោយគ្នាទៅវិញទៅមក** ។ ការសិក្សានេះគឺផ្អែកលើប្រភពចំណេះដឹងដែលមានស្រាប់ទាំងផ្នែកទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែង រួមជាមួយនឹងការចុះស្រាវជ្រាវផ្ទាល់ ។ ដើម្បីរក្សានូវគោលគំនិតដើមដែលសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ ការសិក្សាបានប្រើប្រាស់នូវវិធីសាស្ត្របែបចូលរួម ដែលក្នុងនោះក្រៅពីការប្រមូលព័ត៌មាន និងយោបល់ត្រលប់ពីប្រតិបត្តិករផ្សេងៗគ្នាជាច្រើននោះ ការសិក្សានៅបានផ្តល់ឱកាសដល់ប្រជាពលរដ្ឋសាមញ្ញ អ្នកដឹកនាំសហគមន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃៗទៀត បានបញ្ចេញទស្សនៈរបស់ពួកគេប្រាស្រ័យទាក់ទងជាមួយគ្នាទៅវិញទៅមក និងចូលរួមទៅក្នុងការឆ្លុះបញ្ចាំង និងការវិភាគរួមគ្នា ។

១០. ដំណើរការស្រាវជ្រាវបានចាប់ផ្តើមជាមួយនឹង **ការសិក្សាតាមឯកសារ** ដោយពិនិត្យមើលទៅលើឯកសារដែលត្រូវបានបោះពុម្ពផ្សាយ និងមិនទាន់បោះពុម្ព ទាំងក្នុង និងក្រៅប្រទេសកម្ពុជា ។ ក្រុមអ្នកស្រាវជ្រាវ ក្រោមកិច្ចសហការជាមួយបុគ្គលិកកម្មវិធីពង្រឹងសមត្ថភាពដើម្បីការទទួលខុសត្រូវសង្គមនៅកម្ពុជា (PECSA) ក៏បានធ្វើ **សំរង់បទពិសោធន៍ស្តីពីការងារទទួលខុសត្រូវ**

[៣] ការកំណត់នូវដំណាក់កាលទាំងនេះ គឺស្រង់ចេញពី Civic Engagement Analytical Framework ដែលជាឧបករណ៍វិភាគមួយ បង្កើតឡើងដោយ Participation and Civic Engagement Group របស់ធនាគារពិភពលោកដើម្បីវាយតំលៃពីលក្ខខ័ណ្ឌនៃការចូលរួមរបស់ប្រជាពលរដ្ឋ ។

**សង្គម**នៅកម្ពុជានាពេលបច្ចុប្បន្ន [៤] ។ អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ (CAS) បានប្រមូលព័ត៌មានបែបគុណភាពដ៏មានតំលៃពី **កិច្ចសំភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងការពិភាក្សាជាក្រុម** (Focus Group Discussion - FGDs) ដែលបានធ្វើឡើងនៅក្នុងខេត្តចំនួនបួន និងទីក្រុងភ្នំពេញ [៥] ។ ដើម្បីប្រមូលទិន្នន័យបែបបរិមាណក្រុមស្រាវជ្រាវ របស់ CAS ក៏បានធ្វើការអង្កេតចំនួនពីរគឺ **ការស្ទាបស្ទង់មតិសាធារណៈ** (ដែលបានប្រមូលចំលើយពីប្រជាពលរដ្ឋសាមញ្ញប្រមាណ៩០០ នាក់ដែលត្រូវបានជ្រើសរើសដោយចោះៗ ទៅលើបញ្ហាទាក់ទងនឹងការទទួលខុសត្រូវសង្គម និង**ការស្ទាបស្ទង់មតិក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាល** តាមការផ្ញើតារាងសំណួរទៅអង្គការដែលពាក់ព័ន្ធក្នុងសកម្មភាពអភិបាលកិច្ច (ប្រមូលបានការឆ្លើយតបពីបុគ្គលចំនួន១៥០នាក់ដែលតំណាងអោយអង្គការក្រៅរដ្ឋាភិបាលចំនួន១១៣) ។ ជាចុងក្រោយ ក្រុមស្រាវជ្រាវក៏បានធ្វើការសិក្សាតាម**ករណីសិក្សា**បែបស៊ីជំរៅចំនួន ៥ ករណីក្នុងបំណងស្វែងយល់អោយបានស៊ីជំរៅអំពីទឹកចិត្ត បទពិសោធន៍ជោគជ័យ និងបញ្ហាប្រឈមនៃគំនិតផ្តួចផ្តើមនានាផ្នែកទទួលខុសត្រូវសង្គម [៦] ។ អនុសាសន៍ និងការផ្តល់យោបល់ទៅលើសកម្មភាព ត្រូវបានស្នើឡើងរួមគ្នារវាងក្រុមការងារ CAS និងធនាគារពិភពលោក ដោយផ្អែកលើការវិភាគលើរបកគំហើញពីការស្រាវជ្រាវនេះ ក៏ដូចជាការផ្តល់យោបល់និងព័ត៌មានត្រលប់ពីអ្នកផ្តល់ព័ត៌មានសំខាន់ៗក្នុងការពិភាក្សាតាមក្រុម និងអ្នកចូលរួមនៅក្នុងសិក្ខាសាលារបស់ PECSA ព្រមទាំងសមាជិកនៃក្រុមប្រឹក្សាភិបាលការស្រាវជ្រាវនេះ។ សេចក្តីព្រាងបឋមនៃរបាយការណ៍ត្រូវបានត្រួតពិនិត្យកែលំអដោយសមាជិកក្រុមប្រឹក្សាភិបាលការស្រាវជ្រាវ និងអ្នកត្រួតពិនិត្យទាំងក្នុង និងក្រៅប្រទេស [៧] ។

## ១.២. ទិដ្ឋភាពសំខាន់ៗនៃបរិបទកម្ពុជា

១១. ស្ថានភាពនៃការចូលរួមរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវសង្គមនៅកម្ពុជា បានទទួលរងនូវឥទ្ធិពលពីកត្តាបរិបទសំខាន់ៗមួយចំនួន ។ ក្នុងនោះរួមមាន ឥទ្ធិពលនៃ**សង្គ្រាមនាពេលថ្មីៗ កត្តានយោបាយ កត្តាសង្គម-វប្បធម៌** ចរិតលក្ខណៈនិងប្រវត្តិនៃ**ទំនាក់ទំនងរវាងប្រជាពលរដ្ឋនិងរដ្ឋ** ក៏ដូចជាលក្ខណៈដោយឡែកនៃ**សង្គមស៊ីវិល**របស់កម្ពុជា និង**ទំនាក់ទំនងរវាងសង្គមស៊ីវិល និងរដ្ឋផងដែរ ។** បើទោះបីកត្តាទាំងនេះ ភាគច្រើនត្រូវបានសិក្សា និងរៀបរាប់នៅក្នុងឯកសារដែលមានស្រាប់ក្តី ក៏បច្ចុប្បន្ននេះ កត្តាទាំងនេះកំពុងបន្តប្រែប្រួលនៅកម្ពុជា (ជាផលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សមាហរណកម្មអន្តរជាតិ បំរែបំរួលផ្នែកប្រជាសាស្ត្រ រួមទាំងចំណាកស្រុកមកទីក្រុង និងការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយារបស់ប្រជាពលរដ្ឋវ័យក្មេង)។ ខាងក្រោមគឺជាទិដ្ឋភាពរួមដោយសង្ខេបនៃកត្តានីមួយៗទាក់ទងទៅនឹងប្រធានបទនៃការចូលរួមរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវសង្គម ។

### ១.២.១. ដំណាក់កាលក្រោយសង្គ្រាម

---

[៤] សំរង់បទពិសោធន៍នេះ ពុំមានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយទេ ប៉ុន្តែវាបានកំណត់ឃើញមានគំនិតផ្តួចផ្តើមជិត៩០ ។ បញ្ជីរាយពីគំនិតផ្តួចផ្តើមទាំងនោះអាចផ្តល់ជូនទៅតាមសំណូមពរ ។

[៥] ក្រុមអ្នកសិក្សាស្រាវជ្រាវ ក៏ទទួលបានទិន្នន័យផងដែរពីលទ្ធផល និងអនុសាសន៍ ពីបណ្តាសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ ដែលរៀបចំឡើង ដោយកម្មវិធី PECSA នៅក្នុងតំបន់ផ្សេងៗគ្នានៃប្រទេសកម្ពុជា ដែលធ្វើឡើងចន្លោះពីខែតុលា ដល់ ខែវិច្ឆិកា ២០០៧ ។

[៦] របកគំហើញមួយចំនួនពីការស្រាវជ្រាវ ត្រូវបានបង្ហាញជូននៅក្នុងរបាយការណ៍នេះ ។ បញ្ជីសំណួរ សេចក្តីណែនាំសំរាប់កិច្ចសំភាសន៍ និងទិន្នន័យពីការអង្កេតក៏អាចផ្តល់ជូនបានតាមសំណូមពរផងដែរ។

[៧] សមាជិកក្រុមប្រឹក្សាភិបាល និងអ្នកត្រួតពិនិត្យ មានរាយនាមនៅក្នុងសេចក្តីថ្លែងអំណរគុណ ។ បញ្ជីឈ្មោះអ្នកចូលរួមនៅក្នុងកិច្ចប្រជុំត្រួតពិនិត្យរបាយការណ៍អាចផ្តល់ជូនតាមសំណើ ។

១២. **សង្គមកម្ពុជានៅកំពុងផ្សះខ្លួនពីសង្គ្រាមស៊ីវិល និងសោកនាដ្ឋកម្មនៃអស្ថេរភាពសង្គមដែលបានអូសបន្លាយជិតបីទសវត្ស** ។ ក្រៅពីសោកនាដ្ឋកម្មនៃការបាត់បង់ជីវិតមនុស្សរាប់មិនអស់ សង្គ្រាមរ៉ាំរ៉ៃរាប់សិបឆ្នាំ របបប្រល័យពូជសាសន៍ និងការដឹកនាំផ្តាច់ការ បានបំផ្លិចបំផ្លាញសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងស្ថាប័ននយោបាយ និងសង្គមរបស់ប្រទេសនេះយ៉ាងធ្ងន់ធ្ងរ ។ បើទោះបីមានការរីកចំរើនគួរអោយកត់សំគាល់ចាប់តាំងពីមានកិច្ចព្រមព្រៀងសន្តិភាពនាដើមទសវត្សឆ្នាំ ១៩៩០ យ៉ាងណាក្តី ក៏កម្ពុជានៅតែប្រឈមនឹងភាពក្រីក្រក្នុងកំរិតមួយខ្ពស់ ហើយសូចនាករនៃការអភិវឌ្ឍន៍សង្គម និងធនធានមនុស្សនៅមានលក្ខណៈអន់ខ្សោយនៅឡើយ ។ បើនិយាយពីអ្វីដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវសង្គមវិញ សង្គ្រាមរ៉ាំរ៉ៃជាច្រើនឆ្នាំនោះបានធ្វើអោយបាត់បង់នូវជំនឿទុកចិត្ត និងសាមគ្គីភាពសង្គមយ៉ាងធ្ងន់ធ្ងរ ។ ប្រការនេះបានបង្កអោយប្រជាពលរដ្ឋបន្តខ្លាចរអារចំពោះអាជ្ញាធរ ព្រួយបារម្ភខ្លាចអំពើឃោរឃៅនោះវិលត្រលប់មកវិញ ហើយមានបំណងប្រាថ្នាយ៉ាងជ្រាលជ្រៅចង់អោយមានស្ថេរភាពនយោបាយ និងសង្គម ។ ដូចមានលើកឡើងនៅក្នុងផ្នែក ២.គ.១ រួចហើយ បរិបទប្រវត្តិសាស្ត្របែបនេះបាននាំអោយសកម្មភាពរួបរួមជាសមាគមមានមានការថយចុះយ៉ាងខ្លាំង ។ ក្នុងករណីមានការរួបរួមជាសមាគមបែបនោះ ក៏សមាគមទាំងនោះច្រើនតែមានលក្ខណៈបែបប្រពៃណី និងរបស់មូលដ្ឋាន (ជាទូទៅពាក់ព័ន្ធនឹងវត្តអារាមក្នុងមូលដ្ឋាន) មានទ្រង់ទ្រាយតូចៗ (ជាធម្មតាមានតែអ្នករាប់អានគ្នាជិតស្និទជាសមាជិក) ហើយច្រើននៅឯកោ ដោយពុំសូវមានទំនាក់ទំនងជាមួយគេឯងឡើយ (មានទំនាក់ទំនងជាមួយសមាគមប្រហាក់ប្រហែលគ្នាតិចតួច) ។

### ១.ខ.២. កត្តានយោបាយ

១៣. **លទ្ធិប្រជាធិបតេយ្យពហុបក្សបានលេចជារូបរាងឡើងហើយមែន ប៉ុន្តែនៅមានលក្ខណៈក្មេងខ្ចីនិងដោយអន្ទើនៅឡើយ** ។ ស្ថាប័នបែបប្រជាធិបតេយ្យទើបតែចាប់កកើតមានឡើង ហើយនៅពុំទាន់មានដំណើរការ និងប្រសិទ្ធិភាពពេញលេញនៅឡើយទេ ។ បើទោះបីជាអំណាចនីតិប្រតិបត្តិ ជាគោលការណ៍ត្រូវបានត្រួតពិនិត្យដោយស្ថាប័ននីតិបញ្ញត្តិ និងតុលាការក្តី ក៏ជាក់ស្តែង ស្ថាប័នទាំងនេះពុំមានសមត្ថភាពបំពេញនូវអាណត្តិរបស់ខ្លួនអោយមានប្រសិទ្ធិភាពឡើយនាពេលបច្ចុប្បន្ននេះ ។ ក្នុងការអនុវត្តន៏ជាក់ស្តែង ស្ថាប័ននីតិប្រតិបត្តិច្រើនតែមានភាពលប់លើអំណាចដទៃទៀតក្នុងរដ្ឋាភិបាល ។ គណៈបក្សនយោបាយមួយ គឺគណៈបក្សប្រជាជនកម្ពុជា បាននិងកំពុងបន្តភាពលប់លើរបស់ខ្លួន ហើយមានផ្នត់គំនិតយ៉ាងមុតមាំក្នុងការចាត់ទុករដ្ឋាភិបាល ថាជាឧបករណ៍សំរាប់អនុវត្តគោលនយោបាយរបស់គណៈបក្ស ។ គណៈបក្សនយោបាយពុំទាន់បានធ្វើសមាហរន្តកម្មគោលការណ៍លទ្ធិប្រជាធិបតេយ្យនៃការសម្រេចចិត្តតាមបែបចូលរួម និងការទទួលខុសត្រូវចំពោះថ្នាក់ក្រោម ទៅក្នុងអភិបាលកិច្ចផ្ទៃក្នុងរបស់ខ្លួនអោយបានពេញលេញនៅឡើយទេ (Un, 2004) ។ គោលការណ៍ និងគុណតំលៃនៃលទ្ធិប្រជាធិបតេយ្យកំពុងកើតមានកើតឡើង ហើយទស្សនាទានដូចជាការចែករំលែកអំណាច ពលរដ្ឋនិយម ការសំរេចចិត្តតាមបែបចូលរួម និងការទទួលខុសត្រូវចំពោះថ្នាក់ក្រោមគឺនៅមានលក្ខណៈថ្មីថ្មោងនៅឡើយ ហើយពុំទាន់ត្រូវបានអនុវត្តពេញលេញនៅឡើយទេ ។ សិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ដូចជាការទទួលបានព័ត៌មាន សេរីភាពនៃការបញ្ចេញមតិ និងការចូលរួមដោយចំហ ត្រូវបានទទួលស្គាល់ ប៉ុន្តែពុំទាន់ត្រូវបានអនុវត្ត ឬធានាអោយបានពេញលេញនោះទេ ។

១៤. កម្ពុជាមានប្រវត្តិជាសង្គមបិតុនិយមតាំងពីយូរលង់ណាស់មកហើយ ពោលគឺជាសង្គមដែលគ្រប់គ្រងដោយអ្នកដឹកនាំផ្តាច់ការ និងក្តោបក្តាប់អំណាចទាំងស្រុង (Chandler 1991:3-4) ។ បើទោះបីជារចនាសម្ព័ន្ធនយោបាយកំពុងតែមានការផ្លាស់ប្តូរគួរអោយ

កត់សំគាល់ក្តី ក៏រដ្ឋបាលរបស់កម្ពុជានៅតែបន្តទទួលរងឥទ្ធិពលពីការគ្រប់គ្រងតាមបែបប្រពៃណី និងបែបទំនាក់ទំនងចៅហ្វាយនាយ-កូនចៅនៅឡើយ[៨] ។ ក្នុងខណៈដែលមានកិច្ចខិតខំប្រឹងប្រែងជាប្រចាំ ដើម្បីដោះស្រាយបញ្ហាយ៉ាងណាក្តី អំពើពុករលួយនៅតែជាការពិតមួយដែលកំពុងរីករាលដាលយ៉ាងពាសពេញ ហើយជាឧបសគ្គដ៏ធំបងចំពោះការអភិវឌ្ឍន៍ ។ ការលំបាករបស់រដ្ឋាភិ-បាលក្នុងការលើកកំពស់ប្រសិទ្ធិភាពអភិបាលកិច្ច ការអនុវត្តន៏ច្បាប់ និងក្នុងការកែលំអការផ្តល់សេវាសាធារណៈ គឺមួយផ្នែកធំដោយសារការ ជ្រៀតចូលនៃរចនាសម្ព័ន្ធអំណាចក្រៅផ្លូវការបែបបិតុនិយម ទៅក្នុងស្ថាប័នការិយាធិបតេយ្យផ្លូវការ ។ នៅកម្ពុជាក្នុងឆ្នាំថ្មី១កន្លងទៅនេះ អំណាចរបស់ចៅហ្វាយរួមជាមួយនឹងបណ្តាញកូនចៅរបស់គេ បានបន្សុីចូលគ្នាជាមួយនឹងរចនាសម្ព័ន្ធផ្លូវការរបស់រដ្ឋាភិបាល ហើយបង្កើតបាននូវអ្វីម្យ៉ាងដែលហៅថា ប្រព័ន្ធអភិបាលកិច្ច *បិតុនិយមបែបទំនើប* ។ នៅក្នុងប្រព័ន្ធបែបនេះ ចំណូលសាធារណៈ (ដូចជា ចំណូលពីវិនិយោគក្រៅប្រទេស ធនធានធម្មជាតិ និងជំនួយអភិវឌ្ឍន៍ ជាដើម) ត្រូវបានអ្នកត្រួតត្រាមានអំណាច "ក្តោបក្តាប់យក" និងត្រួតត្រាជាលក្ខណៈសម្បតិផ្ទាល់ខ្លួន ។ (CDRI, 2007:3; Hughes, 2003:15,39-43) ។ ចៅហ្វាយជាតិទាំងនេះរក្សាមុខតំណែងនិងឥទ្ធិពលរបស់ខ្លួនដោយការបូករួមបញ្ចូលគ្នានូវអំណាចនយោបាយ កងទ័ព សេដ្ឋកិច្ច និងរដ្ឋបាល តាមរយៈ "ការប្រទាក់ក្រឡាគ្នានៃបណ្តាញចៅហ្វាយនាយ និងកូនចៅទៅតាមទ្រង់ទ្រាយសាជីជ្រុង" (CDRI, 2007: 58; Heder,1995; Un, 2004) ។ កាតព្វកិច្ចដែលផ្អែកលើមិត្តភាព ញាតិសន្តាន និងទំនុកចិត្តគ្នាបែបនេះ ធ្វើអោយមន្ត្រីសាធារណៈមាន "ការទទួលខុសត្រូវ" ក្រៅផ្លូវការចំពោះតួអង្គជាច្រើន រួមមានគណៈបក្សនយោបាយ អ្នកជំនួញដែលមានឥទ្ធិពល គ្រួសារ និងមិត្តភក្តិ ។ នៅក្នុងករណីជាច្រើន ការទទួលខុសត្រូវ "ក្រៅផ្លូវការ" រវាងចៅហ្វាយនាយ និងសាច់ញាតិ មិត្តភាព ឬបណ្តាញក្នុងនយោបាយបែបនេះ មានអំណាចខ្លាំងជាងនៅក្នុងប្រព័ន្ធនៃរចនាសម្ព័ន្ធផ្លូវការ និងក្នុងវិធានការិយាធិបតេយ្យទៅទៀត ។ នៅក្នុងស្ថានភាពបែបនេះ ទឹកចិត្តដើម្បីអោយមានតម្លាភាព និងការឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋត្រូវថយចុះ ហើយសកម្មភាពណាដែលមានសក្តានុពលតិចតួច ត្រូវបានបំភ្លេចចោល រីឯតួនាទីអភិវឌ្ឍន៍របស់រដ្ឋាភិបាលត្រូវទទួលការប៉ះទង្គិច (CDRI, 2007) ។

១៥. **អំណាចច្រើនតែត្រូវបានប្រមូលផ្តុំនៅថ្នាក់កណ្តាល បែងចែកតាមឋានានុក្រមយ៉ាងម៉ឺងម៉ាត់ និងកាន់កាប់ជាលក្ខណៈបុគ្គលជាជាងជាលក្ខណៈស្ថាប័ន ។** អំណាច និងឥទ្ធិពលក្នុងការធ្វើសេចក្តីសំរេចចិត្តភាគច្រើននៅតែបន្តកំណត់ដោយឋានៈសង្គម និងទំនាក់ទំនងផ្ទាល់ខ្លួន ជាជាងកំណត់ដោយតួនាទី និងករណីយកិច្ចជាលក្ខណៈស្ថាប័ន ដែលប្រការនេះធ្វើអោយប្រព័ន្ធនៃការទទួលខុសត្រូវធម្មតា (ផ្នែកនយោបាយ ច្បាប់ ការិយាធិបតេយ្យ និងរដ្ឋបាល) គ្មានប្រសិទ្ធិភាព ហើយធ្វើអោយប្រជាពលរដ្ឋមានការលំបាកក្នុងការពឹងផ្អែកទៅលើយន្តការផ្លូវការដែលត្រូវបានបង្កើតឡើង សំរាប់ការចូលរួមជាមួយអាជ្ញាធរសាធារណៈ[៩] ។ នៅកម្ពុជា ជាលក្ខណៈប្រពៃណី អំណាចត្រូវបានកាន់កាប់តាមរូបភាព *មានទាំងអស់ទល់នឹងគ្មានទាំងអស់* មានន័យថាបើភាគីមួយមានអំណាច គឺមានទាំងអស់ខណៈដែលភាគីម្ខាងទៀតគ្មានអំណាចអ្វីទាំងអស់ ។ នៅកម្ពុជាពុំសូវមានប្រពៃណីនៃការចែករំលែក

---

[៨] កើតមានជាទូទៅនៅក្នុងសង្គមបិតុនិយម, ប្រព័ន្ធនៃការគ្រប់គ្រងបែបចៅហ្វាយនាយ-កូនចៅ ត្រូវបានបង្កើតឡើងតាមរយៈទំនាក់ទំនង និងកាតព្វកិច្ចរបស់បុគ្គល ។ នៅពេលដែលបុគ្គលណាម្នាក់ធ្វើល្អអ្វីមួយចំពោះបុគ្គលម្នាក់ទៀត បុគ្គលទី២ជំពាក់ "បំណុលកាតព្វកិច្ច" ទៅបុគ្គលទី១ (CDRI, 2007:41) ។ កាតព្វកិច្ចចំបងបំផុតរបស់កូនចៅ គឺត្រូវធ្វើអោយចៅហ្វាយនាយ នោះបន្តមានទ្រព្យធន និងអំណាច ដើម្បីអោយគាត់អាចរក្សាអាជ្ញាធររបស់ខ្លួនបាន ហើយចៅហ្វាយនាយនោះក៏អាចបន្តធ្វើល្អ ចំពោះបុគ្គលដែលនៅក្រោមអំណាចរបស់ខ្លួនផងដែរ (ibid. យោងតាម Weber 1978).

[៩] យោងតាម CDRI បុគ្គលក្នុងជួររដ្ឋាភិបាលពុំចាំបាច់ត្រូវមានតួនាទីជាអាជ្ញាធរផ្លូវការ ដើម្បីទទួលបានអំណាចធ្វើសេចក្តីសំរេចចិត្តឡើយ ហើយជាឧទាហរណ៍ វាមិនមែនជារឿងចំឡែកឡើយក្នុងការដែលរដ្ឋលេខាធិការមានអំណាចច្រើនជាងរដ្ឋមន្ត្រីនោះ (CDRI, 2007:54,59)

អំណាចក្នុងចំណោមក្រុមនានាក្នុងសង្គមដោយផ្អែកលើមូលដ្ឋានលទ្ធិប្រជាធិបតេយ្យឡើយ[១០] ។ ដូចនៅក្នុងប្រទេសជាច្រើនដែរ គឺមានប្រពៃណីដ៏ច្បាស់លាស់ដែលថា អ្នកដែលពុំសូវមានអំណាច (អ្នកដែលស្ថិតនៅក្រោមការគ្រប់គ្រង) "មិនអាចធ្វើអ្វីបានទាំងអស់ដើម្បីការពារខ្លួន" ដែលហេតុដូច្នេះហើយពួកគេត្រូវទទួលខុសត្រូវចំពោះអ្នកដែលមានអំណាច (អ្នកគ្រប់គ្រង) ។ ទ្រឹស្តីដែលថា អ្នកកាន់អំណាចនយោបាយត្រូវទទួលខុសត្រូវចំពោះអ្នកដែលពុំសូវមានអំណាច គឺពុំសូវមានគេដឹងប៉ុន្មានឡើយ ហើយវាផ្ទុយទៅនឹងផ្នត់គំនិតជាលក្ខណៈប្រពៃណីអំពីទំនាក់ទំនងផ្នែកនយោបាយ និងសង្គមនៅកម្ពុជា ។ គោលការណ៍គ្រឹះនៃប្រជាធិប-តេយ្យដែលចាត់ទុកអ្នកកាន់អំណាចថាជា "អ្នកបំពេញភារកិច្ច" ដែលមានកាតព្វកិច្ចបំរើប្រយោជន៏សាធារណៈ និងទទួលខុសត្រូវចំពោះប្រជាពលរដ្ឋសាមញ្ញនោះ គឺជារឿងមួយមិនងាយទៅរួចឡើយ ។ នៅក្នុងបរិបទប្រទេសកម្ពុជា ហើយក៏ដូចជានៅក្នុងបណ្តាប្រទេសជាច្រើនទៀតដែរ វាតំរូវអោយតួអង្គនានាក្នុងរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋមានការកែប្រែយ៉ាងម៉ឺងម៉ាត់នូវឥរិយាបថ និងអាកប្បកិរិយាដូចដែលកំពុងមានក្នុងពេលបច្ចុប្បន្ននេះ ។ ស្ថានភាពដូចសព្វថ្ងៃនឹងមានសភាពកាន់តែធ្ងន់ធ្ងរថែមទៀត បើមានអតុល្យភាពអំណាចខ្លាំងរវាងផ្នែករដ្ឋាភិបាល (ដែលមានអំណាចខ្លាំង) និងវិស័យឯកជននិងសង្គមស៊ីវិល (ដែលពុំសូវមានអំណាច) ។ ជារួមទៅ វិធីដែលល្អបំផុតសំរាប់លើកកំពស់ការទទួលខុសត្រូវសង្គមនៅកម្ពុជា គឺធ្វើយ៉ាងណាអោយសង្គមស៊ីវិល និងវិស័យឯកជនមានការរីកធំធាត់ និងរឹងប៉ឹងជាបន្តបន្ទាប់ប្រៀបទៅនឹងរដ្ឋាភិបាល ។

១៦. **ដំណើរការកំណែទំរង់នយោបាយ និងវិមជ្ឈការនាពេលបច្ចុប្បន្នបានផ្តល់នូវឱកាសល្អៗ ដើម្បីជំរុញអោយមានការចូលរួមរបស់ប្រជាពលរដ្ឋ និងមានការទទួលខុសត្រូវសង្គមបានល្អប្រសើរ ។** ការបង្កើតក្រុមប្រឹក្សាឃុំ-សង្កាត់នៅក្នុងឆ្នាំ ២០០២ បានផ្តល់នូវសក្តានុពលធំធេងសំរាប់បង្ខិតរដ្ឋាភិបាលអោយបាន "ជិតជាមួយនឹងប្រជាពលរដ្ឋ" និងបង្កើតការប្រាស្រ័យទាក់ទងជាផ្លូវការរវាងប្រជាពលរដ្ឋ និងស្ថាប័នរដ្ឋ ។ វិមជ្ឈការក៏បានផ្តល់នូវលទ្ធភាពសំខាន់ៗសំរាប់បង្កើនទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល និងអាជ្ញាធរដែនដី តាមរយៈការចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ការរួមចំណែកក្នុងការពិភាក្សាអំពីការអភិវឌ្ឍន៏មូលដ្ឋាន ឬបញ្ហាជាក់លាក់ដែលឃុំ-ភូមិប្រឈមមុខ ព្រមទាំងការចូលរួមនៅក្នុងដំណើរការសំរេចចិត្ត ។ ការស្រាវជ្រាវនេះកត់សំគាល់ឃើញថា ក្រុមប្រឹក្សាឃុំ-សង្កាត់ កំពុងចាប់ផ្តើមផ្លាស់ប្តូរផ្នត់គំនិត និងភាសា ជុំវិញទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋា-ភិបាលនោះហើយ (Ojendal/Kim, 2007) ។ ការចុះសិក្សានៅតាមមូលដ្ឋានបានរកឃើញថា កន្លងមកប្រជាពលរដ្ឋបានចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងកំរិតមួយគួរអោយចាប់អារម្មណ៏ ប៉ុន្តែភាគច្រើនការចូលរួមរបស់ពួកគេមានលក្ខណៈអកម្មដោយពួកគេគ្រាន់តែចូលរួមស្តាប់ប៉ុណ្ណោះ ។ ក្រៅពីនេះការសិក្សានេះក៏បានរកឃើញផងដែរ នូវការចាប់អារម្មណ៏ និងឆន្ទះរបស់អង្គការសង្គមស៊ីវិលក្នុងការកសាងទំនាក់ទំនង និងធ្វើអន្តរកម្មជាមួយអាជ្ញាធរ ។ ហេតុដូច្នេះ ការបន្តគាំទ្រដល់ដំណើរការវិមជ្ឈ-ការដែលកំពុងដំណើរការនេះ និងការពង្រឹងរចនាសម្ព័ន្ធរដ្ឋាភិបាលថ្នាក់មូលដ្ឋាន គឺជាយុទ្ធសាស្រ្តមួយដ៏សមស្របសំរាប់លើកកំពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវសង្គម ។ តែទោះជាយ៉ាងណាក្តី បញ្ហាប្រឈមចំបងៗ គឺរួមមានការអភិវឌ្ឍន៏សមត្ថភាព និងជំនាញរបស់មេឃុំ-ចៅសង្កាត់ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយនិងការលើកកំពស់អាជ្ញាធរ និងធនធាននៃរចនាសម្ព័ន្ធរដ្ឋាភិបាលថ្នាក់មូលដ្ឋាននៅពេលអនាគត ។ បើគិតតាមទស្សនាទាននៃការទទួលខុសត្រូវសង្គម អាទិភាពជាក់លាក់ដែលត្រូវធ្វើ គឺការបង្កើតឡើងនូវយន្តការ និងជំនាញក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ដែលមានលក្ខណៈអំណោយផលសំរាប់ការចូលរួម រួចហើយធ្វើការ (តាមរយៈការបណ្តុះបណ្តាល កំណែទំរង់ស្ថាប័ន និងគ្រឿងលើកទឹកចិត្ត) បង្វែរស្ថានភាពដូចសព្វថ្ងៃ ព្រោះថា

[១០] យោងតាមសុភាសិតបុរាណ "ភ្នំមួយមិនអាចមានខ្លាពីរ" ។

បច្ចុប្បន្ននេះអាជ្ញាធរដែនដីបែរទៅជាទទួលខុសត្រូវចំពោះ "ថ្នាក់លើ" ដូចជាប្រធានគណៈបក្សនិងអាជ្ញាធររដ្ឋាភិបាលកណ្តាលជាដើម ជាជាងទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ "ថ្នាក់ក្រោម" ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនទៅវិញ (CDRI, 2007:59) ។

### ១.ខ.៣. កត្តាវប្បធម៌-សង្គម

១៧. បញ្ហាកង្វះជំនឿទុកចិត្ត និងធនធានសង្គម ដោយសារវិបត្តិសង្រ្គាមកាលពីពេលថ្មីៗនៅកម្ពុជានោះ ត្រូវបានលើកយកមកពិភាក្សារួចហើយ ។ ឯកត្តាខ្លះទៀតដែលមានតាំងពីយូរណាស់មកហើយៗដែលពាក់ព័ន្ធទៅនឹងមរតកនៃសង្គម វប្បធម៌ និងសាសនារបស់កម្ពុជានោះ ក៏មានឥទ្ធិពលទៅលើឥរិយាបថ និងអាកប្បកិរិយានៃការទទួលខុសត្រូវសង្គមផងដែរ ។ **ទស្សនៈ និងក្រមសីលធម៌នៃព្រះពុទ្ធសាសនា មានឥទ្ធិពលចំរុះទៅលើគោលគំនិតនៃអភិបាលកិច្ចល្អ ការទទួលខុសត្រូវ និងយុត្តិធម៌សង្គម ។** ព្រះពុទ្ធសាសនាបង្រៀនថា អ្នកដឹកនាំត្រូវតែប្រព្រឹត្តប្រកបដោយក្រមសីលធម៌ល្អ (ដើម្បីទទួលបាននូវគុណសម្បត្តិផ្នែកសាសនា) និងគោរពក្រមប្រពៃណីនៃចរិយាអោយប្រកបដោយគុណធម៌ ។ ហេតុដូច្នេះហើយ ព្រះពុទ្ធសាសនាបានដាក់សំពាធផ្នែកគុណធម៌យ៉ាងធ្ងន់ទៅលើអ្នកដឹកនាំនយោបាយនិងសង្គម ដើម្បីអោយគេប្រតិបត្តិដោយការទទួលខុសត្រូវ និងមេត្តាធម៌ ។ ផ្ទុយទៅវិញ សង្គមកម្ពុជាមានកិរិតវិសមភាពខ្ពស់ និងមានឋានានុក្រមសង្គមដ៏តឹងរ៉ឹង ។ ទិដ្ឋភាពខ្លះនៃវប្បធម៌បែបព្រះពុទ្ធសាសនា ច្រើនតែលើកទឹកចិត្តអោយផ្តល់ការគោរពប្រតិបត្តិចំពោះអាជ្ញាធរ និងទទួលយកនូវឋានៈរបស់អ្នកដឹកនាំនៅក្នុងឋានានុក្រមនេះ[១១] ។ ជំនឿលើកម្មផល និងព្រេងវាសនា ក៏មានឥទ្ធិពលទៅលើផ្នត់គំនិតខ្មែរអំពីការទទួលខុសត្រូវសង្គម និងយុត្តិធម៌ផងដែរ ។ អ្នកសង្កេតការណ៍ខ្លះបានផ្តល់ចំណាប់អារម្មណ៍ថា ព្រះពុទ្ធសាសនានៅកម្ពុជាបានចាត់ទុកសេចក្តីសុខសន្តិភាព ភាពសុខដុមរម្យនា និងការស្រុះស្រួលគ្នាជារឿងសំខាន់បំផុត ប៉ុន្តែតាមរបៀបមួយដែលពុំចាំបាច់ទាមទារអោយមានការទទួលខុសត្រូវ ឬការចងកម្មពៀរនោះទេ (Marks, 1999:716-717) ។ តែទោះជាដូច្នេះក្តី ស្របពេលជាមួយគ្នានេះស្ថាប័នព្រះពុទ្ធសាសនា និងការអនុវត្តន៍ជាក់ស្តែងកំពុងមានការវិវត្តន៍ទៅមុខ ហើយអង្គការផ្នែកសាសនាជាច្រើន (ដូចជាអង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ មូលបែតង និងសន្តិសេនា ជាដើម) បានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រតិបត្តិនូវគុណតំលៃស្នូលនៃព្រះពុទ្ធសាសនា ដើម្បីដោះស្រាយបញ្ហាសំខាន់ៗនាពេលបច្ចុប្បន្ន ដូចជាការអភិវឌ្ឍន៍សេដ្ឋកិច្ច យុត្តិធម៌សង្គម និង ការការពារបរិយាកាស ។

១៨. យោងតាមឋានៈសង្គមក្នុងឋានានុក្រមជាលក្ខណៈប្រពៃណី ស្ត្រីត្រូវបានចាត់ទុកថាមានឋានៈទាបជាងបុរស ។ **ទំនាក់ទំនងយេនឌ័ររវាងបុរស និងស្ត្រីដែលមិនសមភាពគ្នានេះគឺជាឧបសគ្គមួយដ៏ចំបង ។** កត្តានេះបានធ្វើអោយប៉ះពាល់ដល់សុខុមាលភាពស្ត្រីនិងកំហិតការអភិវឌ្ឍន៍ប្រទេសជាតិ ។ ស្ត្រីនៅកម្ពុជាមានសភាពក្រីក្រ និងពុំសូវបានទទួលការអប់រំទេ បើប្រៀបទៅនឹងបុរស (UNIFEM et. al., 2004) ។ អំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ រួមទាំងអំពើហិង្សាក្នុងគ្រួសារ រំលោភផ្លូវភេទ អំពើហិង្សាទៅលើអ្នករកស៊ីផ្លូវភេទនិងការជួញដូរមនុស្សគឺជាការបារម្ភដ៏ធំមួយ ។ ទាក់ទងទៅនឹងបញ្ហាអភិបាលកិច្ច វិធានការណ៍ពង្រឹងអំណាចផ្នែកយេនឌ័រនៅកម្ពុជា គឺស្ថិតក្នុងចំណោមអត្រាដែលទាបបំផុតក្នុងតំបន់អាស៊ី ដែលកត្តានេះឆ្លុះបញ្ចាំងអំពីការមានភាពជា

---

[១១] ជំនឿដ៏មុតមាំមួយទៅលើព្រះពុទ្ធសាសនាអំពីកម្មផល និងព្រេងវាសនា (ដូចជា ផ្នត់គំនិតដែលប្រជាពលរដ្ឋគ្រប់រូបមានជាលក្ខណៈធម្មជាតិ ហើយដែលពុំអាចផ្លាស់ប្តូរព្រេងវាសនាបាន ) នាំអោយមានការអភិរក្សនូវឋានៈសង្គមសព្វថ្ងៃ ដោយការគិតថាថា ការផ្លាស់ប្តូរសង្គមប្រហែលជាមិនអាចកើតឡើង ឬមិនអាចធ្វើទៅបានទេ (Chandler, 1991:4) ។ ផ្អែកលើជំនឿទៅលើព្រេងវាសនា ប្រជាពលរដ្ឋក្រីក្រច្រើនតែទទួលយកនូវវណ្ណៈតូចទាបរបស់ខ្លួនថាជាអ្វីដែលព្រហ្មលិខិតបានកំណត់មក ហើយរំពឹងថាអ្នកដែលមានវណ្ណៈខ្ពង់ខ្ពស់ ចែករំលែកនូវទ្រព្យសម្បត្តិអោយខ្លួន ដើម្បីទទួលបាននូវបុណ្យកុសល ។ (CDRI, 2007:54; Legerwood/Vijghen, 2002:144)

តំណាងអោយស្ត្រីទាបនៅក្នុងជួររដ្ឋាភិបាល និងសភាជាតិ ។ តែទោះជាយ៉ាងណាក្តី ទំនាក់ទំនងផ្នែកយេនឌ័រនៅកម្ពុជាកំពុងការប្រែប្រួលយ៉ាងខ្លាំង ។ ការបោះឆ្នោតកាលពីពេលថ្មីៗនេះ ឃើញមានការកើនឡើងគួរអោយកត់សំគាល់នូវចំនួនបេក្ខភាពជាស្ត្រី និងអ្នកតំណាងរាស្ត្រដែលបានជាប់ឆ្នោត ជាពិសេសនៅថ្នាក់មូលដ្ឋាន ។ បើទោះបីបទដ្ឋានដែលកំណត់ពីអាកប្បកិរិយាស្ត្រីដែលហៅថា *ច្បាប់* នៅតែបន្តរាំងដល់ឱកាសរបស់ស្ត្រីក្នុងការចេញទៅធ្វើការក្រៅផ្ទះក្តី ក៏ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងនយោបាយកំពុងតែបើកចំហនូវលទ្ធភាពថ្មីៗសំរាប់ពួកគេ ។ ដូចដែលនឹងមានពិភាក្សានៅក្នុងផ្នែកបន្តបន្ទាប់ក្នុងរបាយការណ៍នេះត្រូវមានការពិចារណាទៅលើផលប្រយោជន៍ និងសេចក្តីត្រូវការដោយឡែករបស់ស្ត្រី ដើម្បីឈានទៅសំរេចអោយបាននូវការចូលរួមរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវសង្គមនៅកម្ពុជា ។

១៩. **ការជៀសវាងទំនាស់និងវប្បធម៌នៃ "ការយល់មុខ" ជាកត្តាពង្រឹងនូវឋានានុក្រមសង្គម និងរក្សានូវស្ថានភាពអោយនៅដូចដើម ។** វប្បធម៌ និងប្រពៃណីរបស់កម្ពុជាផ្តល់ភាពសំខាន់ទៅលើការប្រព្រឹត្តសមរម្យ និងថ្លៃថ្នូរ ព្រមទាំងការជៀសវាងនូវទំនាស់ ឬការធ្វើអោយប៉ះពាល់ដល់អ្នកដទៃ ។ បទដ្ឋានសង្គមដ៏មានឥទ្ធិពល គឺផ្តោតលើ "ការរក្សានូវតុល្យភាព" (Luco, 2003: 26) ។ សារៈតានៃវប្បធម៌បែបនេះ គួបផ្សំជាមួយនឹងស្នាមរបួសដោយសារសង្គ្រាមផងនោះ បានចង្អុលបង្ហាញថា ប្រជាពលរដ្ឋកម្ពុជាភាគច្រើនអោយតំលៃយ៉ាងខ្ពស់ទៅលើការរក្សានូវសេចក្តីសុខសន្តិភាព និងភាពសុខដុមរម្យនា ព្រមទាំងការជៀសវាងនូវការទាស់ទែង ជាពិសេសជាមួយអ្នកដែលគេចាត់ទុកថាមានអំណាច (CDRI, 2007:55) ។ មានទំនោរដ៏មុតមាំមួយ ក្នុងការរក្សាទំនាក់ទំនងក្នុងសង្គមកុំអោយជំពាក់ជំពិន ឬជាប់កាតព្វកិច្ចអ្វីមួយ និងក្នុងសភាពស្ងប់ស្ងាត់ ហើយមានទំនោរក្នុងការដកខ្លួនចេញ ជាជាងការចេញមកប្រឈមមុខ បើមានទំនាស់កើតឡើង ។ បទដ្ឋានសង្គមបែបនេះមានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងភាពសំខាន់នៃការការពារមុខមាត់ ទាំងសំរាប់ខ្លួនឯង និងអ្នកដទៃ ។ ទំលាប់នៃការការពារមុខមាត់នេះ ក៏ជាចរិតលក្ខណៈមួយដ៏សំខាន់នៃនយោបាយផងដែរ ហើយប្រសិនបើយើងមិនគោរព (ឬមិនអើពើនឹងវាដោយចេតនា) អាចនាំអោយមានផលលំបាកធ្ងន់ធ្ងរដែលក្នុងនោះអាចជាការប៉ះពាល់ដល់ទំនាក់ទំនងផ្ទាល់ខ្លួននិងបណ្តាលអោយមានការបែកបាក់ជាអចិន្ត្រៃយ៍នូវសម្ព័ន្ធភាពនយោបាយ និង/ឬទំនាក់ទំនងបែបចៅហ្វាយនាយ-កូនចៅទៀតផង ។ ចរិតលក្ខណៈវប្បធម៌សង្គមបែបនេះ អាចបកស្រាយបានថាវាជាហេតុផលមួយផ្នែកដែលធ្វើអោយសង្គមស៊ីវិល និងការតស៊ូមតិមិនសូវមានប្រសិទ្ធិភាព ប្រសិនបើការតស៊ូមតិនោះមានរូបភាពជាការវាយប្រហារដោយចំហ ឬជាការប្រកាន់យកនូវជំហរតឃ្លើនពេកចំពោះរដ្ឋាភិបាល ។ ដូចមានពិភាក្សានៅក្នុងចំណុច ២.ឃ ហើយវិធីសាស្ត្របែបនេះ ជួនកាលទទួលបានជោគជ័យ និងនាំអោយមានការផ្លាស់ប្តូរជាវិជ្ជមាន ប៉ុន្តែជាញឹកញាប់ វិធីសាស្ត្របែបនោះមិនអាចទាក់ទាញ ឬទ្រទ្រង់ការគាំទ្រ (ពីប្រជាពលរដ្ឋដែលមានការគោរព និងប្រឆាំងទៅនឹងទំនាស់) បានឡើយ ហើយច្រើនតែនាំអោយមានការជំទាស់កាន់តែខ្លាំងឡើង ជាជាងធ្វើអោយមានកិច្ចសហការរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ។

### ១.ខ.៤. ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល

២០. ទំនាក់ទំនងនៃអំណាចរវាងមន្ត្រីរដ្ឋាភិបាល និងប្រជាពលរដ្ឋស៊ីវិល បង្ហាញថាក្រុមទាំងពីរនេះមានលក្ខណៈខុសគ្នាឆ្ងាយណាស់ដែលប្រការនេះបានរាំងលទ្ធភាពរបស់ប្រជាពលរដ្ឋស៊ីវិលក្នុងការទាមទារសិទ្ធិ និងសេរីភាព នៅចំពោះមុខការប្រើប្រាស់អំណាចផ្លូវការហួសហេតុពេក (Hughes/Conway, 2004:30) ។ **ប្រជាពលរដ្ឋកម្ពុជាជាច្រើន ជាពិសេសអ្នកដែលមានវ័យចំណាស់ និងអ្នកដែលរស់នៅតំបន់ជនបទមានទស្សនៈបិតុនិយមច្រើនចំពោះរដ្ឋាភិបាល** ។ ឧទាហរណ៍ នៅក្នុងការស្ទាបស្ទង់មតិមួយដែលធ្វើ

ឡើងនៅឆ្នាំ ២០០០ អ្នកឆ្លើយសំណួរប្រមាណ ៥៦% ចាត់ទុកអាជ្ញាធរដែនដីជា"ឪពុកម្តាយ"ឯប្រជាពលរដ្ឋសាមញ្ញជា "កូនចៅ" (CAS/TAF, 2001:26) ។ ការសិក្សាស្រាវជ្រាវថ្មី១មួយទៀតអំពីការដោះស្រាយទំនាស់ដីធ្លីក្នុងឆ្នាំ២០០៥/២០០៦ (CAS/World Bank, 2006) និងការចុះសិក្សាផ្ទាល់នៅតាមមូលដ្ឋានសំរាប់ការសិក្សានេះ ក៏បានរកឃើញនូវទស្សនៈនិងការយល់ឃើញដូចគ្នានេះដែរនៅតាមសហគមន៍[១២] ។ ប្រជាពលរដ្ឋសាមញ្ញ ជាពិសេសអ្នកនៅតាមជនបទ បានសំដែងនូវអារម្មណ៍ដែលផុសចេញពីផ្នត់គំនិតយ៉ាងជ្រៅរបស់ខ្លួនថា អ្វី១គឺ"ស្រេចតែលើ"មន្ត្រីសាធារណៈ និងអ្នកកាន់អំណាច ។ **ហេតុនេះហើយ រឿងសិទ្ធិប្រជាពលរដ្ឋ ការផ្តល់អំណាចដល់ប្រជាពលរដ្ឋ ឬថាមន្ត្រីរដ្ឋាភិបាលជាអ្នករ៉ាប់រងភារកិច្ចនោះ ពុំមានអ្វីជាការសំខាន់សំរាប់ពួកគាត់ឡើយ ។** កាតព្វកិច្ចបែបប្រជាធិបតេយ្យរបស់រដ្ឋាភិបាលក្នុងការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ និងសិទ្ធិ (ព្រមទាំងករណីយកិច្ច) របស់ប្រជាពលរដ្ឋក្នុងការស្វែងរកព័ត៌មាន និងការទទួលខុសត្រូវចំពោះខ្លួននោះ ពុំត្រូវបានគេយល់ ឬទទួលស្គាល់ជាទូទៅថាជាគោលការណ៍ជាមូលដ្ឋាននៃការទទួលខុសត្រូវសង្គមឡើយនៅកម្ពុជា ។ ដោយសារការគិតថាខ្លួនជាអ្នកតូចទាប និងគ្មានប្រយោជន៍អ្វីនោះ ជាប្រពៃណីប្រជាពលរដ្ឋតែងស្ទាក់ស្ទើរក្នុងការសួរដេញដោលអាជ្ញាធរ (កុំថាឡើយត្រូវប្រឈមមុខ) ហើយពុំសូវមានសង្ឃឹមថាមតិរបស់ "អ្នកតូចតាច" ដូចខ្លួនអាចមានឥទ្ធិពលអ្វីទៅលើសកម្មភាព ឬការសំរេចចិត្តរបស់រដ្ឋាភិបាលឡើយ ។ ដូចពាក្យសុភាសិតបុរាណមួយថា "កុំយកពងមាន់ទៅជល់នឹងថ្ម" នោះបង្ហាញថា វាគ្មានប្រយោជន៍អ្វីទេដែលអ្នកទន់ខ្សោយត្រូវទៅប្រឈមមុខជាមួយអ្នកមានអំណាចនោះ ។

២១. បើទោះបីបទដ្ឋាននៃវប្បធម៌-សង្គម និងលំនាំនយោបាយបែបប្រពៃណីមានឥទ្ធិពលដ៏សំខាន់យ៉ាងណាក្តី ក៏វាជាប្រការសំខាន់ណាស់ក្នុងការទទួលស្គាល់ថា**ឥរិយាបថ គុណតំលៃ និងកំរិតនៃការយល់ដឹងជាសាធារណៈ កំពុងមានការផ្លាស់ប្តូរយ៉ាងជាក់ស្តែងនៅកម្ពុជា** (Hughes, 2001; Hughes/Ojendal, 2006; Ojendal/Kim, 2006; CAS/World Bank, 2006) ។ ប្រទេសកម្ពុជាមានប្រជាពលរដ្ឋវ័យក្មេងច្រើន[១៣] ដែលកំពុងតែពេបប្រទះជាមួយនឹងគំនិតថ្មីទំនើប១ជាច្រើន ដោយសារមានចរាចរមនុស្សច្រើន (ចំណាកស្រុកមកទីក្រុង និងចំណូលជនបរទេសច្រើន) និងដោយសារប្រជាពលរដ្ឋមានវិទ្យុ ទូរទស្សន៍កាន់តែច្រើនឡើង ព្រមទាំងការប្រើប្រាស់អ៊ីនធឺណែត (បើទោះបីមានអត្រាតិចតួច) ។ ដូចមានរៀបរាប់នៅក្នុងរបាយការណ៍នេះហើយថា ការស្រាវជ្រាវនៅតាមមូលដ្ឋាន បានរកឃើញនូវការប្រែប្រួលគួរអោយកត់សំគាល់ខ្លះអំពីឥរិយាបថ សេចក្តីសង្ឃឹម និងអាកប្បកិរិយា រវាងប្រជាពលរដ្ឋជំនាន់ថ្មី និងប្រជាពលរដ្ឋជំនាន់មុន ។ ហេតុដូច្នេះហើយ ប្រជាពលរដ្ឋវ័យក្មេង១អាចជាប្រភពនៃការផ្លាស់ប្តូរដ៏មានសក្តានុពលជុំវិញបញ្ហាទំនាក់ទំនងរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ ក៏ដូចជាការលើកកំពស់ការទទួលខុសត្រូវសង្គម និងអភិបាលកិច្ចល្អនៅកម្ពុជា ។

---

[១២] ឧទាហរណ៍ : ក្នុងករណីមួយ អ្នកស្រុកដែលមានការខឹងសម្បារ បានចោទប្រកាន់មេឃុំដោយបើកចំហ ថាជាឪពុកម្នាក់ដែលគ្មានការទទួលខុសត្រូវចំពោះពួកគាត់ ដោយសារគាត់បានផ្តល់ដីរបស់អ្នកភូមិអោយទៅអ្នកវិនិយោគមកពីខាងក្រៅ ដោយពុំមានពិគ្រោះយោបល់ជាមួយអ្នកភូមិដែលមានការពាក់ព័ន្ធ (J4P, 2006:32) ។ ក្នុងពេលសំភាសន៍ជាមួយអ្នកដឹកនាំសមាគមកសិករនៅក្នុងខេត្តកំពង់ធំ *(ស្រុកសន្ទុក)* ប្រធានភូមិក៏ត្រូវបានគេហៅថាជាឪពុករបស់អ្នកភូមិផងដែរដែលគាត់ចេះថែទាំកូនចៅរបស់គាត់ ដោយបានចូលរួមក្នុងកិច្ចប្រជុំរបស់សមាគមកសិករបានទៀងទាត់ ។ គាត់ក៏ជាអ្នកដែលបានប្រមែប្រមូលអ្នកភូមិអោយបង្កើតសមាគម ហើយបានខិតខំពន្យល់អ្នកភូមិម្តងហើយម្តងទៀតអោយគេមកចូលរួមប្រជុំ និងដើរតួនាទីជាអ្នកសំរបសំរួលអោយអង្គការសេដាក ។ នៅក្នុងក្រុមពិភាក្សាក្នុងខេត្តកំពង់ចាម *(ស្រុកព្រៃឈរ)* អ្នកចូលរួមបានហៅអភិបាលខេត្តថាជាឪពុករបស់អភិបាលស្រុក ហើយអភិបាលស្រុកជាឪពុករបស់មេឃុំ ។ល។

[១៣] ៧០%នៃចំនួនប្រជាជន មានអាយុក្រោម៣០ឆ្នាំ ។

### ១.ខ.៥. សង្គមស៊ីវិល

២២. សង្គមស៊ីវិលនៅកម្ពុជាក៏ជាផលមួយនៃប្រវត្តិសាស្ត្រដ៏ពិសេសផ្នែកនយោបាយ និងសង្គមរបស់ប្រទេសនេះដែរ ។ អ្នកសង្កេតការណ៍បានកត់សំគាល់ថា នៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ក្រុមឯករាជ្យនានាក្នុងសង្គមដែលខិតខំសំដែងនូវមតិរបស់ខ្លួនជាសាធារណៈ និងចោទសួរ ឬព្យាយាមអោយមានឥទ្ធិពលទៅលើការសំរេចចិត្តរបស់រដ្ឋាភិបាល ត្រូវបានរដ្ឋាភិបាលគៀបសង្កត់យ៉ាងធ្ងន់ធ្ងរ (Yonekura, 1999) ។ នៅពេលមានកិច្ចព្រមព្រៀងសន្តិភាពនៅដើមទសវត្សឆ្នាំ១៩៩0 សហគមន៍អន្តរជាតិបានយល់ឃើញថា ការបង្កើតអោយមាន "សង្គមស៊ីវិល" ជាការធានាដ៏សំខាន់ដើម្បីទប់ស្កាត់ការកើតឡើងជាថ្មីនូវការគាបសង្កត់ពីសំណាក់រដ្ឋាភិបាលនៅកម្ពុជា (Hughes, 2003:138) ។ UNTAC (ហើយក្រោយមកទៀតមានអង្គការអន្តរជាតិជាច្រើន) បានគាំទ្រដល់ការកើតឡើងនូវអង្គការក្រៅរដ្ឋាភិបាលដែលមានអណត្តិការងារលើកកំពស់លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៏សង្គម ។ ជាលទ្ធផល **អង្គការក្រៅរដ្ឋាភិបាលអាជីពភាគច្រើននៅកម្ពុជាបច្ចុប្បន្ននេះកើតមានឡើងអាស្រ័យដោយឥទ្ធិពល និងការគាំទ្រផ្នែកហិរញ្ញវត្ថុពីម្ចាស់ជំនួយអន្តរជាតិ ជាជាងដោយសារការបើកចំហបន្តិចម្តងៗនៃឱកាសបែបប្រជាធិបតេយ្យ ការរីកដុះដាលដោយឯកឯងនៃអង្គការសហគមន៍ ការកកើតមាននូវវប្បធមិស្ម័គ្រចិត្ត/សកម្មជនសង្គម ឬសមាគមសប្បុរសធមិរបស់មនុស្សក្នុងវណ្ណៈកណ្តាល ។**

២៣. **ប្រការដែលថាអង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជាធ្វើអ្វី "តំរូវតែចិត្តម្ចាស់ជំនួយ" នោះ វាបានក៏រិតនូវប្រសិទ្ធិភាពអង្គការទាំងនោះក្នុងនាមជាអ្នកលើកកំពស់អភិបាលកិច្ចល្អ និងជាកាត្តាលីករដែលជំរុញអោយមានការចូលរួមរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវសង្គម ។** ដោយសារអង្គការទាំងនោះត្រូវបានបង្កើតឡើងដោយអ្នកខាងក្រៅ ជាជាងការរីកលូតលាស់នៅក្នុងស្រុកដោយឯកឯងអង្គការក្រៅរដ្ឋាភិបាលភាគច្រើនពុំសូវមានការផ្សារភ្ជាប់ជាមួយសហគមន៍ និងការចាក់ឬសរឹងមាំនៅក្នុងសង្គមទេ។ លើកលែងតែសហជីពកម្មករចេញ (គួរអោយកត់សំគាល់) អង្គការសង្គមស៊ីវិលភាគច្រើននៅកម្ពុជា ដែលមិននៅក្នុងសហគមន៍ពុំមែនជាអង្គការដែលមានសមាជិកភាពឡើយ ហើយក៏ពុំមានក្រុមគាំទ្រជាក់លាក់យូរអង្វែង ឬមានមូលដ្ឋានសង្គមអ្វីដែរ ដែលស្ថានភាពនេះបាននាំអោយអ្នកវិភាគម្នាក់ចាត់ទុកវិស័យអង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជាថាជា "ចលនាស៊ីវិលដោយគ្មានប្រជាពលរដ្ឋ" (Un, 2004:272) ។ ប្រការនេះបានធ្វើអោយអង្គការទាំងនោះឃ្លាតឆ្ងាយពីប្រជាពលរដ្ឋ ឯការគ្មានសមត្ថភាពក្នុងការបង្ហាញនូវការគាំទ្រពីប្រជាពលរដ្ឋបែបនេះ បានធ្វើអោយប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ និងឥទ្ធិពលរបស់អង្គការទាំងនោះ ហើយធ្វើអោយមន្ត្រីរដ្ឋាភិបាលចាប់សាកសួរអំពីភាពស្របច្បាប់ និងភាពជាតំណាងរបស់អង្គការទាំងនោះ ។ ការតំរូវចិត្តម្ចាស់ជំនួយ ក៏អាចជាប្រការនាំអោយអង្គការក្រៅរដ្ឋាភិបាលភាគច្រើនប្រមូលផ្តុំតែនៅក្នុងទីក្រុងភ្នំពេញ ច្រើនជាងនៅតំបន់ជនបទ ។ បើទោះបីការអនុវត្តន៏នូវវិមជ្ឈការនាពេលបច្ចុប្បន្ន បានជំរុញម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលអោយ ផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតទៅលើអង្គការសហគមន៍យ៉ាងណាក្តី ក៏កិច្ចខិតខំប្រឹងប្រែងក្នុងការផ្តល់អំណាចដល់ប្រជាពលរដ្ឋ ការលើកកំពស់ការចូលរួមពីសហគមន៍ ឬការកសាងសង្គមស៊ីវិលពីក្រោមទៅលើ កំពុងនៅមានក៏រិតនៅឡើយចំពោះ ។ ដោយសារអង្គការទាំងនោះមានការពឹងផ្អែកយ៉ាងខ្លាំងទៅលើមូលនិធិពីម្ចាស់ជំនួយ (ដែលអ្នកសង្កេតការណ៍មួយចំនួនយល់ឃើញថាស្ថានភាពនេះឆ្លុះបញ្ចាំងពីថាមភាពនៃការមានទំនាក់ទំនងបែបចៅហ្វាយនាយ-កូនចៅ) ។ បច្ចុប្បន្ននេះ អង្គការក្រៅរដ្ឋាភិបាលមានទឹកចិត្តដ៏រឹងមាំដើម្បីផ្តល់អាទិភាពលើក្របខ័ណ្ឌកម្មវិធី និងលក្ខខ័ណ្ឌនៃរបាយការណ៏របស់ម្ចាស់ជំនួយ ហើយទន្ទឹមនឹងនោះគេមិនសូវមានទឹកចិត្តក្នុង

ការឆ្លើយតប និងទទួលខុសត្រូវចំពោះប្រជាពលរដ្ឋនៅតាមសហគមន៍ទេ ។ ជាចុងក្រោយ ការដែលអង្គការក្រៅរដ្ឋាភិបាលពឹងផ្អែកទៅលើមូលនិធិម្ចាស់ជំនួយពេកក៏ធ្វើអោយនិរន្តរភាពហិរញ្ញវត្ថុរបស់ពួកគេមិនមានភាពច្បាស់លាស់ និងបង្កើតអោយមានបញ្ហាប្រឈមមួយចំនួនក្នុងការសំរបទស្សនាទាននិងរបៀបវារៈបរទេស ជាមួយតថភាពក្នុងស្រុកជាក់ស្តែង (វប្បធម៌ នយោបាយ សង្គម) ។ ដូចមានពិភាក្សានៅក្នុងរបាយការណ៍នេះហើយ ទាំងម្ចាស់ជំនួយនិងអង្គការសង្គមស៊ីវិលកម្ពុជា ដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាទាំងនេះ ។ ប្រអប់ទី១ បង្ហាញពីទិដ្ឋភាពរួមនៃប្រភេទអង្គការសង្គមស៊ីវិលធំៗនៅកម្ពុជា ។

**ប្រអប់ទី ១ : ទិដ្ឋភាពរួមនៃអង្គការសង្គមស៊ីវិលនៅកម្ពុជា**

អង្គការសង្គមស៊ីវិលនៅកម្ពុជាត្រូវបានបែងចែកជាក្រុមចំបង៧ដូចតទៅ :

❶ *សមាគមបែបប្រពៃណី*- សមាគមបែបប្រពៃណី គណៈកម្មការ និងក្រុមជួយខ្លួនឯង ច្រើនតែមានការផ្សារភ្ជាប់ទៅនឹងវត្តអារ៉ាម ហើយជាប្រភេទនៃការរួបរួមគ្នាដែលកើតមានច្រើនបំផុត និងមានតាំងពីយូរយារណាស់មកហើយ ព្រមទាំងតំណាងអោយជីវភាពទូទៅរបស់ប្រជាពលរដ្ឋសាមញ្ញ ។ ដូចដែលមានពិភាក្សានៅក្នុង ២.គ.១. បើទោះបីសមាគមបែបនេះមាននៅស្ទើរគ្រប់ភូមិនៅកម្ពុជា មានអ្នកភូមិប្រមាណប្រហែល ១៥% ប៉ុណ្ណោះដែលមានការពាក់ព័ន្ធក្នុងសមាគមទាំងនោះ ។

❷ *អង្គការសហគមន៍បែប "ទំនើប"*- ក្នុងចំណោមភូមិប្រមាណ ១៣,០០០ នៅកម្ពុជា មានភូមិចំនួន ៨,០០០ ដែលមានគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ដែលគណៈកម្មាធិការនេះត្រូវបានបង្កើតឡើងដើម្បីអោយអ្នកភូមិបានចូលរួមពាក់ព័ន្ធដោយផ្ទាល់ក្នុងការងារអភិវឌ្ឍន៍ក្នុងមូលដ្ឋាន និងការធ្វើផែនការពីថ្នាក់ក្រោមមកលើ ។ តែទោះជាយ៉ាងនេះក្តីក្នុងការអនុវត្តន៍ជាក់ស្តែង គណៈកម្មាធិការបែបនេះច្រើនតែទទួលនូវភាពលុបលើ ឬឥទ្ធិពលយ៉ាងធំធេងពីម្ចាស់ជំនួយ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ឬគណៈបក្ស ឬមន្ត្រីរដ្ឋាភិបាលនៅមូលដ្ឋាន ។ ដោយសារកង្វះនូវស្វ័យភាពបែបនេះហើយ ទើបគណៈកម្មាធិការនោះមិនត្រូវបានចាត់ទុកថាជាអង្គការសង្គមស៊ីវិលពិតប្រាកដទេ។ ដូចដែលមានពិភាក្សានៅក្នុងចំណុច២.គ.១.នៃរបាយការណ៍នេះ អង្គការសហគមន៍ប្រភេទដទៃទៀត (ដូចជាសមាគមស្ត្រី សមាគមយុវជន សមាគមកសិករ ឬសមាគមអ្នកនេសាទ ជាដើម) ភាគច្រើនទើបតែកើតមានឡើងក្នុងពេលថ្មីៗនេះប៉ុណ្ណោះ ដែលភាគច្រើនបង្កើតឡើងដោយមានជំនួយពីខាងក្រៅ គឺអង្គការក្រៅរដ្ឋាភិបាល ។ មានការប៉ាន់ប្រមាណថា សមាគមបែបនេះមានប្រជាពលរដ្ឋចូលរួមប្រហែល ១២% នៃប្រជា-ពលរដ្ឋសរុបទាំងអស់ ។

❸ *អង្គការក្រៅរដ្ឋាភិបាល*— ការសិក្សា (ការសិក្សារបស់ CDC អោយ Danida) ថ្មីៗមួយបានចង្អុលបង្ហាញពីការរីកចំរើនដ៏ផុលផុស នៃវិស័យអង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជា បើទោះបីការសិក្សានោះនិយាយថាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជិកាជាច្រើនមិនទាន់មានសកម្មភាពអ្វីក៏ដោយ ។ ការសិក្សានោះបានរកឃើញថា មានអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកចំនួន ១៤៩៥ និង អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិចំនួន ៣៣៧ បានចុះបញ្ជិកា (គិតមកដល់ចុងឆ្នាំ ២០០៥) ។ មានការប៉ាន់ប្រមាណថា មានអង្គការក្នុងស្រុកប្រមាណ

តែ ៤៥% (ឬចំនួន ៦៦៨ អង្គការ) ដែលត្រូវបានចាត់ទុកថាកំពុងមានសកម្មភាព ហើយក្នុងចំណោមអង្គការអន្តរជាតិដែលបានចុះបញ្ជិកា មានអង្គការប្រមាណ ៩៣% ដែលមានសកម្មភាព ។ មានអង្គការក្នុងស្រុកចំនួន ១០០ ដែលមានភាពលេចធ្លោនៅក្នុងវិស័យអង្គការក្រៅរដ្ឋាភិបាល ហើយក្នុងចំណោមនោះមាន "ប្រហែលពី ៣០ ទៅ ៤០ អង្គការ ដែលចាត់ទុកថាមានភាពរឹងមាំ" (Khlok, Nil, et. al August 2003) ។ អង្គការក្រៅរដ្ឋាភិបាលមានបុគ្គលិកខ្មែរចំនួន ២៤,០០០ នាក់ និងបុគ្គលិកបរទេសប្រហែល ១,២០០ នាក់ ។ អង្គការក្រៅរដ្ឋាភិបាលភាគច្រើនប្រមូលផ្តុំគ្នានៅតំបន់ទីក្រុង ជាពិសេសនៅទីក្រុងភ្នំពេញ ។ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកប្រមាណ ៧០% មានមូលដ្ឋាននៅទីក្រុងភ្នំពេញ ហើយពាក់កណ្តាលនៃចំនួនដែលនៅសល់ មានមូលដ្ឋាននៅខេត្តបាត់ដំបង កណ្តាល និងសៀមរាប ។ សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលផ្តោតលើការផ្តល់សេវា បើទោះបីមានសញ្ញាណថា អង្គការទាំងនោះមានសកម្មភាពចំរុះក្តី ។ នៅក្នុងឯកសារចុះបញ្ជិការបស់ពួកគេ អង្គការក្នុងស្រុកប្រមាណ ៧០% បានថែងពីគោលបំណងរបស់ខ្លួន ថាជាអ្នកផ្តល់សេវាផ្នែកសង្គមកិច្ច ហើយមានអង្គការក្នុងស្រុកប្រមាណតែ ៧% ប៉ុណ្ណោះដែលបានអះអាងថាសកម្មភាពរបស់ខ្លួនគឺផ្តោតលើសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ។

❹ *សហជីពកម្មករ* — នៅក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា សហជីពត្រូវបានទទួលស្គាល់ជាផ្លូវការថា ជាអង្គការមហាជន ហើយត្រូវបានចាត់ទុកថាជាអង្គមួយនៃក្បាលម៉ាស៊ីនរបស់រដ្ឋ ។ នៅក្នុងកំឡុងពេល និងក្រោយសម័យអ៊ុនតាក់ មានការអនុញ្ញាតអោយមានសហជីពឯករាជ្យ ប៉ុន្តែមិនមានឥទ្ធិពលណាមួយភ្លាមៗដើម្បីទាញយកប្រយោជន៍ពីសេរីភាពផ្នែកការរួបរួមជាសមាគមទេ ។ ទើបតែក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ នៅពេលដែលឧស្សាហកម្មកាត់ដេរមានការរីកលូតលាស់យ៉ាងឆាប់រហ័យ ដែលសហជីពមានការកើតឡើងយ៉ាងព្រោងព្រាត (ដែលជាទូទៅត្រូវបានបង្កើតតាមរោងចក្រនីមួយៗ) ព្រមជាមួយនឹងការបង្កើតឡើងនូវសហព័ន្ធសហជីព។ បើទោះបីកាលពីឆ្នាំ ១៩៩៧ មានសហជីពតែចំនួន ២០ ប៉ុណ្ណោះដែលបានចុះបញ្ជិកាក្តី ក៏ចំនួនសហជីពបានកើនឡើងរហូតដល់ ២៤៥ គិតមកដល់ខែមករា ឆ្នា ២០០២ ហើយបន្តកើនឡើងដល់ ៣៧០ នៅខែ សីហា ២០០៥ រួមជាមួយនឹងសហព័ន្ធសហជីពចំនួន ១៥ ផង ។ មានការប៉ាន់ប្រមាណថា កំលាំងពលកម្មផ្លូវការចំនួន ៤០% បានចូលរួមក្នុងសហជីព ក្នុងនោះភាគច្រើនជាស្ត្រីដែលកំពុងធ្វើការនៅក្នុងឧស្សាហកម្មកាត់ដេរ (Makin 2006: 25) ។ សហជីពមានការពឹងផ្អែកយ៉ាងច្រើនទៅលើថវិកាពីប្រភពខាងក្រៅ ជាជាងបានមកពីប្រាក់សមាជិកភាព (មានការប៉ាន់ស្មានថា សមាជិកសហជីពប្រហែលតែ ១០% ប៉ុណ្ណោះដែលបង់ប្រាក់សមាជិកភាពសហជីព) ។ ប្រភពថវិការបស់សហជីពនេះភាគច្រើនបានមកពីអ្នកនយោបាយក្នុងស្រុក ឬពីម្ចាស់ជំនួយ និងអង្គការសហជីពអន្តរជាតិ ។

❺ *អង្គការយុវជន* — ដោយសារកម្ពុជាជាប្រទេសមួយដែលប្រជាពលរដ្ឋរបស់ខ្លួនប្រមាណ ៧០% មានអាយុក្រោម ៣០ ឆ្នាំ អង្គការយុវជនមានតួនាទីសំខាន់ណាស់ ជាពិសេសក្នុងការដោះស្រាយបញ្ហាពិសេសរបស់យុវជន និងក្នុងការកសាងសមត្ថភាពរបស់យុវជនសំរាប់រួមចំណែកដល់ការអភិវឌ្ឍន៍សង្គម ។ មានអង្គការយុវជនដែលមានភាពរឹងមាំ និងដែលសកម្មប្រហែលជាង ១០ អង្គការ បានចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍សង្គម សកម្មភាពស្ម័គ្រចិត្ត និង ការរួមចំណែករបស់យុវជនក្នុងដំណើរការនយោបាយ និង លទ្ធិប្រជាធិបតេយ្យ

ការកសាងបណ្តាញ និងការតស៊ូមតិ ។ ជាងនេះទៀត ក៏មានសមាគម និងក្លឹបនិស្សិតកាន់តែច្រើនឡើងៗ នៅទូទាំងប្រទេស ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងច្រើន រួមទាំងការអប់រំ និងការលើកកំពស់ការយល់ដឹងលើបញ្ហាមួយចំនួនផងដែរ ។

❻ *ប្រភេទផ្សេងៗទៀត* — ចំនួន "ស្ថាប័នផ្តល់ប្រឹក្សា" និងអង្គការស្រាវជ្រាវឯករាជ្យ មានការកើនឡើងច្រើន ជាពិសេសនៅភ្នំពេញ ដែលអង្គការទាំងនេះមានឥទ្ធិពលកាន់តែច្រើនឡើងៗ ជាពិសេសជាមួយម្ចាស់ ជំនួយ ប្រព័ន្ធផ្សព្វផ្សាយ និងអង្គការក្រៅរដ្ឋាភិបាល ។ ស្ថាប័នឧត្តមសិក្សា និងសមាគមនិស្សិតឯករាជ្យ ក៏ជាតួអង្គក្នុងសង្គមស៊ីវិលដ៏សំខាន់ផងដែរ ប៉ុន្តែគ្រាន់តែពុំសូវមានការផ្សារភ្ជាប់រឹងមាំទៅនឹងការអភិវឌ្ឍន៍សហគមន៍។ ក្រៅពីនេះនៅមានអង្គការ និងសមាគមសារព័ត៌មានឯករាជ្យមួយចំនួនតូចទៀត បើទោះបីសមាគមទាំងនេះមិនមានឥទ្ធិពលអ្វីជាដុំកំភួនក៏ដោយ (មើលចំណុច ២.ខ.៤) ។ នៅមានសមាគមអាជីវកម្មដ៏មានឥទ្ធិពលមួយក្រុមទៀត ប៉ុន្តែជាប្រការល្អការពិភាក្សាពីក្រុមនេះគួរធ្វើឡើងនៅក្នុងការសិក្សាអំពីវិស័យឯកជន ។ តែទោះជាយ៉ាងនេះក្តីសមាគមអាជីវកម្មនេះ បានរួមចំណែកជាមួយអង្គការសង្គមស៊ីវិលកាន់តែច្រើនឡើងៗក្នុងការពិភាក្សាអំពីបញ្ហាគោលនយោបាយ និងការងារទាក់ទងនឹងអភិបាលកិច្ច ។

២៤. អង្គការក្រៅរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តរួមចំណែកយ៉ាងសំខាន់បំផុតដល់ការអភិវឌ្ឍន៍ផ្នែកនយោបាយ និងសង្គមនៅកម្ពុជា[១៤] ។ តែទោះជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍន៍នៃវិស័យអង្គការក្រៅរដ្ឋាភិបាលអាជីព ពុំគួរយកទៅផ្គូរផ្គងជាមួយនឹងការកកើតឡើងនៃ "សង្គមស៊ីវិល " កម្ពុជាដែលជាម្ចាស់ស្រុក និងមានលក្ខណៈទូលំទូលាយនោះទេ[១៥] (Yonekura, 1999; SIDA, 2006: 16,18) ។ ប្រសិនបើសង្គមស៊ីវិល ត្រូវបានចាត់ទុកថាជា "ដែនសាធារណៈដែលប្រជាពលរដ្ឋអាចប្រាស្រ័យទាក់ទងគ្នាដោយសេរីដើម្បីលើកកំពស់ផលប្រយោជន៍រួម" នោះ "[១៦] អញ្ចឹងសង្គមស៊ីវិលនៅកម្ពុជានៅមានភាពទន់ខ្សោយនៅឡើយ ។ ដូចមានពិភាក្សានៅក្នុងផ្នែកទី២នៃរបាយការណ៍នេះហើយ ក៏រិតនៃការរួបរួមជាសមាគមរបស់ប្រជាពលរដ្ឋនៅថ្នាក់សហគមន៍នៅមានកំរិតទាបនៅឡើយ ដែលក្នុងនោះដែននៃស្វ័យភាពដែលបុគ្គលអាចមកចូលរួមដោយសេរីដើម្បីបញ្ចេញមតិយោបល់ និងធ្វើសកម្មភាពរួមអ្វីមួយ គឺនៅមានភាពតូចចង្អៀតនៅឡើយ ហើយក្រឹត្យក្រមស្ថាប័ន និងវប្បធម៌ដែលកំណត់នូវដែនស្វ័យភាពបែបនោះ មិនមានលក្ខណៈងាយស្រួលសំរាប់ការរួបរួមជាសមាគម ការបញ្ចេញមតិ និងការចូលរួមរបស់ប្រជាពលរដ្ឋឡើយ ។ ហេតុដូច្នេះហើយ កិច្ចខិតខំប្រឹងប្រែងដើម្បី "ពង្រឹងសង្គមស៊ីវិល" មិនត្រូវបញ្ចប់ត្រឹមការអភិវឌ្ឍន៍សមត្ថភាពរបស់អង្គការក្រៅរដ្ឋាភិបាលប៉ុណ្ណឹងទេ ប៉ុន្តែត្រូវសង្កត់ធ្ងន់ទៅលើការបង្កើតនូវដែនសាធារណៈ និងបរិយាកាសអំណោយផលសំរាប់ការធ្វើសកម្មភាព

---

[១៤] ចាប់តាំងពីជំនាន់ UNTAC ម្ចាស់ជំនួយអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ គឺជាប្រភពនៃធនធានអភិវឌ្ឍន៍មួយដ៏សំខាន់ និងជាអ្នកតស៊ូមតិដ៏ខ្លាំងក្លា និងមានឥទ្ធិពលចំពោះកំណែទំរង់អភិបាលកិច្ច ។ តែទោះជាយ៉ាងនេះក្តី ក្នុងពេលអនាគត ឥទ្ធិពលរបស់តួអង្គទាំងនេះទំនងជានឹងធ្លាក់ចុះដោយសារចំណូលសាធា-រណៈ(ពីផ្នែករ៉ែ និងប្រេង) មានការកើនឡើង ហើយសេចក្តីត្រូវការផ្នែកជំនួយអភិវឌ្ឍន៍ត្រូវបានកាត់បន្ថយ ។

[១៥] ក្នុងប្រទេសកម្ពុជា "សង្គមស៊ីវិល" ជាញឹកញាប់តែងត្រូវបានគេយល់ និង សំដៅថាជាអង្គការមិនមែនរដ្ឋាភិបាល ។

[១៦] សូមមើល Heinrich/Malena, 2007.

របស់ប្រជាពលរដ្ឋ ។ ការបើកចំហនូវឱកាសនយោបាយ និងការបង្កើតនូវបរិយាកាសអំណោយផលផ្នែកគោលនយោបាយ គឺមួយភាគធំស្ថិតនៅក្នុងដៃនៃរាជរដ្ឋាភិបាលកម្ពុជា ។ ដៃគូអភិវឌ្ឍន៍មានតួនាទីដ៏សំខាន់ក្នុងការតស៊ូមតិ និងគាំទ្រដំណើរការទាំងនេះ។ យោងតាម Hughes និង Conway (2004:30) "វាមិនមានសញ្ញាណបង្ហាញថាមាន "សង្គមស៊ីវិល" ណាស់នៅកម្ពុជា ប្រសិនបើគិតថាសង្គមស៊ីវិលជាដែនដែលបុគ្គលមានអារម្មណ៍ថាមានសេរីភាពក្នុងការឃ្លាំមើលជំហរនយោបាយដោយឯករាជ្យពីមន្ត្រីរដ្ឋាភិបាលដែលគេត្រូវឃ្លាំមើល និងអាចសួរដេញដោលនោះ" ។ បើទោះជាបីយ៉ាងនេះក្តី ករណីសិក្សាពីការស្រាវជ្រាវថ្មីៗមួយ បានរកឃើញនូវភស្តុតាងគួរអោយកត់សំគាល់ពីការដែលប្រជាពលរដ្ឋមាន "ឆន្ទៈកាន់តែច្រើនឡើងៗក្នុងការទាមទារដោយចំហ បើទោះបីជាប្រឆាំងទៅនឹងអ្នកមានអំណាចក៏ដោយ ក្នុងករណីដែលពួកគេត្រូវបានដកហូតដីធ្លីដោយអយុត្តិធម៌...[ដែលនេះមួយផ្នែកគឺដោយសារ]...ការកកើតឡើងនៃសង្គមស៊ីវិល ដែលកាន់តែមានលក្ខណៈបើកចំហ"(CAS/World Bank, 2006) ។

### ១.ខ.៦. ទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល

២៥. **ការប្រាស្រ័យទាក់ទងគ្នាជាលក្ខណៈស្ថាប័នរវាងសង្គមស៊ីវិលកម្ពុជា និងរដ្ឋាភិបាលឃើញកើតមានតិចតួច ។** កាលពីមុនពេលមានការអនុវត្តនីវិមជ្ឈការ អង្គការសហគមន៍មានលទ្ធភាពតិចតួច ក្នុងការចូលរួមពាក់ព័ន្ធជាមួយអាជ្ញាធរសាធារណៈ ។ ហេតុដូច្នេះកំណែទំរង់ដូចពេលបច្ចុប្បន្ននេះបានផ្តល់នូវឱកាសដ៏សំខាន់ សំរាប់កសាងនូវទំនាក់ទំនងជាលក្ខណៈស្ថាប័ន រវាងសមាគមប្រជាពលរដ្ឋ និងមន្ត្រីរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន ។ បើនិយាយពីអង្គការសង្គមស៊ីវិលដែលធ្វើការនៅថ្នាក់ខេត្ត និងថ្នាក់ជាតិវិញ រដ្ឋាភិបាលច្រើនមានឥរិយាបថបែប "មានមន្ទិលសង្ស័យ" ចំពោះពួកគេ (SIDA, 2003:12) – ដោយក្នុងនោះទំនាក់ទំនងជាមួយអង្គការខ្លះមានលក្ខណៈជាការសហការល្អ ហើយជាមួយអង្គការខ្លះទៀតមានលក្ខណៈប្រទើងប្រទះ ពោលគឺអាស្រ័យលើចរិតលក្ខណៈនៃអណត្តិ និងសកម្មភាពរបស់អង្គការទាំងនោះ ។ ជួនកាលអ្នកតំណាងរដ្ឋាភិបាល ប្រើពាក្យថាអង្គការ "ល្អ" (សំដៅដល់អង្គការដែលផ្តល់សេវាសង្គម) និងអង្គការក្រៅរដ្ឋាភិបាលដែល "អាក្រក់" (សំដៅដល់អង្គការដែលចេះចោទសួរ ឬរិះគន់សកម្មភាពរបស់រដ្ឋាភិបាល ឬពាក់ព័ន្ធនៅក្នុងសកម្មភាពតស៊ូមតិ) ។ លើកលែងតែអង្គការក្រៅរដ្ឋាភិបាលដែលធ្វើសកម្មភាពផ្នែកផ្តល់សេវាទាំងស្រុងចេញ ទំនាក់ទំនងរវាងរដ្ឋាភិបាលជាមួយអង្គការសង្គមស៊ីវិលក្រៅពីនេះ ជាពិសេសអង្គការដែលធ្វើការផ្នែកលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ច្រើនតែពោរពេញទៅដោយការមន្ទិលសង្ស័យ និងភាពមិនទុកចិត្តគ្នាទៅវិញទៅមក ។

២៦. បើនិយាយពី*ការរួមចំណែករបស់អង្គការសង្គមស៊ីវិលចំពោះអភិបាលកិច្ចល្អ* តាមរយៈការស្វែងរក និងផ្សព្វផ្សាយព័ត៌មានអំពីរដ្ឋាភិបាល ការចូលរួមក្នុងដំណើរការពិភាក្សា និងការសំរេចចិត្ត ក៏ដូចជាការធ្វើអោយរដ្ឋាភិបាលមានការទទួលខុសត្រូវនោះ គឺនៅមានលក្ខណៈថ្មីថ្មោងនៅឡើយ ហើយមានបញ្ហាប្រឈមច្រើន ។ ដូចមានរៀបរាប់នៅក្នុងប្រអប់ទី១ហើយ ក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលកម្ពុជាដែលបានចុះបញ្ជិកា មានអង្គការតែមួយចំនួនតូចប៉ុណ្ណោះ (ប្រមាណ៧%) ដែលពាក់ព័ន្ធក្នុងសកម្មភាពផ្នែកលទ្ធិប្រជាធិបតេយ្យ ការតស៊ូមតិ និងការចរចារអំពីគោលនយោបាយ ។ បញ្ហា និងដំណើរការផ្នែកអភិបាលកិច្ចនៅកម្ពុជា មានលក្ខណៈនយោបាយយ៉ាងខ្លាំង ម្ល៉ោះហើយកិច្ចខិតខំប្រឹងប្រែងណាមួយក្នុងការស្វែងរកព័ត៌មានអំពីរដ្ឋាភិបាល ការចោទជាសំណួរ ឬសំដែងពីក្តីបារម្ភជាសាធារណៈ ឬការចង់ដឹងចង់លឺពីសកម្មភាពរបស់រដ្ឋាភិបាល ច្រើនតែត្រូវបានចាត់ទុកថាជាការដេញដោលអំពីអាជ្ញាធររដ្ឋាភិបាល ឬសកម្មភាព "ប្រឆាំង"។ ក្នុងរយៈកាលជាង១០ឆ្នាំកន្លងមកនេះ វាគ្មានអ្វីនៅសង្ស័យទៀតឡើយថា អង្គការក្រៅរដ្ឋាភិបាលបានរួមចំណែកយ៉ាងវិជ្ជមាន ដល់ការកកើតឡើងនៃវប្បធម៌ប្រជាធិបតេយ្យនៅកម្ពុជា ជាពិសេសតាម

រយៈការលើកកំពស់ការយល់ដឹង និងសកម្មភាពបណ្តុះបណ្តាល ។ អង្គការសិទ្ធិមនុស្ស រួមជាមួយនឹងអង្គការដទៃទៀតដែលធ្វើការផ្តែកតស៊ូមតិ បានបង្កើតអោយមានសហគមន៍ដ៏រស់រវើកមួយ បានធ្វើយុទ្ធនាការសាធារណៈធំៗអំពីបញ្ហាសំខាន់ៗ និងបានចាប់ផ្តើមពង្រឹងទំនាក់ទំនងរវាងរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន ។ តែទោះជាយ៉ាងណាក្តី កិច្ចខិតខំប្រឹងប្រែងរបស់អង្គការសង្គមស៊ីវិល ក្នុងការជួយដោយផ្ទាល់អោយរដ្ឋាភិបាលកាន់តែមានប្រសិទ្ធិភាព និងមានការទទួលខុសត្រូវនោះ ដូចជាតាមរយៈការពិភាក្សាអំពីបញ្ហាគោលនយោបាយ ការឃ្លាំមើល និងវាយតំលៃសកម្មភាពរបស់រដ្ឋាភិបាល ការផ្តល់យោបល់ត្រលប់ និង"ការរិះគន់ប្រកបដោយលក្ខណៈស្ថាបនា" ការស្វែងរកការទទួលខុសត្រូវជាដើមនោះ គឺនៅមានលក្ខណៈថ្មីថ្មោង និងផុយស្រួយនៅឡើយនៅកម្ពុជា ។ **ការបង្កើតឡើងនូវតួនាទីទទួលខុសត្រូវសង្គមទាំងនេះ នឹងជួយដល់សង្គមស៊ីវិលអោយបំពេញតួនាទីរបស់ខ្លួន ក្នុងនាមជាអ្នកដើរតួនាដ៏សំខាន់ ក្នុងការជួយកម្ពុជាអោយបំពេញភារកិច្ចរបស់ខ្លួន អោយកម្ពុជាក្លាយជាប្រទេសដែលអនុវត្តលទ្ធិប្រជាធិបតេយ្យពេញលេញ ដែលអាចបំរើប្រយោជន៍ប្រជាពលរដ្ឋរបស់ខ្លួនគ្រប់រូបប្រកបដោយប្រសិទ្ធិភាព និងសមធម៌ ។**

## ១.គ. រូបភាពនៃការទទួលខុសត្រូវសង្គមនៅកម្ពុជា

២៧. ការទទួលខុសត្រូវសង្គមរួមមានបណ្តុំសកម្មភាព និងវិធីសាស្ត្រខុសៗគ្នាជាច្រើន ហើយសកម្មភាពទាំងនេះអាចផ្តួចផ្តើមឡើងដោយតួអង្គជាច្រើនផ្សេងៗគ្នា (ដូចជា ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល មន្ត្រីរដ្ឋាភិបាល ឬអ្នកផ្តល់សេវាសាធារណៈ) ដោយប្រើប្រាស់នូវវិធីសាស្ត្រខុសៗគ្នា (ឧទាហរណ៍ : ការស្រាវជ្រាវ ការឃ្លាំមើល ការតស៊ូមតិ ការធ្វើផែនការដោយមានការចូលរួម ការអប់រំប្រជាពលរដ្ឋ ការផ្សព្វផ្សាយព័ត៌មាន ការកសាងសម្ព័ន្ធភាព) ។ ដូចមានបង្ហាញជូននៅក្នុងរូបភាពទី១ខាងក្រោមនេះ វិធីសាស្ត្រទាំងនេះអាចយកមកអនុវត្តបានទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ នៅគ្រប់ដំណាក់កាលនៃវដ្តរៀបចំគោលនយោបាយ និងការគ្រប់គ្រងចំណាយសាធារណៈ ។ **បើទោះបីគំនិតផ្តួចផ្តើមនៃការទទួលខុសត្រូវសង្គម ទើបតែកើតមាននៅកម្ពុជាក្តី ក៏ការសិក្សាស្រាវជ្រាវនេះបានរកឃើញសកម្មភាពការងារផ្នែកទទួលខុសត្រូវសង្គម (ក្នុងទ្រង់ទ្រាយតូចៗ) ជាច្រើន ទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ហើយបានរកឃើញភស្តុតាងនៃការចាប់អារម្មណ៍ និងសក្តានុពលគួរអោយកត់សំគាល់សំរាប់ពង្រីក និងលើកកំពស់សកម្មភាពរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលនៅក្នុងផ្នែកនេះ ។**

***រូបភាពទី១ : ឧទាហរណ៍នៃការទទួលខុសត្រូវសង្គមនៅកម្ពុជា*** *(និងស្ថាប័នដែលគាំទ្រ)*

| ផ្នែក | ថ្នាក់មូលដ្ឋាន <----------------------------------> ថ្នាក់ជាតិ | |
|---|---|---|
| **គោលនយោបាយ និងផែនការ** | ការរៀបចំផែនការមូលដ្ឋានដោយមានការចូលរួម កិច្ចពិភាក្សា និងភាពជាដៃគូរបស់ប្រជាពលរដ្ឋ និង ក្រុមប្រឹក្សាឃុំ-សង្កាត់ (ក្រុមប្រឹក្សាឃុំ-សង្កាត់ , PACT, CCSP, GTZ) | ឥទ្ធិពល និងការចូលរួមរបស់ប្រជាពលរដ្ឋ និងសង្គមស៊ីវិល ទៅលើការរៀបចំគោលនយោបាយ (NGO Forum, CLEC, MEDiCAM) |
| **ចំណូលសាធារណៈ** | ការផ្សព្វផ្សាយជាសាធារណៈពីការផ្ទេរហិរញ្ញវត្ថុ ទៅអោយក្រុមប្រឹក្សាឃុំ-សង្កាត់ | ឃ្លាំមើលចំណូលរដ្ឋាភិបាល (Extractive Industries Transparency International -EITI, បោះពុម្ពផ្សាយនូវអ្វីដែលអ្នកបានចំណាយ) |
| **ថវិកាសាធារណៈ** | ត្រួតពិនិត្យការគ្រប់គ្រងថវិការបស់ក្រុមប្រឹក្សាឃុំ | កម្មវិធីឃ្លាំមើលថវិកាជាតិ (NGO Forum) |

| | | |
|---|---|---|
| | -សង្កាត់ (គណៈកម្មាធិការគណនេយ្យភាពខេត្ត) | |
| **ចំណាយសាធារណៈ** | ការឃ្លាំមើលការចំណាយក្នុងមូលដ្ឋាន (ឃ្លាំមើលថវិកា*កម្មវិធីសកម្មភាពអាទិភាព* ដោយគណៈកម្មការទ្រទ្រង់សាលា) | ការតាមដានដោយឯករាជ្យលើការចំណាយ (ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ការអង្កេតតាមដានចំណាយសាធារណៈ រដ្ឋាភិបាល និងធនាគារពិភពលោក) |
| **សេវាសាធារណៈ** | ការឃ្លាំមើល និងផ្តល់យោបល់ត្រលប់ របស់ប្រជាពលរដ្ឋ ទៅលើការផ្តល់សេវាសាធារណៈនៅថ្នាក់មូលដ្ឋាន (ក្រុមអភិវឌ្ឍន៍ភូមិ) | ការចូលរួមរបស់សង្គមស៊ីវិលនៅក្នុង ក្រុមការងារបច្ចេកទេសតាមវិស័យ (ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល, Medicam, NGO Forum, គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់) |
| **ការឃ្លាំមើលសាធារណៈ** | របាយការណ៍ពីចំណាត់ថ្នាក់របស់ប្រជាពលរដ្ឋចំពោះការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ (គំរោងគាំទ្រក្រុមប្រឹក្សា ឃុំ-សង្កាត់) | ការសិក្សាពីអំពើពុករលួយ ការឃ្លាំមើលសភាជាតិ ជំនួយផ្នែកច្បាប់ដល់អ្នកដែលទទួលផលប៉ះពាល់អវិជ្ជមាន ដោយគោលនយោបាយ- សកម្មភាពរបស់រដ្ឋាភិបាល (CLEC) គំរោង "ការឃ្លាំមើលតុលាការ" (មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម) |

### ១.គ.១. ការរួមចំណែកដល់គោលនយោបាយ និងផែនការសាធារណៈ

២៨. **ការទទួលខុសត្រូវសង្គមអាចត្រូវបានលើកកំពស់ទៅថ្នាក់លើៗតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងការរៀបចំគោលនយោបាយ និងផែនការសាធារណៈ ។** សកម្មភាពបែបនេះ អាចផ្តួចផ្តើមឡើងដោយរដ្ឋាភិបាល ឬសង្គមស៊ីវិល ។ ឧទាហរណ៍ កំណែទំរង់វិមជ្ឈការនាពេលថ្មីៗនេះ និងការដែលក្រុមប្រឹក្សាឃុំ-សង្កាត់បើកទូលាយអោយមានការចូលរួមក្នុងការរៀបចំផែនការមូលដ្ឋាន បើទោះបីមិនទាន់ត្រូវបានអនុវត្តបានពេញលេញក្តី ក៏ជាឱកាសដ៏សំខាន់មួយក្នុងការជំរុញការទទួលខុសត្រូវសង្គមឡើងទៅថ្នាក់លើៗដែរ ។ អង្គការក្រៅរដ្ឋាភិបាល និងម្ចាស់ជំនួយមួយចំនួន (ដូចជា PACT, CCSP, GTZ) កំពុងដើរតួនាទីយ៉ាងសកម្មក្នុងការកសាងសមត្ថភាព និងយន្តការសំរាប់អោយមានការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋ និងអង្គការសហគមន៍ក្នុងកិច្ចការក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ឧទាហរណ៍ សូមមើលប្រអប់ទី២ សំរាប់សេចក្តីអត្ថាធិប្បាយនៃកម្មវិធីកំណែទំរង់រដ្ឋបាលមូលដ្ឋាន (LAAR)។ នៅថ្នាក់ជាតិ មានអង្គការសង្គមស៊ីវិល និងសម្ព័ន្ធភាពកាន់តែច្រើនឡើងៗ ដែលមានចេតនាជំរុញអោយមានច្បាប់ ឬគោលនយោបាយថ្មី ឬចង់មានឥទ្ធិពលទៅលើខ្លឹមសារនៃច្បាប់បែបនោះ ជាតួយ៉ាងដូចជាសម្ព័ន្ធភាពដើម្បីសេរីភាពព័ត៌មាន[១៧] CLEC, NGO Forum ហើយនៅក្នុងផ្នែកបរិស្ថានមាន អង្គការអភិរក្សអន្តរជាតិ មូលនិធិជីវិតសត្វព្រៃពិភពលោក និងសង្គមអភិរក្សពិភពលោក ។ មានឧទាហរណ៍ជាច្រើនផ្សេងទៀត ដែលក្នុងនោះអង្គការសង្គមស៊ីវិលត្រូវបានរដ្ឋាភិបាលអញ្ជើញអោយចូលរួមនៅក្នុងក្រុមការងារបច្ចេកទេស និងវេទិកាចំរុះ ដើម្បីពិភាក្សាបញ្ហាគោលនយោបាយសាធារណៈសំខាន់ៗ ។ ដោយសារចរិតលក្ខណៈនៃវេទិកាបែបនេះ ដែលមិនសូវបើកចំហពេញលេញនោះ ម្ល៉ោះហើយមានតែអង្គការសង្គមស៊ីវិលធំៗ និងដែលមានលក្ខណៈអាជីព (គាំទ្រដោយម្ចាស់ជំនួយ) ប៉ុណ្ណោះ ដែលបានចូលរួម (ដូចជា MEDiCAM, NEP, CLEC, NGO Forum)។

[១៧] រាជរដ្ឋាភិបាលកម្ពុជាពុំទាន់បានផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីព្រាងគោលនយោបាយស្តីពីការទទួលបានព័ត៌មានសាធារណៈនៅឡើយទេ ដែលកិច្ចការនេះគឺជាការសន្យាចំពោះគណៈកម្មការសំរបសំរួលរវាងរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ ។ ដំណើរការ និងបញ្ហាពាក់ព័ន្ធទៅនឹងច្បាប់ និងការអនុវត្តន៍អំពីព័ត៌មាននេះត្រូវបានពិភាក្សានៅក្នុងចំណុច ២.គ.៤។

### ប្រអប់ទី ២ : ការលើកកំពស់ភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំ-សង្កាត់ និងអង្គការសហគមន៍ - កម្មវិធីLAAR

កម្មវិធីកំណែទំរង់រដ្ឋបាលមូលដ្ឋាន (កម្មវិធី LAAR) ដែលគ្រប់គ្រងដោយអង្គការ PACT និងឧបត្ថម្ភដោយ USAID មានគោលបំណងធ្វើសកម្មភាពនៅក្នុងឃុំជាង ៣00 នៅក្នុងខេត្តចំនួន ៧ ។ កម្មវិធីនេះ ជួយពង្រឹងដល់ដំណើរការកំណែទំរង់វិមជ្ឈ-ការរបស់រដ្ឋាភិបាល តាមរយៈការកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជ្រើសតាំងឡើងតាមរយៈការបោះឆ្នោត និងជំរុញអោយមានភាពជាដៃគូប្រកបដោយលក្ខណៈស្ថាបនាជាមួយអង្គការសហគមន៍ ។ កម្មវិធីនេះមានគោលបំណងបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការអភិវឌ្ឍន៍ឃុំ-សង្កាត់ ពង្រឹងតម្លាភាព ការទទួលខុសត្រូវ និងភាពជាដៃគូរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងបង្កើនការយល់ដឹងអំពីបញ្ហាយេនឌ័រ បញ្ហាយុវជន និងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងឃុំ-សង្កាត់ ។ ជាមួយនឹងវឌ្ឍនភាពដ៏ច្រើនពីដំណើរការវិមជ្ឈការដែលសំរេចបានតាំងពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់នៅឆ្នាំ ២00២ **កម្មវិធី LAAR ទទួលស្គាល់** នូវតំរូវការអោយមានការបន្តបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ (បន្ថែមពីលើការរៀបចំផែនការឃុំ) និងបង្កើតនូវយន្តការតម្លាភាព និងការទទួលខុសត្រូវបន្ថែមទៀត អោយស្របគ្នានឹងយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល ។ កម្មវិធីនេះយល់ឃើញថាកង្វះធនធានថវិកា សមត្ថភាពបុគ្គលិកនៅមានកំរិត និងកង្វះអំណាចក្នុងការសំរេចចិត្ត គឺជាបញ្ហាប្រឈមដ៏ចំបង ។ កម្មវិធីនេះប្រើប្រាស់វិធីសាស្ត្រចំរុះ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ។ កម្មវិធីផ្តល់នូវឱកាស **កសាងសមត្ថភាព ហ្វឹកហ្វឺន និងបង្ហាត់បង្ហាញ** សំរាប់អង្គការសង្គមស៊ីវិល និងក្រុមប្រឹក្សាឃុំ ដោយផ្តោតលើការបង្កើនការចូលរួមរបស់សាធារណជនក្នុងកិច្ចការរបស់ក្រុមប្រឹក្សា និងបង្កើនតម្លាភាព និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងមូលនិធិក្រុមប្រឹក្សា ។ កម្មវិធីនេះផ្តល់**ជំនួយថវិកាអភិវឌ្ឍសង្គម** ជាគ្រឿងលើកទឹកចិត្តដល់ក្រុមប្រឹក្សា ដើម្បីពួកគេបានដាក់បញ្ចូលការវិនិយោគផ្នែកសង្គមទៅក្នុងផែនការឃុំ-សង្កាត់ ។ កម្មវិធីក៏ផ្តល់ផងដែរនូវជំនួយថវិកាម្តងទៅអោយក្រុមប្រឹក្សាឃុំ-សង្កាត់ អង្គការក្រៅរដ្ឋាភិបាល អង្គការសហគមន៍ និងបណ្តាញភូមិដែលមានភាពច្នៃប្រឌិតខ្ពស់ ដើម្បីបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ និងភាពជាដៃគូជាមួយក្រុមប្រឹក្សា ។ កម្មវិធីនេះព្យាយាមលើកកំពស់**តម្លាភាព និងការទទួលខុសត្រូវ** នៅថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់ដំណើរការនៃការ *វាយតំលៃការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់* ដែលរួមមានការអង្កេតវាយតំលៃរបស់ប្រជាពលរដ្ឋ និងស្វ័យវាយតំលៃរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។ កម្មវិធីនេះក៏គាំទ្រផងដែរនូវយន្តការដើម្បីបង្កើនលំហូរព័ត៌មាន និងកិច្ចពិភាក្សារវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល ។ យន្តការទាំងនោះរួមមាន បណ្តាញសង្គមស៊ីវិលនិងក្រុមប្រឹក្សាឃុំ វេទិកាថ្នាក់ខេត្តដែលផ្តោតលើបញ្ហាសាធារណៈ ក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការ សមាគមអន្តរឃុំ ការិយាល័យទំនាក់ទំនងអង្គការក្រៅរដ្ឋាភិបាល និងសមាគមវិមជ្ឈការថ្នាក់តំបន់ ។ កម្មវិធីក៏អនុវត្តផងដែរនូវ**យុទ្ធសាស្ត្រផ្សព្វផ្សាយ**ចំរុះ ដើម្បីលើកកំពស់ ការយល់ដឹងជុំវិញការអនុវត្តន៍ល្អបំផុតនៃភាពជាដៃគូ ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងសកម្មភាពឃុំ-សង្កាត់ សិទ្ធិរបស់ប្រជាពលរដ្ឋ និងរបស់ក្រុមប្រឹក្សា និងគំនិតផ្តួចផ្តើមគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ។

ប្រភព : *www.pactcambodia.org/Programs/Program_LAAR*

### ១.គ.២. ការឃ្លាំមើលចំណូលសាធារណៈ

២៩. ហិរញ្ញវត្ថុសាធារណៈគឺជាមធ្យោបាយដើម្បីបំលែងគោលនយោបាយ និងផែនការរបស់រដ្ឋាភិបាលអោយក្លាយទៅជាសកម្មភាព កម្មវិធី និងសេវាជាក់ស្តែង ។ ហេតុ**ដូច្នេះ ការឃ្លាំមើលរបស់ប្រជាពលរដ្ឋទៅលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាផ្នែកមួយដ៏សំខាន់នៃការទទួលខុសត្រូវសង្គម ហើយប្រហែលជាបញ្ហាប្រឈមមួយដ៏លំបាកបំផុតនៅកម្ពុជា ។** ដើម្បីអោយប្រជាពលរដ្ឋអាចត្រួតពិនិត្យតាមដាន និងឃ្លាំមើលចំណាយសាធារណៈបាន ពួកគេត្រូវមានលទ្ធភាពទទួលបានព័ត៌មានអំពីចំណូលរបស់រដ្ឋាភិបាល ។ ប៉ុន្តែព័ត៌មានអំពីចំណូលនេះភាគច្រើនត្រូវបានរដ្ឋបាលកម្ពុជាចាត់ទុកថាជាព័ត៌មានសំងាត់ បើទោះបីជាថ្មីៗនេះមានសញ្ញាណនៃការបើកចំហ និងការរីកចំរើនខ្លះក៏ដោយ (សូមមើលប្រអប់ទី២) ។ ការផ្សព្វផ្សាយជាសាធារណៈកាលពីពេលថ្មីៗនូវព័ត៌មាន អំពីការផ្ទេរថវិកាទៅអោយក្រុមប្រឹក្សាឃុំ-សង្កាត់ គឺជាជំហានវិជ្ជមានមួយឆ្ពោះទៅកាន់ការធ្វើអោយមានតម្លាភាពហិរញ្ញវត្ថុនៅថ្នាក់មូលដ្ឋាន ។ នៅថ្នាក់ជាតិ ឆន្ទៈរបស់រដ្ឋាភិបាលក្នុងការពិចារណាទទួលយកនូវគំនិតផ្តួចផ្តើមជាសកលស្តីពីតម្លា-ភាពឧស្សាហកម្មនិស្សារណកម្ម (Exractive Industries Transparency Initiative –EITI) និងកិច្ចខិតខំដូចគ្នានេះរបស់អង្គការសង្គមស៊ីវិលដើម្បីចូលរួមក្នុងយុទ្ធនាការសាកលស្តីពី**បោះពុម្ពផ្សាយនូវអ្វីដែលអ្នកចំណាយ** - ទាំងអស់នេះបង្ហាញនូវឱកាសដ៏សំខាន់ក្នុងការលើកកំពស់តម្លាភាព និងការទទួល ខុសត្រូវ ទាក់ទងទៅនឹងចំណូលពីប្រេង និងរ៉ែនាពេលអនាគត ។

### ១.គ.៣. ការចូលរួមយោបល់អំពីថវិកាសាធារណៈ

៣០. **ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងវិភាគថវិកាសាធារណៈ គឺជាប្រភេទនៃការទទួលខុសត្រូវសង្គមដ៏សំខាន់មួយទៀត ។** ការរៀបចំថវិកាដោយមានការចូលរួម គឺជាអ្វីដែលមានលក្ខណៈសាមញ្ញបំផុតនៅថ្នាក់មូលដ្ឋាន ។ នៅថ្នាក់ជាតិ រូបភាពទូទៅនៃការទទួលខុសត្រូវសង្គមដែលពាក់ព័ន្ធនឹងថវិកា គឺមានដូចជាកិច្ចខិតខំរបស់សង្គមស៊ីវិល (និងរដ្ឋាភិបាល) ក្នុងការវិភាគទៅលើផលប៉ះពាល់ និងឥទ្ធិពលនៃការបែងចែកថវិកា ដើម្បីជួយបំភ្លឺនូវខ្លឹមសារបច្ចេកទេសនៃថវិកា លើកកំពស់ការយល់ដឹងសាធារណៈអំពីបញ្ហានានាពាក់ព័ន្ធនឹងថវិកា បង្ហាញពីភាពខុសគ្នារវាងគោលនយោបាយអាទិភាពដែលរដ្ឋាភិបាលបានលើកឡើង និងការបែងចែកធនធាន ព្រមទាំងធ្វើយុទ្ធនាការអប់រំសាធារណៈដើម្បីអោយសាធារណៈជនយល់ដឹងពីបញ្ហាថវិកា ។ តែទោះជាយ៉ាងនេះក្តី សកម្មភាពទាំងនេះត្រូវបានបន្ទុចបង្អាក់ដោយបញ្ហាកង្វះនូវព័ត៌មានអំពីថវិកាសាធារណៈ ។

៣១. នៅកម្ពុជា ដោយសារកំណែទំរង់វិមជ្ឈការនៅមានភាពថ្មីថ្មោង ហើយធនធានហិរញ្ញវត្ថុសំរាប់ក្រុមប្រឹក្សាឃុំ-សង្កាត់មានចំនួនតិចតួចខ្លាំងពេក ការរៀបចំថវិកាសំរាប់មូលដ្ឋានតាមបែបចូលរួម ពុំទាន់មានឱកាសសំរាប់អភិវឌ្ឍន៍អោយល្អនៅឡើយទេ ។ "ប្រអប់គណនេយ្យភាព" ដែលបង្កើតឡើងក្នុងគោលបំណងទទួលបណ្តឹងរបស់ប្រជាពលរដ្ឋអំពីការប្រើប្រាស់ ឬការគ្រប់គ្រងថវិកាឃុំ-សង្កាត់មិនត្រឹមត្រូវនោះ គឺជាវិធានការណ៍ដែលផ្តួចផ្តើមឡើងដោយរដ្ឋាភិបាល ដើម្បីលើកកំពស់ការឃ្លាំមើលរបស់សាធារណជនទៅលើការគ្រប់គ្រងហិរញ្ញវត្ថុក្នុងមូលដ្ឋាន ។ តែទោះជាយ៉ាងនេះក្តី ដូចដែលមានពិភាក្សានៅក្នុងផ្នែកទី ២ បើគិតមកដល់ពេលបច្ចុប្បន្ននេះ យន្តការនេះមានប្រសិទ្ធិភាពតិចតួចណាស់ ។ ទាក់ទងទៅនឹងថវិកាជាតិ ការផ្តួចផ្តើមដែលគួរអោយកត់សំគាល់បំផុតគឺគំរោងឃ្លាំមើលថវិកាជាតិរបស់អង្គការ NGO Forum ដែលទើបបង្កើតឡើងថ្មីៗ ។ គំរោងនេះមានបំណងផ្តល់ព័ត៌មានដល់សាធារណជនទូទៅអំពីបញ្ហាថវិកា និងការចូលរួមយោបល់ទៅលើការរៀបចំថវិកាជាតិ (សូមមើលប្រអប់ទី៣) ។

### ១.គ.៤. ការឃ្លាំមើលចំណាយសាធារណៈ

៣២. ដូចមានរៀបរាប់ខាងលើរួចហើយ ចំណុចដ៏សំខាន់នៃការទទួលខុសត្រូវសង្គម គឺការដែលប្រជាពលរដ្ឋអាចធ្វើអោយរដ្ឋាភិបាលមានការទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិកាសាធារណៈ ។ ក្នុងឆ្នាំកន្លងទៅថ្មីៗនេះ រដ្ឋាភិបាលជាច្រើននៅជុំវិញពិភពលោក បានទទួលនូវការរួមចំណែកពីសង្គមស៊ីវិលអោយលើកកំពស់តម្លាភាពហិរញ្ញវត្ថុរបស់ពួកគេ តាមរយៈការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានអំពីគណនីនិងចំណាយ ។ កិច្ចខិតខំប្រឹងប្រែងក្នុងការតាមដានមើលចំណាយសាធារណៈ ឬត្រួតពិនិត្យការចែកចាយបរិក្ខារសាធារណៈ (ដូចជា ឱសថ ឬសៀវភៅសិក្សា) គឺជាឧទាហរណ៍នៃការអនុវត្តន៍ការទទួលខុសត្រូវសង្គម ដែលអាចយកមកអនុវត្តនៅថ្នាក់ជាតិ ដើម្បីវិភាគពីលំហូរនៃធនធានហិរញ្ញវត្ថុ (ឬធនធានរូបវ័ន្ត) ចាប់ពីពេលបែងចែករហូតដល់ទីដៅរបស់វា និងដើម្បីកំណត់រកចន្លោះប្រហោង និង/ឬឧបសគ្គណាមួយនៅក្នុងប្រព័ន្ធ ។ វិធីសាស្ត្រនេះ តែងតែពាក់ព័ន្ធនឹងការប្រៀបធៀបព័ត៌មានដែលទទួលបានពីកំណត់ត្រាដកប្រាក់ពីក្រសួងហិរញ្ញវត្ថុ គណនីដែលដាក់ស្នើដោយខ្សែបណ្តោយក្រសួង និងព័ត៌មានដែលទទួលបានពីការសំភាសន៍ដោយឯករាជ្យ (ឧទាហរណ៍. តាមរយៈការប្រើប្រាស់ឧបករណ៍មួយចំនួន ដូចជាសវនកម្មសង្គមជាដើម) ។ ព័ត៌មានត្រូវបានផ្សព្វផ្សាយ តាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ការបោះពុម្ពផ្សាយ និងជំនួបប្រជុំជាសាធារណៈ ។

៣៣. **នៅកម្ពុជា បើទោះបីជាព័ត៌មានអំពីចំណាយសាធារណៈនៅតែពិបាករកបានក៏ដោយ ក៏មានកិច្ចខិតខំប្រឹងប្រែងថ្មីៗមួយចំនួន ក្នុងការត្រួតពិនិត្យ និងតាមដានការចំណាយរបស់រាជរដ្ឋាភិបាលដែរ ។** ឧទាហរណ៍ នៅថ្នាក់មូលដ្ឋាន គណៈកម្មាធិការទ្រទ្រង់សាលាត្រូវបានផ្តល់អាណត្តិជាផ្លូវការជូនដើម្បីឃ្លាំមើលថវិកា និងចំណាយរបស់សាលារៀន(បើទោះបីតាមការអនុវត្តន៍ជាក់ស្តែង ការឃ្លាំមើលបែបនោះកំរនឹងកើតឡើងក៏ដោយ - ដូចមានពិភាក្សានៅក្នុងផ្នែកទី ២នៃរបាយការណ៍នេះ) ។ សមាជិករបស់ *ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល* ក៏ធ្លាប់ប៉ុនប៉ងត្រួតពិនិត្យការចំណាយរបស់ក្រសួងអប់រំដែរ ប៉ុន្តែពុំសូវទទួលបានជោគជ័យឡើយ ។ ការអង្កេតពីការតាមដានចំណាយសាធារណៈ (PETS) ចំនួនពីរត្រូវបានធ្វើឡើងដោយធនាគារពិភពលោកនៅកម្ពុជា ក្រោមកិច្ចសហការជាមួយរាជរដ្ឋាភិបាល (សំរាប់ការចំណាយលើវិស័យសុខាភិបាល និងអប់រំ) ប៉ុន្តែពុំសូវមានការចូលរួមពីអង្គការសង្គមស៊ីវិលឡើយ ហើយពុំសូវមានកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើអោយសាធារណៈជនទទួលបានព័ត៌មានពីការសិក្សានេះឡើយ ។ **នៅពេលអនាគត ការធ្វើ PETS គួរមានការចូលរួមអោយបានច្រើន រួចហើយផ្សព្វផ្សាយនូវរបកគំហើញជាសាធារណៈ (ដោយប្រើភាសា និងតាមរូបភាពដែលសាមញ្ញ) នោះការសិក្សាបែបនេះនឹងបានជាឧបករណ៍នៃការទទួលខុសត្រូវសង្គមមួយប្រកបដោយប្រសិទ្ធិភាព ។**

### ប្រអប់ទី ៣ : គំរោងឃ្លាំមើលថវិកាជាតិរបស់អង្គការ NGO Forum

ដោយសារសង្គមស៊ីវិលមានការព្រួយបារម្ភកាន់តែច្រើនឡើងៗអំពីការចំណាយ នូវចំណូលដែលនឹងទទួលបានពីធនធានប្រេង និងឧស្ម័ននៅពេលខាងមុខនេះ (ដែលអ្នកខ្លះរំពឹងថាចំណូលនេះនឹងមានចន្លោះពី ៥០០ ទៅ ១៥០០ លានដុល្លាអាមេរិកក្នុងមួយឆ្នាំ [១៨]) កាលពីពេលថ្មីៗនេះ NGO Forum (ដោយមានការគាំទ្រពីគំរោងថវិកាអន្តរជាតិ) បានចាប់ផ្តើមនូវគំរោងមួយដើម្បីឃ្លាំមើលការគ្រប់គ្រងថវិកាជាតិ។ *គំរោងឃ្លាំមើលថវិកាជាតិ* ខិតខំឆ្លើយតបទៅនឹងបញ្ហាកង្វះព័ត៌មាននា ពេលបច្ចុប្បន្ន ទាក់ទងនឹងថវិកា និងការចំណាយរបស់រាជរដ្ឋាភិបាល និងដើម្បីពង្រឹងសមត្ថភាពរបស់សង្គមស៊ីវិលក្នុងការចូលរួមពិភាក្សាអំពីគោលនយោបាយ និងថវិកាជាមួយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ ដើម្បីសំរេចគោលដៅនេះ NGO Forum បានចាប់ផ្តើមរៀបចំនូវកិច្ចប្រជុំជាទៀងទាត់ជាមួយបណ្តាញអភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្ម (TEDN) ដែលទើបនឹងបង្កើតឡើងថ្មីៗនេះ ដោយក្នុងនោះសមាសភាពរួមមាន អង្គការក្រៅរដ្ឋាភិបាលចំនួន ១៨ ដែលមានចំណាប់អារម្មណ៍លើបញ្ហាថវិកា។ NGO Forum ក៏ចាប់ផ្តើមបង្កើតនូវមជ្ឈមណ្ឌលធនធានឯកសារតូចមួយ និង ប្រព័ន្ធទិន្នន័យស្តីពីថវិកាជាតិ និងរៀបរៀងឯកសារពាក់ព័ន្ធដែលទទួលបានពីរដ្ឋាភិបាល ម្ចាស់ជំនួយ ស្ថាប័នសិក្សាធិការ និងសហគមន៍អង្គការក្រៅរដ្ឋាភិបាល ។ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយនឹងវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC) (ឯករាជ្យ) មានការខិតខំវិភាគថវិកាឆ្នាំ ២០០៧ ដើម្បីសិក្សាស្វែងយល់លើទិន្នាការនៃការបែងចែកថវិកាតាមវិស័យ ការគៀងគរចំណូល និង ដើម្បីបង្កើតនូវមគ្គុទេសក៍ស្តីពីថវិកាជាតិសំរាប់ប្រជាពលរដ្ឋសាមញ្ញ។ NGO Forum ក៏ចាប់ផ្តើម បង្កើតនូវទំនាក់ទំនងការងារជាមួយតួអង្គសំខាន់ៗនៅក្នុងការរៀបចំថវិកាផងដែរដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បណ្តាក្រសួងតាមវិស័យ គណៈកម្មការហិរញ្ញវត្ថុរបស់រដ្ឋសភា អគ្គសវនករ ក្រុមការងារបច្ចេកទេសផ្នែកគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ម្ចាស់ជំនួយ និងស្ថាប័នស្រាវជ្រាវ។ ការទាមទារអោយរដ្ឋាភិបាលមានតម្លាភាពផ្នែកពហិរញ្ញវត្ថុសាធារណៈ គឺជាកិច្ចការថ្មី និងពិបាកនៅក្នុងបរិបទនៃប្រទេសកម្ពុជា ហើយ NGO Forum ទទួលស្គាល់ថា វាទាមទារពេលវេលាថែមទៀត ដើម្បីឈានទៅមានពិភាក្សាពិគ្រោះយោបល់ និងការសហការប្រកបដោយអត្ថន័យ ទាក់ទងនឹងដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ លទ្ធភាពទទួលបានព័ត៌មានផ្នែកហិរញ្ញវត្ថុគឺមានដោយអន្លើ និងមិនអាចព្យាករណ៍ទុកបានឡើយ ហើយជាធម្មតា វាតំរូវអោយប្រើប្រាស់ទំនាក់ទំនងផ្ទាល់ខ្លួន ជាមួយនឹងមន្ត្រីរដ្ឋាភិបាលដែលងាយធ្វើការជាមួយ ឬទំនាក់ទំនងជាមួយនឹងម្ចាស់ជំនួយដែលមានឥទ្ធិពល ។ បញ្ហាប្រឈមចំបងមួយទៀត គឺកង្វះចំណេះដឹង និង ជំនាញសំរាប់ការងារប្រភេទនេះនៅក្នុងចំណោមសង្គមស៊ីវិលកម្ពុជា ។ ចាំបាច់ត្រូវមានការបណ្តុះបណ្តាល និងកសាងសមត្ថភាពជាប្រចាំ ដើម្បីជួយអង្គការសង្គមស៊ីវិល អោយមានការយល់ដឹងអំពីដំណើរការរៀបចំថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដើម្បីអភិវឌ្ឍន៍សមត្ថភាពរបស់ពួកគេ អោយចេះវិភាគថវិកាសាធារណៈ និងឯកសារហិរញ្ញវត្ថុសំខាន់ៗ ដទៃទៀត ។

ប្រភព : *NGO Forum ២០០៧*

[១៨] បើប្រៀបទៅនឹងថវិការបស់រដ្ឋាភិបាលប្រមាណ ៩០០ លានដុល្លា ។

### ១.គ.៥. ការកែលំអសេវាសាធារណៈ

៣៤. **ប្រភេទមួយទៀតនៃការទទួលខុសត្រូវសង្គម មានគោលបំណងលើកកំពស់ភាពពាក់ព័ន្ធ លទ្ធភាពទទួលបាន និងគុណភាពនៃសេវាសាធារណៈ ។** ជាទូទៅ ចំណុចនេះសំដៅដល់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការឃ្លាំមើល និងការវាយតំលៃទៅលើសេវាសំខាន់ៗជាអាទិភាព ។ នៅថ្នាក់ជាតិមានវិធីសាស្ត្រផ្សេងៗសំរាប់ធ្វើកិច្ចការនេះ ដូចជាការស្ទាបស្ទង់មតិសាធារណៈ សវនាការសាធារណៈ ឬប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ ដែលអាចយកមកប្រើប្រាស់ដើម្បីសុំយោបល់ត្រលប់ពីប្រជាពលរដ្ឋ ហើយយោបល់ទាំងនោះត្រូវយកមកផ្សព្វផ្សាយ និងបង្ហាញជូនចំពោះមន្ត្រីរដ្ឋាភិបាល ដើម្បីជំរុញអោយការទទួលខុសត្រូវ និងការផ្លាស់ប្តូរ ។ នៅថ្នាក់មូលដ្ឋាន មានមធ្យោបាយតាមបែបចូលរួមមួយចំនួនដែលអាចយកមកប្រើប្រាស់ (ទាំងដោយអ្នកផ្តល់សេវា និងសង្គមស៊ីវិល) ដើម្បីជួយដល់ប្រជាពលរដ្ឋអោយឃ្លាំមើល វាយតំលៃ និងស្វែងរកការទទួលខុសត្រូវ ក្នុងបំណងធ្វើអោយការផ្តល់សេវាសាធារណៈមានប្រសិទ្ធិភាព ។ ឧទាហរណ៍ ប័ណ្ណដាក់ពិន្ទុរបស់សហគមន៍ អនុញ្ញាតអោយទាំងអ្នកប្រើប្រាស់ និងអ្នកផ្តល់សេវាវាយតំលៃទៅលើសេវាសាធារណៈដោយឡែកៗពីគ្នា និងបន្ទាប់មកត្រូវចូលរួមជួបប្រជុំគ្នាដោយផ្ទាល់ ដើម្បីចែករំលែករបកគំហើញ របស់ពួកគេ ពិភាក្សាអំពីបញ្ហា និងស្វែងរកដំណោះស្រាយ ។

៣៥. នៅកម្ពុជា ក្រុមមួយចំនួនដូចជា ក្រុមអភិវឌ្ឍន៍ភូមិ (សូមមើលប្រអប់ទី៤) បានខិតខំកែលំអនូវគុណភាពនៃសេវាសាធារណៈក្នុងមូលដ្ឋាន តាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ ដូចជាតាមរយៈការបង្កើតគណៈកម្មាធិការសមាគមសុខភាពភូមិ ។ នៅថ្នាក់ជាតិ មានការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងក្រុមការងារតាមវិស័យ ដែលអាចបង្កើតជាឱកាសសំរាប់តួអង្គក្នុងសង្គមស៊ីវិល បានផ្តល់យោបល់ត្រលប់ និងលើកឡើងនូវបញ្ហាទាក់ទងទៅនឹងសេវាជាអាទិភាព ។ ឧទាហរណ៍ តាមរយៈការចូលរួមនៅក្នុងក្រុមការងារផ្នែកអប់រំ បណ្តាញភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល និងសមាជិកបណ្តាញ មានឱកាសលើកឡើងនូវបញ្ហាដែលពាក់ព័ន្ធទៅនឹងការផ្តល់ធនធានPAP (កម្មវិធីសកម្មភាពអាទិភាព) យឺតយ៉ាវទៅដល់សាលារៀននៅទីជនបទ ប្រាក់ខែគ្រូបង្រៀនតិចតួច និងការលក់សៀវភៅសិក្សា (ដែលតំរូវសំរាប់ការចែកចាយដល់សាលារៀននៅទីជនបទ) ។ ជាអកុសល រហូតមកដល់ពេលនេះ ការចូលរួមបែបនេះបានត្រឹមនាំមកនូវវិធានការណ៍កែតំរូវម្តងម្កាលប៉ុណ្ណោះ ។

### ប្រអប់ទី ៤ : សមាគមសុខភាពភូមិ - ក្រុមអភិវឌ្ឍន៍ភូមិ (KAP)

ក្រុមអភិវឌ្ឍន៍ភូមិ គឺជាអង្គការក្រៅរដ្ឋាភិបាល ដែលផ្តោតលើការងារអភិវឌ្ឍន៍សហគមន៍ និងកាត់បន្ថយភាពក្រីក្រ ។ អង្គការនេះមានមូលដ្ឋាននៅក្នុងខេត្តបាត់ដំបង ។ ប្រជាពលរដ្ឋក្រីក្រតាមតំបន់ជនបទ ដែលក្រុមអភិវឌ្ឍន៍ភូមិធ្វើការជាមួយ បានចាត់ទុកថាបញ្ហាផ្នែកសុខភាព គឺជាបញ្ហាអាទិភាពរបស់ពួកគេ ។ ដើម្បីឆ្លើយតបទៅនឹងតំរូវការដែលបានលើកឡើងនេះ ក្រុមអភិវឌ្ឍន៍ភូមិបានផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសតាំងពីឆ្នាំ២០០៥ មក ដើម្បីជួយអ្នកភូមិអោយបង្កើតនូវ "សមាគមសុខភាពភូមិ" ជាមធ្យោបាយដើម្បីអោយពួកគេអាចមានលទ្ធភាពប្រើប្រាស់សេវាថែទាំសុខភាពសាធារណៈដោយចំណាយតិច ឬមិនចាំបាច់ចំណាយថវិកាតែម្តង ។ សមាជិករបស់ សមាគមសុខភាពភូមិទាំងនេះដែលសព្វថ្ងៃកំពុងមានដំណើរការនៅក្នុងភូមិចំនួន ៣៧ នៃឃុំចំនួន ១៤ ក្នុងខេត្តបាត់ដំបង បាននិយាយថា ពួកគេទទួលបានព័តិមានកាន់តែច្រើន និងមានភាពអង់អាចច្រើនជាងមុន ដូច្នេះពួកគេអាចចរចាអំពីការប្រើប្រាស់សេវាសុខភាពសាធា-រណៈកាន់តែប្រសើរជាងមុន ។ ក្រុមអភិវឌ្ឍន៍ភូមិផ្តល់តែការណែនាំផ្នែកបច្ចេកទេសប៉ុណ្ណោះ ។ អ្នកភូមិខ្លួនឯងគឺជាអ្នកកំណត់តំរូវការជាអាទិភាព គៀងគរប្រជាពលរដ្ឋអោយបង្កើតជាសមាគម បោះឆ្នោតជ្រើសរើសគណៈកម្មាធិការរបស់សមាគម និងបង្កើតបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈដោយខ្លួនឯង ។ នៅពេលបង្កើតរួចហើយ សមាគមទាំងនោះមានឱកាសចូលរួមក្នុងទស្សនៈកិច្ចសិក្សាទៅកាន់មន្ទីរពេទ្យស្រុក និងខេត្ត និងជួបជាមួយប្រធានមន្ទីរពេទ្យ និងអ្នកផ្តល់សេវាកម្ម ។ ទស្សនៈកិច្ចដែលរៀបចំដោយក្រុមអភិវឌ្ឍន៍ភូមិនេះ មានគោលបំណងជួយសមាគមអោយកាន់តែយល់ដឹងអំពីសេវាសុខភាព និងបទបញ្ញានានា និងដើម្បីអោយគេប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយនឹងអ្នកផ្តល់សេវាថែទាំងសុខភាព និងអ្នកគ្រប់គ្រងដែលពាក់ព័ន្ធ ។ អ្នកតំណាងដែលចូលរួមក្នុងទស្សនៈកិច្ចសិក្សានេះមានភារកិច្ចរាយការណ៍ និងចែករំលែកព័តិមានទាំងអស់ទៅសមាជិកដទៃទៀតរបស់សមាគម ។ សមាគមធ្វើការងារជាមួយមន្ទីរពេទ្យដើម្បីបង្កើតកិច្ចព្រមព្រៀងផ្តល់សេវាសុខភាពដោយគិតថ្លៃទាប ឬមិនគិតថ្លៃ ទៅអោយសមាជិករបស់សមាគមណាដែលក្រីក្រខ្លាំង និងគ្មានលទ្ធភាពចំណាយ ។ ដើម្បីសំគាល់នូវអត្តសញ្ញាណ និងការទទួលខុសត្រូវ សមាជិកម្នាក់ៗរបស់សមាគមត្រូវបានជូននូវផ្តល់ប័ណ្ណសំគាល់ខ្លួនមួយ ហើយបុគ្គលិកមន្ទីរពេទ្យព្រមព្រៀងពាក់ផ្លាកឈ្មោះរបស់ខ្លួននៅពេលដែលពួកគេកំពុងបំពេញការងារ ។ ប្រសិនបើបុគ្គលិកមន្ទីរពេទ្យមិនអនុវត្តតាមលក្ខខ័ណ្ឌនៅក្នុងកិច្ចព្រមព្រៀង ឬផ្តល់សេវាមិនបានល្អ សមាជិករបស់សមាគមអាចកត់ឈ្មោះបុគ្គលិករូបនោះ ហើយរាយការណ៍នៅពេលក្រោយ ។ រៀងរាល់មួយខែម្តង ឬពីរខែដង ក្រុមអភិវឌ្ឍន៍ភូមិរៀបចំកិច្ចប្រជុំជាមួយនឹងសមាគមដើម្បីប្រមូលព័តិមានត្រលប់ពីអ្នកប្រើប្រាស់សេវាសុខភាព បន្ទាប់មកក្រុមអភិវឌ្ឍន៍ភូមិប្រើប្រាស់ព័តិមានទាំងនេះដើម្បីចរចារអោយមានការកែលំអសេវាសុខភាពបន្ថែមទៀត សំរាប់សមាជិករបស់សមាគម ។

*ប្រភព : CAS/WB, ២០០៧b*

### ១.គ.៦. ការត្រួតពិនិត្យវិស័យសាធារណៈ

៣៦. **ប្រភេទចុងក្រោយនៃការទទួលខុសត្រូវសង្គម គឺសំដៅដល់ការអនុវត្តន៍ទាំងឡាយណាដែលមានគោលបំណងធ្វើអោយប្រសើរដល់ការឃ្លាំមើលលើវិស័យសាធារណៈ ឬការលើកកំពស់ប្រសិទ្ធិភាពនៃយន្តការឃ្លាំមើលបែបធម្មតា ។** គ្រប់រដ្ឋាភិបាលទាំងអស់តែងមានយន្តការផ្ទៃក្នុងតាមទំរង់ផ្សេងៗដើម្បីលើកកំពស់ ឬធានាការទទួលខុសត្រូវរបស់មន្ត្រីសាធារណៈ ។ យន្តការទាំងនោះរួមមាន (១) យន្តការនយោបាយ (ឧទាហរណ៍ : ឧបសគ្គនៃរដ្ឋធម្មនុញ្ញ ការបែងចែកអំណាច អង្គនីតិបញ្ញត្តិ) (២) យន្តការសារពើពន្ធ (ដូចជា ប្រព័ន្ធសវនកម្មផ្លូវការ និងគណនេយ្យហិរញ្ញវត្ថុ) (៣) យន្តការរដ្ឋបាល (ឧទាហរណ៍ តំរូវការអោយមានការរាយការណ៍តាមឋានានុក្រម បទដ្ឋាននៃភាពស្មោះត្រង់ក្នុងវិស័យសាធារណៈ ក្រមសីលធម៌នៃការផ្តល់សេវាសាធារណៈ វិធាន និងនីតិវិធីអំពីតម្លាភាព និងការឃ្លាំមើលសាធារណៈ) និង (៤) យន្តការច្បាប់ (ឧទាហរណ៍ : ភ្នាក់ងារប្រឆាំងអំពើពុករលួយ ការិយាល័យប្រជាពលរដ្ឋ និងតុលាការ) (Goetz and Gaventa, 2001) ។ **ដូចមានពិភាក្សាពីខាងដើមរួចហើយ ក្នុងករណីប្រទេសកម្ពុជា យន្តការផ្ទៃក្នុងសំរាប់ការទទួលខុសត្រូវគឺមានរួចជាស្រេច ប៉ុន្តែប្រសិទ្ធិភាពនៃយន្តការទាំងនោះត្រូវបានកំរិតដោយកត្តាមួយចំនួន**រួមមាន រចនាសម្ព័ន្ធគ្រប់គ្រងបែបចៅហ្វាយនាយ-កូនចៅ ភាពលប់លើរបស់អង្គប្រតិបត្តិ និងសមត្ថភាពទន់ខ្សោយរបស់រដ្ឋសភា និងតុលាការ ព្រមទាំងកង្វះព័ត៌មានអំពីរដ្ឋាភិបាលសំរាប់សាធារណៈជន ។ សង្គមស៊ីវិលបានខិតខំដោះស្រាយបញ្ហាទាំងនេះ ។ ឧទាហរណ៍ : មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម បានធ្វើការត្រួតពិនិត្យសភា ផ្តួចផ្តើមអោយមានកម្មវិធី "ឃ្លាំមើលតុលាការ" និងផ្សព្វផ្សាយលទ្ធផលសិក្សាអំពីអំពើពុករលួយជាសាធារណៈ ។ នៅថ្នាក់មូលដ្ឋាន កម្មវិធីគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ បានប្រើប្រាស់នូវកម្មវិធី *ការធ្វើចំណាត់ថ្នាក់ដោយប្រជាពលរដ្ឋ* ដើម្បីត្រួតពិនិត្យ និងវាយតំលៃការអនុវត្តន៍ការងាររបស់អាជ្ញាធររដ្ឋាភិបាលក្នុងមូលដ្ឋាន ។

៣៧. ទំហំ និងចំនួននៃគំនិតផ្តួចផ្តើមទទួលខុសត្រូវសង្គមនៅកម្ពុជានៅមានកំរិតទាបនៅឡើយ ប៉ុន្តែការដកពិសោធន៍នាពេលបច្ចុប្បន្នរួមជាមួយនឹងដំណើរការនៃវិមជ្ឈការ និងវិសហមជ្ឈការដូចដែលមានសព្វថ្ងៃ បានបង្ហាញពីសក្តានុពលល្អសំរាប់ពេលអនាគត ។ **រហូតមកដល់បច្ចុប្បន្ននេះ ឥទ្ធិពលនៃគំនិតផ្តួចផ្តើមផ្នែកទទួលខុសត្រូវសង្គមនៅមានកំរិតទាបនៅឡើយ ហើយពុំទាន់បានរួមចំណែកដល់ការកែលំអសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅឡើយទេ ។** ផ្នែកខាងក្រោមៗនៃរបាយការណ៍នេះនឹងវិភាគពីកត្តាសំខាន់ៗដែលមានឥទ្ធិពលទៅលើការទទួលខុសត្រូវសង្គម ហើយដោយសារវិធីសាស្ត្រនៃការទទួលខុសត្រូវសង្គមមានសក្តានុពលដ៏ធំធេងចំពោះអភិបាលកិច្ចល្អនៅកម្ពុជា ផ្នែកខាងក្រោមៗនៃរបាយការណ៍ក៏បានដាក់ស្នើជាអនុសាសន៍ សំរាប់ជំនះឧបសគ្គនានា និងច្បាមយកឱកាសដែលមានស្រាប់ ។

# ២. ការវិភាគទៅលើលក្ខខ័ណ្ឌ និងសមត្ថភាពដើម្បីការទទួលខុសត្រូវសង្គមនៅកម្ពុជា

## ២.ក. អំពីព័ត៌មាន

៣៨. កត្តាអំណោយផលដ៏សំខាន់មួយសំរាប់ការទទួលខុសត្រូវសង្គម គឺការដែលប្រជាពលរដ្ឋមាននូវ *ព័ត៌មានសាធារណៈ* ដែលត្រឹមត្រូវ និងពាក់ព័ន្ធដល់ពួកគេ ។ កាលបើប្រជាពលរដ្ឋពុំមានលទ្ធភាពទទួលបាន ឬបង្កើតព័ត៌មានអំពីគោលនយោបាយ និងនីតិវិធី គំរោងថវិកា ការចំណាយ កម្មវិធីនិងសេវាសាធារណៈទេ នោះពួកគេពុំមានគំនិតយោបល់សំរាប់ចូលរួមក្នុងការពិភាក្សាជាសាធារណៈ ឬឃ្លាំមើលសកម្មភាពរបស់រដ្ឋាភិបាល ឬចរចារជាមួយមន្ត្រីសាធារណៈអោយមានប្រសិទ្ធិភាពណាស់ ។ បទពិសោធន៏ជាទូទៅបង្ហាញថា បើទោះបីនៅគ្រាដំបូងរដ្ឋាភិបាលតែងមានភាពស្ទាក់ស្ទើរក្នុងការចែករំលែកព័ត៌មានក៏ដោយ ក៏ទីបំផុតភាពជឿជាក់ និងទំនុកចិត្តពីសាធារណៈដែលទទួលបានពីការចែករំលែកព័ត៌មាន បានធ្វើអោយរដ្ឋាភិបាលស្ងប់ចិត្តដោយសារតែអត្ថប្រយោជន៏នៃតម្លាភាពបែបនោះ ។

៣៩. ទាក់ទងនឹងបញ្ហាព័ត៌មានសំរាប់ប្រជាពលរដ្ឋ ការស្រាវជ្រាវនេះបានរកឃើញទាំងឱកាស និងបញ្ហាប្រឈមសំខាន់ៗមួយចំនួននៅក្នុងបរិបទកម្ពុជា ។ ឱកាសសំខាន់ៗរួមមាន (ក) **ការផ្សាយនៃវិទ្យុ និងទូរទស្សន៏ដែលគ្របដណ្តប់នូវវិសាលភាពធំទូលាយ** ហើយ និង (ខ) ប្រការដែល**ប្រជាពលរដ្ឋបានបង្ហាញពីការចាប់អារម្មណ៏របស់គេចំពោះព័ត៌មានសាធារណៈ** (ជាពិសេសព័ត៌មានស្តីពីបញ្ហានៅមូលដ្ឋាន ដែលផលប៉ះពាល់ផ្ទាល់ដល់សុខុមាលភាពរូបវ័ន្តរបស់ពួកគេ) ។) ក្រៅពីនេះប្រជាពលរដ្ឋក៏គិតថា **វាជាការសំខាន់ណាស់ដែលពួកគេគួរទទួលបានព័ត៌មាន** ។ កត្តាប្រឈមចំបងៗរួមមាន (គ) **ប្រជាពលរដ្ឋពុំសូវយល់ដឹងអំពីសិទ្ធិក្នុងការទទួលព័ត៌មាន និងភាពស្ទាក់ស្ទើរក្នុងការស្នើសុំព័ត៌មានដែល"រសើប" (កុំថាឡើយដល់ទៅទាមទារ)** និង (ឃ) **គ្មាន"វប្បធម៌ ឬទំលាប់"នៃតម្លាភាព និងការចែករំលែកព័ត៌មាន**នៅគ្រប់កំរិតថ្នាក់នៃរដ្ឋាភិបាល ដែលទាំងនេះបណ្តាលអោយ (ង) **ប្រជាពលរដ្ឋទូទៅមានព័ត៌មាន និងចំណេះដឹងតិចតួចអំពីបញ្ហាក្នុងវិស័យសាធារណៈ ។** (ច) **ឯតួនាទីរបស់អង្គការសង្គមស៊ីវិលផ្នែកព័ត៌មានសាធារណៈ (ការទទួលបាន ផ្សព្វផ្សាយ និងទាមទាររក)ដែលមានភាពទន់ខ្សោយនោះ** អាចជាបញ្ហាប្រឈមផង និងជាឱកាសផង ។

### ២.ក.១. ប្រភពនៃព័ត៌មានសាធារណៈ

៤០. **វិទ្យុ និងទូរទស្សន៏ មានការផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងជាប្រភពនៃព័ត៌មានសាធារណៈដ៏សំខាន់បំផុតនៅក្នុងប្រទេសកម្ពុជា សូម្បីសំរាប់ប្រជាជនដែលក្រីក្រខ្លាំងក៏ដោយ ។** ដូចដែលបង្ហាញជូននៅក្នុងរូបភាពទី២[១៨] រួចហើយ ការស្ទាបស្ទង់មតិសាធារណៈបង្ហាញថាវិទ្យុ និងទូរទស្សន៏ គឺជាប្រភពនៃព័ត៌មានសាធារណៈដ៏ចំបងនៅក្នុងប្រទេសកម្ពុជា ហើយបន្ទាប់មកគឺប្រធានភូមិ និងមេឃុំ ។ ចំណុចនេះឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីចំណង់ចំណូលចិត្តចំពោះការផ្សព្វផ្សាយតាមផ្ទាល់មាត់ (ជាជាងតាមរយៈសំណេរ

[១៨] តួលេខទាំងអស់ដែលបង្ហាញជូននៅក្នុងរបាយការណ៍នេះ គឺផ្អែកលើរបកគំហើញពីការស្ទាបស្ទង់មតិសាធារណៈ និងការអង្កេតជាមួយអង្គការក្រៅរដ្ឋាភិបាលដែលធ្វើឡើងដោយ CAS ។

ជាលាយល័ក្ខអក្សរ) ហើយប្រការនេះក៏ស្របគ្នានឹងការសំភាសន៍ និងការពិភាក្សាជាក្រុមផងដែរ [១៩] ។ ការសិក្សាស្រាវជ្រាវនេះបានរកឃើញនូវភាពខុសគ្នាគួរអោយកត់សំគាល់ រវាងពីក្រុមប្រជាសាស្ត្រមួយទៅក្រុមមួយទៀត ។ ឧទាហរណ៍ ប្រជាពលរដ្ឋវ័យក្មេងៗ និងអ្នកដែលរស់នៅតំបន់ទីក្រុង (អ្នកដែលមានកំរិតវប្បធម៌ខ្ពស់ជាង) ច្រើនតែគិតថា កាសែតគឺជាប្រភពនៃព័ត៌មានរបស់ពួកគេ ។ ដូចដែលមានបង្ហាញក្នុងរូបភាពទី៣រួចហើយ ផ្ទុយពីអ្នកដែលមានធនធានច្រើន អ្នកដែលគិតថាខ្លួនជាអ្នក "ក្រីក្រខ្លាំង" ច្រើនតែទទួលបានព័ត៌មានពីញាតិសន្តាន មិត្តភក្តិ ឬអ្នកជិតខាង ជាជាងការទៅរកប្រធានភូមិ ឬមេឃុំ ដែលប្រការនេះបង្ហាញថាពួកគេពុំសូវមានទំនាក់ទំនងជាមួយ ហើយពុំសូវមានភាពកក់ក្តៅក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដឹកនាំ និង"អ្នកកាន់អំណាច"នៅថ្នាក់មូលដ្ឋានទេ ។ តែទោះជាយ៉ាងណាក្តី អ្វីដែលគួរអោយកត់សំគាល់បំផុតនោះគឺថា សូម្បីក្នុងចំណោមអ្នកដែល "ក្រីក្រខ្លាំង" ក៏ដោយ ក៏ពួកគេភាគច្រើនទទួលបានព័ត៌មានពីវិទ្យុ និងទូរទស្សន៍ដែរ ដែលប្រការនេះអាចអោយយើងសន្និដ្ឋានបានថា ប្រព័ន្ធផ្សព្វផ្សាយទាំងពីរនេះមានសក្តានុពលយ៉ាងធំធេងសំរាប់ការផ្សព្វផ្សាយនូវព័ត៌មានសាធារណៈដែលពាក់ព័ន្ធ ។ បញ្ហា និងភាពទន់ខ្សោយមួយចំនួន ដែលបច្ចុប្បន្នកំពុងបង្កការរាំងស្ទះដល់ប្រសិទ្ធិភាពនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅកម្ពុជា ត្រូវបានពិភាក្សានៅក្នុងចំណុច ២.ខ.៤.។

**រូបភាពទី២ : ប្រភពសំខាន់ៗនៃព័ត៌មានសាធារណៈ**




ប្រភព : CAS/WB, 2007

[១៩] ជាឧទាហរណ៍ បើទោះបីជាក្តារព័ត៌មានត្រូវបានដាក់នៅក្បែរផ្សារ ដោយមានបង្ហាញអំពីឈ្មោះ និងលេខទូរស័ព្ទរបស់សមាជិកនៃគណៈកម្មការគណនេយ្យភាពខេត្ត ឬអំពីតំលៃផ្លូវការនៃសេវាសាធារណៈក៏ដោយ ក៏ប្រជាជនភាគច្រើនពុំយកចិត្តទុកដាក់ចំពោះព័ត៌មានទាំងនោះឡើយ ។ ក្នុងពេលចុះស្រាវជ្រាវផ្ទាល់នៅមូលដ្ឋាន នៅពេលដែលក្រុមស្រាវជ្រាវសាកសួរអំពីខ្លឹមសារនៅក្នុងក្តារព័ត៌មាន ស្ទើរតែពុំមាននរណាម្នាក់អាចរៀបរាប់ (ឬចាប់អារម្មណ៍) អំពីខ្លឹមសារដែលមាននៅលើក្តារព័ត៌មានឡើយ ហើយនៅពេលដែលសួរថា តើពួកគេអាចរកព័ត៌មានអំពីតំលៃឈ្នួលផ្លូវការសំរាប់សេវាសាធារណៈនៅឯណានោះ មានតែ១៤%នៃអ្នកឆ្លើយសំណួរក្នុងការស្ទាបស្ទង់មតិសាធារណៈប៉ុណ្ណោះ ដែលបានលើកឡើងអំពីក្តារព័ត៌មានរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ខណៈដែល ៥៤%ឆ្លើយថាប្រធានភូមិ និង៤៤%ឆ្លើយថាមេឃុំ ។ នេះពុំមែនមានន័យថា មិនគួរបន្តប្រើប្រាស់ក្តារព័ត៌មាននោះទេ ប៉ុន្តែការផ្សព្វផ្សាយព័ត៌មានអោយប្រជាពលរដ្ឋបានឃើញជាសាធារណៈនាំអោយមានឥទ្ធិពលវិជ្ជមាន បើទោះបីជាប្រជាពលរដ្ឋកំរនឹងអានព័ត៌មានទាំងនោះក៏ដោយ ។ ព័ត៌មានដែលមានបិតផ្សាយនៅលើក្តារសាធារណៈនោះ ក៏គួរយកមកផ្សព្វផ្សាយតាមវិទ្យុផងដែរ រួមជាមួយនឹងការពន្យល់អំពីគោលបំណង និងទីតាំងនៃក្តារព័ត៌មានផងដែរ ។

**រូបភាពទី៣ ៖ ប្រភពសំខាន់ៗនៃព័ត៌មានសាធារណៈសំរាប់ប្រជាពលរដ្ឋដែល "ក្រីក្រខ្លាំង"**




ប្រភព ៖ CAS/WB, 2007

## ២.ក.២. ចំណាប់អារម្មណ៍ជាអាទិភាពរបស់ប្រជាពលរដ្ឋ

៤១. **ប្រជាពលរដ្ឋយល់ថា វាជាការសំខាន់ដែលពួកគេទទួលបានព័ត៌មាន ហើយបានបង្ហាញពីចំណាប់អារម្មណ៏របស់គេ ក្នុងការទទួលបានព័ត៌មានសាធារណៈ ជាពិសេសព័ត៌មានអំពីបញ្ហានៅមូលដ្ឋានដែលប៉ះពាល់ដោយផ្ទាល់ដល់សុខុមាលភាពរូបវ័ន្តរបស់ពួកគេ ។** ការស្រាវជ្រាវនេះបានរកឃើញថាប្រជាពលរដ្ឋដ៏ច្រើនលើសលប់មានអារម្មណ៏ថា វាជាការសំខាន់ណាស់ក្នុងការទទួលបានព័ត៌មានអំពីបញ្ហា និងកិច្ចការសាធារណៈ ។ ឧទាហរណ៏ យោងតាមការស្ទាបស្ទង់មតិសាធារណៈ ប្រជាពលរដ្ឋប្រមាណ ៩៤% គិតថាសំខាន់ (សំខាន់ខ្លាំង ឬបង្គួរ) ក្នុងការដែលពួកគេត្រូវបានផ្តល់ជូននូវព័ត៌មានអំពីច្បាប់នានារបស់កម្ពុជា ។ ការស្ទាបស្ទង់មតិសាធារណៈ ក៏ដូចជាការពិភាក្សាតាមក្រុម និងកិច្ចសំភាសន៏ស៊ីជំរៅដែរ បានបង្ហាញអំពីចំណាប់អារម្មណ៏យ៉ាងជ្រាលជ្រៅរបស់ប្រជាពលរដ្ឋ ក្នុងការចង់ដឹងចង់លឺពីបញ្ហាសាធារណៈ ជាពិសេសបញ្ហាដែលពាក់ព័ន្ធផ្ទាល់ទៅនឹងសេចក្តីត្រូវការជាក់ស្តែង និងចំណាប់អារម្មណ៏របស់ពួកគេ ។ នៅពេលដែលសួរអំពីប្រភេទព័ត៌មានដែលពួកគេចាប់អារម្មណ៏ជាងគេបំផុត អ្នកឆ្លើយតបភាគច្រើនលើសលប់បានលើកឡើងអំពីបញ្ហាសន្តិសុខសាធារណៈ (៧៥,៣%) បន្ទាប់មកគឺព័ត៌មានអំពីបញ្ហាសុខភាព (៧១,៧%) ចំណេះដឹងពាក់ព័ន្ធទៅនឹងរបរចិញ្ចឹមជីវិត ដូចជាបច្ចេកទេសកសិកម្ម (៥៤,៧%) បញ្ហាសហគមន៏ (៤៩,២%) និង សកម្មភាពរដ្ឋាភិបាល (៤៨,១%) សូមមើលរូបភាពទី៤ ។ មានភាពខុសប្លែកគ្នាខ្លះទៅតាមភេទ ដោយបុរសសំដែងនូវចំណាប់អារម្មណ៏ច្រើនជាងទៅលើបញ្ហាសន្តិសុខសាធារណៈនិងសកម្មភាពរបស់រដ្ឋាភិបាល ហើយស្ត្រីផ្តោតអាទិភាពខ្ពស់ទៅលើបញ្ហាសុខភាព [២០] ។

[២០] ការបារម្ភដ៏ចំបងរបស់ពួកគេអំពីបញ្ហាសុវត្ថិភាព និង សន្តិសុខសាធារណៈនេះ គឺត្រូវបានអ្នកសង្កេតការណ៏មួយខ្លះអះអាងថាគឺដោយសារស្លាកស្នាមឈឺចាប់បន្ទាប់ពីសង្គ្រាម ការបន្តព្រួយបារម្ភអំពីស្ថេរភាពនយោបាយ និងការភ័យខ្លាចចំពោះការវិលត្រលប់មកវិញនៃអំពើហិង្សា ។

**រូបភាពទី៤ : ចំណាប់អារម្មណ៍ជាអាទិភាពរបស់ប្រជាពលរដ្ឋទាក់ទងទៅនឹងព័ត៌មានសាធារណៈ**




ប្រភព : CAS/WB, 2007

### ២.ក.៣. កង្វះការទាមទាររកព័ត៌មាន

៤២. បើទោះបីជាប្រជាពលរដ្ឋមានចំណាប់អារម្មណ៍ និងអោយតំលៃទៅលើព័ត៌មានសាធារណៈយ៉ាងណាក្តី **ការទាមទាររបស់ពួកគេរកព័ត៌មានសាធារណៈ គឺនៅមានកំរិតតិចតួចនៅឡើយ ដោយសារកង្វះការយល់ដឹងអំពីសិទ្ធិក្នុងការទទួលបានព័ត៌មាន ភាពស្ទាក់ស្ទើរក្នុងការស្នើសុំព័ត៌មានដែលមានលក្ខណៈ "រសើប" និងការយល់ដឹងតិចតួចអំពីវិធីស្វែងរក ឬវិធីប្រើប្រាស់ព័ត៌មានដើម្បីធ្វើអោយមានការផ្លាស់ប្តូរ** ។ ការពិភាក្សាតាមក្រុម និងការសំភាសន៍ផ្ទាល់ បានបង្ហាញអោយដឹងថាប្រជាពលរដ្ឋ (និងអង្គការសង្គមស៊ីវិល) មានការយល់ដឹងតិចតួច អំពីសិទ្ធិក្នុងការទទួលព័ត៌មាន (ដូចជាអំពីកាតព្វកិច្ចរបស់អាជ្ញាធរក្នុងការផ្តល់ព័ត៌មានក្នុងលក្ខណៈជាប្រព័ន្ធដល់សាធារណជន) ។ ការសិក្សាស្រាវជ្រាវនេះបានរកឃើញនូវការយល់ឃើញដូចៗគ្នា ជាពិសេសនៅថ្នាក់សហគមន៍ ថាបញ្ហាអភិបាលកិច្ចពុំមែនជារឿងដែលប្រជាពលរដ្ឋសាមញ្ញត្រូវព្រួយបារម្ភឡើយ ហើយថាបញ្ហាអភិបាលកិច្ច និងភាពអន់ខ្សោយក្នុងការផ្តល់សេវាសាធារណៈនេះ អាចត្រូវបានដោះស្រាយដោយថ្នាក់លើតែប៉ុណ្ណោះ ។ ដោយសារបទដ្ឋានជាប្រពៃណីដែលគេត្រូវផ្តល់ការគោរពចំពោះអាជ្ញាធរ ជាទូទៅប្រជាពលរដ្ឋពុំហ៊ានសួរអាជ្ញាធររកព័ត៌មានឡើយ ជាពិសេសព័ត៌មានដែលពាក់ព័ន្ធទៅនឹងថវិកា ឬចំណាយសាធារណៈ ដែលគេយល់ថាព័ត៌មាន "រសើប" ។ ការស្វែងរកព័ត៌មានបែបនេះត្រូវបានគេយល់ឃើញថាជាការជ្រៀតជ្រែកការងាររបស់អាជ្ញាធរ ហើយប្រជាពលរដ្ឋក៏យល់ឃើញថា វាពុំមែនជាតួនាទី ឬសិទ្ធិរបស់ពួកគេឡើយក្នុងការជំរុញអោយអាជ្ញាធរទទួលខុសត្រូវនោះ ។

៤៣. **ឥរិយាបថបែបបិតុនិយម និងទំនាក់ទំនងនៃអំណាចជាលក្ខណៈបុគ្គលដ៏មុតមាំ (ដូចមានពិភាក្សានៅក្នុងផ្នែកទី ១) និងការមិនផ្តល់អំណាចដល់ប្រជាពលរដ្ឋ (ដូចមានពិភាក្សានៅក្នុងជំពូក ២.ខ.២) ក៏ជាចំណែកមួយធ្វើអោយប្រជាពលរដ្ឋមានការស្ទាក់ស្ទើរក្នុងការទាមទាររកព័ត៌មានដែរ** ។ ការស្រាវជ្រាវដែលត្រូវបានធ្វើឡើងនៅក្នុងខេត្តចំនួន ៤ បានរកឃើញថា (ដោយសារការប្រាស្រ័យទាក់ទងមានលក្ខណៈបុគ្គលច្រើនហួសហេតុជាងលក្ខណៈជាស្ថាប័ននោះ ប្រជាពលរដ្ឋមានភាពស្ទាក់ស្ទើរក្នុងការប្រថុយប្រថានបង្កអោយប៉ះទង្គិចដល់ទំនាក់ទំនងរបស់ពួកគេជាមួយអ្នកដែលមានឥទ្ធិពលក្នុងសហគមន៍ (ដូចជាប្រធានភូមិ ក្រុមប្រឹក្សា

ឃុំ-សង្កាត់ និងមន្ត្រីដទៃទៀតក្នុងមូលដ្ឋាន) ដោយការសួរសំណួរដែលពុំសូវសមរម្យ ឬស្វែងរកព័ត៌មានដែលមានលក្ខណៈរសើប ដូចជាព័ត៌មានអំពីការគ្រប់គ្រងហិរញ្ញវត្ថុជាដើម ។ គោលគំនិតដែលប្រៀបទំនាក់ទំនងរវាងអាជ្ញាធរ និងប្រជាពលរដ្ឋ ទៅនឹងទំនាក់ទំនងរវាងឪពុកម្តាយនិងកូនចៅនោះ (ដូចមានពិភាក្សានៅក្នុងផ្នែកទី ១) បានពង្រឹងដល់ផ្នត់គំនិតនៃការស្តាប់បង្គាប់ និងផ្តេកផ្តួលទៅលើអាជ្ញាធរ ហើយក្នុងពេលជាមួយគ្នានោះ ប្រជាពលរដ្ឋភាគច្រើនគិតថាខ្លួនឯងគ្មានលទ្ធភាព ឬសិទ្ធិបន្តិចបន្តួច ឬគ្មានទាល់តែសោះក្នុងការទាមទារព័ត៌មានឡើយ ។ ជាញឹកញាប់ កិច្ចសំភាសន៍តែងបង្ហាញអោយឃើញថា ប្រជាពលរដ្ឋមិនមានភាពច្បាស់លាស់សោះក្នុងការសួរ ឬសូម្បីស្នើសុំព័ត៌មានពីអាជ្ញាធរ ព្រោះខ្លាចអាជ្ញាធរយល់ឃើញថាការស្នើសុំបែបនេះ គឺជាការមិនទុកចិត្ត និងបង្កអោយមានការខឹងសម្បារ បំបាក់មុខមាត់ ឬឥទ្ធិពលអវិជ្ជមានណាមួយ ។ ជាឧទាហរណ៍ សមាជិកម្នាក់នៃគណៈកម្មការទ្រទ្រង់សាលារៀននៅក្នុងខេត្តកំពង់ធំ *(ស្រុកស្ទោង)* បានពន្យល់ថា គាត់ពុំហ៊ានសួរនាយកសាលាអំពីការចំណាយក្នុងសាលារៀននោះទេ ដោយសារគាត់ខ្លាចធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងរវាងគាត់ និងនាយកសាលា និងបង្កបញ្ហាដល់ខ្លួនគាត់ ជាពិសេសគឺចំពោះកូនៗរបស់គាត់ដែលទៅរៀននៅឯសាលានោះតែម្តង ។

៤៤. **ការទាមទារ និងការចែករំលែកព័ត៌មានសាធារណៈដូចជា ព័ត៌មានអំពីគោលនយោបាយ ផែនការ និងថវិការបស់រដ្ឋាភិបាល ក៏ត្រូវបានរារាំងដោយភាពស្មុគស្មាញនៃព័ត៌មានទាំងនេះផងដែរ ហើយជាញឹកញាប់ក៏ដោយសារមិនមានការយល់ដឹងអំពីភាពពាក់ព័ន្ធនៃព័ត៌មានទាំងនោះចំពោះការចាប់អារម្មណ៍ និងរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋផងដែរ ។** នៅតំបន់ជនបទ ការមានកំរិតវប្បធម៌ទាប និងអនក្ខរភាពដ៏លើសលប់ក៏ជាកត្តាកំហិតសមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងការស្វែងរក និងរក្សាព័ត៌មានផងដែរ ជាពិសេសប្រសិនបើព័ត៌មាននោះមានលក្ខណៈលំអិត ឬបច្ចេកទេសពេក ។

### ២.ក.៤. កង្វះតម្លាភាព និងលទ្ធភាពទទួលបានព័ត៌មានសាធារណៈ

៤៥. **ខណៈដែលប្រជាពលរដ្ឋពុំសូវមានការទាមទាររកព័ត៌មាន តម្លាភាពរបស់រដ្ឋាភិបាលក៏នៅមានកំរិតទាប ហើយលទ្ធភាពទទួលបានព័ត៌មានសាធារណៈនៅកម្ពុជាក៏នៅមានកំរិតស្តួចស្តើងនៅឡើយ ។** អ្នកឆ្លើយនឹងសំណួរនៅក្នុងការអង្កេតទៅលើអង្គការក្រៅរដ្ឋាភិបាលបានបង្ហាញអោយដឹងថា ការមានលទ្ធភាពតិចតួចក្នុងការទទួលបានព័ត៌មានសាធារណៈនេះ គឺជាឧបសគ្គចំបងទី២ (បន្ទាប់ពីបញ្ហាកង្វះឆន្ទៈនយោបាយ) ចំពោះការទទួលខុសត្រូវសង្គម ។ នៅក្នុងសង្គមកម្ពុជា ពុំមានទំលាប់ក្នុងការចែករំលែកព័ត៌មានសាធារណៈជាលក្ខណៈប្រព័ន្ធ ឬជាលក្ខណៈផ្លូវការឡើយ បើទោះបីជាមានការអំពាវនាវយ៉ាងទទូចជាប្រចាំពីអង្គការសង្គមស៊ីវិល និងសហគមន៍ម្ចាស់ជំនួយ អោយមានដាក់ចេញនូវច្បាប់ស្តីពីសេរីភាពព័ត៌មានយ៉ាងណាក្តី ក៏ច្បាប់ស្តីពីការទទួលបានព័ត៌មាននេះនៅពុំទាន់ត្រូវបានអនុម័តនៅឡើយ ។ ទោះជាយ៉ាងណាក្តី រដ្ឋាភិបាលបានព្រមព្រៀងនៅក្នុងជំនួបរបស់ខ្លួនជាមួយម្ចាស់ជំនួយ ថានឹងរៀបចំគោលនយោបាយមួយស្តីពីការទទួលបានព័ត៌មាន ជាជំហានមួយមុននឹងការបង្កើតច្បាប់ និងបានចាត់តាំងអោយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច (MONASRI) ជាអ្នកដឹកនាំការងារនេះ ។ ដោយមានសំណើរបស់ MONASRI ធនាគារពិភពលោកបានរៀបចំសិក្ខាសាលាមួយស្តីពីច្បាប់នៃសេរីភាពព័ត៌មានសំរាប់មន្ត្រី និងបុគ្គលិករបស់ MONASRI (ខែវិច្ឆិកា ២០០៦) ហើយបន្ទាប់មក MONASRI បានបង្កើតក្រុមការងារអន្តរនាយកដ្ឋានមួយ (ដោយមានការចូលរួមពីអង្គការក្រៅរដ្ឋាភិបាល) ដែលក្រុមការងារនេះបានជួបប្រជុំគ្នាពីខែមិថុនា-សីហា ២០០៧ ដើម្បីរៀបចំសេចក្តីព្រាងគោលនយោបាយ ។ កិច្ចការនេះទទួលបានការគាំទ្រពី USAID/PACT និងការផ្តល់យោបល់ពីក្រុមប្រឹក្សាភិបាលអន្តរជាតិមួយ

ក្រុម ។ គិតត្រឹមខែកញ្ញា ឆ្នាំ ២០០៨ សេចក្តីព្រាងគោលនយោបាយនេះ នៅពុំទាន់ត្រូវបានផ្សព្វផ្សាយនៅក្នុងចំណោមក្រសួងពាក់ព័ន្ធដែលមាននាយកដ្ឋានរបស់ខ្លួនចូលជាសមាជិកនៃក្រុមការងារនោះនៅឡើយទេ ដែលការធ្វើបែបនេះគប្បីកើតឡើងមុនពេលដាក់សេចក្តីព្រាងគោលនយោបាយនោះទៅក្រុមប្រឹក្សារដ្ឋមន្ត្រីអោយពិចារណា ។

៤៦. មន្ត្រីរដ្ឋាភិបាលពុំមានទំលាប់ក្នុងការចែករំលែកព័ត៌មានឡើយ ។ ហេតុដូច្នេះហើយពួកគេពុំមានអារម្មណ៍ថាមានសុវត្ថិភាពទេ ក្នុងការសំរេចចិត្តថាព័ត៌មានបែបណាដែលអាច ឬគួរចែករំលែកទៅខាងក្រៅនោះ ជាពិសេសចំពោះមន្ត្រីរាជការនៅថ្នាក់ក្រោមៗ ។ ជាងនេះទៀត ពួកគេតែងមានការស្ទាក់ស្ទើរក្នុងការបញ្ចេញព័ត៌មានដែលមានលក្ខណៈ "រសើប "(ដូចជាព័ត៌មានអំពីហិរញ្ញវត្ថុជាដើម) ។ តំណាងអង្គការក្រៅរដ្ឋាភិបាលដែលត្រូវបានសំភាសន៍ តែងសង្កត់ធ្ងន់ពីការលំបាកក្នុងការរកព័ត៌មានពាក់ព័ន្ធពីបណ្តាក្រសួង ដូចជាព័ត៌មានអំពីគោលនយោបាយ កម្មវិធី ថវិកា និងការចំណាយ ។ ឧទាហរណ៍ *បណ្តាញភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP)* បានរាយការណ៍អំពីភាពជាក់ស្តែងក្នុងការដែលពុំអាចស្វែងរកព័ត៌មានបាន (សំរាប់គោលបំណងស្រាវជ្រាវ) ពីក្រសួងអប់រំ យុវជន និងកីឡា អំពីចំណាយសំរាប់ប្រៀវត្សរ៍គ្រូបង្រៀន ។ មន្ត្រីរបស់ក្រសួងនេះពុំគិតថាខ្លួនមាន "សមត្ថកិច្ច" ក្នុងការបញ្ចេញនូវព័ត៌មានបែបនេះទេ ហើយបានចោទសួរអ្នកតំណាង NEP ថាមានសិទ្ធិអ្វីក្នុងការចង់ដឹងអំពីព័ត៌មានទាំងនេះ ។ អង្គការ NGO Forum ក៏ជួបការលំបាកស្រដៀងគ្នានេះដែរ ក្នុងការស្វែងរកព័ត៌មានលំអិត និងត្រឹមត្រូវពីបណ្តាក្រសួងនានា ហើយដែលការស្វែងរកព័ត៌មានបែបនេះត្រូវពឹងផ្អែកទៅលើ "ខ្សែរយៈ" នៅក្នុងជួររដ្ឋាភិបាល ឬទំនាក់ទំនងជាមួយអង្គការអន្តរជាតិដែលមានឥទ្ធិពលដូចជាធនាគារពិភពលោកជាដើម ដើម្បីទទួលបានព័ត៌មានសំរាប់គំរោងឃ្លាំមើលថវិកាជាតិរបស់ខ្លួន ។

៤៧. ការគ្រប់គ្រងមូលនិធិ និងការចំណាយសាធារណៈគឺជាមុខងារស្នូលរបស់រដ្ឋាភិបាល ហើយបើយោងតាមគោលការណ៍នៃអភិបាលកិច្ចល្អ រដ្ឋាភិបាលមានកាតព្វកិច្ចធានាអោយមាននូវតម្លាភាពនិងការទទួលខុសត្រូវចំពោះសាធារណជន លើការប្រើប្រាស់មូលនិធិទាំងនេះ ។ ព័ត៌មានអំពីហិរញ្ញវត្ថុសាធារណៈ (ដូចជាព័ត៌មានទាក់ទងនឹងចំណូល ថវិកា ការចំណាយ សវនកម្ម និងដំណើរការសំរេចចិត្តផ្នែកហិរញ្ញវត្ថុរបស់រដ្ឋាភិបាល) គួរអោយបានដឹងដល់ប្រជាពលរដ្ឋ ។ តែទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវនេះបានរកឃើញថា **លទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានអំពីហិរញ្ញវត្ថុសាធារណៈ (អំពីចំណូល ថវិកា និងការចំណាយរបស់រាជរដ្ឋាភិបាលកម្ពុជា) នៅមានកំរិតតិចតួចជាខ្លាំង ។** បើទោះបីជាមានការវិវត្តន៍ខ្លះៗក្នុងការកែលំអមុខងារសវនកម្មនៅកម្ពុជាយ៉ាងណាក្តី ក៏ការឃ្លាំមើលជាសាធារណៈទៅលើការគ្រប់គ្រងហិរញ្ញវត្ថុដោយរាជរដ្ឋាភិបាល នៅតែមានភាពទន់ខ្សោយនៅឡើយ (World Bank, 2004: 42; NGO Forum, 2007) ។ របាយការណ៍របស់អាជ្ញាធរសវនកម្មជាតិ ពុំទាន់ត្រូវបានបោះពុម្ពផ្សាយនៅឡើយ ហើយច្បាប់កំពូលស្តីពីលទ្ធកម្ម ជាមួយនឹងអង្គភាពគោលសំរាប់ឃ្លាំមើល និងពង្រឹងការអនុវត្តន៍ គឺនៅពុំទាន់មាននៅឡើយ ។ ក្រៅពីនេះទៀត ការស្វែងរកព័ត៌មានថ្មីៗដែលអាចទុកចិត្តបានពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរបស់មន្ត្រីសាធារណៈព្រមទាំងអំពីលទ្ធកម្ម និងការចំណាយសាធារណៈនៅពុំទាន់អាចធ្វើទៅបាននៅឡើយទេ ។ សភាជាតិនៃកម្ពុជាពុំផ្តល់ការឃ្លាំមើលប្រកបដោយប្រសិទ្ធិភាពទៅលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយរាជរដ្ឋាភិបាលទេ ហើយប្រជាពលរដ្ឋពុំមានយន្តការល្អណាមួយដើម្បីទាមទារអោយមានការឃ្លាំមើលបែបនោះឡើយ ។

៤៨. **កង្វះនូវទំលាប់នៃការមានតម្លាភាព និងការចែករំលែកព័ត៌មាននេះ ពុំមែនកើតមានតែក្នុងវិស័យសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែក៏សង្កេតឃើញមានក្នុងចំណោមអង្គការសង្គមស៊ីវិលផងដែរ** ។ អ្នកស្រាវជ្រាវបានរកឃើញថាអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ក៏មានភាពស្ទាក់ស្ទើរក្នុងការ "បង្ហាញ"នូវព័ត៌មានលំអិតអំពីការបំពេញការងារ និងអភិបាលកិច្ចរបស់ខ្លួនដែរ ។ ឧទាហរណ៍ ក្នុងពេលសំភាសន៍ជាមួយអ្នកតំណាងអង្គការក្រៅរដ្ឋាភិបាល មានអ្នកតំណាងអង្គការតែមួយចំនួនតូចប៉ុណ្ណោះ ដែលមានឆន្ទៈបើកចំហផ្តល់ព័ត៌មានអំពីសំណើគំរោង ថវិកា និងរបាយការណ៍វាយតំលៃនៃអង្គការរបស់ខ្លួន ។ បុគ្គលិកអង្គការសង្គមស៊ីវិលជាច្រើនមានអារម្មណ៍ថាខ្លួនត្រូវបានហាមឃាត់ ហើយនៅក្នុងករណីជាច្រើន ពួកគាត់ពុំអាចផ្តល់ព័ត៌មានលំអិតបានឡើយបើទោះបីជាមានការអនុញ្ញាតពីថ្នាក់ដឹកនាំរបស់ខ្លួនអោយផ្តល់ជូនហើយក៏ដោយ ។ បើទោះបីគេពុំបានធ្វើការបដិសេធន៍ដោយចំហក្តី ក៏របៀបដែលពួកគាត់ឆ្លើយតបទៅនឹងសំណួរដែលមានលក្ខណៈ "រសើប" ទាំងនេះ បានបង្ហាញអោយឃើញយ៉ាងច្បាស់ថា អង្គការក្រៅរដ្ឋាភិបាលអាចគិតថាការធ្វើអោយមានតម្លាភាព អាចធ្វើអោយប៉ះពាល់ដល់ស្ថានភាពរបស់ខ្លួននៅពេលដែលប្រកួតប្រជែងយកមូលនិធិពីម្ចាស់ជំនួយ ។ ព័ត៌មានអំពីថវិកាត្រូវបានគេចាត់ទុកជាពិសេសថាជាព័ត៌មានសំងាត់ បើទោះបីជាធនធានទាំងនោះភាគច្រើនត្រូវបានម្ចាស់ជំនួយផ្តល់ជូនក្នុងគោលបំណងលើកកំពស់តម្លាភាព ហើយអណត្តិការងាររបស់អង្គការទាំងនោះគឺដើម្បីបំរើផលប្រយោជន៍សាធារណៈ (របស់ក្រុមគោលដៅ)ក៏ដោយ ។ តម្លាភាព និងការចែករំលែកព័ត៌មានបែរជាមានកំរិតខ្ពស់ជាងនៅក្នុងចំណោមសមាគមបែបប្រពៃណី ដោយក្នុងនោះ ៧៥% នៃអ្នកឆ្លើយសំណួរក្នុងការស្ទាបស្ទង់មតិសាធារណៈបាននិយាយថាពួកគេបានទទួលព័ត៌មានអំពីចំណូល និងចំណាយរបស់សមាគមមូលដ្ឋានរបស់ខ្លួន (ប្រៀបទៅនឹង ៤១% ក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាល) ។

## ២.ក.៥. ប្រជាពលរដ្ឋមានព័ត៌មាន និងចំណេះដឹងតិច

៤៩. ជាលទ្ធផល ការស្រាវជ្រាវនេះបានរកឃើញថា ជាទូទៅប្រជាពលរដ្ឋមាន**ព័ត៌មាន និងចំណេះដឹងតិចអំពីបញ្ហាសាធារណៈ** ។ ដូចដែលមានបង្ហាញជូននៅក្នុងរូបភាពទី៥ហើយ បើទោះបីជាអ្នកឆ្លើយសំណួរស្ទើរគ្រប់រូប (៩៤%) យល់ថា ការយល់ដឹងអំពីច្បាប់នៃកម្ពុជាគឺជារឿងសំខាន់ក៏ដោយ ក៏អ្នកឆ្លើយសំណួរមួយចំនួនធំ (៧២%) បានលើកឡើងថាពួកគេយល់ដឹងតិចតួច ឬមិនដឹងអ្វីទាល់តែសោះអំពីច្បាប់ទាំងនោះ[២១] ។ អ្វីដែលមិនគួរភ្ញាក់ផ្អើលនោះគឺថា ការស្រាវជ្រាវនេះបានរកឃើញថា **ចំណេះដឹងរបស់ប្រជាពលរដ្ឋអំពីផ្នែកហិរញ្ញវត្ថុសាធារណៈគឺមានកំរិតទាបយ៉ាងខ្លាំង** ។ ដូចមានបង្ហាញនៅក្នុងរូបភាពទី ៦ ហើយ អ្នកឆ្លើយសំណួរក្នុងការស្ទាបស្ទង់មតិសាធារណៈចំនួនពាក់កណ្តាល បាននិយាយថាពួកគេគ្មានដឹងអ្វីទាល់តែសោះអំពីបញ្ហាថវិកាជាតិ ហើយ ៣៥,៧%ទៀតបានឆ្លើយថា "មិនដឹង" ។ អ្នកឆ្លើយសំណួរចំនួន ៨,៩% ឆ្លើយថាគេដឹង "បន្តិចបន្តួច" អំពីថវិកាជាតិ ហើយមានតែ ៥,៥%ប៉ុណ្ណោះដែលនិយាយថា ពួកគេមានការយល់ដឹងច្រើន ។ ក្រៅពីនេះក៏មានគំលាតរវាងភេទដែរ ដោយបុរសប្រមាណ ៨,៩% អះអាងថាមានការយល់ដឹងពីបញ្ហាថវិកាជាតិ ឯស្ត្រីមានត្រឹមតែ ២,៦% ប៉ុណ្ណោះដែលបានអះអាងដូច្នេះ ។

[២១] ការយល់ឃើញអំពីចំណេះដឹងផ្នែកច្បាប់ពុំមានភាពខុសប្លែកគ្នាគួរអោយកត់សំគាល់ក្នុងចំណោមអ្នកមានវ័យខុសគ្នាឡើយ ប៉ុន្តែវាមានកំរិតខ្ពស់ជាងក្នុងចំណោមក្រុមបុរសជាងក្នុងចំណោក្រុមស្ត្រី និង អ្វីដែលពុំគួរភ្ញាក់ផ្អើលផងដែរនោះគឺ វាមានកំរិតខ្ពស់ជាងក្នុងចំណោមអ្នកដែលមានកំរិតវប្បធម៌ខ្ពស់ ។

**រូបភាពទី៥ : ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីច្បាប់ (បែងចែកទៅតាមភេទ)**




ប្រភព : CAS/WB, 2007

**រូបភាពទី៦ : ចំណេះដឹងរបស់ប្រជាពលរដ្ឋអំពីថវិកាជាតិ**




ប្រភព : CAS/WB, 2007

៥០. **នៅថ្នាក់មូលដ្ឋាន បើទោះបីប្រជាពលរដ្ឋជាទូទៅមានការយល់ដឹងច្រើនអំពីក្រុមប្រឹក្សាឃុំ-សង្កាត់ក្តី ក៏ការដឹងលឺអំពីបញ្ហាថវិកា និងចំណាយរបស់ឃុំនៅមានកំរិតទាបដែរ** ។ បើទោះបីអ្នកចូលរួមនៅក្នុងក្រុមពិភាក្សាបង្ហាញពីចំណាប់អារម្មណ៏ ក្នុងការចង់ដឹងអំពីថវិកាឃុំ និងវិធីនៃការប្រើប្រាស់ធនធានក្នុងឃុំយ៉ាងណាក៏ដោយ ក៏ពួកគេបានបញ្ជាក់អោយដឹងថា ព័ត៌មានបែបនេះកំរនឹងមានណាស់ ហើយក៏ពុំមែនសំរាប់ប្រជាពលរដ្ឋសាមញ្ញឡើយ ។ ឧទាហរណ៏ ការស្រាវជ្រាវនេះបានរកឃើញថា ប្រជាពលរដ្ឋភាគច្រើន (៨១%នៃបុរស និង៧២%នៃស្ត្រី) ដឹងអំពីការផ្លាស់ប្តូរនៃសមាសភាពក្រុមប្រឹក្សាឃុំ-សង្កាត់ បន្ទាប់ពីការបោះឆ្នោតក្នុងឆ្នាំ២០០៧ និងដឹងអំពីគណៈបក្សនៃបេក្ខភាពមេឃុំ ។ ក្នុងពេលសំភាសន៏ អ្នកឆ្លើយសំណួរខ្លះបានរៀបរាប់ពីឈ្មោះសមាជិកក្រុមប្រឹក្សាម្នាក់ៗ និងគណៈបក្សនយោបាយដែលផ្តល់បេក្ខភាពដល់អ្នកទាំងនោះផង ។ ម្យ៉ាងទៀត រូបភាពទី៧បង្ហាញថា មានអ្នកឆ្លើយសំណួរត្រឹមតែ ១១,៤% ប៉ុណ្ណោះដែលធ្លាប់ឮ ឬឃើញព័ត៌មានអំពីថវិកាឃុំរបស់ពួកគេ (ដែលអត្រាយល់ដឹងនេះគឺខ្ពស់ក្នុង

ចំណោមបុរសជាងស្ត្រីបន្តិចបន្តួច) ។ ក្នុងចំណោមប្រជាជនដែលធ្លាប់ចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ មានតែ ២១.៧%ប៉ុណ្ណោះដែលបានទទួលព័ត៌មានមួយចំនួនអំពីថវិកា ។ បើទោះបីច្បាប់បានចែងថា គួររៀបចំអោយមានសវនាការ និង ការពិគ្រោះយោបល់សាធារណៈ នៅពេលរៀបចំផែនការថវិកាយ៉ាងណាក្តី ក៏ក្នុងការអនុវត្តន៍ជាក់ស្តែង មានរាយការណ៍ថាទង្វើ បែបនេះកំរនឹងមានណាស់ ។ **ការដែលប្រជាពលរដ្ឋពុំសូវមានសេចក្តីក្លាហាន និងមានអំណាច រួមជាមួយនឹងឥរិយាបថបែប បិតុនិយមផង ធ្វើអោយពួកគេពុំសូវហ៊ានទាមទាររកព័ត៌មានទេ ។** នៅក្នុងការពិភាក្សាជាក្រុមនៅក្នុងខេត្តសៀមរាប(*ស្រុកពួក*) ទស្សនៈជាទូទៅរបស់ប្រជាពលរដ្ឋគឺថា "អ្នកភូមិពុំគួរខ្វល់ខ្វាយអំពីបញ្ហាទាំងនេះទេ" ព្រោះ"មានតែក្រុមប្រឹក្សាឃុំប៉ុណ្ណោះ ដែល ជាអ្នកធ្វើការសំរេចចិត្ត និងត្រូវមានព័ត៌មានទាំងអស់នោះ"។ ប្រជាពលរដ្ឋតែងជឿថា ក្រុមប្រឹក្សាឃុំមិនចង់អោយពួកគេចូល រួមទេ ហេតុដូច្នេះហើយទើបពួកគេពុំចាំបាច់សួររកព័ត៌មានទេ ដោយខ្លាចធ្វើអោយប៉ះពាល់ដល់ក្រុមប្រឹក្សាឃុំឬ ខ្លាចការសួររបស់ ពួកគេត្រូវបដិសេធ ។

**រូបភាពទី៧ : ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីថវិកាក្រុមប្រឹក្សាឃុំ-សង្កាត់**




ប្រភព : CAS/WB, 2007

## ២.ក.៦. តួនាទីអង្គការសង្គមស៊ីវិលអំពីបញ្ហាព័ត៌មាន

៥១. ការរួមចំណែកក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធជាសាធារណៈ និងអប់រំប្រជាពលរដ្ឋអំពីបញ្ហាសំខាន់ៗដែលជាក្តីបារម្ភរួម គឺជា មុខងារស្នូលរបស់សង្គមស៊ីវិល ។ ការជួយដល់ប្រជាពលរដ្ឋសាមញ្ញៗអោយទទួលបានព័ត៌មាន និងយល់ដឹងអំពីបញ្ហាក្នុងវិស័យ សាធារណៈ គឺជាជំហានដំបូងដ៏ចាំបាច់បំផុត ឆ្ពោះទៅរកការធានាអោយបាននូវការទទួលខុសត្រូវសង្គម ។ **តែទោះជាយ៉ាងណាក្តី នៅកម្ពុជា តួនាទីរបស់អង្គការសង្គមស៊ីវិលដែលធ្វើការផ្នែកអភិបាលកិច្ច ក្នុងការស្វែងរក ការបង្កើតអោយមាន ការប្រើប្រាស់ និងការចែករំលែកព័ត៌មាន ទើបតែកើតមានបន្តិចម្តងៗ ហើយនៅមិនទាន់មានការអភិវឌ្ឍន៍អោយបានប្រសើរនៅឡើយទេ ។** ដូចមានបង្ហាញនៅក្នុងរូបភាពទី៨ អង្គការក្រៅរដ្ឋាភិបាលដែលត្រូវបានអង្កេត បានអោយដឹងថា (១) សកម្មភាព (២) សមត្ថភាពក្នុងផ្នែកព័ត៌មាននេះ ហើយនិង (៣) ការផ្តល់ភាពសំខាន់ទៅលើព័ត៌មាន ឬប្រព័ន្ធផ្សព្វផ្សាយថាជាមធ្យោបាយលើក កំពស់ការទទួលខុសត្រូវសង្គម គឺទាំងអស់នេះនៅមានកំរិតទាបនៅឡើយ ។ មានអ្នកឆ្លើយសំណួរដ៏តិចតួច (៨.៣%) ដែលបាន ចាត់ទុកថា អង្គការក្រៅរដ្ឋាភិបាលជាប្រភពនៃព័ត៌មានសាធារណៈ (សូមមើលរូបភាពទី២) ប៉ុន្តែអ្វីដែលគួរអោយចាប់អារម្មណ៍

នោះគឺថា ប្រជាពលរដ្ឋវ័យក្មេងៗ (អាយុក្រោម៣០ឆ្នាំ) ក្នុងសមាមាត្រពីរដងលើសពីប្រជាជនវ័យចំណាស់ គិតថាអង្គការក្រៅរដ្ឋាភិបាលគឺជាប្រភពនៃព័ត៌មាន ។ តែទោះជាយ៉ាងណាក្តី របកគំហើញទាំងនេះអាចមើលរំលងនូវឥទ្ធិពលនៃយុទ្ធនាការផ្សព្វផ្សាយព័ត៌មានរបស់អង្គការក្រៅរដ្ឋាភិបាល ព្រោះថាព័ត៌មានដែលប្រជាពលរដ្ឋទទួលបានពីអ្នកដឹកនាំក្នុងមូលដ្ឋាន ពីអ្នកជិតខាង មិត្តភក្តិ និងសូម្បីពីប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុ និងទូរទស្សន៍) នោះអាចមានប្រភពដើមមកពីអង្គការក្រៅរដ្ឋាភិបាល ។

៥២. **មានតែអង្គការសង្គមស៊ីវិលមួយចំនួនតូចប៉ុណ្ណោះដែលបានអភិវឌ្ឍន៍ជំនាញឯកទេសផ្នែកIEC (ព័ត៌មាន-ការអប់រំ-ទំនាក់ទំនង) និងប្រព័ន្ធផ្សព្វផ្សាយដែលទាក់ទងទៅនឹងប្រធានបទស្តីពីអភិបាលកិច្ច ឬការទទួលខុសត្រូវសង្គម ។** នៅពេលដែលធ្វើសកម្មភាពផ្នែក IEC ជាទូទៅគេបានផ្តោតជាពិសេសទៅលើគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត និងសិទ្ធិមនុស្ស ឬមានគោលបំណងរិះគន់ជាសាធារណៈនូវស្ថានភាពជាក់លាក់នៃភាពអយុត្តិធម៌ និទ្ទណ្ឌភាព ឬការរំលោភសិទ្ធិមនុស្ស។ កិច្ចខិតខំប្រឹងប្រែងរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការស្វែងរកព័ត៌មានសាធារណៈ ការពិត និងភស្តុតាង ភាគច្រើនធ្វើឡើងតែសំរាប់ស្ថានភាពជាក់លាក់មួយចំនួនដែលមានភាពស្រួចស្រាល (ដូចជាទំនាស់ដីធ្លីរួមដែលធ្ងន់ធ្ងរ ឬការបំលាស់ប្តូរទីលំនៅដោយបង្ខំជាដើម)។ អង្គការសង្គមស៊ីវិលពុំសូវមានកិច្ចខិតខំប្រឹងប្រែងជាលក្ខណៈប្រព័ន្ធក្នុងការស្វែងរក និងវិភាគព័ត៌មានអំពីរដ្ឋាភិបាល ឬក៏បង្កើត និងផ្សព្វផ្សាយព័ត៌មានពីស្ថាប័នស្រាវជ្រាវឯករាជ្យ ឬយោបល់ត្រលប់របស់ប្រជាពលរដ្ឋណាស់ ។ ទំនាក់ទំនងរវាងសង្គមស៊ីវិល និងរដ្ឋាភិបាលដែលមានលក្ខណៈទន់ខ្សោយ ហើយដែលជួនកាលមានភាពតានតឹង លទ្ធភាពតិចតួចក្នុងការទទួលបានព័ត៌មាន និងការមានចំណេះដឹង ឬសមត្ថភាពទាប គឺជាបច្ច័យអាក្រក់ដែលធ្វើអោយស្ថានភាពកាន់តែធ្ងន់ធ្ងរឡើង ។

**រូបភាពទី៨ :**

**កំរិតនៃសកម្មភាព សមត្ថភាព និងភាពសំខាន់របស់អង្គការសង្គមស៊ីវិលអំពីព័ត៌មានសាធារណៈ- ការងារផ្សព្វផ្សាយ**




ប្រភព : CAS/WB, 2007a

៥៣. **ការស្រាវជ្រាវនេះបានរកឃើញថា សូម្បីតែក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលអាជីព ក៏មានព័ត៌មានសាធារណៈ និងចំណេះដឹងទាបនៅឡើយ ។** ដូចមានបង្ហាញនៅក្នុងរូបភាពទី៩ ការអង្កេតក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាល បានរកឃើញថា អ្នកឆ្លើយសំណួរដែលជាបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលអាជីពនិយាយថា ពួកគេមានព័ត៌មាន និងចំណេះដឹងតិចតួចអំពីគោលនយោបាយ នីតិវិធី និងថវិកាសាធារណៈ ។ នៅពេលដែលត្រូវបានសុំអោយវាយតំលៃទៅលើចំណេះដឹង និងសមត្ថភាពរបស់ខ្លួន បុគ្គលិក

អង្គការក្រៅរដ្ឋាភិបាលទាំងនោះ បានកំណត់ឃើញថា ចំណេះដឹងអំពីគោលនយោបាយថវិកាជាតិ គឺជាចំណុចខ្សោយដ៏ចំបងបំផុតរបស់ពួកគេ ហើយត្រូវការកសាងសមត្ថភាពលើផ្នែកនេះ ។ ចំណុចខ្សោយបន្ទាប់មកទៀត គឺចំណេះដឹងអំពីនីតិវិធីរដ្ឋបាលសាធារណៈ និងសមត្ថភាពក្នុងការស្វែងរកព័ត៌មានសាធារណៈដែលចាំបាច់ ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវសង្គម ។ អ្វីដែលគួរអោយភ្ញាក់ផ្អើលនោះគឺថា អ្នកឆ្លើយសំណួរជាងមួយភាគបីពុំបានឆ្លើយទៅនឹងសំណួរទាំងនេះទេ ដែលនេះឆ្លុះបញ្ចាំងអោយឃើញថាអ្នកឆ្លើយសំណួរក្នុងអង្គការទាំងនោះពុំមានសមត្ថភាព ឬឆន្ទៈគ្រប់គ្រាន់ក្នុងការវាយតំលៃអោយបានស៊ីជំរៅទៅលើកំរិតចំណេះដឹង និងសមត្ថភាពរបស់ខ្លួនទេ ។

**រូបភាពទី៩ : ស្វ័យវាយតំលៃលើសមត្ថភាពរបស់អង្គការក្រៅរដ្ឋាភិបាលទាក់ទងទៅនឹងការទទួលខុសត្រូវសង្គម**




ប្រភព : CAS/WB, 2007a

៥៤. **វិធីសាស្ត្រនៃការទទួលខុសត្រូវសង្គម ជាញឹកញាប់តំរូវអោយមាននូវមូលដ្ឋានចំណេះដឹងរឹងមាំ និងកំរិតនៃជំនាញឯកទេសមួយច្បាស់លាស់ ដែលសូម្បីតែអង្គការក្រៅរដ្ឋាភិបាលអាជីព ក៏គិតថានេះជាបញ្ហាប្រឈមរបស់គេដែរ ។** ការចូលរួមប្រកបដោយប្រសិទ្ធិភាពជាមួយតួអង្គក្នុងរដ្ឋាភិបាល ជាពិសេសក្នុងការពិគ្រោះយោបល់ និងពិភាក្សាថ្នាក់ខ្ពស់ វាតំរូវអោយមានមិនត្រឹមតែជំនាញតាមវិស័យ ឬជំនាញបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានការយល់ដឹងយ៉ាងច្បាស់លាស់អំពីគោលនយោបាយ និងនីតិវិធីរដ្ឋបាល នីតិវិធីច្បាប់ និងតុលាការផងដែរ ។ ឧទាហរណ៍ នៅក្នុងកិច្ចសំភាសន៍ពាក់ព័ន្ធនឹងសកម្មភាពរបស់ COPCEL មានការលើកឡើងថា នៅពេលពិភាក្សាតុមូលជាមួយរដ្ឋាភិបាល និងមន្ត្រីគណៈបក្សនយោបាយ អ្នកតំណាងរបស់សង្គមស៊ីវិលច្រើនតែពុំសូវដឹង និងពុំសូវមានសមត្ថភាពផ្នែកគោលនយោបាល ច្បាប់ និងនីតិវិធីពាក់ព័ន្ធនឹងការបោះឆ្នោត នោះបើប្រៀបនឹងអ្នកចូលរួមដទៃទៀត ។ គំលាតនៃចំណេះដឹង និងជំនាញអាចជាបញ្ហាធំជាងនេះទៀតនៅក្នុងផ្នែកហិរញ្ញវត្ថុសាធារណៈ ដែលជាផ្នែកមានបច្ចេកទេសស្មុគស្មាញ ហើយដែលពុំមែនជាផ្នែកឯកទេសរបស់អង្គការសង្គមស៊ីវិលនោះ ។ មន្ត្រីនៃគំរោងឃ្លាំមើលថវិកាជាតិរបស់អង្គការ NGO Forum (ដែលគំរោងនេះត្រូវអនុវត្តក្រោមកិច្ចសហការជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួនទៀតដែលមានចំណាប់អារម្មណ៍) បានរៀបរាប់ថា ការយល់ដឹងអំពីបញ្ហាថវិកាក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលភាគច្រើន គឺនៅមានកំរិតទាបនៅឡើយ ហើយនេះគឺជាឧបសគ្គមួយនៅពេលដំណើរការគំរោងក្នុងដំណាក់កាលដំបូង ។ ការឃ្លាំមើលថវិកាដែលមានលក្ខណៈ

ជាប្រព័ន្ធ និងប្រកបដោយសមត្ថភាព ទាមទារអោយមានការកសាងសមត្ថភាពជាប្រចាំដើម្បីបង្កើនចំណេះដឹង និងជំនាញរបស់តួអង្គក្នុងសង្គមស៊ីវិល ។

៩៥. **ប្រភេទនៃយន្តការផ្សព្វផ្សាយព័ត៌មាន ដែលអង្គការក្រៅរដ្ឋាភិបាលកំពុងប្រើប្រាស់សព្វថ្ងៃ ដូចជារបាយការណ៍ជាលាយល័ក្ខអក្សរ ព្រឹត្តិប័ត្រ ឬវិបសាយ[២២] កំរនឹងមានរៀបចំឡើងសំរាប់ប្រជាពលរដ្ឋសាមញ្ញណាស់** ព្រោះប្រជាពលរដ្ឋរស់នៅទីជនបទមានការអប់រំ និងអក្ខរភាពតិចតួច ។ សំភារៈផ្សព្វផ្សាយទាំងនោះច្រើនមានអត្ថបទវែងៗ និងវាក្យស័ព្ទបច្ចេកទេសដែលស្មុគស្មាញ ឬពិបាកយល់ ហើយនៅគ្រប់ករណីទាំងអស់ ឯកសារទាំងនោះត្រូវបានបោះពុម្ពផ្សាយនៅក្នុងទីក្រុងភ្នំពេញ ហើយកំរត្រូវបានចែកចាយទៅដល់ថ្នាក់ខេត្ត ស្រុក ឃុំ ឬភូមិណាស់ ។ ការសំភាសន៍ផ្ទាល់នៅតាមសហគមន៍បានអោយដឹងថាប្រជាពលរដ្ឋកំរនឹងឃើញសំភារៈទាំងនោះណាស់ ។ ដូចបានរៀបរាប់ខាងដើមរួចហើយ ប្រជាពលរដ្ឋចូលចិត្តការផ្តល់ព័ត៌មានតាមរយៈពាក្យសំដីនិយាយ (ដូចជាតាមវិទ្យុ និង ទូរទស្សន៍) ហើយប្រសិនបើអាចធ្វើបានគឺការសន្ទនាដោយផ្ទាល់តែម្តងរឹតតែប្រសើរ ប៉ុន្តែគួរអោយស្តាយការអប់រំសាធារណៈ ឬអង្គការសង្គមស៊ីវិលផ្អែកតស៊ូមតិ កំរនឹងប្រើប្រាស់វិធីសាស្ត្របែបនេះណាស់ ។

៩៦. **គំនិតផ្តួចផ្តើមពិសេសមួយរបស់អង្គការសង្គមស៊ីវិល ដែលមានបំណងធ្វើអោយសហគមន៍មានលទ្ធភាពទទួលបានព័ត៌មានដោយផ្ទាល់ និងបានប្រើប្រាស់យន្តការដែលប្រជាពលរដ្ឋចូលចិត្តនោះ (ទំនាក់ទំនងផ្ទាល់និងការនិយាយផ្ទាល់មាត់) គឺបណ្តាញ"ទីប្រឹក្សាប្រជាពលរដ្ឋ" ដែលគាំទ្រដោយ KID** ។ ទីប្រឹក្សាប្រជាពលរដ្ឋចំនួន ២៥៤នាក់ ក្នុងខេត្តចំនួន៩ (២៤ស្រុក) បានផ្តល់ព័ត៌មាន និងដំបូន្មានដល់ប្រជាពលរដ្ឋដោយឥតគិតថ្លៃ ព្រមទាំងបានផ្តល់ការគាំទ្រដោយផ្ទាល់ និងជាក់ស្តែងនៅពេលដែលប្រជាពលរដ្ឋត្រូវប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន ។ ការប្តេជ្ញាចិត្ត និងប្រសិទ្ធិភាពរបស់ទីប្រឹក្សាប្រជាពលរដ្ឋទាំងនេះមានភាពខុសគ្នាច្រើនពីម្នាក់ទៅម្នាក់ ហើយជួនកាលគុណភាពនៃព័ត៌មានក៏នៅមានកំរិតផងដែរ (អាស្រ័យដោយកង្វះការបណ្តុះបណ្តាលអោយបានគ្រប់គ្រាន់ និងកត្តាដទៃទៀតដែលមានពិភាក្សានៅក្នុងករណីសិក្សាខាងក្រោម) ។ តែទោះជាយ៉ាងណាក្តី ការស្រាវជ្រាវនេះបានរកឃើញថា ទីប្រឹក្សាប្រជាពលរដ្ឋដែលសកម្ម និងប្រកបដោយសមត្ថភាព តែងទទួលការពឹងពាក់ជាញឹកញាប់ពីប្រជាពលរដ្ឋដែលមកសុំពិគ្រោះយោបល់ និងត្រូវបានប្រជាពលរដ្ឋគ្រប់វណ្ណៈសង្គម (អ្នកក្រ អ្នកមាន មន្ត្រីសាធារណៈ) អោយតំលៃខ្ពស់ ដោយមិនប្រកាន់ពីទំនាក់ទំនងនយោបាយ ឬ តំណែងតួនាទីក្នុងសង្គមឡើយ ។ ការពិភាក្សាតាមក្រុម និងកិច្ចសំភាសន៍បានអោយដឹងថា នៅកន្លែងណាដែលទីប្រឹក្សាប្រជាពលរដ្ឋមានភាពសកម្ម ហើយប្រជាពលរដ្ឋបានដឹងពីវត្តមានរបស់គាត់ ទីប្រឹក្សាប្រជាពលរដ្ឋមានឱកាសរួមចំណែកយ៉ាងធំធេងក្នុងការលើកកំពស់ការយល់ដឹង និងចំណេះដឹងអំពីសិទ្ធិប្រជាពលរដ្ឋ គោលការណ៍

---

[២២] ការស្រាវជ្រាវនេះបានរកឃើញថា អ៊ីនធឺណែតគឺជាប្រភពព័ត៌មានសាធារណៈសំរាប់តែប្រជាពលរដ្ឋប្រមាណ ០,២% ប៉ុណ្ណោះ។ បើទោះបីជាអ៊ីនធឺណែត និងអ៊ីម៉ែលកំពុងតែមានប្រជាប្រិយភាពក្នុងចំណោមក្រុមមួយចំនួន (អ្នកទីក្រុង និងមានកំរិតវប្បធម៌ខ្ពស់ ដូចជាសិស្ស-និស្សិត ឬបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល) ក៏ដោយ ប្រជាពលរដ្ឋសាមញ្ញ និងអង្គការសង្គមស៊ីវិលក្នុងមូលដ្ឋានភាគច្រើនពុំទាន់មានលទ្ធភាពប្រើប្រាស់សេវាទាំងនេះឡើយ ជាពិសេសនៅតាមតំបន់ជនបទ។ ឧទាហរណ៍ ចេតនារបស់ KID ក្នុងការបង្កើតមជ្ឈមណ្ឌលព័ត៌មានប្រជាពលរដ្ឋ (CIC) ដោយភ្ជាប់ទៅនឹងប្រព័ន្ធអ៊ីនធឺណែតនៅតាមទីរួមខេត្តនៅទូទាំងប្រទេសត្រូវទទួលបរាជ័យ ។ ក្នុងចំណោមមជ្ឈមណ្ឌលព័ត៌មានប្រជាពលរដ្ឋដែលបើកដំណើរការដំបូងចំនួន ២២ នៅសល់តែការិយាល័យ៣ប៉ុណ្ណោះដែលនៅបន្តដំណើរការ ។ យោងតាមនាយករបស់ CIC ក្នុងខេត្តកំពង់ចាម អ្នកមកប្រើប្រាស់ភាគច្រើនគឺជាសិស្ស-និស្សិត ឬបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលដែលរស់នៅក្នុងទីរួមខេត្ត ។ អង្គការក្រៅរដ្ឋាភិបាលអាជីពជាច្រើនក្នុងទីក្រុងភ្នំពេញបានបង្កើតវិបសាយរបស់ខ្លួន ប៉ុន្តែការស្រាវជ្រាវនេះបានរកឃើញថា វិបសាយទាំងនោះត្រូវបានប្រើប្រាស់ស្ទើរតែទាំងស្រុងដោយជនបរទេស និងក្រុមអ្នកមានការអប់រំខ្ពស់ក្នុងតំបន់ទីក្រុងតែប៉ុណ្ណោះ ។

លទ្ធិប្រជាធិបតេយ្យ និងនីតិវិធីរដ្ឋបាល និងនីតិវិធីច្បាប់ ។ ដូចមានរៀបរាប់នៅក្នុងប្រអប់ទី ៥ ខាងក្រោមនេះ ជួនកាលសូម្បីតែអាជ្ញាធរមូលដ្ឋានក៏ផ្តល់តំលៃយ៉ាងខ្ពស់ចំពោះទីប្រឹក្សាប្រជាពលរដ្ឋដែរ ថាគេជាប្រភពព័ត៌មាន និងជាជំនួយដ៏សំខាន់ផ្នែកច្បាប់ ឬបញ្ហានានារបស់សហគមន៍ ។

**ប្រអប់ទី ៥ : រូបភាពនៃ"ទីប្រឹក្សាប្រជាពលរដ្ឋ" ដែលមានប្រជាប្រិយភាព**

លោក ក ជាអតីតនាយកសាលាទើបចូលនិវត្តន៍កាលពីពេលថ្មីៗ ។ គាត់រស់នៅក្នុងស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ហើយជា "ទីប្រឹក្សាប្រជាពលរដ្ឋ" ដ៏មានប្រជាប្រិយ និងល្បីឈ្មោះនៅក្នុងឃុំរបស់គាត់ ។ ចាប់តាំងពីគាត់ចាប់ផ្តើមធ្វើការងារស្ម័គ្រចិត្តនេះនៅឆ្នាំ ២000 មក គាត់បាននិងកំពុងប្តេជ្ញាចិត្តជាប់ជាប្រចាំ ក្នុងការជួយប្រជាពលរដ្ឋនៅក្នុងឃុំរបស់គាត់អោយយល់ដឹងពីបែបបទរដ្ឋបាល និងច្បាប់នានា ដែលចាំបាច់ក្នុងការស្វែងរកសេវាសាធារណៈ ឬដើម្បីដោះស្រាយវិវាទណាមួយ ។ កត្តាមួយដែលធ្វើអោយគាត់ទទួលបានជោគជ័យ គឺការស្តាប់ដោយយកចិត្តទុកដាក់ចំពោះបញ្ហារបស់ប្រជាពលរដ្ឋ ការទទួលបានព័ត៌មានពីច្រើនប្រភព រួមទាំងពីអាជ្ញាធរមូលដ្ឋានផង ការពិភាក្សារកជំរើសដំណោះស្រាយជាមួយភាគីពាក់ព័ន្ធ និងព្យាយាមបង្កលក្ខណៈអោយភាគីវិវាទមកជួបជុំគ្នារួចហើយសំរបសំរួលរកដំណោះស្រាយ ។ លោក ក មានឱកាសទទួលបានព័ត៌មានដោយស្រួលពីអាជ្ញាធរមូលដ្ឋាន (ឧទាហរណ៍ ព័ត៌មានអំពីនីតិវិធីរដ្ឋបាល ផែនការអភិវឌ្ឍន៍ឃុំ ឬសូម្បីព័ត៌មានអំពីថវិកា និងការចំណាយរបស់ឃុំ) នៅពេលដែលគាត់ត្រូវការ ព្រោះគាត់តែងតែត្រូវបានអញ្ជើញយ៉ាងទៀងទាត់អោយចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ហើយគាត់មានទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋាន ។ ប៉ុន្តែករណីបែបនេះមិនមែនតែងកើតមានគ្រប់ពេលនោះទេ ។ ដំបូងឡើយ អាជ្ញាធរមូលដ្ឋានមានការសង្ស័យថា "ទីប្រឹក្សាប្រជាពលរដ្ឋ" នឹងបង្កអោយមានបញ្ហាដោយការ "ញុះញង់" អោយប្រជាពលរដ្ឋរិះគន់ និងវាយប្រហារមកលើអាជ្ញាធរ ។ ប៉ុន្តែជារឿយៗ លោក ក តែងខិតខំស្វែងរកឱកាសផ្លូវការ និងមិនផ្លូវការដើម្បីពន្យល់ពីតួនាទីរបស់គាត់អោយអាជ្ញាធរមូលដ្ឋានបានយល់ និងអោយពួកគេដឹងពីសារៈប្រយោជន៍ តាមរយៈការបង្ហាញពីគោលជំហផ្តល់ប្រឹក្សារបស់គាត់ ដោយផ្អែកលើការពិចារណាលើផលប្រយោជន៍របស់គ្រប់ភាគីដែលពាក់ព័ន្ធដោយមិនលំអៀង ឬប្រកាន់ភាគីណាមួយឡើយ ។ កំណើននៃជោគជ័យរបស់គាត់ក្នុងការដោះស្រាយវិវាទរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ និងរវាងប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន តាមរយៈការអប់រំ ការពិគ្រោះយោបល់ និងការផ្សះផ្សារមិនត្រឹមតែធ្វើអោយគាត់ទទួលបានប្រជាប្រិយភាពប៉ុណ្ណោះទេ តែថែមទាំងទទួលបានការកោតសរសើរជាផ្លូវការ និងការសហការល្អពីអាជ្ញាធរមូលដ្ឋានទៀតផង ។ បច្ចុប្បន្ននេះ សូម្បីតែមេឃុំក៏សុំដំបូន្មានពីគាត់ដែរ។ ជារឿយៗ លោក ក ប្រើប្រាស់ឱកាសបែបនេះដើម្បីពាំនាំការព្រួយបារម្ភ សេចក្តីត្រូវការ និងសំណើរបស់ប្រជាពលរដ្ឋទៅអោយអាជ្ញាធរមូលដ្ឋានបានដឹង ហើយគាត់ក៏មានការប្តេជ្ញាចិត្តខ្ពស់ដើម្បីរាយការណ៍ទៅអ្នកភូមិវិញផងដែរ ។

*ប្រភព : CAS/WB, ២00៧b*

### ២.ក.៧. អនុសាសន៍ និងសកម្មភាពដែលគួរអនុវត្ត

៩៧. ជំហានដំបូងដ៏សំខាន់ឈានទៅរកការទទួលខុសត្រូវសង្គម គឺត្រូវធ្វើអោយប្រជាពលរដ្ឋទទួលបានព័ត៌មាន ។ ការស្រាវជ្រាវនេះបានរកឃើញថា បើទោះបីជាប្រជាពលរដ្ឋគិតថា ការមានព័ត៌មានគឺជាប្រការសំខាន់សំរាប់ពួកគេ និងបានបង្ហាញពីចំណាប់អារម្មណ៍លើបញ្ហាសាធារណៈក៏ដោយ ក៏នៅមានកត្តាមួយចំនួនដែលធ្វើអោយប្រជាពលរដ្ឋពុំសូវមានព័ត៌មាន ក្នុងនោះមានដូចជា កង្វះការយល់ដឹងអំពីសិទ្ធិទទួលបានព័ត៌មាន កង្វះការយល់ដឹងអំពីវិធីស្វែងរក និងប្រើប្រាស់ព័ត៌មាន កង្វះព័ត៌មានដែលពាក់ព័ន្ធ និងព័ត៌មានដែលស្មុគស្មាញពិបាកប្រើប្រាស់ជាដើម ។

៩៨. អនុសាសន៍ចំនួនបីត្រូវបានស្នើឡើងដើម្បីដោះស្រាយបញ្ហាទាំងនេះ ។ អនុសាសន៍ដែលជាអាទិភាពទី ១ ជាពិសេសសំរាប់អង្គការសង្គមស៊ីវិល ប៉ុន្តែអាចសំរេចទៅបានបើមានកិច្ចសហការល្អពីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (DP) នោះគឺ (១) **បំផុសប្រជាពលរដ្ឋចាប់ពីថ្នាក់ក្រោមឡើងទៅអោយចេះទាមទាររកព័ត៌មានសាធារណៈ** ដូចជាតាមរយៈការលើកកំពស់ការយល់ដឹងអំពីសិទ្ធិទទួលបានព័ត៌មាន និងអប់រំប្រជាពលរដ្ឋអំពីវិធីសាស្ត្រ និងហេតុផលក្នុងការទាមទាររកព័ត៌មានសាធារណៈ ។ ការទាមទាររបស់ប្រជាពលរដ្ឋរកព័ត៌មាន ក៏ត្រូវធ្វើឡើងស្របគ្នាជាមួយទំនុកចិត្តប្រជាពលរដ្ឋលើសមត្ថភាពរបស់ខ្លួនក្នុងការប្រើប្រាស់ព័ត៌មានទាំងនោះដើម្បីធ្វើអោយមានការផ្លាស់ប្តូរពិតប្រាកដដែរ ។ (សូមមើលអនុសាសន៍ ខ.១ ទាក់ទងនឹងការផ្តល់អំណាចដល់ប្រជាពលរដ្ឋ) ។ អនុសាសន៍ទី២គឺ (២) **លើកកំពស់លទ្ធភាពទទួលបានព័ត៌មានសាធារណៈដែលពាក់ព័ន្ធផ្ទាល់នឹងសុខុមាលភាពប្រជាពលរដ្ឋ** (ឧទាហរណ៍ ទាក់ទងទៅនឹងសេវា និងការចំណាយសាធារណៈនៅក្នុងវិស័យសុខាភិបាល និងអប់រំ) **ជាពិសេសនៅថ្នាក់ក្រោមជាតិ ដូចជាថ្នាក់ឃុំ ស្រុក និងខេត្ត ដែលប្រជាពលរដ្ឋសាមញ្ញមានលទ្ធភាពច្រើនក្នុងការទទួលបានព័ត៌មានទាំងនោះ ។** អនុសាសន៍នេះត្រូវបានស្នើឡើងជាពិសេសសំរាប់ប្រតិបត្តិករក្នុងរដ្ឋាភិបាល និងអ្នកធ្វើការជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ប៉ុន្តែសកម្មភាពមួយចំនួនដែលត្រូវបានស្នើឡើង គប្បីមានការជួយជ្រោមជ្រែងពីអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ។ អនុសាសន៍ទី ៣ (សំរាប់ដៃគូអភិវឌ្ឍន៍និងអង្គការដែលជួយសង្គមស៊ីវិល គឺដើម្បី (៣) **ជួយអង្គការសង្គមស៊ីវិលអោយទទួលបានព័ត៌មាន និងមានចំណេះដឹងកាន់តែប្រសើរឡើងអំពីបញ្ហា និងសកម្មភាពក្នុងផ្នែកសាធារណៈ/សកម្មភាពរបស់រដ្ឋាភិបាល និងជួយអភិវឌ្ឍសមត្ថភាពនិងតួនាទីរបស់ពួកគេក្នុងការបង្កើត ស្វែងរក កែសំរួលអោយសាមញ្ញ និងផ្សព្វផ្សាយព័ត៌មានទាំងនោះជាសាធារណៈ ។**

៩៩. *<u>អនុសាសន៍ ក.១ - បំផុសប្រជាពលរដ្ឋអោយចេះទាមទាររកព័ត៌មានសាធារណៈ</u>*

ក) អង្គការសង្គមស៊ីវិលដែលកំពុងធ្វើការនៅតាមសហគមន៍ (ក្នុងគ្រប់វិស័យ) ត្រូវបានលើកទឹកចិត្តអោយបញ្ចូលផ្នែក "ព័ត៌មានសាធារណៈ" ទៅក្នុងកម្មវិធីបច្ចុប្បន្នរបស់ខ្លួន ដូចជាការចែករំលែកជាមួយសមាជិក ឬប្រជាពលរដ្ឋជាក្រុមគោលដៅរបស់ខ្លួននូវព័ត៌មានអំពីច្បាប់ គោលនយោបាយ ផែនការ និងថវិកាសាធារណៈដែលពាក់ព័ន្ធទៅនឹងសកម្មភាពបច្ចុប្បន្ន (ដូចជាក្នុងវិស័យសុខាភិបាល អប់រំ កសិកម្ម ដីធ្លី ព្រៃឈើ ។ល។) ដោយជួយប្រជាពលរដ្ឋអោយយល់អំពីភាពពាក់ព័ន្ធរបស់ព័ត៌មានទាំងនោះទៅនឹងការចាប់អារម្មណ៍ មុខរបរចិញ្ចឹមជីវិត និងសុខុមាលភាពរបស់ពួកគេ) និងជំរុញឬសំរបសំរួលអោយមានកិច្ចខិតខំប្រឹងប្រែងស្វែងរកព័ត៌មានបែបនោះបន្ថែមទៀត ។ សកម្មភាពបែបនោះគប្បីពិចារណាផងដែរទៅលើអាទិភាព និងសេចក្តីត្រូវការជាក់លាក់របស់ក្រុមស្ត្រី យុវជន និងក្រុមគោលដៅដទៃទៀត ។ (*សកម្មភាពដែលអង្គការសង្គមស៊ីវិលនៅសហគមន៍ត្រូវធ្វើ ហើយដែលប្រពៃបំផុតត្រូវមានការគាំទ្រពីបណ្តាញអង្គការសង្គមស៊ីវិលនៅថ្នាក់ខ្ពស់ និងម្ចាស់ជំនួយ*) ។

ខ) លើកកំពស់ "អក្ខរភាពផ្នែកអភិបាលកិច្ច" ក្នុងចំណោមប្រជាពលរដ្ឋសាមញ្ញតាមរយៈយុទ្ធនាការ IEC ដែលផ្តល់ព័ត៌មានជាមូលដ្ឋានអំពីស្ថាប័ន និងដំណើរការអភិបាលកិច្ច គោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ និងក្នុងបំណងបំផុសអោយប្រជាពលរដ្ឋធ្វើការតស៊ូបញ្ចាំងអោយបានស៊ីជំរៅលើព័ត៌មានទាំងនោះ ។ សកម្មភាពទាំងនេះក៏អាចយកទៅអនុវត្តនៅក្នុងបរិបទនៃកម្មវិធីអក្ខរកម្មផងដែរ (ដោយបញ្ចូលខ្លឹមសារនៃបញ្ហាក្នុងវិស័យសាធារណៈ និងដំណើរការអភិបាលកិច្ចទៅក្នុងកម្មវិធីពង្រឹងជំនាញអំណាន) ។ (*សកម្មភាពគួរសំរាប់អង្គការសង្គមស៊ីវិល ជាពិសេសបណ្តាញរបស់អង្គការសង្គមស៊ីវិលនៅថ្នាក់សហគមន៍ ជាមួយនឹងការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលមួយ ឬច្រើនជាងនេះដែលមានជំនាញឯកទេសណាមួយច្បាស់លាស់*) ។

គ) ពន្លឿនកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ហើយប្រើប្រាស់ឱកាសនោះដើម្បីផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋអំពីសិទ្ធិរបស់គេក្នុងការទទួលបានព័ត៌មាន ព័ត៌មានដែលអាចរកបាន (និងព័ត៌មានអ្វីដែលមិនមាន) ហើយត្រូវធ្វើដូចម្តេចដើម្បីទទួលបានព័ត៌មានទាំងនោះ ។ (*សកម្មភាពដែលត្រូវធ្វើដោយរដ្ឋាភិបាល ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ និងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលដើម្បីផ្សព្វផ្សាយព័ត៌មានជាសាធារណៈ*) ។

៦០. *<u>អនុសាសន៍ ក.២</u> - លើកកំពស់លទ្ធភាពទទួលបានព័ត៌មានសាធារណៈដែលពាក់ព័ន្ធដោយផ្ទាល់នឹងសុខុមាលភាពប្រជាពលរដ្ឋ ជាពិសេសនៅថ្នាក់ក្រោមជាតិ (ថ្នាក់ឃុំ ស្រុក និងខេត្ត)*

ក) ណែនាំអោយមានវិធានការណ៍លើកកំពស់សេវាកម្មស៊ីវិលដែលមានតម្លាភាព និងយកអតិថិជនជាធំ ឧទាហរណ៍ : ណែនាំអោយប្រើក្រមនៃការអនុវត្តន៍ស្តីពីលទ្ធភាពទទួលបានព័ត៌មានពីរដ្ឋាភិបាល រៀបចំអោយមានយន្តការសំរាប់ចែករំលែកព័ត៌មាន (ដូចជា ការផ្សព្វផ្សាយដើម្បីប្រយោជន៍សាធារណៈនិងបង្កើតការិយាល័យផ្តល់ព័ត៌មាន និងដំបូន្មានដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន) និងការបង្កើតអោយមានគ្រឿងលើកទឹកចិត្ត (ដូចជា ការទទួលស្គាល់ជាផ្លូវការ និងមិនផ្លូវការ និងការជូនរង្វាន់លក្ខណៈវិនិច្ឆ័យ សំរាប់វាយតំលៃការអនុវត្តន៍ការងារ) សំរាប់មន្ត្រីរាជការដើម្បីសំរបសំរួលការទទួលបានព័ត៌មានព្រមទាំងការដាក់ទោសទណ្ឌទៅលើអ្នកដែលបង្កការរាំងស្ទះដល់ដំណើរការនេះ ។ (*សកម្មភាពគួរទៅខាងរដ្ឋាភិបាល និងមានការគាំទ្រពីដៃគូអភិវឌ្ឍន៍*)

ខ) ណែនាំដល់អ្នកផ្តល់សេវានៅតាមមូលដ្ឋាន អោយផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានអំពីថវិកា និងចំណាយរបស់មណ្ឌលសេវាក្នុងមូលដ្ឋាន (ដូចជា សាលារៀន និងមណ្ឌលសុខភាព) ។ (*សកម្មភាពគួរទៅខាងរដ្ឋាភិបាល*)

គ) លើកកំពស់ និងគាំទ្រដល់ការបង្កើតឡើងនូវប្រព័ន្ធផ្សព្វផ្សាយនៅថ្នាក់មូលដ្ឋាន ដើម្បីប្រយោជន៍សាធារណៈជន ។ ដូចគ្នានេះដែរ គប្បីពង្រីកបន្ថែមនូវគំនិតផ្តួចផ្តើមដែលមានស្រាប់ ដូចជាបណ្តាញទីប្រឹក្សាប្រជាពលរដ្ឋ ដើម្បីផ្តល់ការគាំទ្រផ្ទាល់ដល់ប្រជាពលរដ្ឋក្នុងសហគមន៍ក្នុងការស្វែងរកព័ត៌មានដែលគេត្រូវការ ។ (*សកម្មភាពគួរទៅខាងអង្គការសង្គមស៊ីវិល និងមានការគាំទ្រពីដៃគូអភិវឌ្ឍន៍*)

ឃ) បង្កលក្ខណៈអោយព័ត៌មាន និងដំណើរការរៀបចំផែនការថ្នាក់មូលដ្ឋាន ការគ្រប់គ្រងថវិកា និងការចំណាយ មានភាពបើកចំហ និងងាយស្រួលរកបានជាងមុន ។ អង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាល គួរគាំទ្រ និងឃ្លាំមើលថាតើក្រុមប្រឹក្សាឃុំ-សង្កាត់ អនុវត្តទៅតាមបទបញ្ញត្តិជាធរមាននៃការរៀបចំផែនការតាមបែបចូលរួម និងតម្លាភាពថវិកាដែរឬយ៉ាងណា ។ ក្រុម

ប្រឹក្សាឃុំ-សង្កាត់គួរផ្សព្វផ្សាយព័ត៌មានអំពីការរៀបចំផែនការ ថវិកា និងចំណាយ (តាមរយៈក្តារព័ត៌មានសាធារណៈ វេទិកាសាធារណៈ វិទ្យុនិងសារព័ត៌មាន) ។ (*សកម្មភាពនេះត្រូវទៅខាងអង្គការសង្គមស៊ីវិល រដ្ឋាភិបាលនិងក្រុមប្រឹក្សាឃុំ-សង្កាត់*)

៦១. <u>*អនុសាសន៍ក.៣*</u>*- ពង្រឹងចំណេះដឹងរបស់អង្គការសង្គមស៊ីវិលអំពីបញ្ហាសាធារណៈ និងកិច្ចការរបស់រដ្ឋាភិបាល ហើយកសាងសមត្ថភាពពួកគេក្នុងការធ្វើការសិក្សាស្រាវជ្រាវដោយឯករាជ្យ វិភាគ និងរៀបចំសំភារៈ IEC សំរាប់គោលបំណងការទទួលខុសត្រូវសង្គម ។*

ក) រៀបចំសិក្ខាសាលាសំរាប់ចែករំលែកព័ត៌មានតាមក្រុមគោលដៅ និងតាមវិស័យជាក់លាក់ ដើម្បីជួយដល់ប្រតិបត្តិករ និងសកម្មជនក្នុងអង្គការសង្គមស៊ីវិល អោយបានលើកកំពស់ចំណេះដឹងរបស់គេអំពីច្បាប់ គោលនយោបាយ នីតិវិធីរដ្ឋបាលសាធារណៈ ដំណើរការនៃការធ្វើសេចក្តីសំរេចចិត្ត ថវិកា និងកម្មវិធីនានាដែលពាក់ព័ន្ធ ។ សិក្ខាសាលាទាំងនេះអាចត្រូវរៀបចំ គាំទ្រ និងសំរបសំរួលដោយដៃគូអភិវឌ្ឍន៍ ប៉ុន្តែការចែករំលែកព័ត៌មានគប្បីត្រូវធ្វើឡើងដោយមន្ត្រីសាធារណៈ និងអ្នកឯកទេសតាមវិស័យដែលពាក់ព័ន្ធផ្ទាល់ ។ (*សកម្មភាពត្រូវទៅខាងអង្គការដែលគាំទ្រដល់អង្គការសង្គមស៊ីវិល ក្រោមកិច្ចសហការជាមួយអង្គការសង្គមស៊ីវិលផ្សេងទៀត ដែលមានចាប់អារម្មណ៍ ដៃគូអភិវឌ្ឍន៍ រាជរដ្ឋាភិបាល និងអ្នកឯកទេសដែលពាក់ព័ន្ធ*)

ខ) ផ្តល់ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ការបណ្តុះបណ្តាល និងឱកាសសំរាប់ការកសាងសមត្ថភាព ដើម្បីលើកកំពស់សមត្ថភាពរបស់អង្គការសង្គមស៊ីវិលក្នុងការស្រាវជ្រាវ វិភាគ ទំនាក់ទំនង និងធ្វើសកម្មភាពអប់រំសាធារណៈ ។ (*សកម្មភាពត្រូវទៅខាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល*)

គ) ផ្តល់មូលនិធិ (រយៈពេលវែង និងដោយពុំមានលក្ខខ័ណ្ឌពិសេស) ដល់បញ្ញវ័ន្ត និងអ្នកសិក្សាជាជនជាតិខ្មែរល្បីៗអោយរួបរួមគ្នាបង្កើតជាវិទ្យាស្ថានស្រាវជ្រាវឯករាជ្យពិតប្រាកដ មិនស្ថិតក្រោមឥទ្ធិពលរបៀបវារៈណាមួយពីខាងក្រៅ និងអាចបំផុសអោយមានការពិភាក្សាស៊ីជំរៅដោយឯករាជ្យ ផ្តល់ការគាំទ្រផ្នែកវិភាគ និងយុទ្ធសាស្ត្រដល់សកម្មជនក្នុងសហគមន៍ និងជួយកសាងសមត្ថភាពដល់អ្នកសិក្សានិងបញ្ញវ័ន្តជំនាន់ក្រោយៗ ។ (*សកម្មភាពត្រូវទៅខាងអ្នកសិក្សា និងបញ្ញវ័ន្ត ដោយមានជំនួយពីដៃគូអភិវឌ្ឍន៍*)

ឃ) លើកកំពស់ និង គាំទ្រភាពជាដៃគូ ដែលក្នុងនោះអង្គការសង្គមស៊ីវិលអាចធ្វើការក្រោមកិច្ចសហការជាមួយក្រសួងនានារបស់រដ្ឋ (ដូចជាក្រសួងកសិកម្ម, រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងសុខាភិបាល, ក្រសួងអប់រំ, ក្រសួងកិច្ចការនារី, ក្រសួងការងារ) ដើម្បីកែសំរួលនិងផ្សព្វផ្សាយព័ត៌មានសាធារណៈសំខាន់ៗ (ដូចជាខ្លឹមសារនៃច្បាប់និងគោលនយោបាយជាអាទិភាព) ។ (*សកម្មភាពត្រូវទៅខាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដោយមានការឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍*)

ង) លើកកំពស់ និងគាំទ្រដល់ទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល និងតួអង្គក្នុងប្រព័ន្ធផ្សព្វផ្សាយអោយមានលក្ខណៈកាន់តែរឹងមាំ ។ (*សកម្មភាពត្រូវទៅខាងអង្គការសង្គមស៊ីវិល និងតួអង្គក្នុងប្រព័ន្ធផ្សព្វផ្សាយ និងអាចមានការឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍*)

ច) គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់អង្គការសង្គមស៊ីវិល (ដូចជាគំរោងឃ្លាំមើលថវិកាជាតិរបស់អង្គការ NGO Forum) ដើម្បីកែសំរួលព័ត៌មានអំពីថវិកាអោយសាមញ្ញនិងបោះពុម្ពផ្សាយព័ត៌មានទាំងនោះ លើកកំពស់ "អក្ខរភាពផ្នែកថវិកា" ក្នុងចំណោមប្រជាពលរដ្ឋ ព្រមទាំងអភិវឌ្ឍនិងប្រើប្រាស់ជំនាញរបស់អង្គការសង្គមស៊ីវិលក្នុងការវិភាគ ការតស៊ូមតិ និងការឃ្លាំមើលថវិកា ។ សំរបសំរួល និងគាំទ្រសហគមន៍ គំនិតផ្តួចផ្តើមរបស់សង្គមស៊ីវិលក្នុងការឃ្លាំមើលការចំណាយ និងលទ្ធផលការងារ

(រៀនសូត្រនិងពង្រីកបន្ថែមនូវបទពិសោធន៍ដូចជាគណៈកម្មាធិការត្រួតពិនិត្យឃុំ-សង្កាត់ ដែលគាំទ្រដោយអង្គការ PACT)។
*(សកម្មភាពតំរូវទៅខាងអង្គការសង្គមស៊ីវិល ដោយមានការគាំទ្រពីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍)*

## ២.ខ. ការបញ្ចេញមតិ

៦២. **លទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការសំដែងនូវមតិយោបល់ សេចក្តីត្រូវការ និងការបារម្ភរបស់ពួកគេ ដើម្បីអោយអាជ្ញាធររដ្ឋាភិបាលដឹងកាន់តែច្បាស់ពីអាទិភាពរបស់ពួកគេ និងពីរបៀបបំរើប្រជាពលរដ្ឋអោយកាន់តែប្រសើរនោះ គឺជាផ្នែកចំបងមួយទៀតនៃការទទួលខុសត្រូវសង្គម ។** ប្រសិនបើប្រជាពលរដ្ឋមិនពេញចិត្តនឹងសេវាសាធារណៈដែលបានផ្តល់ ឬគិតថាសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន ប៉ុន្តែគេគ្មានវិធីដើម្បី "បញ្ចេញមតិ" អំពីការមិនសប្បាយចិត្ត និងការបារម្ភរបស់ពួកគេ នោះគេនឹងពុំសូវមានលទ្ធភាពធ្វើមានការផ្លាស់ប្តូរជាវិជ្ជមានសមទៅតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទេ ។ ជាថ្មីម្តងទៀត នៅក្នុងបរិបទកម្ពុជា ការស្រាវជ្រាវនេះបានរកឃើញទាំងឱកាសផង និងបញ្ហាប្រឈមផង ទាក់ទងនឹងការសំដែងមតិរបស់ប្រជាពលរដ្ឋនេះ ។ របកគំហើញ និងបញ្ហាសំខាន់ៗពាក់ព័ន្ធនឹង ១) **ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ** ២) **ការផ្តល់អំណាចដល់ប្រជាពលរដ្ឋ** ៣) **តួនាទីសំខាន់ៗរបស់អ្នកដឹកនាំនៅមូលដ្ឋាន** និង ៤) **កង្វះយន្តការសំរាប់ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ជាពិសេសខ្វះប្រព័ន្ធផ្សព្វផ្សាយនៅថ្នាក់ក្រោមជាតិ ។**

### ២.ខ.១. ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ

៦៣. **ប្រជាពលរដ្ឋកម្ពុជាពិតជាបានបង្ហាញនូវចំណាប់អារម្មណ៍ និងឆន្ទៈក្នុងការប្រើប្រាស់នូវមតិរបស់ពួកគេ** ដូចជាតាមរយៈការចូលរួមនៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ និងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ការបោះឆ្នោតគឺជាយន្តការមួយដ៏សំខាន់ដែលប្រជាពលរដ្ឋប្រើប្រាស់នូវមតិផ្នែកនយោបាយរបស់ពួកគេដោយជ្រើសរើសអ្នកតំណាងនយោបាយរបស់ខ្លួន សំដែងនូវចំណូលចិត្ត និងផ្តល់យោបល់ត្រលប់អំពីការអនុវត្តន៍ការងាររបស់រដ្ឋាភិបាល ។ អ្វីដែលគួរអោយរីករាយផងដែរនោះ អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិសាធារណៈជាង៧៥% បានអះអាងថា ពួកគេបានចូលរួមនៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងឆ្នាំ ២០០៧ (ជាតួលេខមួយដែលមានកំរិតខ្ពស់បើប្រៀបទៅនឹងអត្រានៃអ្នកចូលរួមបោះឆ្នោតនៅក្នុងប្រទេសអភិវឌ្ឍន៍ភាគច្រើន) ។ ដូចមានបង្ហាញនៅក្នុងរូបភាពទី១០ហើយ កំរិតនៃការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ ក៏មានលក្ខណៈគួរអោយចាប់អារម្មណ៍ផងដែរ ដោយក្នុងនោះមានអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិសាធារណៈជិតមួយភាគបីបានចូលរួមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ ។ អ្វីដែលគួរអោយកត់សំគាល់ផងដែរនោះ គឺពុំមានភាពខុសប្លែកគ្នាច្រើនរវាងបុរស និងស្ត្រីឡើយ ដោយអត្រានៃការចូលរួមនោះមានកំរិតខ្ពស់នៅក្នុងចំណោមស្ត្រីជាងបុរសបន្តិចបន្តួច (ស្ត្រី ៣០% និង បុរស ២៧%)។

៦៤. តែទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវនេះបានរកឃើញថា **ប្រជាពលរដ្ឋច្រើនតែចូលរួមបានច្រើន ប្រសិនបើពួកគេត្រូវបានអញ្ជើញជាផ្លូវការ និងអោយបានច្បាស់លាស់**[២៣] ។ ឧទាហរណ៍ បើទោះបីអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិប្រមាណ ៧០% ដឹងថាប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិចូលរួមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ក៏ដោយ (ដូចមានបង្ហាញជូននៅក្នុងរូបភាពទី១១)

---

[២៣] របកគំហើញនេះស្របគ្នានឹងការការរកឃើញរបស់ Pellini (Cambodia Development Review, 2005:10).

ហេតុផលដែលលើកឡើងច្រើនជាងគេបំផុតក្នុងការដែលគេ*មិន*ចូលរួម គឺការដែលពួកគាត់មិនត្រូវបានអញ្ជើញជាផ្លូវការ ។ ទោះជាយ៉ាងណាក៏ដោយ វាគួរអោយកត់សំគាល់ផងដែរថា ប្រជាពលរដ្ឋដែលមានអាយុលើស ៥០ ឆ្នាំក្នុងចំនួនប្រហែលពីរដងច្រើនជាងអ្នកដែលមានអាយុក្រោម ៣០ ឆ្នាំតែងលើកយកហេតុផលនេះមកអះអាង ក្នុងការដែលគេមិនបានចូលរួម ឯអ្នកដែលមានអាយុក្រោម ៣០ ឆ្នាំ អះអាងថាពួកគេ "មិនសូវមានពេល" (សូមមើលរូបភាព ទី១២) ។ អ្វីដែលសំខាន់ និងគួរជាទីពេញចិត្តដែរនោះគឺថា មានអ្នកឆ្លើយសំណួរក្នុងការស្ទាបស្ទង់មតិនោះតែមួយចំនួនតូចប៉ុណ្ណោះ (ជាមធ្យម៥,៣%) ពីគ្រប់ក្រុមអាយុទាំងអស់ដែលបានលើកហេតុផល "មិនសូវចាប់អារម្មណ៍" ថាជាមូលហេតុផលនៃការមិនចូលរួមរបស់ពួកគេ ។ ការសំភាសន៍ផ្ទាល់នៅតាមមូលដ្ឋានបានបង្ហាញអោយឃើញពីចេតនាដ៏មុតមាំក្នុងជៀសវាងការបដិសេធ ឬ "ការអាម៉ាស់មុខ" ហេតុនេះហើយប្រជាពលរដ្ឋរីករាយនឹងចូលរួម តែក្នុងករណីដែលមានសញ្ញាជាផ្លូវការច្បាស់លាស់ ថាពួកគេនឹងត្រូវបានទទួលស្វាគមន៍ដោយអាជ្ញាធរប៉ុណ្ណោះ ។ ឧទាហរណ៍ អ្នកចូលរួមនៅក្នុងក្រុមពិភាក្សាមួយនៅក្នុងខេត្តកំពង់ធំ ( *ស្រុកសន្ទុក* ) បង្ហាញនូវការសោកស្តាយដែលសមាជិករបស់សមាគមកសិកររបស់ពួកគាត់ ពុំធ្លាប់ចូលរួមនៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍឃុំ-សង្កាត់ ដោយសារតែពួកគាត់ពុំធ្លាប់បានទទួលការអញ្ជើញ ។ អ្នកចូលរួមនៅក្នុងក្រុមពិភាក្សាក្នុងខេត្តសៀមរាប ( *ស្រុកពួក*) ក៏លើកឡើងពីស្ថានភាពស្រដៀងគ្នានេះដែរថា ជាទូទៅប្រជាពលរដ្ឋសាមញ្ញមិនចូលរួមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំទេ ដោយសារពួកគាត់មិនធ្លាប់ត្រូវបានអញ្ជើញអោយចូលរួម ហើយពួកគាត់ខ្លាចគេបដិសេធមិនអោយចូលរួម ។ សូម្បីតែអ្នកដឹកនាំអង្គការសង្គមស៊ីវិលដែលចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ជាទៀងទាត់នោះ ក៏បានលើកឡើងពីភាពចាំបាច់ដែលគាត់ត្រូវមានការអញ្ជើញជាផ្លូវការផងដែរ ។

> "ប្រសិនបើពួកគេ [ក្រុមប្រឹក្សាឃុំ-សង្កាត់] មិនអញ្ជើញប្រជាជនដោយជូនជាលិខិតអញ្ជើញទេនោះ ប្រជាជននឹងមិនហ៊ានទៅចូលរួមទេ ។[...] ប្រសិនបើគេមិនបានអញ្ជើញខ្ញុំទេ នោះខ្ញុំមិនហ៊ានទៅទេ លុះត្រាតែគេអញ្ជើញខ្ញុំ [ទើបខ្ញុំទៅចូលរួម] ។" (ប្រធានសមាគមផ្តល់សាច់ប្រាក់មួយនៅក្នុងខេត្តកំពង់ធំ *ស្រុកស្ទោង*) ។

**រូបភាពទី១០ : ភាគរយនៃប្រជាពលរដ្ឋដែលបានចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់**




ប្រភព : CAS/WB, 2007

## រូបភាពទី១១ : ហេតុផលរបស់ប្រជាពលរដ្ឋក្នុងការមិនចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់




ប្រភព : CAS/WB, 2007

## រូបភាពទី១២ : ហេតុផលរបស់ប្រជាពលរដ្ឋក្នុងការមិនចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ (តាមអាយុ)




ប្រភព : CAS/WB, 2007

៦៥. **បើទោះបីជាអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនេះក្នុងចំនួនដ៏ច្រើនបានចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ក្តី ក៏ការចូលរួមរបស់ពួកគេ ភាគច្រើនមានភាពអកម្ម (គឺគ្រាន់តែស្តាប់)** ។ រូបភាពទី១២ បង្ហាញថា យោងតាមការស្ទាបស្ទង់មតិសាធារណៈ ប្រជាពលរដ្ឋមិនដល់ ១០% ផង (និងស្ត្រីតិចជាង១%) ដែលចូលរួមក្នុងកិច្ចប្រជុំបានឡើងនិយាយ ហើយប្រជាពលរដ្ឋក្នុងចំនួនតិចជាងនេះទៀតដែលហ៊ានលើកឡើងអំពីបញ្ហា សួរសំណួរ ឬធ្វើការទាមទារអ្វីមួយ ។ ចំណុចសំខាន់ដែលគេត្រូវការលិខិតអញ្ជើញជាផ្លូវការ និងភាពស្ទាក់ស្ទើររបស់គេក្នុងការនិយាយស្តី បង្ហាញអំពីឆន្ទៈរបស់ប្រជាពលរដ្ឋ ក្នុងការគោរពដល់អ្វីដែលអាជ្ញាធរសាធារណៈចង់បាន និងមិនចង់អោយគេយល់ឃើញថាជាពួកគាត់ជាអ្នកតំរូវឬ បំពានដែនអំណាច ។

**រូបភាពទី១៣ : ចរិតលក្ខណៈនៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់**




ប្រភព : CAS/WB, 2007

៦៦. ការស្រាវជ្រាវនេះបានរកឃើញថា **ប្រជាពលរដ្ឋសាមញ្ញមានភាពស្ទាក់ស្ទើរក្នុងការបង្ហាញដោយចំហនូវការមិនឯកភាពណាមួយ ឬការរិះគន់ចំពោះសកម្មភាពរបស់រដ្ឋាភិបាល ឬអាជ្ញាធរ** ។ ការសំភាសន៏ និងការពិភាក្សាតាមក្រុមនៅខេត្តចំនួនបួន បានបង្ហាញអោយដឹងថា អ្នកភូមិមិនមានសេចក្តីក្លាហានក្នុងការសួរដេញដោល ឬរិះគន់ការអនុវត្តន៏ការងាររបស់អាជ្ញាធរទេ ហើយយល់ថាការធ្វើដូច្នេះអាចនឹងធ្វើអោយអាជ្ញាធរមានការខឹងសម្បារ ឬធ្វើការសងសឹកណាមួយ ។ ប្រធានភូមិ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងមន្ត្រីដទៃទៀតក្នុងមូលដ្ឋានគឺជាជនដែលមានឥទ្ធិពលតាមរូបភាពជាច្រើននៃជីវិតរបស់សហគមន៏ ហើយប្រជាពលរដ្ឋមានការស្ទាក់ស្ទើរក្នុងការប្រថុយប្រថានធ្វើអោយថ្នាំងថ្នាក់ដល់ទំនាក់ទំនងរបស់ពួកគេជាមួយជនទាំងនោះ ដោយសារតែការសួរសំណួរបែបដេញដោល ឬលើកឡើងនូវបញ្ហាដែលមានលក្ខណៈរសើបនោះ ។ ការសំភាសន៏ និងការពិភាក្សាតាមក្រុមបានបង្ហាញអោយដឹងថា ប្រជាពលរដ្ឋមិនស្ទាក់ស្ទើរនឹងរិះគន់សេវាសាធារណៈដែលអន់ខ្សោយ ឬការរិះគន់ចំៗ ចំពោះការយល់ឃើញថាមានភាពអយុត្តិធម៌ណាមួយជាលក្ខណៈស្ងាត់នោះទេ ប៉ុន្តែពួកគេមានភាពស្ទាក់ស្ទើរក្នុងការធ្វើបែបនេះក្នុងទីសាធារណៈ ។ ទីប្រឹក្សាប្រជាពលរដ្ឋម្នាក់នៅក្នុងខេត្តកំពង់ចាម (*ស្រុកត្បូងឃ្មុំ*) បាននិយាយថា ប្រជាពលរដ្ឋរអ៊ូរទាំនៅពេលដែលពួកគេមិនពេញចិត្ត (ឧទាហរណ៏ ជាមួយនឹងការងាររបស់សាធារណការដែលមានគុណភាពអន់) ប៉ុន្តែ "ការរិះគន់បែបនេះច្រើនតែធ្វើឡើងពីក្រោយខ្នងអាជ្ញាធរប៉ុណ្ណោះ ហើយនៅក្នុងអង្គប្រជុំជាសាធារណៈ ប្រជាពលរដ្ឋមិនហ៊ាននិយាយស្តីអ្វីឡើយ" ។ ការសង្កេតស្រដៀងគ្នា

នេះដែរដោយជំនួយការមេភូមិម្នាក់ (និងជាសមាជិកសមាគមកសិករមួយ) ក្នុងខេត្តកំពង់ធំ (*ស្រុកសន្ទុក*) បានអោយដឹងថា "អ្នកភូមិមិននិយាយពីអ្វីដែលពួកគេមិនពេញចិត្តនៅចំពោះមុខប្រធានភូមិ ឬមេឃុំដោយផ្ទាល់នោះទេ ។ ពួកគេហ៊ាននិយាយតែពេលនៅពីក្រោយខ្នងអ្នកទាំងនោះប៉ុណ្ណោះ ។ ពួកគេមិនដែលលើកឡើងនូវបញ្ហាទាំងនោះជាសាធារណៈឡើយ ។"

៦៧. **មន្ត្រីសាធារណៈមិនមានភាពសាំទៅនឹងការពិនិត្យពិច័យ ឬរិះគន់ពីសំណាក់ប្រជាពលរដ្ឋ និងតំណាងអង្គការសង្គមស៊ីវិល លើការងាររបស់ពួកគេទេ ហើយការសំដែងនូវមតិយោបល់ដែលមានសភាពហ្មត់ចត់ ឬសូម្បីការចោទសួរជាសំណួរក៏ពុំត្រូវបានលើកទឹកចិត្ត ឬទទួលយកដែរ ។** យោងតាមអ្នកផ្តល់បទសំភាសន៍ និងអ្នកចូលរួមក្នុងក្រុមពិភាក្សាបានអោយដឹងថា សេរីភាពក្នុងការបញ្ចេញមតិពុំទាន់ត្រូវបានគោរព ឬការពារក្នុងលក្ខណៈជាប្រព័ន្ធនៅឡើយទេ ។ អ្នកដែលសួរសំណួរ រិះគន់ ឬ"រាយការណ៍អំពីស្ថានភាពអ្វីមួយ" តែងត្រូវបានអាជ្ញាធរចាត់ទុកជា "អ្នកញុះញង់" ឬជា "គណបក្សប្រឆាំង" ហើយជនបែបនោះត្រូវបានរាយការណ៍ថាអាចប្រឈមមុខទៅនឹងការតបតវិញ (ដូចជា មិនត្រូវបានគេរាប់រកក្នុងសង្គម មិនត្រូវបានផ្តល់ជូនសេវា ឬអាចមានរហូតដល់ការគំរាមកំហែងដល់រូបកាយផង) ។ អ្នកផ្តល់បទសំភាសន៍ បានរាយការណ៍អំពីករណីជាច្រើនដែលប្រជាពលទទួលរងផលវិបាកជាអវិជ្ជមានដោយសារពួកគេបានសំដែងការរិះគន់ ឬទស្សនៈផ្សេងពីអាជ្ញាធរ ។ ឧទាហរណ៍ ទាក់ទងនឹងប្រជាពលរដ្ឋមួយក្រុមដែលបានតវ៉ាប្រឆាំង ចំពោះការបណ្តេញពួកគេអោយទៅរស់នៅកន្លែងផ្សេង ដោយសារការស្ថាបនាផ្លូវថ្នល់ថ្មីមួយនៅក្បែរទីរួមខេត្តបាត់ដំបង អ្នកចូលរួមម្នាក់នៅក្នុងក្រុមពិភាក្សា[២៤] បានលើកឡើងថា "ពួកគេបានសំរេចចិត្តនិយាយ ដោយសារពួកគេប្រឈមទៅនឹងបញ្ហាធ្ងន់ធ្ងរ ។" សូម្បីតែអ្នកតំណាងអង្គការក្រៅរដ្ឋាភិបាល ក៏គិតថាគាត់ត្រូវបានរារាំងផងដែរ នៅពេលដែលមានវត្តមានអាជ្ញាធរច្រើន ហើយក៏ពុំហ៊ានធ្វើការជំទាស់ដោយចំហ ឬសួរសំណួរដែលធ្ងន់ធ្ងរ ("បង្កអោយមានការខឹងសម្បារ") ដែរ ។ ឧទាហរណ៍ អ្នកតំណាងសង្គមស៊ីវិលម្នាក់ (ក្នុងចំណោមសមាជិករដ្ឋាភិបាលចំនួន១៣នាក់) នៃគណៈកម្មការគណនេយ្យខេត្ត បាននិយាយថាគាត់មានអារម្មណ៍ "ចាញ់ច្រាប" និង "វាលខ្លួន" ដែលហេតុនេះហើយគាត់មិនហ៊ានសួរសំណួរដែលរសើប ឬនិយាយអ្វីដែលបង្កអោយមានការប៉ះពាល់ធ្ងន់ធ្ងរឡើយ ។

៦៨. បើទោះជាដូច្នេះក៏ដោយ ការស្រាវជ្រាវនេះក៏បានរកឃើញផងដែរថា **ដំណើរការវិមជ្ឈការបច្ចុប្បន្ន ផ្តល់នូវសក្តានុពលដ៏សំខាន់ក្នុងការជំរុញអោយមានការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយារបស់ប្រជាពលរដ្ឋ និងអាជ្ញាធរ ប្រសិនបើដំណើរការវិមជ្ឈការនេះត្រូវបានគ្រប់គ្រងអោយបានហ្មត់ចត់ ។** ឧទាហរណ៍ នៅក្នុងឃុំមួយក្នុងខេត្តកំពង់ធំ (*ស្រុកស្ទោង*) ក្រុមអ្នកស្រាវជ្រាវបានពើបប្រទះនូវបណ្តាញមួយនៃសមាគមបែបប្រពៃណីប្រកបដោយថាមភាព ដែលបណ្តាញនោះស្ថិតក្រោមសំរបសំរួលពីគណៈកម្មាធិការសំរបសំរួលវត្ត (PaCoCo) ។ គណៈកម្មការសំរបសំរួលវត្តនេះបានកសាងទំនាក់ទំនងល្អជាមួយក្រុមប្រឹក្សាឃុំ ហើយបានធ្វើទំនាក់ទំនងទៀងទាត់លើបញ្ហា ក្តីបារម្ភ និងសេចក្តីត្រូវការរបស់អ្នកភូមិ ។ ដូចមានរៀបរាប់ក្នុងប្រអប់ទី ៦ ខាងក្រោម ការប្រាស្រ័យទាក់ទងគ្នានេះគឺជាលទ្ធផលនៃដំណើរការដ៏យូរអង្វែង (ដែលមានការចូលរួមពីអង្គការក្រៅរដ្ឋាភិបាលចំនួនបួនដែលមានមូលដ្ឋាននៅក្នុងខេត្ត, គាំទ្រដោយអង្គការ GTZ) ដែលមានគោលបំណងពង្រឹងសមត្ថភាពរបស់សមាគមក្នុងមូលដ្ឋាន អង្គការសហគមន៍ អង្គការសង្គមស៊ីវិល ដើម្បីលើកកំពស់ និងសំរបសំរួលការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការសំរេចចិត្តនៅថ្នាក់ឃុំ ។

[២៤] រៀបចំដោយកម្មវិធី PECSA របស់ធនាគារពិភពលោក ក្នុងខែតុលា ២០០៧ ។

### ប្រអប់ទី៦ : ឧទាហរណ៍នៃការពង្រឹងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ នៅក្នុងបរិបទវិមជ្ឈការ

នៅក្នុងការពិភាក្សាតាមក្រុម និងការសំភាសន៍នៅខេត្តកំពង់ធំ ( *ស្រុកស្ទោង* ) អ្នកដឹកនាំសមាគមបានលើកឡើងអំពីការផ្លាស់ប្តូរឥរិយាបថរបស់អ្នកភូមិ និងរបស់អាជ្ញាធរនៅក្នុងឃុំរបស់ពួកគេ ។ បើតាមប្រធាន PaCoCo ការមានសិក្ខាសាលាបណ្តុះបណ្តាល និងការពិភាក្សាជាសាធារណៈអោយបានទៀងទាត់អំពីគោលការណ៍វិមជ្ឈការ បានជួយធ្វើអោយការប្រាស្រ័យទាក់ទងរវាងសមាគមមូលដ្ឋាន និងអ្នកដឹកនាំគណៈកម្មាធិការរបស់ក្រុមប្រឹក្សាឃុំ មានភាពល្អប្រសើរជាងមុន ។ ការណែនាំអោយមានការពិភាក្សាអំពីផែនការអភិវឌ្ឍន៍ឃុំនៅតាមភូមិ ដើម្បីបញ្ជូនយោបល់ និងសំណូមពរនានាទៅអោយក្រុមប្រឹក្សាឃុំ និងការចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំនោះ បានរួមចំណែកធ្វើអោយទំនាក់ទំនងរវាងអ្នកភូមិ និងអាជ្ញាធរមូលដ្ឋានកាន់តែប្រសើរឡើង ។ កាលពីមុនអ្នកភូមិមិនសប្បាយចិត្តពេលឃើញមន្ត្រីសាធារណៈចូលរួមនៅក្នុងគណៈកម្មាធិការសំរបសំរួល/បណ្តាញ និងមិនចង់អោយមន្ត្រីទាំងនោះចូលរួមឡើយ ។ ស្របពេលជាមួយគ្នានោះ អាជ្ញាធរបានគិតថាពួកគេកំពុងរងការគំរាមកំហែង ដោយសារមានកំណើននៃការចងបណ្តាញរបស់សមាគម និងការបង្កើនគណៈកម្មាធិការកាន់តែច្រើនឡើងៗ ។ ពួកគេភ័យខ្លាចថា អង្គការសង្គមស៊ីវិលដែលចូលរួមអាចរាយការណ៍ពីការរិះគន់ចំពោះការងាររបស់អាជ្ញាធរមូលដ្ឋានទៅថ្នាក់លើ ។ ឥឡូវនេះ ឥរិយាបថរបស់ភាគីទាំងសងខាង គឺអ្នកភូមិនិងអាជ្ញាធរមូលដ្ឋាន មានការផ្លាស់ប្តូរយ៉ាងច្រើន ។ មេឃុំទទួលស្គាល់ពីទំនាក់ទំនងល្អដែលសមាគមបានបង្កើតអោយមានជាមួយនឹងក្រុមប្រឹក្សាឃុំ តាមរយៈគណៈកម្មាធិការសំរបសំរួលវត្តអារាម ហើយបានសង្កត់ធ្ងន់ពីការទទួលផលប្រយោជន៍ទាំងសងខាង ។ ឧទាហរណ៍ ឥឡូវនេះក្រុមប្រឹក្សាឃុំមិនចាំបាច់ប្រមូលវិភាគទានពីអ្នកភូមិសំរាប់សកម្មភាពអភិវឌ្ឍន៍ឃុំដោយផ្ទាល់ពីប្រជាពលរដ្ឋនោះទេ ដោយសារពេលនេះវិភាគទានទាំងនេះ ត្រូវបានសំរបសំរួលតាមរយៈអ្នកដឹកនាំសមាគមសន្សំប្រាក់របស់ភូមិ ។ ទោះជាយ៉ាងណាក៏ដោយ ទំនាក់ទំនងនិងការការចូលរួមរបស់សមាគមបែបប្រពៃណីដើម្បីធ្វើអោយល្អប្រសើរដល់ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាលល្អបែបនេះ នៅមានភាពផុយស្រួយនៅឡើយ ហើយពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រជាប្រិយភាពនៃអ្នកដឹកនាំម្នាក់ៗ ក្នុងការកសាងទំនាក់ទំនងផ្ទាល់ខ្លួនទៅតាមឋានៈសង្គម និងការគោរពដែលគាត់ទទួលបាននៅក្នុងភូមិនិងឃុំ ។ សមាជិកក្រុមប្រឹក្សាឃុំមួយចំនួននៅតែមានអារម្មណ៍មិនសុខស្រួលនៅឡើយ ហើយយល់ថា "ត្រូវបានបណ្តាញភូមិ និងអ្នកដឹកនាំអង្គការសង្គមស៊ីវិលតាមចាប់កំហុស" នៅពេលដែលពួកគាត់ស្ថិតនៅក្រោមការឃ្លាំមើល និងរិះគន់ ។ ប៉ុន្តែមេឃុំក៏ទទួលស្គាល់ផងដែរថា ឥឡូវនេះអាជ្ញាធរមានការយល់ដឹងច្បាស់ជាងមុនច្រើនអំពីតំរូវការ និងទស្សនៈរបស់អ្នកភូមិ និងអំពីអ្វីដែលកំពុងកើតមានឡើងនៅក្នុងបណ្តាភូមិក្នុងឃុំ ។ បើទោះបីជាការគោរពគ្នាទៅវិញទៅមក និងការប្រាស្រ័យទាក់ទងគ្នាមានភាពល្អប្រសើរច្រើនជាងមុនក្តី ភាគីទាំងសងខាងដឹងថានៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីជំនះអារម្មណ៍បែកបាក់គ្នា និងការមិនជឿទុកចិត្តគ្នា ដែលតែងកើតឡើងដោយសារតែរចនាសម្ព័ន្ធបែបឋានានុក្រមនៃវិស័យសាធារណៈ និងឥទ្ធិពលនយោបាយនៃគណបក្សនៅក្នុងប្រទេសកម្ពុជា។

*ប្រភព:* CAS/WB, ២០០៧b

### ២.៦.២ ការផ្តល់អំណាចដល់ប្រជាពលរដ្ឋ

៦៩. **អាស្រ័យដោយបទដ្ឋានវប្បធម៌ និងគថភាពនយោបាយសង្គម ប្រជាពលរដ្ឋមិនសូវមានអំណាច និងសេចក្តីក្លាហានទៅលើសមត្ថភាពរបស់ខ្លួន (ទាំងជាលក្ខណៈបុគ្គល ឬសមូហភាព) ដើម្បីធ្វើអោយមានឥទ្ធិពលដល់ការសំរេចចិត្ត ឬអោយមានការផ្លាស់ប្តូរទេ ។** ឥរិយាបថបិតុនិយម ភាពជាក់ស្តែងនៃការគ្រប់គ្រងបែបចៅហ្វាយនាយ-កូនចៅ និងការភ័យខ្លាចចំពោះការតបតពីសំណាក់អាជ្ញាធរ ជាហេតុផលធ្វើអោយប្រជាពលរដ្ឋមានអារម្មណ៏ថាគ្មានអំណាច និងគ្មានពំនឹង ។ ឧទាហរណ៏ នៅពេលសួរថាតើប្រជាពលរដ្ឋសាមញ្ញអាចមានឥទ្ធិពលទៅលើការគ្រប់គ្រងថវិកាសាលារៀនតាមរយៈគណៈកម្មការទ្រទ្រង់សាលារៀនបានដែរ ឬយ៉ាងណានោះ អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិសាធារណភាគច្រើនបានឆ្លើយថាអត់ទេ ។ នៅពេលដែលសួរថា តើនរណាអាចការពារប្រជាពលរដ្ឋពីការបង់ប្រាក់ក្រៅផ្លូវការទៅអោយអាជ្ញាធរបាន? ចំលើយដ៏ខ្ពស់ជាងគេ (២៨%) ដែលគួរអោយភ្ញាក់ផ្អើលនោះ គឺថា "គ្មាននរណាម្នាក់ឡើយ" ដែលកត្តានេះបង្ហាញអោយឃើញពីអារម្មណ៏នៃភាពគ្មានពំនឹងដ៏ធំធេងនៅចំពោះមុខវត្តមាននៃប្រព័ន្ធគ្រប់គ្រងបែបចៅហ្វាយនាយ-កូនចៅ និងវប្បធម៌ជូនសគុណក្រៅផ្លូវការដែលបានចាក់ឬសយ៉ាងជ្រៅក្នុងសង្គមនេះ ។ ដូចមានបង្ហាញជូន នៅក្នុងរូបភាពទី១៣ហើយ ចំលើយខ្ពស់បន្ទាប់មកទៀត (២៣%នៃអ្នកចូលរួម) នោះគឺ "រដ្ឋាភិបាលថ្នាក់កណ្តាល" ដែលមានឥទ្ធិពលធ្វើអោយមានការផ្លាស់ប្តូរទៅលើទង្វើបែបនេះបាន ។ មានអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនោះប្រមាណតែ ៧% ប៉ុណ្ណោះ ដែលថាប្រជាពលរដ្ឋគួរធ្វើការ "ប្រឆាំងរួមគ្នា" ចំពោះទង្វើបែបនោះ ដែលជាថ្មីម្តងទៀតភាគរយនេះបង្ហាញអោយឃើញច្បាស់ពី ការយល់ដឹងតិចតួចអំពីអំណាចដែលប្រជាពលរដ្ឋត្រូវមាន និងផ្នត់គំនិតដ៏ជ្រាលជ្រៅដែលថា មានតែរដ្ឋាភិបាលប៉ុណ្ណោះ ជាពិសេសអាជ្ញាធរថ្នាក់លើ ដែលអាចធ្វើអោយមានការផ្លាស់ប្តូរបាន ។ នៅក្នុងកិច្ចសំភាសន៏ និងការពិភាក្សាតាមក្រុម អ្នកភូមិនិងបុគ្គលិក អង្គការក្រៅរដ្ឋាភិបាលថ្នាក់ខេត្ត បានសំដែងនូវទស្សនៈស្រដៀងគ្នានេះថា ប្រជាពលរដ្ឋពុំមានយន្តការដទៃណាឡើយ ហើយមានតែអាជ្ញាធរជាន់ខ្ពស់ប៉ុណ្ណោះ ដែលមានអំណាចផ្លាស់ប្តូរទំលាប់ទាំងនេះបាន ។ នៅពេលដែលសួរថាតើនរណាអាចមានឥទ្ធិពលទៅ លើការសំរេចចិត្តអំពីថវិកាជាតិ ចំលើយដូចក្នុងរូបភាពទី១៤បង្ហាញថា អ្នកឆ្លើយតបមិនដល់មួយភាគដប់ (៨,៧%) ផងដែល យល់ថាអង្គការក្រៅរដ្ឋាភិបាលអាចមានឥទ្ធិពលមួយចំនួន និង 0% បានឆ្លើយថាប្រជាពលរដ្ឋ ឬអង្គការសហគមន៏អាចមានឥទ្ធិពលទៅលើបញ្ហានេះ ។ ទំនុកចិត្តទៅលើឥទ្ធិពលរបស់តំណាងរាស្ត្រដែលជាប់ឆ្នោតក៏មានកំរិតទាបផងដែរ គឺប្រមាណត្រឹមមួយភាគបួន(២៦,៥%)នៃអ្នកឆ្លើយតបប៉ុណ្ណោះដែលយល់ឃើញថារដ្ឋសភាអាចមានឥទ្ធិពលទៅលើថវិកាជាតិ[២៥] ។ ប្រជាពលរដ្ឋភាគច្រើនបានបញ្ជាក់អោយដឹងថា មានតែនាយករដ្ឋមន្ត្រី (៤៤%) ឬ "រដ្ឋាភិបាលថ្នាក់កណ្តាល" (៣៦%) ប៉ុណ្ណោះដែលជាអ្នកធ្វើការសំរេចចិត្តលើបញ្ហានេះ ។ ការដែលប្រជាពលរដ្ឋខ្វះទំនុកចិត្តថាពួកគេ (ជាលក្ខណៈបុគ្គល ឬសមូហភាព) មិនអាចមានឥទ្ធិពលទៅលើការសំរេចចិត្តនៃវិស័យសាធារណៈនោះ គឺជាឧបសគ្គមួយដ៏ចំបងក្នុងការលើកកំពស់ការចូលរួមរបស់ប្រជា ពលរដ្ឋ និងការទទួលខុសត្រូវសង្គម ។

៧០. **ក្រុមស្ត្រី យុវជន និងប្រជាពលរដ្ឋក្រីក្រ មានបញ្ហាប្រឈមខ្លាំងជាងគេក្នុងការទទួលបានព័ត៌មាន បញ្ចេញមតិ និងការជះឥទ្ធិពលដើម្បីអោយមានការផ្លាស់ប្តូរ ។ គប្បីមានកិច្ចខិតខំប្រឹងប្រែងជាក់លាក់ និងចំគោលដៅ ដើម្បីពង្រឹងអំណាច និងគាំទ្រក្រុម**

---

[២៥] វាជាប្រការគួរអោយកត់សំគាល់ដែលថា ក្នុងចំណោម "ប្រជាពលរដ្ឋដែលក្រីក្រខ្លាំង" មានអ្នកឆ្លើយសំណួរត្រឹមតែ ៨%ប៉ុណ្ណោះ ដែលមានយល់ថា រដ្ឋសភា ឬរាជរដ្ឋាភិបាលថ្នាក់កណ្តាលអាចមានឥទ្ធិពលទៅលើថវិកាជាតិ ដោយឡែកមតិភាគច្រើនយល់ឃើញថា មានតែនាយករដ្ឋមន្ត្រីប៉ុណ្ណោះ ដែលមានឥទ្ធិពលទៅលើការសំរេចចិត្តយ៉ាងដូច្នេះ ។

**ដល់ក្រុមជំអភ័ព្វទាំងនេះ ។** បើទោះបីជាក្នុងពេលបច្ចុប្បន្ន មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួនតូចកំពុងមានកិច្ចខិតខំប្រឹងប្រែងនៅតាមសហគមន៍ដើម្បីផ្តល់អំណាច និងពង្រឹងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋយ៉ាងណាក្តី ក៏មានឧទាហរណ៍ល្អៗមួយចំនួនដែលយើងអាចយកមករៀនសូត្របាន (សូមមើលប្រអប់ទី២ ទី៦ ទី៨ និង ទី១០) ។

**រូបភាពទី១៤ : ទស្សនៈប្រជាពលរដ្ឋអំពីអ្នកដែលអាចការពារពួកគេពីការបង់ថ្លៃឈ្នួលក្រៅផ្លូវការទៅអោយអាជ្ញាធរ**




ប្រភព : CAS/WB, ២០០៧

**រូបភាពទី១៥ : ឥទ្ធិពលរបស់ប្រជាពលរដ្ឋទៅលើការសំរេចចិត្តអំពីថវិកាជាតិ**




ប្រភព : CAS/WB, ២០០៧

## ២.១.៣. ការពឹងផ្អែកយ៉ាងធំធេងទៅលើអ្នកដឹកនាំនៅមូលដ្ឋាន

៧១. ដោយសារប្រជាពលរដ្ឋមិនសូវមានអំណាច កង្វះទំនុកចិត្តលើស្ថាប័នសាធារណៈ និងនិន្នាការនៃការពឹងផ្អែកលើខ្សែរយៈ និងទំនាក់ទំនងផ្ទាល់ខ្លួន **ប្រជាពលរដ្ឋសាមញ្ញមានការពឹងផ្អែកយ៉ាងធំធេងទៅលើគំនិតផ្តួចផ្តើម និងអន្តរាគមន៍របស់អ្នកដឹកនាំនៅ**

**មូលដ្ឋាន** ។ បុគ្គលដែលមានឥទ្ធិពល (ដូចជាប្រធានភូមិ មេឃុំ អ្នកដឹកនាំសហគមន៍ ប្រធានសមាគម គ្រូបង្រៀន ។ល។) ដើរតួនាទីជាអន្តរការី និង "ជាអ្នកពាំនាំ "យ៉ាងសំខាន់បំផុត ។ ឧទាហរណ៍ : ដូចមានបង្ហាញជូននៅក្នុងរូបភាពទី ១៥ ហើយបើយោងតាមការស្ទាបស្ទង់មតិសាធារណៈ ប្រសិនបើប្រជាពលរដ្ឋមិនពេញចិត្តនឹងសេវាសាធារណៈណាមួយ គេច្រើនទៅរកប្រធានភូមិ ឬមេឃុំដើម្បីអោយជួយ ។ ជាការគួរអោយកត់សំគាល់បំផុតនោះគឺថា បន្ទាប់ពីមេភូមិ និងមេឃុំ ចំលើយក្នុងអត្រាខ្ពស់បន្ទាប់គឺ "គ្មាននរណាម្នាក់ឡើយ"![២៦] ។

៧២. នៅក្នុងការចុះសំភាសន៍តាមមូលដ្ឋាន **ប្រជាពលរដ្ឋតែងសង្កត់ធ្ងន់ពីតួនាទីដ៏ពិសេសរបស់ប្រធានភូមិ ក្នុងការផ្តួចផ្តើម សំរបសំរួល និងត្រួតពិនិត្យមើលសកម្មភាពក្នុងភូមិ** ហើយប្រជាពលរដ្ឋបាននិយាយដែរថាពួកគេកំរនឹងចូលរួមនៅក្នុងសកម្មភាពសហគមន៍ណាស់ ប្រសិនបើគ្មានការអញ្ជើញ ឬការអនុញ្ញាតពីប្រធានភូមិ ។

> "ប្រធានភូមិគឺជាអ្នកគៀងគរអ្នកភូមិអោយចូលរួមកិច្ចប្រជុំដំបូងជាមួយអង្គការសេដាក ហើយគាត់ក៏ជាជនបង្គោលម្នាក់ក្នុងចំណោមជនបង្គោលជាច្រើននៅក្នុងភូមិ ដែលបានផ្តួចផ្តើមបង្កើតសមាគមកសិករដែរ ។"
> *សមាជិកនៃសមាគមកសិករក្នុងខេត្តតាកែវ (ស្រុកត្រាំកក់)*

> "នៅពេលដែល KID រៀបចំវគ្គបណ្តុះបណ្តាល ប្រធានភូមិគឺជាអ្នកដែលផ្តល់ព័ត៌មាន និងប្រមូលអ្នកភូមិអោយចូលរួមនៅក្នុងកិច្ចប្រជុំ ។" *ទីប្រឹក្សាប្រជាពលរដ្ឋក្នុងខេត្តកំពង់ចាម (ស្រុកត្បូងឃ្មុំ)*

**រូបភាពទី១៦ : តើប្រជាពលរដ្ឋត្រូវប្តឹងទៅនរណាអំពីបញ្ហាសេវាសាធារណៈ?**




ប្រភព : CAS/WB, 2007

[២៦] អ្វីដែលគួរអោយកត់សំគាល់នោះគឺថា ចំលើយដែលថា "គ្មាននរណាម្នាក់"ជួយនោះ មានកំរិតទាបក្នុងចំណោមយុវជនវ័យក្មេងៗដែល មានអាយុពី១៨-៣០ឆ្នាំ (១៦%) បើធៀបទៅនឹងប្រជាជនដែលមានអាយុច្រើនជាង៥០ឆ្នាំ (៣៧%) ។ ប្រជាជនវ័យក្មេងៗច្រើនងាកទៅរក ជំនួយពីអង្គការក្រៅរដ្ឋាភិបាលច្រើនជាង ប៉ុន្តែជាទូទៅអ្នកដែលជ្រើសរើសយក "អង្គការក្រៅរដ្ឋាភិបាល " មានកំរិតទាប (ប្រមាណ១៣%) ក្នុងចំណោមគ្រប់ក្រុមអាយុ ហើយការស្រាវជ្រាវបែបគុណភាពបានអោយដឹងថា ចំលើយនេះប្រហែលជាចង្អុលបង្ហាញអំពីទំនាក់ទំនងផ្ទាល់ខ្លួនជាមួយបុគ្គលជាអ្នកដឹកនាំអង្គការក្រៅរដ្ឋាភិបាល (ជាជាងការស្វែងអន្តរាគមន៍ដែលមានលក្ខណៈស្ថាប័ន) ។

៧៣. **ក្រៅពីការពឹងផ្អែកយ៉ាងធំធេងទៅលើអ្នកដឹកនាំនៅតាមមូលដ្ឋាន ការស្រាវជ្រាវនេះក៏បានរកឃើញនូវចំណុចខ្សោយ និងបញ្ហាប្រឈមមួយចំនួនទៀតពាក់ព័ន្ធទៅនឹងការដឹកនាំ** រួមមានការដឹកនាំតាមបែបប្រពៃណីដែលមានលក្ខណៈផ្ដាច់ការពីថ្នាក់លើមកថ្នាក់ក្រោម និងមានលក្ខណៈបិតុនិយមនៅគ្រប់កំរិតថ្នាក់ (ផ្ទុយពីលក្ខណៈប្រជាធិបតេយ្យ "ពីក្រោមទៅលើ") តួនាទីដឹកនាំមានលក្ខណៈបុគ្គលនិយមខ្ពស់ (ជាជាងមានលក្ខណៈស្ថាប័ននិយម) និងនិន្នាការនៃការក្តោបក្តាប់តួនាទីដឹកនាំ (ឧទាហរណ៍ ប្រធានភូមិក៏ជាប្រធានសមាគមកសិករក្នុងមូលដ្ឋាន ។ល។) ។ អ្នកដឹកនាំជាច្រើននៅមូលដ្ឋាន (ទាំងក្នុងជួររដ្ឋាភិបាល និងសង្គមស៊ីវិល) មានឥរិយាបថបែបឋានានុក្រមផ្ដាច់ការថ្នាក់លើ-ថ្នាក់ក្រោម ហើយមិនសូវមានផ្នត់គំនិតដែលថា "ការដឹកនាំជាការបំរើសេវា" ឬ "ការទទួលខុសត្រូវចំពោះថ្នាក់ក្រោម" នោះទេ ។ ជាលទ្ធផល ជាជាងខិតខំពង្រឹងអំណាច ឬលើកកំពស់ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ អ្នកដឹកនាំជាច្រើនបានប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួន ដើម្បីធ្វើការសំរេចចិត្តជាឯកតោភាគី និងបង្កអោយមាន "ភាពលំអៀង" ដែលប្រការនេះរឹតតែបន្តធ្វើអោយប្រព័ន្ធគ្រប់គ្រងបែបគ្របដណ្តប់ និងបែបចៅហ្វាយនាយ-កូនចៅនោះនៅបន្តជានិរន្តរ៍ ។ អ្នកដឹកនាំនៅតាមមូលដ្ឋាន (ទាំងអាជ្ញាធរសាធារណៈ និងស្ថាប័នមិនមែនរដ្ឋ) ដែលមានការប្តេជ្ញាចិត្តពិតប្រាកដក្នុងការលើកកំពស់ ការអភិវឌ្ឍន៍តាមបែបចូលរួម និងការផ្ដល់អំណាចដល់ប្រជាពលរដ្ឋ តែងជួបបញ្ហាខ្វះសមត្ថភាព និងធនធាន គ្មានលទ្ធភាពទទួល បានការបណ្តុះបណ្តាល និងខ្វះការគាំទ្រ ។

## ២.១.៤. កង្វះយន្តការសំរាប់ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ

៧៤. **ក្រៅពីការបោះឆ្នោតនិងការចូលរួមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ មានឱកាស និងយន្តការតិចតួចសំរាប់ប្រជាពលរដ្ឋ-អង្គការសង្គមស៊ីវិលនៅថ្នាក់មូលដ្ឋានធ្វើការសំដែងមតិ និងការព្រួយបារម្ភរបស់គេជាសាធារណៈនោះ ។** កិច្ចសំភាសន៍ជាមួយអ្នកដឹកនាំ និងសមាជិកអង្គការសង្គមស៊ីវិលបង្ហាញអោយដឹងថា វេទិកាសាធារណៈ (ប្រសិនបើត្រូវបានរៀបចំដោយយកចិត្តទុកដាក់ក្នុងបំណងជំរុញ និងការពារសេរីភាពនៃការបញ្ចេញមតិ) នោះ ត្រូវបានគេមើលឃើញថាជាយន្តការមួយដ៏សំខាន់ ដើម្បីអោយប្រជាពលរដ្ឋអាចបញ្ចេញមតិយោបល់ និងបញ្ហានានាដោយចំហនៅចំពោះវត្តមានរបស់តំណាងរដ្ឋាភិបាល និងប្រជាពលរដ្ឋពាក់ព័ន្ធដទៃទៀត ។ ប្រជាពលរដ្ឋចូលចិត្តការប្រាស្រ័យទាក់ទងដោយផ្ទាល់បែបនេះ ជាជាងការបញ្ចេញមតិក្នុងទំរង់ជាការសរសេរក្នុងលក្ខណៈអនាមិក (ដូចជាប្រអប់ទទួលពាក្យបណ្តឹងនៅឃុំជាដើម) ។ ឧទាហរណ៍ វេទិកាថ្នាក់ឃុំដែលរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាលមានមូលដ្ឋាននៅក្នុងខេត្ត (គាំទ្រដោយ NDI) នៅមុនពេលបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ ២០០៧ ជាដើម មានប្រជាប្រិយភាពជាខ្លាំង ហើយបានទាក់ទាញមនុស្សជាច្រើនអោយចូលរួម ។ តែទោះជាយ៉ាងណាក្តី ការស្រាវជ្រាវនេះបានរកឃើញថា **វេទិកាសាធារណៈបែបនេះកំរនឹងមាននៅថ្នាក់មូលដ្ឋានណាស់ ។** វេទិកាសាធារណៈភាគច្រើនត្រូវបានរៀបចំដោយអង្គការក្រៅរដ្ឋាភិបាលដែលមានមូលដ្ឋាននៅក្នុងទីក្រុងភ្នំពេញ ហើយដោយសារតែមានធនធាន និងសមត្ថភាពរៀបចំតិចតួច វេទិកាសាធារណៈទាំងនោះច្រើនតែធ្វើឡើងនៅទីក្រុង ឯអ្នកចូលរួមត្រូវបានកំណត់ និងជ្រើសរើសដោយអង្គការដែលជាអ្នករៀបចំ ។ អង្គការមួយចំនួនតូច ដូចជាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា[២៧] និងមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម មានរៀបចំវេទិកា

---

[២៧] ឧទាហរណ៍ ពីឆ្នាំ ២០០៣ ដល់ ២០០៦ CCHR បានរៀបចំធ្វើវេទិកាសាធារណៈចំនួន ១៦៥ លើក នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ហើយភាគច្រើនផ្តោតលើបញ្ហាទំនាស់ដីធ្លី ។ (របាយការណ៍ប្រចាំឆ្នាំរបស់ CCHR 2005-2006:17)

សាធារណៈនៅតាមបណ្តាទីរួមខេត្តមួយចំនួន ប៉ុន្តែកំរនឹងមានការរៀបចំបែបនេះនៅតាមស្រុកណាស់ ហើយចំពោះ នៅថ្នាក់ឃុំ និងភូមិវិញ គឺស្ទើរតែគ្មានតែម្តង ។

៧៥. **នៅថ្នាក់ជាតិ អង្គការក្រៅរដ្ឋាភិបាលអាជីពធំៗ មានលទ្ធភាពប្រើប្រាស់យន្តការបញ្ចេញមតិច្រើន** (ដូចជាកិច្ចប្រជុំ សិក្ខាសាលា សន្និសីទសារព័ត៌មាន ការបោះពុម្ពផ្សាយ និងវិបសាយ) **ប៉ុន្តែទន្ទឹមនឹងនោះពួកគេក៏ប្រឈមទៅនឹងឧបសគ្គក្នុងការគៀងគរ និងបង្ហាញពីប្រជាប្រិយភាព និងជំរុញអោយមានការឆ្លើយតបពីរដ្ឋាភិបាលផងដែរ ។** បណ្តាញអង្គការក្រៅរដ្ឋាភិបាលធំៗមួយ ចំនួន (ដូចជា NGO Forum, NEP ឬ MEDiCAM) មានលទ្ធភាពក្នុងការទំនាក់ទំនងដោយផ្ទាល់ជាមួយមន្ត្រីរដ្ឋាភិបាលថ្នាក់កំពូលៗតាមរយៈការចូលរួមនៅក្នុងវេទិកា ដូចជាកិច្ចប្រជុំក្រុមការងារបច្ចេកទេស ឬកិច្ចប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិខេត្ត ។ បើទោះជាដូច្នេះក្តី ក្នុងពេលបច្ចុប្បន្ននេះ មានតែអង្គការក្រៅរដ្ឋាភិបាល "កំរិតខ្ពស់" មួយចំនួនតូចប៉ុណ្ណោះដែលមានលទ្ធភាពចូលរួមក្នុងវេទិកាបែបនេះ ហើយអង្គការទាំងនោះពឹងផ្អែកយ៉ាងខ្លាំងទៅលើមូលនិធិពីម្ចាស់ជំនួយ ម្ល៉ោះហើយក៏ទទួលឥទ្ធិពលពីម្ចាស់ជំនួយតាមការចាប់អារម្មណ៍និងអាទិភាពរបស់គេដែរ ។ ជាលទ្ធផល មតិរបស់អង្គការទាំងនោះពុំសូវឆ្លុះបញ្ចាំងអំពីសេចក្តីត្រូវការជាអាទិភាព និងក្តីបារម្ភរបស់សហគមន៍ឡើយ ។ ឧទាហរណ៍ ការស្រាវជ្រាវនេះបានរកឃើញថា បញ្ហានយោបាយសង្គមជាច្រើនដែលជាក្តីបារម្ភធំបំផុតរបស់ប្រជាពលរដ្ឋសាមញ្ញ (ឧទាហរណ៍ ការភ័យខ្លាចចំពោះឧក្រិដ្ឋកម្មដែលមានការគ្រោងទុក ការធ្វេសប្រហែសរបស់នគរបាលក្នុងការការពារប្រជាពលរដ្ឋក្រីក្រ និងចំណាកស្រុកដ៏ច្រើនសន្ធឹកសន្ធាប់របស់ប្រជាជនវ័យក្មេងពីទីជនបទមកទីក្រុង ឬទៅក្រៅប្រទេសដើម្បីស្វែងរកការងារធ្វើ) ពុំត្រូវបានយកចិត្តទុកដាក់ដោះស្រាយពីសំណាក់កម្មវិធីតស៊ូមតិរបស់អង្គការក្រៅរដ្ឋាភិបាលឡើយ ហើយភាគច្រើនបញ្ហាទាំងនោះមិនត្រូវបានលើកយកមកពិភាក្សាជាសាធារណៈទេ ឯប្រធានបទ "ក្តៅគគុក" មួយចំនួនតូច ដូចជាការរំលោភសិទ្ធិមនុស្ស និងទំនាស់អំពីដីសាធារណៈ ច្រើនតែជាមានភាពលប់លើរឿងរ៉ាវដទៃៗទៀត ។ អង្គការមួយចំនួនបានអោយដឹងថា វាជាការលំបាកសំរាប់អង្គការក្រៅរដ្ឋាភិបាល ក្នុងការមិន "បំរើសេចក្តីត្រូវការរបស់សហគមន៍អន្តរជាតិ" សោះនោះ ព្រោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍មិនតែងតែស្របជាមួយអាទិភាព និងសេចក្តីត្រូវការរបស់ម្ចាស់ជំនួយជានិច្ចកាលនោះទេ ។

៧៦. នៅក្នុងបណ្តាប្រទេសជាច្រើន **យន្តការដ៏សំខាន់មួយដែលប្រជាពលរដ្ឋប្រើប្រាស់ដើម្បីបញ្ចេញមតិយោបល់របស់គេ និងពិភាក្សាអំពីបញ្ហាសាធារណៈគឺប្រព័ន្ធផ្សព្វផ្សាយ ។** បទពិសោធន៍នានាបង្ហាញថា ស្ទើរគ្រប់គំនិតផ្តួចផ្តើមអំពីការទទួលខុសត្រូវសង្គមទាំងអស់ដែលទទួលបានជោគជ័យ សុទ្ធតែបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយជាលក្ខណៈយុទ្ធសាស្ត្រ ដើម្បីផ្សព្វផ្សាយព័ត៌មាន លើកកំពស់ការយល់ដឹងជុំវិញបញ្ហាដែលប៉ះពាល់ប្រយោជន៍សាធារណៈ សំដែងមតិយោបល់ និងបង្កើតអោយមាននូវសំពាធជាសាធារណៈ ។ ជាធម្មតាប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ តែងតែដើរតួជាកំលាំងចលករនាំមុខក្នុងការផ្តល់ព័ត៌មាន និងអប់រំប្រជាពលរដ្ឋ ឃ្លាំមើលការអនុវត្តការងាររបស់រដ្ឋាភិបាល និងបង្ហាញពីអំពើខុសឆ្គងទាំងឡាយ (Malena, 2004) ។ **តែទោះជាយ៉ាងនេះក្តី នៅកម្ពុជា មានកត្តាមួយចំនួនដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងការដើរតួជាយន្តការនៃការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ និងលើកកំពស់ការទទួលខុសត្រូវសង្គម ។**

៧៧. **បើទោះបីជាក្នុងពេលជាងមួយទសវត្សកន្លងមក វិស័យសារព័ត៌មានបានរីកធំធាត់គួរអោយកត់សំគាល់យ៉ាងណាក្តី**[២៨] **ក៏ប្រព័ន្ធផ្សព្វផ្សាយរបស់កម្ពុជា នៅតែបន្តមានមូលដ្ឋានតែក្នុងទីក្រុងភ្នំពេញស្ទើរតែទាំងអស់ ។** លើកលែងតែស្ថានីយ៍វិទ្យុសាធារណៈ និងវិទ្យុឯករាជ្យថ្នាក់តំបន់មួយចំនួន (ក្នុងខេត្តសៀមរាប កំពត និងភាគពាយ័ព្យ) គ្មានប្រព័ន្ធផ្សព្វផ្សាយណាដែលមានមូលដ្ឋាននៅក្រៅទីក្រុងភ្នំពេញឡើយ ។ ក្រៅពីនេះក៏គ្មានកាសែតណាដែលមានមូលដ្ឋាននៅក្រៅទីក្រុងភ្នំពេញដែរ នេះម្យ៉ាងគឺដោយសារគ្មានការដឹកនាំ និងម្យ៉ាងទៀតទំហំនៃការជាវកាសែតដែលមានបរិមាណតិចតួចនោះបានធ្វើអោយដំណើរការផ្នែកហិរញ្ញវត្ថុមិនអាចទៅរួច ។ ដូចដែលនឹងរៀបរាប់នៅក្នុងប្រអប់ទី៧ ខាងក្រោម សារព័ត៌មានថ្នាក់តំបន់តែមួយគត់ដែលធ្លាប់បានដំណើរការនៅក្នុងខេត្តចំនួន៤កាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ(*សំណេរថ្មី*) ត្រូវបង្ខំចិត្តដកត្រលប់មកទីក្រុងភ្នំពេញវិញ នៅពេលដែលការគាំទ្រពីម្ចាស់ជំនួយបានបញ្ចប់ទៅ និងទំហំនៃការលក់ពុំគ្រប់គ្រាន់អាចធានានិរន្តរភាពហិរញ្ញវត្ថុបាន ។ ប្រព័ន្ធផ្សព្វផ្សាយក្នុងមូលដ្ឋាន (ឧទាហរណ៍ វិទ្យុសហគមន៍) អាចជាឧបករណ៍ដ៏មានឥទ្ធិពលក្នុងការផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន អំពីបញ្ហាពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ឃុំ-ស្រុក និងផ្តល់ជាវេទិកាសំរាប់បុគ្គលនិងក្រុមចែករំលែកមតិយោបល់និងការបារម្ភរបស់ពួកគេជាសាធារណៈ ។ **ដោយសារកង្វះប្រព័ន្ធផ្សព្វផ្សាយថ្នាក់មូលដ្ឋានបែបនេះហើយ ទើបប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលនៅទីជនបទ និងសូម្បីនៅទីរួមស្រុកនិងខេត្ត ស្ទើរតែគ្មានមធ្យោបាយដើម្បីទទួលបានព័ត៌មានអំពីមូលដ្ឋាន ឬបញ្ចេញមតិរបស់ខ្លួនអោយគេលឺជាសាធារណៈ ឡើយ ។**

៧៨. ប្រព័ន្ធផ្សព្វផ្សាយមានសក្តានុពលកាន់តែច្រើនសំរាប់ជាយាននៃការសំដែងមតិរបស់ប្រជាជន នៅពេលដែលប្រព័ន្ធផ្សព្វផ្សាយនោះមានលក្ខណៈឆ្លើយឆ្លងទៅវិញទៅមក និងបើកចំហអោយមានការរួមចំណែកពីប្រជាពលរដ្ឋសាមញ្ញ និងតួអង្គដទៃៗទៀតក្នុងសង្គម ក្រៅពីរង្វង់នៃរដ្ឋាភិបាលឬអ្នកជំនួញថ្នាក់ខ្ពស់ ។ នៅកម្ពុជា**បច្ចុប្បន្ននេះ ពុំមានប្រព័ន្ធផ្សព្វផ្សាយណាមួយដែលចាត់ចែងដោយប្រជាពលរដ្ឋ ឬសហគមន៍ឡើយ ហើយប្រភេទនៃប្រព័ន្ធផ្សព្វផ្សាយបែបឆ្លើយឆ្លង (ដែលប្រជាពលរដ្ឋសាមញ្ញអាចបញ្ចេញទស្សនៈ សួរសំណួរ និងប្រាស្រ័យទាក់ទងជាមួយផ្នែកសាធារណៈ) នេះមានតែនៅតាមកម្មវិធីសំណេះសំណាលតាមទូរស័ព្ទរបស់វិទ្យុឯករាជ្យមួយចំនួនតូចប៉ុណ្ណោះ ។** ការចំណាយលើថ្លៃទិញទូរស័ព្ទ និងលទ្ធភាពក្នុងការហៅទូរស័ព្ទចេញបាន មានន័យថាកម្មវិធីសំណេះសំណាលតាមទូរស័ព្ទ គឺសំរាប់តែអ្នកចូលរួមជាប្រចាំមួយចំនួនតូចដែលរស់នៅទីក្រុង និងមានជីវភាពធូធារប៉ុណ្ណោះ ឯជនក្រីក្រ ឬអ្នកដែលរស់នៅទីជនបទនៅតែគ្មានមធ្យោយបញ្ចេញមតិរបស់ខ្លួនអោយគេលឺជាសាធារណៈដដែល ។ វិទ្យុជាតិកម្ពុជាដែលជាស្ថានីយវិទ្យុរបស់រដ្ឋនោះ ក៏បានចាប់ផ្តើមកម្មវិធីសំណេះសំណាលតាមទូរស័ព្ទនេះដែរ កាលពីពេលថ្មីៗនេះ ហើយអាចផ្តល់ការហៅទូរស័ព្ទត្រលប់ទៅអ្នកចូលរួមវិញ ប្រសិនបើគេបានទុកលេខទូរស័ព្ទអោយ ដែលទង្វើបែបនេះជួយកាត់បន្ថយចំណាយទូរស័ព្ទរបស់អ្នកចូលរួមក្នុងកម្មវិធី ។

---

[២៨] នៅដើមទសវត្សឆ្នាំ១៩៩០ មានស្ថានីយទូរទស្សន៍ ១ ស្ថានីយវិទ្យុ ៣ និងសារព័ត៌មានមួយចំនួនតូចប៉ុណ្ណោះ (Weiss, 2004:3) ។ សព្វថ្ងៃនេះ កម្ពុជាមានប៉ុស្តិ៍ទូរទស្សន៍ជាច្រើន ស្ថានីយវិទ្យុចំនួន២០ (Freedom House, 2006) និងសារព័ត៌មាន/ទស្សនាវដ្តីប្រមាណ២០០ (កិច្ចសំភាសន៍ជាមួយនិពន្ធនាយកសារព័ត៌មានសំណេរថ្មី ០២ ឧសភា ២០០៧) ។

**ប្រអប់ទី៧ : ឧទាហរណ៍នៃការបោះពុម្ពផ្សាយតាមតំបន់ដើម្បីជាយន្តការបញ្ចេញមតិរបស់ប្រជាពលរដ្ឋមូលដ្ឋាន**

បង្កើតឡើងនៅក្នុងឆ្នាំ ២004 ដោយក្រុមហ៊ុនប្រឹក្សា និងអភិវឌ្ឍន៏សារព័ត៌មាន (MCD) ដំបូងឡើយសារព័ត៌មាន *សំណេរថ្មី* ទទួលការឧបត្ថម្ភថវិកាពី USAID តាមរយៈមូលនិធិអាស៊ី និងជំនួយពីមូលនិធិ Soros Foundation ដើម្បីបង្កើតគំរោងសាកល្បងមួយ ដែលមានគោលបំណងបង្កើតប្រភពព័ត៌មាន និងយន្តការបញ្ចេញមតិរបស់ប្រជាជននៅថ្នាក់មូលដ្ឋាន ។ អ្នកយកព័ត៌មានពីរនាក់នៅក្នុងខេត្តចំនួនបួន (កំពង់ចាម សៀមរាប បាត់ដំបង និង ក្រុងព្រះសីហនុ) ប្រមូលព័ត៌មានពីថ្នាក់ស្រុក និងឃុំ សំភាសន៏ជាមួយអាជ្ញាធរមូលដ្ឋាន និងតំណាងរបស់សង្គមស៊ីវិល ហើយសរសេរអត្ថបទប្រចាំសប្តាហ៏អំពីការងារមួយចំនួនដូចជា សកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន កិច្ចខំប្រឹងប្រែងផ្នែកវិមជ្ឈការ បញ្ហាផ្នែកកសិកម្ម សុខុមាលភាពសង្គម និងព្រឹត្តិការណ៏អភិវឌ្ឍន៏ថ្នាក់មូលដ្ឋាន ។ សារព័ត៌មាននេះមានគោលបំណងជួយអ្នករស់នៅតាមមូលដ្ឋាន (រួមទាំងអាជ្ញាធរមូលដ្ឋាន និងអ្នកដឹកនាំអង្គការសង្គមស៊ីវិលតាមមូលដ្ឋានផង) អោយបង្កើតឡើងនូវការយល់ដឹងរួមគ្នាកាន់តែរឹងមាំអំពីបញ្ហា ព្រឹត្តិការណ៏ ការព្រួយបារម្ភ និងការអភិវឌ្ឍន៏នានាដែលកើតមាននៅនឹងមូលដ្ឋាន ។ នៅក្នុងកំឡុងពេលមានជំនួយមូលនិធិពេញលេញ *សំណេរថ្មី* ចែកចាយសារព័ត៌មានចំនួន ១០.000 ច្បាប់ជារៀងរាល់សប្តាហ៏ (ខ្លះដោយមិនគិតថ្លៃ) ទៅតាមបណ្តាស្រុកក្នុងខេត្តគោលដៅ ។ ការចាប់ផ្តើមមុនដំបូងមិនមែនជាការងាយស្រួលឡើយ ។ នៅពេលចាប់ផ្តើមដំបូង អាជ្ញាធរមូលដ្ឋានសង្ស័យ និងស្ទាក់ស្ទើរមិនចង់សហការជាមួយអ្នកយកព័ត៌មាន និងមិនចង់ផ្តល់បទសំភាសន៏ ឬផ្តល់ព័ត៌មានពាក់ព័ន្ធនឹងបញ្ហាជាក់លាក់នៅក្នុងមូលដ្ឋានឡើយ។ អតិថិជនភាគច្រើនគឺជាអង្គការក្រៅរដ្ឋាភិបាលនៅមូលដ្ឋាន ហើយមានប្រជាជនធម្មតាតិចតួចណាស់ដែលជាវកាសែតនេះ ។ បន្ទាប់ពីចេញផ្សាយអស់រយៈពេលជាងមួយឆ្នាំមក ឥរិយាបថមានការផ្លាស់ប្តូរបន្តិចម្តងៗ ។ ប្រជាពលរដ្ឋកាន់តែច្រើនបានដឹងថាព័ត៌មានផ្តល់ដោយសារព័ត៌មាននេះមានសារៈប្រយោជន៏អោយពួកគេស្វែងយល់ពីស្ថានភាពថ្មីៗដែលកើតឡើងជុំវិញខ្លួនគេ និងអំពីអ្វីដែលកំពុងកើតមានឡើងនៅក្នុងឃុំ និងស្រុករបស់ពួកគេ ។ អ្នកខ្លះក៏ដឹងផងដែរថា សារព័ត៌មានថ្នាក់មូលដ្ឋាននេះគឺជាមធ្យោបាយដ៏ល្អមួយដើម្បីពាំនាំអោយអាជ្ញាធរ (ជាពិសេសអាជ្ញាធរខេត្ត) បានដឹងពីការព្រួយបារម្ភរបស់ពួកគេ ហើយពួកគេបានស្នើអោយសារព័ត៌មាននេះចេញផ្សាយពីរឿងរ៉ាវនេះឬរឿងនោះកាន់តែច្រើនឡើងៗ ដូចជាការត្អូញត្អែរអំពីកង្វះទីផ្សារដើម្បីលក់ផលិតផលកសិកម្មនៅក្នុងតំបន់ជាដើម ។ ស្របពេលជាមួយគ្នានេះដែរអាជ្ញាធរមូលដ្ឋាន (ជាពិសេសនៅថ្នាក់ខេត្ត) កាន់តែចាប់អារម្មណ៏ឡើងៗចំពោះសារព័ត៌មានថ្នាក់មូលដ្ឋាននេះ ព្រោះជាប្រភពព័ត៌មានច្បាស់ការណ៏អំពី អារម្មណ៏ និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋនៅក្នុងស្រុក និងឃុំរបស់ពួកគេ ។ ប៉ុន្តែគេនៅតែមានការស្ទាក់ស្ទើរក្នុងការទិញសារ-ព័ត៌មាននេះ ។ សូម្បីតែនៅតាមទីប្រជុំ ជនខេត្តនិងស្រុក ក៏មានប្រជាជនតិចតួចប៉ុណ្ណោះដែលចង់ចំណាយថវិកា ២000 រៀល ដើម្បីជាវសារព័ត៌មានប្រចាំសប្តាហ៏នេះ ។ នៅពេលដែលថវិកាឧបត្ថម្ភពីខាងក្រៅត្រូវបានកាត់ផ្តាច់ *សំណេរថ្មី* មិនអាចបន្តដំណើរការនៅតាមខេត្តទាំងនេះបានទៀតឡើយ ។ បច្ចុប្បន្នសារព័ត៌មាននេះផ្តោតលើព្រឹត្តិការណ៏ថ្នាក់ជាតិ ហើយមានលក់តែនៅក្នុងទីក្រុងភ្នំពេញ និងខេត្តសៀមរាបប៉ុណ្ណោះ ។

*ប្រភព: CAS/WB, ២00៧b*

៧៩. **សេរីភាពសារព័ត៌មានក្នុងប្រទេសកម្ពុជាមិនទាន់ត្រូវបានទទួលស្គាល់ពេញលេញនៅឡើយទេ ហើយក៏មិនត្រូវបានការពារដែរ ។** ប្រព័ន្ធផ្សព្វផ្សាយត្រូវបានអ្នកនយោបាយជាន់ខ្ពស់ប្រើប្រាស់ជាយូរយាណាស់មកហើយ សំរាប់ជាឧបករណ៏ពង្រឹងអំណាច និងការឃោសនា ហើយប្រព័ន្ធផ្សព្វផ្សាយក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន នៅតែបន្តស្ថិតក្រោមការគ្រប់គ្រងផ្នែកនយោបាយយ៉ាងតឹងរ៉ឹង និង/ឬមានការស្វ័យត្រួតពិនិត្យយ៉ាងហ្មត់ចត់ (Weiss, 2004:4-8) ។ បច្ចុប្បន្ននេះប្រព័ន្ធផ្សព្វផ្សាយមួយចំនួនធំក្នុងប្រទេសកម្ពុជា ពឹងផ្អែកទៅលើការឧបត្ថម្ភមូលនិធិពីអ្នកដឹកនាំនយោបាយ ដែលកត្តានេះឆ្លុះបញ្ចាំងអោយឃើញយ៉ាងច្បាស់អំពីភាពលំអៀង និងការប្រកាន់បក្សពួក ។ ប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស ជាពិសេសទូរទស្សន៍ ត្រូវបានក្តោបក្តាប់យ៉ាងលើសលប់ដោយគណៈបក្សប្រជាជនកម្ពុជា ដែលជាគណៈបក្សកំពុងកាន់អំណាច ហើយផ្តល់ឱកាសតិចតួចបំផុតសំរាប់ការចោទសួរ ឬរិះគន់រដ្ឋាភិបាល (Un, 2004; SIDA, 2006) ។ ប្រព័ន្ធផ្សព្វផ្សាយតាមរយៈការបោះពុម្ពមានសេរីភាពច្រើនបង្គួរនិង បើកចំហចំពោះគ្រប់គណៈបក្សនយោបាយធំៗទាំងអស់ ប៉ុន្តែមានតែនៅតំបន់ទីក្រុងប៉ុណ្ណោះ និងបានចែកចាយទៅដល់ប្រជាពលរដ្ឋមិនដល់ ១០% ផងដែលក្នុងនោះភាគច្រើនគឺសំរាប់ក្រុមដែលមានជីវភាពធូរធារ និងអ្នកមានកំរិតវប្បធម៌ខ្ពស់ ។ តែទោះជាយ៉ាងណាក្តី សារព័ត៌មានជាភាសាខ្មែរពីរដែលធំជាងគេ និងដែលមានអ្នកអានច្រើនជាងគេបំផុតនោះ ត្រូវបានចាត់ទុកថាជាសារព័ត៌មានដែលគាំទ្រគណៈបក្សកាន់អំណាច និងពុំមាននិន្នាការចុះផ្សាយបញ្ហាដែលមានលក្ខណៈរសើប ឬផ្តល់ឱកាសអោយមានការសំដែងមតិដែលមិនពេញចិត្ត ឬដែលផ្ទុយពីទស្សនៈរបស់រដ្ឋាភិបាលឡើយ ។ សារព័ត៌មានជាភាសា អង់គ្លេសមានសេរីភាពច្រើនជាងសារព័ត៌មានជាភាសាខ្មែរក្នុងស្រុក ប៉ុន្តែក៏ហាក់នៅមានភាពប្រុងប្រយ័ត្នក្នុងការរាយការណ៍អំពី បញ្ហាដែលមានលក្ខណៈរសើប (ដូចជាអំពើពុករលួយ) ហើយកំពុងប្រឈមនឹងឧបសគ្គក្នុងការស្វែងរកព័ត៌មានដែលត្រឹមត្រូវ និង ត្រូវបានអានដោយប្រជាជនខ្មែរមួយចំនួនតូចប៉ុណ្ណោះ (ភាគច្រើនអ្នកទីក្រុងដែលមានកំរិតវប្បធម៌ខ្ពស់) ។

៨០. **អ្នកសារព័ត៌មានមួយចំនួនតូចដែលយកព័ត៌មានបែបស្រាវជ្រាវទាក់ទងនឹងផលប្រយោជន៏សាធារណៈ តែងជួបប្រទះការអុកឡុកការគំរាមកំហែង និងសំពាធអោយបង្ហាញពីប្រភពព័ត៌មានរបស់ពួកគេ** នៅពេលដែលមានឥស្សរជននយោបាយ ឬមន្ត្រីរដ្ឋាភិបាលដែលមានអំណាចមានពាក់ព័ន្ធទៅនឹងរឿងអាស្រូវអំពើពុករលួយ ការរឹបអូសដីធ្លី ឬការគ្រប់គ្រងធនធានសាធារណៈមិនបានត្រឹមត្រូវនោះ ។ វាគឺជារឿងធម្មតាដែលអ្នកសារព័ត៌មានដែលរិះគន់រដ្ឋាភិបាលត្រូវប្រឈមទៅនឹងបណ្តឹងរដ្ឋប្បវេណីរបស់រដ្ឋាភិបាល និងការយកមកកាត់ទោសក្រោមឥទ្ធិពលនយោបាយពីបទបរិហាកេរ្តិ៍ (ផ្អែកលើបញ្ញត្តិច្បាប់មួយចំនួនដែលមានលក្ខណៈមិនច្បាស់លាស់ និងមានភាពចំរូងចំរាស់) ក្នុងក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីរបបសារព័ត៌មាន និងច្បាប់ប្រឆាំងការផ្សព្វផ្សាយព័ត៌មានមិនពិត[២៩] ។ ក្នុងករណីខ្លះ អ្នកសារព័ត៌មានត្រូវបានឃុំខ្លួន និងព្យួរការងារដោយសារតែពួកគេរិះគន់សកម្មភាពរដ្ឋាភិបាល[៣០] ។ គ្មានការត្រួតពិនិត្យផ្ទាល់ ដើម្បីដកចេញនូវខ្លឹមសារដែលមានលក្ខណៈរសើបពីសារព័ត៌មាននោះទេ ប៉ុន្តែការប្រើប្រាស់ច្បាប់បរិហារ កេរ្តិ៍តាមទំនើងចិត្តបានបង្ខំអោយអ្នកសារព័ត៌មានធ្វើស្វ័យត្រួតពិនិត្យលើខ្លឹមសារដែលខ្លួនត្រូវផ្សព្វផ្សាយ ដើម្បីជៀសវាងបង្កផលប៉ះពាល់ដល់អ្នកដទៃ ហើយកត្តានេះក៏រារាំងអ្នកសារព័ត៌មានពីការរាយការណ៍អំពីករណីដែលរសើបផងដែរ ។

---

[២៩] ចន្លោះឆ្នាំ ២០០៣ និង២០០៤ រដ្ឋាភិបាល ឬមន្ត្រីរដ្ឋាភិបាលបានដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌពីបទបរិហារកេរ្តិ៍ យ៉ាងហោចណាស់ចំនួន ៨ ករណី ចោទប្រកាន់អ្នកតំណាងប្រព័ន្ធផ្សព្វផ្សាយ (SIDA, 2006:7) ។

[៣០] ឧទាហរណ៍ ក្នុងឆ្នាំ២០០៥ ម្ចាស់ស្ថានីយវិទ្យុសំបុកឃ្មុំ (FM 105) ដែលជាវិទ្យុឯករាជ្យ និងមានប្រជាប្រិយភាព ត្រូវបានឃុំខ្លួនបន្ទាប់ពីបានផ្សព្វផ្សាយកម្មវិធីមួយដែលសំដែងទស្សនៈតិះទៀនកិច្ចព្រមព្រៀងព្រំដែនមួយរវាងរដ្ឋាភិបាល និងប្រទេសវៀតណាម ។ បើទោះបីជាគាត់ត្រូវបានដោះលែងក្នុងរយៈពេលប៉ុន្មានខែក្រោយមកក៏ដោយ ការចាប់ខ្លួនគាត់បានជះឥទ្ធិពលបែបគំរាមកំហែងមួយទៅលើបរិយាកាសដែលប្រព័ន្ធផ្សព្វផ្សាយឯករាជ្យកំពុងដំណើរការ ។

៨១. **នៅក្នុងទសវត្សកន្លងមក សមត្ថភាពរបស់ប្រព័ន្ធផ្សព្វផ្សាយមានការរីកចំរើនគួរអោយកត់សំគាល់ ផ្នែកសំភារៈ ការបណ្តុះបណ្តាល និងការបង្កើតកម្មវិធី ។** ដោយមានជំនួយពីបរទេស ដេប៉ាតឺម៉ង់សារព័ត៌មានវិទ្យា និងទំនាក់ទំនងនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានបណ្តុះបណ្តាលអ្នកសារព័ត៌មានជំនាន់ដំបូងដ៏មានសមត្ថភាព (ទាំងផ្នែកបោះពុម្ព និងការផ្សាយតាមរលកធាតុអាកាស) ។ ដេប៉ាតឺម៉ង់នេះ បានចូលរួមនៅក្នុងកិច្ចខិតខំប្រឹងប្រែងកសាងវិជ្ជាជីវៈនេះទាំងសំរាប់អ្នកសារព័ត៌មានថ្មី និងអ្នកដែលមានបទពិសោធន៏ស្រាប់ ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដូចជាអង្គការ PACT Cambodia ក៏បានចូលរួមយ៉ាងសកម្មក្នុងការផ្តល់ការបណ្តុះបណ្តាលដល់អ្នកសារព័ត៌មានកម្ពុជា ក្នុងបំណងលើកកំពស់ការរាយការណ៏អោយមានតម្លាភាពបន្ថែមទៀត និងជំរុញអោយមានការយកព័ត៌មានបែបស៊ើបអង្កេត ។ **បើទោះបីជាមានការរីកចំរើនបែបនេះក៏ដោយ ក៏គុណភាព និងកិត្តិស័ព្ទជារួមនៃទង្វើបែបនេះក្នុងផ្នែកសារព័ត៌មាននៅមានកំរិតទាបនៅឡើយ** (Bou and Salazar, 2005) **។** អ្នកសារព័ត៌មានជាច្រើនមានប្រាក់បៀវត្សរ៏តិចតួច ដែលហេតុនេះហើយពួកគេងាយនឹងទទួលយកការសូកប៉ាន់ ដើម្បីបញ្ចេញ ឬលាក់បាំងរឿងរ៉ាវអ្វីមួយ (SIDA, 2006:7) ។ អ្នកអង្កេតការណ៏មួយចំនួនបានកត់សំគាល់ថា អ្នកសារព័ត៌មានខ្មែរជាច្រើនរៀបចំការផ្សព្វផ្សាយរបស់ខ្លួនអាស្រ័យទៅតាមប្រការដែលថាអ្នកណាជាអ្នកផ្តល់ការឧបត្ថម្ភថវិកាដល់ពួកគេ ជាជាងផ្អែកលើគោលការណ៏នៃការពិត និងគោលការណ៏វិជ្ជាជីវៈនោះ (Transparency International, 2006:27) ។ យោងតាមនិពន្ធនាយករបស់ទស្សនាវដ្តីប្រចាំសប្តាហ៏មួយបានអោយដឹងថា "អ្នកសារព័ត៌មានមួយចំនួនថែមទាំងបានជំរិតទារប្រាក់ពីប្រជាជនដោយគំរាមចុះផ្សាយអត្ថបទដែលប៉ះពាល់ធ្ងន់ធ្ងរ ឬសូម្បីព័ត៌មានមិនពិតផងក៏មាន ដែលប្រការនេះធ្វើអោយខូចដល់កិត្យានុភាពវិជ្ជាជីវៈសារព័ត៌មានទាំងមូលតែម្តង ។" ឥរិយាបថគ្មានក្រមសីលធម៌ ឬគ្មានវិជ្ជាជីវៈរបស់អ្នកសារព័ត៌មានជាច្រើននោះ បានធ្វើអោយការចោទប្រកាន់លើប្រព័ន្ធផ្សព្វផ្សាយ ដែលមានប្រវត្តិមិនសូវល្អស្រាប់ និងការបដិសេធពីរដ្ឋាភិបាល នៅមានបន្តទៅទៀត ។ ការផ្សព្វផ្សាយអត្ថបទដែលគ្មានការស្រាវជ្រាវហ្មត់ចត់ និងគ្មានអំណះអំណាងគ្រប់គ្រាន់ ធ្វើអោយមន្ត្រីរដ្ឋាភិបាលអស់ទំនុកចិត្ត មិនអាចយកជាការបាន ហើយប្រការនេះធ្វើអោយការផ្សាយនោះគ្មានភាពសុក្រឹត ដោយផ្អែកតែលើការមន្ទិលសង្ស័យ និងការបកស្រាយ ។ បើទោះបីជាមានវត្តមានសមាគមអ្នកសារព័ត៌មានខ្លះក៏ដោយ រហូតមកដល់ពេលនេះ គ្មានសមាគមណាមួយអាចការពារប្រយោជន៏វិជ្ជាជីវៈ និងសេរីភាពសារព័ត៌មានរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព ឬធានាគុណភាពវិជ្ជាជីវៈសារព័ត៌មាន និងលើកកំពស់ស្ថានភាពស្វ័យនិយ័តកម្មស្របតាមបទដ្ឋានក្រមសីលធម៌បានឡើយ ។

៨២. **បើទោះជាយ៉ាងណាក្តី ទំនាក់ទំនងរបស់អង្គការសង្គមស៊ីវិលជាមួយអ្នកសារព័ត៌មាន និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយនៅមានកំរិតទាបនៅឡើយ ។** ក្នុងប្រទេសកម្ពុជា ការបញ្ចេញមតិ ក្តីបារម្ភ ឬការរិះគន់របស់សង្គមស៊ីវិល តាមរយៈប្រព័ន្ធផ្សព្វផ្សាយ អាចធ្វើទៅបានចំពោះតែអង្គការក្រៅរដ្ឋាភិបាលអាជីពមួយចំនួនតូចក្នុងទីក្រុងភ្នំពេញ ដែលមានលទ្ធភាពទិញទំព័រសារព័ត៌មាន ឬ ម៉ោងផ្សព្វផ្សាយតាមរលកធាតុអាកាសប៉ុណ្ណោះ (នៅស្ថានីយវិទ្យុឯកជន) ។ សកម្មភាពទាំងនេះអាចរាប់បញ្ចូលនូវការផ្សព្វផ្សាយអំពីវេទិកាសាធារណៈ ឬការពិភាក្សាតុមូលជាមួយតំណាងសង្គមស៊ីវិល (ឧ. COMFREL និង CSD) ឬអញ្ជើញប្រិយមិត្តអ្នកស្តាប់វិទ្យុអោយសួរសំណួរ ឬបញ្ចេញមតិយោបល់ក្នុងកម្មវិធីជជែកកំសាន្តលើប្រធានបទណាមួយដែលបានកំណត់ ដូចជាសិទ្ធិមនុស្ស ឬលទ្ធិប្រជាធិបតេយ្យ (ឧ. CSD, CCHR-VOD, YCC) ។ បើទោះជាយ៉ាងដូច្នេះក្តី ការផ្សាយតាមរលកធាតុអាកាសរបស់អង្គការក្រៅរដ្ឋាភិបាលទាំងនេះបានទៅដល់តែអ្នកស្តាប់មួយចំនួនតូចប៉ុណ្ណោះ ម្យ៉ាងគឺដោយសារតែស្ថានីយវិទ្យុឯកជនដែលពួកគេប្រើប្រាស់ទាំងនោះ (ដូចជា FM 102 មណ្ឌលព័ត៌មានស្ត្រីកម្ពុជា និង FM105 វិទ្យុសំបុកឃ្មុំ) ផ្សព្វផ្សាយមិន

បានទូលំទូលាយនៅទូទាំងប្រទេសឡើយ[៣១] ។ ដោយសារតែប្រព័ន្ធផ្សព្វផ្សាយប្រមូលផ្តុំគ្នាតែនៅក្នុងទីក្រុងភ្នំពេញ អង្គការសង្គមស៊ីវិលដែលធ្វើការនៅថ្នាក់ក្រោមជាតិ កំរនឹងអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយនេះដើម្បីជាយន្តការសំដែងពីក្តីបារម្ភរបស់ពួកគេណាស់ ។ អ្នកធ្វើការនៅថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្តពិបាកពាំនាំព្រឹត្តិការណ៍ក្នុងមូលដ្ឋាន "ដែលមិនសូវសំខាន់ណាស់ណា" អោយប្រព័ន្ធផ្សព្វផ្សាយថ្នាក់ជាតិមកយកព័ត៌មានណាស់ ។ នៅក្នុងកិច្ចសំភាសន៍ អ្នកតំណាងអង្គការសង្គមស៊ីវិលបានកត់សំគាល់ថា កង្វះទំនុកចិត្តទៅលើកិត្យានុភាពរបស់អ្នកសារព័ត៌មាន និងកង្វះលទ្ធភាពក្នុងការបង់ថ្លៃឈ្នួល (ផ្លូវការ និងមិនផ្លូវការ) គឺជាឧបសគ្គបន្ថែមទៀត ។

"យើងមិនសូវមានទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយទេ ដោយយើងមិនគិតថាប្រព័ន្ធផ្សព្វផ្សាយមានប្រសិទ្ធិភាព ក្នុងការផ្សព្វផ្សាយអំពីក្តីបារម្ភរបស់សហជីពកម្មករទេ ។ ផ្ទុយទៅវិញ ជួនកាលប្រព័ន្ធផ្សព្វផ្សាយរាយការណ៍ខុស ឬរាយការណ៍លំអៀង ហើយយើងក៏បានទាមទារអោយមានការកែតំរូវផងដែរ ។" *អ្នកដឹកនាំសហជីព CTSWF ភ្នំពេញ ។*

"បើទោះបីជាប្រព័ន្ធផ្សព្វផ្សាយអាចដើរតួនាទីយ៉ាងសំខាន់ក្នុងបញ្ហាទំនាស់រួមក្តី ដូចយើងបានឃើញក្នុងករណីទំនាស់ដីធ្លី និងព្រៃឈើ សារព័ត៌មានជាច្រើនក៏កំពុងតែលើកឡើងនូវរឿងរ៉ាវផ្សេងដែលពុំឆ្លុះបញ្ចាំងអំពីការពិត ហើយនេះគឺជាអ្វីដែលយើង [NGOs] មិនយល់ស្របជាមួយសោះ ។" *ប្រធានអង្គការក្រៅរដ្ឋាភិបាលក្នុងខេត្តកំពង់ធំ ។*

"បណ្តាញអង្គការក្រៅរដ្ឋាភិបាល [ថ្នាក់ខេត្ត] កំរប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីសំដែងអំពីបញ្ហា និងការបារម្ភណាស់ ព្រោះយើងគ្មានថវិកា ។" *អ្នកតំណាងអង្គការក្រៅរដ្ឋាភិបាលក្នុងខេត្តសៀមរាប ។*

៨៣. **ក្រៅពីនេះទៀត ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយនៅមានកំរិតតិចតួច ដោយសារជាទូទៅមានការស្ទាក់ស្ទើរក្នុងការបើកកកាយដោយចំហានូវការត្អូញត្អែរ ឬការរិះគន់ ជាពិសេសចំពោះបញ្ហាពាក់ព័ន្ធនឹងអាជ្ញាធរ ឬសកម្មភាពរបស់រដ្ឋាភិបាល ។** អង្គការសហគមន៍ និងសូម្បីតែអង្គការក្រៅរដ្ឋាភិបាលថ្នាក់ស្រុក និងថ្នាក់ខេត្ត តែងជៀសវាង "ការប្រឈមមុខ" ដោយចំហ និងជាសាធារណៈជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ឬមន្ត្រីស្រុកតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ព្រោះពួកគេខ្លាចធ្វើអោយមន្ត្រីមានការខឹងសម្បារ ឬមានការចោទថាជា "ជនបរិហាកេរ្តិ៍" ។ នៅក្នុងកិច្ចសំភាសន៍ និងការពិភាក្សាតាមក្រុម អ្នកតស៊ូមតិនៅថ្នាក់ខេត្តម្នាក់បានអោយដឹងថា អង្គការនានានៅថ្នាក់ក្រោមជាតិយល់ថាពួកគេមានភាពទន់ខ្សោយ និងងាយរងគ្រោះ ដែលខុសពីអង្គការក្រៅរដ្ឋាភិបាលធំៗនៅទីក្រុងភ្នំពេញ ដែលទទួលបានការគាំទ្រនិង "ការការពារ" ពីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងម្ចាស់ជំនួយនោះ ។ ពួកគេគិតថា បញ្ហាក្នុងមូលដ្ឋានមិនទំនងនឹងទាក់ទាញការយកចិត្តទុកដាក់ ឬការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងម្ចាស់ជំនួយទេ ដែលស្ថាប័នទាំងនេះត្រូវបានគេយល់ថាជាអ្នកធ្វើអន្តរាគមន៍តែមួយគត់នៅក្នុងករណីធ្ងន់ធ្ងរ ដែលពាក់ព័ន្ធអាជ្ញាធរជាន់ខ្ពស់ (ដូចជាទំនាស់រួមអំពីបញ្ហាធនធានធម្មជាតិ និងដីធ្លីជាដើម) ។

---

[៣១] ខណៈពេលដែលវិទ្យុជាតិកម្ពុជា (RNK) ធ្វើការផ្សាយក្នុងកំលាំង ១០០គីឡូវ៉ាត់ ស្ថានីយវិទ្យុឯកជនសំបុកឃ្មុំ (FM 105) បានចាប់ផ្តើមត្រឹមកំលាំងផ្សាយ ៥ គីឡូវ៉ាត់ ហើយបច្ចុប្បន្នបានបង្កើនដល់ ១០គីឡូវ៉ាត់ ដែលនេះដូចគ្នាទៅនឹងវិទ្យុរបស់មណ្ឌលព័ត៌មានស្ត្រី (FM 102)ដែរ ដែលវិទ្យុនេះមានលក្ខណៈស្រដៀងគ្នាទៅនឹង អង្គការក្រៅរដ្ឋាភិបាលដែរ ។ ការចុះសំភាសន៍ផ្ទាល់នៅតាមតំបន់ជនបទ (ដូចជា ក្នុងខេត្តសៀមរាប និង កំពង់ធំ) បានរកឃើញថា ប្រជាជនមានការយល់ដឹងតិចតួច អំពីការផ្សាយទាំងនេះ ។

៨៤. **ការអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយអោយកាន់តែមានឯករាជ្យភាព មានលក្ខណៈអាជីព និងរស់រវើក គឺជាសមាសធាតុមួយដ៏សំខាន់នៃការទទួលខុសត្រូវសង្គម** ហើយកិច្ចខិតខំជាប្រចាំដើម្បីពង្រឹងប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា គប្បីចាត់ទុកថាជាផ្នែកចំបងនៃកិច្ចខិតខំរួមក្នុងការ "ពង្រឹងសង្គមស៊ីវិល" (Bou and Salazar, 2005) ។ តួអង្គក្នុងប្រព័ន្ធផ្សព្វផ្សាយមានតួនាទីដ៏សំខាន់បំផុត មិនត្រឹមតែដើម្បីត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល ផ្តល់ព័ត៌មានដល់សាធារណជន និងជាយន្តការសំរាប់ការសំដែងមតិរបស់ប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ជាអ្នកតស៊ូមតិដើម្បីសេរីភាពនៃការបញ្ចេញមតិ និងជាអ្នកការពារសិទ្ធិក្នុងការទទួលបានព័ត៌មានផងដែរ ។ កន្លងមក ការគាំទ្រដល់ប្រព័ន្ធផ្សព្វផ្សាយដែលមិនមែនជារបស់រដ្ឋ នៅមានវិសាលភាពតិចតួចនៅឡើយ ដោយភាគច្រើនសង្កត់ធ្ងន់តែលើការអភិវឌ្ឍន៍ជំនាញបច្ចេកទេស ។ ដូច្នេះហើយត្រូវការអោយមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដូចជា ការលើកកំពស់នូវបរិយាកាសអំណោយផលសំរាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ជាពិសេសសារព័ត៌មានផ្នែកស៊ើបអង្កេត និងសារព័ត៌មានដែលបំរើប្រយោជន៍សាធារណៈ ។ ទំនាក់ទំនងរវាងប្រព័ន្ធផ្សព្វផ្សាយនិងតួអង្គសង្គមស៊ីវិលក៏គប្បីលើកកំពស់ដែរ ។

៨៥. **បើទោះបីជាកម្ពុជាមានវប្បធម៌មិនចូលចិត្តអាន ហើយចូលចិត្តតែការប្រាស្រ័យទាក់ទងដោយពាក្យសំដីផ្ទាល់ក៏ដោយ ក៏យើងពុំគួរបោះបង់ចោលការវិនិយោគលើការអភិវឌ្ឍន៍ការបោះពុម្ពផ្សាយដែរ ។** បើទោះបីជាមានប្រជាពលរដ្ឋតែមួយចំនួនតូចជាអ្នកអានសារព័ត៌មានក៏ដោយ ក៏អ្នកអានទាំងនោះសុទ្ធសឹងជាអ្នកដែលមានឥទ្ធិពល (ឧទាហរណ៏ អ្នករៀបចំគោលនយោបាយ អ្នកស្រាវជ្រាវ និងអ្នកផ្តួចផ្តើមគំនិត) ។ ជាញឹកញាប់ចំណងជើង និងអត្ថបទសារព័ត៌មានត្រូវបានជ្រើសរើស និងផ្សព្វផ្សាយតាមវិទ្យុផងដែរ ។ ព័ត៌មានដែលប្រជាពលរដ្ឋទទួលបានពីអ្នកជិតខាង មិត្តភក្តិ ប្រធានភូមិ ។ល។ ក៏អាចមានប្រភពដើមពីសារព័ត៌មានដែរ ។ ផ្តើមចេញពីទស្សនៈនៃការទទួលខុសត្រូវសង្គម ប្រព័ន្ធផ្សព្វផ្សាយផ្នែកបោះពុម្ព គឺជាមធ្យោបាយមួយដ៏សំខាន់ក្នុងការកត់ត្រា និងផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានដែលមានលក្ខណៈបច្ចេកទេស និងលំអិត (ដូចជា ថវិកា ឬការចំណាយ) ដែលព័ត៌មានបែបនេះពិបាកផ្សព្វផ្សាយតាមពាក្យសំដីផ្ទាល់ណាស់ ។ ពាក្យសំដីដែលត្រូវបានសរសេរជាលាយល័ក្ខអក្សរ ក៏ជាមធ្យោបាយមួយដ៏មានឥទ្ធិពលដែរសំរាប់ចែករំលែកនូវការវិភាគស៊ីជំរៅ និងពិភាក្សាបញ្ហាសាធារណៈអោយបានលំអិត ។ នៅពេលអនាគត អក្ខរភាព និងអំណាចទិញ (purchasing power) នឹងកើនឡើង ហើយបរិមាណនៃការលក់សារព័ត៌មានទាំងក្នុងនិងក្រៅទីក្រុង ក៏រំពឹងទុកថានឹងកើនឡើងដែរ [៣២] ។ ដូចគ្នានេះផងដែរ ដោយសារបច្ចុប្បន្ននេះប្រព័ន្ធផ្សព្វផ្សាយផ្នែកបោះពុម្ព បានផ្តល់ឱកាសច្រើនដល់សង្គមស៊ីវិលក្នុងការបញ្ចេញនូវទស្សនៈ ជាងប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស វាគឺពិតជាការល្អប្រសើរ ប្រសិនបើយើងយកចិត្តទុកដាក់ទៅលើប្រព័ន្ធផ្សព្វផ្សាយទាំងពីរប្រភេទ គឺបើកចំហអោយទូលាយនូវប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាសសំរាប់កិច្ចការទទួលខុសត្រូវសង្គម ហើយទន្ទឹមនឹងគ្នានេះបង្កើនការចាប់អារម្មណ៏របស់ប្រជាពលរដ្ឋទៅលើប្រព័ន្ធផ្សព្វផ្សាយផ្នែកបោះពុម្ព [៣៣] ។ វាជាការសំខាន់ដែលត្រូវទទួលស្គាល់ថា ការអភិវឌ្ឍន៍បែបនេះនឹងត្រូវចំណាយពេលវេលាច្រើន និងតំរូវអោយមានទស្សនវិស័យ និងការគាំទ្រយូរអង្វែងពីខាងរដ្ឋាភិបាល ម្ចាស់ជំនួយ និងផ្នែកដទៃទៀត ។

---

[៣២] ឧទាហរណ៏ ការស្ទាបស្ទង់មតិសាធារណៈបានរកឃើញថា ប្រជាពលរដ្ឋវ័យក្មេង (អាយុក្រោម៣០ឆ្នាំ) ចំនួនពីរដងច្រើនជាងប្រជាជនវ័យចំណាស់ បានចាត់ទុកថាកាសែតគឺជាប្រភពនៃព័ត៌មានសាធារណៈ ។ ប្រជាពលរដ្ឋដែលរស់នៅទីរួមខេត្ត អានកាសែតបីដងច្រើនជាងអ្នកដែលរស់នៅតាមទីរួមស្រុក ឬភូមិ ។

[៣៣] លទ្ធភាពមួយដែលគួរសិក្សាមើល គឺការបញ្ចូលអត្ថបទទាក់ទងនឹងបញ្ហាផលប្រយោជន៍សាធារណទៅក្នុងទស្សនាវដ្តីដែលមានប្រជាប្រិយភាព (ឧទាហរណ៏ ទស្សនាវដ្តីប្រជាប្រិយ) ។ ការប្រើប្រាស់ទស្សនាវដ្តីដែលមានប្រជាប្រិយភាពដើម្បីចុះផ្សាយបញ្ហាចំរុះ នឹងរួមចំណែកកាត់ផ្តាច់ឥទ្ធិពលនយោបាយ និងធ្វើអោយមានការយល់កាន់តែច្បាស់ពីបញ្ហាព័ត៌មានសាធារណៈ ។ ខុសពីទស្សនាវដ្តីតាមផ្នែកឯកទេស ឬការបោះពុម្ពបែបបញ្ញវ័ន្ត ទស្សនាវដ្តីបែបប្រជាប្រិយមានអ្នកអានចំរុះ ហើយច្រើនផង រួមទាំងប្រជាពលរដ្ឋសាមញ្ញ សង្គមស៊ីវិល និងតំណាងរដ្ឋាភិបាលផង ។

### ២.១.៥. អនុសាសន៍ និងសកម្មភាពដែលគួរអនុវត្ត

៨៦. ការស្រាវជ្រាវបានរកឃើញថា ប្រជាពលរដ្ឋកម្ពុជាបានបង្ហាញពីចេតនាក្នុងការសំដែងមតិអំពីក្ដីបារម្ភ មតិយោបល់ និងសេចក្ដីត្រូវការរបស់គេ ប៉ុន្តែបច្ចុប្បន្ននេះមានកត្តាមួយចំនួនដែលរារាំងឆន្ទៈ និងលទ្ធភាពរបស់ពួកគេក្នុងការធ្វើដូច្នេះ ។ កង្វះជំនឿទុកចិត្ត (ថាអ្វីដែលពួកគេនិយាយនឹងត្រូវបានគេស្ដាប់ ឬអនុវត្តតាម) និងការភ័យខ្លាចចំពោះការតបត ត្រូវបានរកឃើញថា ជាឧបសគ្គដ៏ចំបងក្នុងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ។ ជាលទ្ធផល ប្រជាពលរដ្ឋពឹងផ្អែកយ៉ាងធំធេងទៅលើអ្នកដឹកនាំក្នុងមូលដ្ឋានដើម្បីលើកឡើងអំពីបញ្ហា និងបង្ហាញពីសេចក្ដីត្រូវការ និងបញ្ចេញទស្សនៈជំនួសអោយខ្លួន ។ អ្នកដឹកនាំនៅសហគមន៍ និងនៅមូលដ្ឋានមានសក្ដានុពលយ៉ាងធំធេងក្នុងការ : ផ្ដល់អំណាច និងគៀងគរប្រជាពលរដ្ឋ ផ្លាស់ប្ដូរឥរិយាបថ និងអាកប្បកិរិយា សំរបសំរួលការទំនាក់ទំនងជាមួយអាជ្ញាធរសាធារណៈ ពាំនាំក្ដីបារម្ភរបស់អ្នកនៅមូលដ្ឋានទៅជំរាបដល់ថ្នាក់ខេត្ត និងថ្នាក់ជាតិ ព្រមទាំងផ្ដល់នូវគំរូនៃការដឹកនាំដែលមានលក្ខណៈឆ្លើយតប និងប្រកបដោយការទទួលខុសត្រូវ ។ ការស្រាវជ្រាវនេះក៏បានរកឃើញផងដែរនូវកង្វះឱកាស និងយន្តការសំរាប់ប្រជាពលរដ្ឋបញ្ចេញទស្សនៈ (ឧទាហរណ៍ ដោយសារខ្វះប្រព័ន្ធផ្សព្វផ្សាយ និងវេទិកាសាធារណៈនៅមូលដ្ឋាន) ។

៨៧. អនុសាសន៍ចំនួនបីត្រូវបានស្នើឡើងដើម្បីដោះស្រាយបញ្ហាទាំងនេះ និងដើម្បីរួមចំណែកពង្រឹងការសំដែងមតិរបស់ប្រជាពលរដ្ឋនៅកម្ពុជា ។ អនុសាសន៍ដំបូង (ពិសេសសំរាប់អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍) គឺ (ក) **គាំទ្រ និងអនុវត្តនូវគំនិតផ្ដួចផ្ដើមទាំងឡាយណាដែលពង្រឹងអំណាចនិងកសាងទំនុកចិត្តរបស់ប្រជាពលរដ្ឋ ហើយបង្ហាញថាមតិនិងសកម្មភាពរបស់ប្រជាពលរដ្ឋ*អាច* នាំមកនូវការផ្លាស់ប្ដូរបាន** ។ ដោយសារអ្នកដឹកនៅមូលដ្ឋានមានតួនាទីដ៏សំខាន់បំផុត អនុសាសន៍ទីពីរ (សំរាប់រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍) គឺ (ខ) **វិនិយោគទៅលើការផ្ដួចផ្ដើម និងគាំទ្រដល់គំរូដឹកនាំនៅសហគមន៍ និងនៅមូលដ្ឋាន ដែលប្រកបដោយលក្ខណៈតំណាង និងដែលមានការទទួលខុសត្រូវ** ។ អនុសាសន៍ទីបីគឺ (គ) **ពង្រីកឱកាស និងយន្តការសំរាប់ការសំដែងមតិរបស់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន** ដោយត្រូវមានកិច្ចខិតខំប្រឹងប្រែងច្បាស់លាស់ដើម្បីធានាថាមតិរបស់អ្នក "ទន់ខ្សោយ" (មតិរបស់ស្ត្រី យុវជន និងប្រជាជនក្រីក្រ) មិនត្រូវបានលប់លើដោយមតិរបស់អ្នក "ខ្លាំងជាង" នោះទេ ។

៨៨. *<u>អនុសាសន៍ខ.១</u>- គាំទ្រគំនិតផ្ដួចផ្ដើមដែលផ្ដល់អំណាច និងកសាងទំនុកចិត្តរបស់ប្រជាពលរដ្ឋ*

ក) កំណត់រកនិងវិភាគពីឧទាហរណ៍ណាដែលការចូលរួមរបស់ប្រជាពលរដ្ឋនាំមកនូវការផ្លាស់ប្ដូរពិតប្រាកដ និងអត្ថប្រយោជន៍ជាក់ស្ដែង ។ ចងក្រងជាឯកសារ ហើយផ្សព្វផ្សាយនូវអ្វីដែលបានមេរៀន លទ្ធផល និងផលប៉ះពាល់នោះ ។ (*សកម្មភាពនេះគួរទៅខាងអង្គការសង្គមស៊ីវិល ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍*)

ខ) កសាងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល (ជាពិសេសអង្គការដែលកំពុងធ្វើសកម្មនៅតាមសហគមន៍) ដើម្បីអនុវត្តវិធីសាស្ត្រតស៊ូមតិដែលផ្ដោតលើប្រជាពលរដ្ឋ និងសិទ្ធិ ដែលវិធីសាស្ត្រនោះមានរួមបញ្ចូលនូវដំណើរការលើកកំពស់ការយល់ដឹងជាសាធារណៈ ការគៀងគរ និងការកសាងសមត្ថភាពប្រជាពលរដ្ឋសាមញ្ញអោយកំណត់ពីអាទិភាពរបស់ខ្លួន និងអោយគេហ៊ាននិយាយ និងតស៊ូមតិដោយខ្លួនឯង ។ ប្រការនេះគួរអោយមានមិនត្រឹមតែបណ្ដុះបណ្ដាលជំនាញប៉ុណ្ណោះទេ ប៉ុន្តែ

ក៏ត្រូវមានឱកាសរៀនសូត្រដើម្បីផ្លាស់ប្តូរឥរិយាបថអោយស៊ីជំរៅ និងក្នុងរយៈពេលវែងផងដែរ ហើយដែលនឹងធ្វើអោយបុគ្គលិកអង្គការសង្គមស៊ីវិលបានឃើញនូវគំនិត គុណតំលៃ និងផ្នត់គំនិតពាក់ព័ន្ធនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលផ្អែកលើ "ការផ្តល់អំណាច" (ដូចជាយកគំរូតាមគំរោង CHART របស់ VBNK ជាដើម[៣៤])។ (*សកម្មភាពគួរទៅខាងអង្គការសង្គមស៊ីវិល ដោយមានការឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍*)

គ) រៀនសូត្រ ពង្រីកបន្ថែម និងអនុវត្តតាមកិច្ចខិតខំប្រឹងប្រែងដែលមានស្រាប់របស់អង្គការសង្គមស៊ីវិល ដែលមានបំណង (មិនត្រឹមតែ "ជួយ" ឬ "និយាយជំនួសអោយ" ប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែក៏មានគោលបំណង) កសាងចំណេះដឹង សេចក្តីក្លាហាន និងសមត្ថភាពរបស់ប្រជាពលរដ្ឋ ដើម្បីរួមចំណែកដល់ការពង្រឹងអំណាចផ្នែកសេដ្ឋកិច្ចនិងនយោបាយរបស់ពួកគេ ។ ( *សកម្មភាពគួរទៅខាងអង្គការសង្គមស៊ីវិល ដោយមានការឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍*)

ឃ) ធានាថាវេទិកាសំរាប់ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ និងកិច្ចពិភាក្សារវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល (ដូចជាវេទិកាសាធារណៈ កិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ កិច្ចប្រជុំរបស់គណៈកម្មការទ្រទ្រង់សាលារៀន ការពិគ្រោះយោបល់សាធារណៈ កិច្ចប្រជុំរបស់គណៈកម្មាធិការ "ចំរុះ" និងក្រុមការងារជាដើម) គឺជា "វេទិកាប្រកបដោយសុវត្ថិភាព" ដែលប្រជាពលរដ្ឋអាចបញ្ចេញមតិដោយពុំមានការភ័យខ្លាចចំពោះការសងសឹក ហើយវេទិកាបែបនោះគប្បីមានថែងអំពីវិធាន និងយន្តការច្បាស់លាស់សំរាប់ការឆ្លើយតប និងការតាមដាន (ដើម្បីកសាងទំនុកចិត្តរបស់ប្រជាពលរដ្ឋថាការបញ្ចេញមតិ និងការចូលរួមរបស់គេនាំមកនូវការផ្លាស់ប្តូរជាក់ស្តែង)។ (*សកម្មភាពគួរទៅខាងរដ្ឋាភិបាល ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអង្គការសង្គមស៊ីវិល ដោយមានការឧបត្ថម្ភគាំទ្រពីដៃគូអភិវឌ្ឍន៍* )។

ង) គាំទ្រដល់កម្មវិធី និងសកម្មភាពទាំងឡាយណាដែលខិតខំកសាងចំណេះដឹង ទំនុកចិត្ត និងសមត្ថភាពរបស់ក្រុមដែល "គេពុំសូវយកចិត្តទុកដាក់ជាមួយ" ដូចជា ក្រុមស្ត្រី យុវជន និង ប្រជាជនក្រីក្រ ។ (*សកម្មភាពគួរទៅខាងអង្គការសង្គមស៊ីវិល ដោយមាន ការឧបត្ថម្ភគាំទ្រពីដៃគូអភិវឌ្ឍន៍* )។

៨៥. *អនុសាសន៍ ខ.២ - ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រដល់អ្នកដឹកនាំបច្ចុប្បន្ន និងអនាគតអ្នកដឹកនាំថ្នាក់មូលដ្ឋាន*

ក) កំណត់រក និងផ្តល់ការបណ្តុះបណ្តាល (ដែលល្អបំផុតគឺសំរាប់រយៈពេលវែង ដែលអាចធ្វើស្វ័យឆ្លុះបញ្ចាំង និងមានលក្ខណៈជាការដកបទពិសោធន៍)[៣៥] ព្រមទាំងការបន្តគាំទ្រដល់អ្នកដឹកនាំបច្ចុប្បន្ន អនាគតអ្នកដឹកនាំ និងអ្នកតំរង់គំនិត (ជាពិសេសនៅថ្នាក់ភូមិ ឃុំ និងស្រុក) ដោយផ្តោតលើគំរូដឹកនាំដែលប្រកបដោយការឆ្លើយតប ការទទួលខុសត្រូវ និងផ្អែកលើគោលការណ៍នៃសេវាសាធារណៈ អភិបាលកិច្ចដែលមានការចូលរួម និងសុចរិតភាព ។ គួរយកចិត្តទុកដាក់ជាពិសេសទៅលើការបណ្តុះបណ្តាលអ្នកដឹកនាំជាស្ត្រី និងយុវជន ។ (*សកម្មភាពគួរទៅខាងអង្គការសង្គមស៊ីវិល ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍*[៣៦] ) ។

---

[៣៤] សូមមើលវិបសាយ http://www.vbnk.org/chart.htm.

[៣៥] ជាថ្មីម្តងទៀត គំរោង CHART របស់ VBNK ផ្តល់នូវគំរូមួយដ៏ល្អ ។

[៣៦] ឧទាហរណ៍ នៅក្នុងបរិបទនៃកម្មវិធីពង្រឹងសមត្ថភាពដើម្បីការទទួលខុសត្រូវសង្គម របស់ធនាគារពិភពលោកនាពេលបច្ចុប្បន្ន។

ខ) ដោយសារប្រធានភូមិមានតួនាទីដ៏សំខាន់ក្នុងនាមជាភ្នាក់ងារអភិវឌ្ឍន៍មូលដ្ឋាន និងផ្តល់ការគាំទ្រដល់ប្រជាពលរដ្ឋ គួរណែនាំអោយមានប្រព័ន្ធបោះឆ្នោតជ្រើសរើសប្រធានភូមិតាមបែបប្រជាធិបតេយ្យ ដើម្បីជំនួយអោយការអនុវត្តបច្ចុប្បន្នដែលប្រធានភូមិត្រូវបានតែងតាំងអាស្រ័យទៅតាមកូតារបស់គណបក្សនយោបាយ ។ (*សកម្មភាពតំរូវទៅខាងរដ្ឋាភិបាល*) ។

៩០. *អនុសាសន៍ ខ.៣- ពង្រីកនិងលើកកំពស់យន្តការសំរាប់ប្រជាពលរដ្ឋបញ្ចេញមតិនៅថ្នាក់មូលដ្ឋាន*

ក) ធ្វើការជាមួយ "ជនមានស្នាដៃ" ក្នុងជួររដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីលើកកំពស់បរិយាកាសគោលនយោបាយ និងទំនាក់ទំនងការងារដែលបង្កលក្ខណៈល្អសំរាប់ការបញ្ចេញមតិ និងទស្សនៈខុសៗគ្នា ការផ្តល់យោបល់ដោយស្មោះត្រង់ និង "ការរិះគន់បែបស្ថាបនា" ដោយគ្មានការភ័យខ្លាចចំពោះការសងសឹក ។ (*សកម្មភាពតំរូវទៅខាង រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍* ) ។

ខ) ធានាថាវេទិកាសំរាប់លើកកំពស់ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ និងការពិភាក្សារវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល(ដូចជាវេទិកាសាធារណៈ កិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ កិច្ចប្រជុំរបស់គណៈកម្មការទ្រទ្រង់សាលារៀន ការពិគ្រោះយោបល់សាធារណៈ កិច្ចប្រជុំគណៈកម្មាធិការ"ចំរុះ" និងក្រុមការងារ) ធ្វើឡើងដោយមានការអញ្ជើញច្បាស់លាស់ដើម្បីអោយប្រជាពលរដ្ឋចូលរួម អញ្ជើញអោយបញ្ចេញមតិ មានបរិយាកាសល្អ (ជាពិសេស សំរាប់អ្នកចូលរួមដែលមិនសូវក្លាហាន ឬមិនសូវមានការអប់រំ) ហើយដំណើរការពិភាក្សាត្រូវមានការសំរបសំរួលល្អ ។ (*សកម្មភាពតំរូវទៅខាងរដ្ឋាភិបាល ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអង្គការសង្គមស៊ីវិល ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍* ) ។

គ) គាំទ្រដល់ការអភិវឌ្ឍន៍នូវប្រព័ន្ធផ្សព្វផ្សាយថ្នាក់មូលដ្ឋានដែលមានលក្ខណៈឆ្លើយឆ្លង ជាពិសេសវិទ្យុសហគមន៍ ។ សំរាប់ជាជំហានដំបូង កំណត់រក និងផ្តល់ការគាំទ្រដល់ក្រុមសហគមន៍ណា ដែលចាប់អារម្មណ៍ក្នុងការផលិតកម្មវិធីក្នុងមូលដ្ឋាន និងលើកទឹកចិត្តស្ថានីយវិទ្យុរដ្ឋ និងឯកជន (ជាពិសេសថ្នាក់ខេត្ត) អោយផ្តល់ពេលវេលាផ្សព្វផ្សាយកម្មវិធីទាំងនេះ ។ (*សកម្មភាពតំរូវទៅខាងក្រសួងព័ត៌មាន អង្គការដែលគាំទ្រប្រព័ន្ធផ្សព្វផ្សាយ ស្ថានីយវិទ្យុ និងអង្គការសង្គមស៊ីវិល ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍*) ។

ឃ) បង្កើត និងគាំទ្រយន្តការបញ្ចេញមតិដែលសមស្របទៅតាមចរិកលក្ខណៈ និងសេចក្តីត្រូវការជាក់ស្តែងរបស់ក្រុមមួយចំនួន (ឧទាហរណ៍ លើកកំពស់ការសំដែងមតិរបស់យុវជនតាមរយៈតន្ត្រី និងវិទ្យុ គាំទ្រដល់ការកកើតឡើងនៃអង្គការ និងបណ្តាញស្ត្រីក្នុងសហគមន៍ រៀបចំអោយមានការពិភាក្សារវាងប្រជាពលរដ្ឋនិងរដ្ឋាភិបាល និង "ការចរចារ" ដែលសង្កត់ធ្ងន់ទៅលើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្រីក្រ និងក្រីក្រខ្លាំង) ។ (*សកម្មភាពតំរូវទៅខាងអង្គការសង្គមស៊ីវិល និងការគាំទ្រពីដៃគូអភិវឌ្ឍន៍*) ។

## ២.គ. ការរួមរួមជាសមាគម

៩១. វិធីសាស្ត្រនៃការទទួលខុសត្រូវសង្គម គឺផ្អែកលើសកម្មភាពរួមរបស់ប្រជាពលរដ្ឋ និងសមត្ថភាពរបស់ពួកគេក្នុងការ "ផ្សារភ្ជាប់ទំនាក់ទំនង" ជាមួយគ្នាទៅវិញទៅមកដើម្បីលើកកំពស់ផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ខ្លួន ។ កំលាំងរបស់សង្គមស៊ីវិលគឺអាស្រ័យយ៉ាងខ្លាំងលើភាពទូលំទូលាយ ភាពស៊ីជំរៅ និងគុណភាពនៃជីវភាពសមាគមបែបនេះ ។ កំរិតនៃការរៀបចំអង្គការសង្គមស៊ីវិល ភាពស្របច្បាប់ ភាពជាតំណាង និងការទទួលខុសត្រូវរបស់អង្គការទាំងនោះចំពោះសមាជិករបស់ខ្លួន ព្រមទាំងសមត្ថភាពរបស់គេក្នុងការកសាងបណ្តាញ និងសម្ព័ន្ធភាព សុទ្ធសឹងតែជាចំណុចសំខាន់នៃជោគជ័យនៃសកម្មភាពទទួលខុសត្រូវសង្គម ។ ដូចដែលបានរៀបរាប់ដោយប្រយោលនៅក្នុងផ្នែកទី១នៃរបាយការណ៍នេះរួចហើយ ១) **ការមិនសូវមានការរួបរួមនិងសមាគមប្រជាពលរដ្ឋនៅតាមមូលដ្ឋាន** គឺជាចំណុចខ្សោយដ៏ចំបងរបស់សង្គមស៊ីវិលនៅកម្ពុជានាពេលបច្ចុប្បន្ននេះ ។ បញ្ហាប្រឈមពាក់ព័ន្ធដទៃទៀត រួមមាន ២) **តំរូវការពង្រឹងអភិបាលកិច្ចផ្ទៃក្នុងរបស់អង្គការសង្គមស៊ីវិល** និង ៣) **ការលើកកំពស់សមត្ថភាពតួអង្គក្នុងសង្គមស៊ីវិលក្នុងការបង្កើតបណ្តាញ និងសម្ព័ន្ធភាពអោយមានប្រសិទ្ធិភាព ។**

### ២.គ.១. សមាគម និងការរួបរួមគ្នារបស់ប្រជាពលរដ្ឋ

៩២. យោងតាមរបកគំហើញពីការស្ទាបស្ទង់មតិសាធារណៈ **បរិមាណប្រជាពលរដ្ឋដែលចូលជាសមាជិកនៃសមាគម និងអង្គការនានានៅកម្ពុជានៅមានចំនួនតិចតួចនៅឡើយ** ។ ដូចមានបង្ហាញជូននៅក្នុងរូបភាពទី១៦ហើយ នៅពេលដែលត្រូវបានសួរថាតើគេជាសមាជិករបស់អង្គការណាមួយដែរឬទេនោះ មានអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិតែចំនួន២៣%ប៉ុណ្ណោះ ដែលបានឆ្លើយថាគេជាសមាជិកអង្គការណាមួយ ។ ចំនួននេះនៅមានកំរិតទាបណាស់បើធៀបទៅនឹងប្រទេសដទៃទៀតនៅលើសកលលោក ។ ប្រជាពលរដ្ឋដែលបានផ្តល់ចំលើយដូច្នេះស្ទើរតែទាំងអស់ (៩៥.៥%) គឺជាសមាជិករបស់អង្គការតែមួយប៉ុណ្ណោះ ។ ប្រជាជនចំនួន ៤%ទៀតនិយាយថាពួកគេគឺជាសមាជិករបស់អង្គការពីរដោយឡែកពីគ្នា ហើយមានតែ ០,៥%ប៉ុណ្ណោះជាសមាជិករបស់អង្គការលើសពីពីរ ។ រូបភាពទី១៧ និង១៨ បង្ហាញពីសមាគមប្រជាពលរដ្ឋ ដែលប្រែប្រួលទៅតាមកត្តាអាយុ ភេទ និងប្រជាសាស្ត្រ ។ ការស្ទាបស្ទង់មតិនេះបានរកឃើញថាប្រជាជនវ័យចំណាស់ច្រើនចូលជាសមាជិកអង្គការណាមួយជាងអ្នកវ័យក្មេង ហើយអ្នកដែលរស់នៅតាមភូមិនិងទីជនបទ ច្រើនចូលជាសមាជិករបស់អង្គការស្ទើរតែពីរដងច្រើនជាងអ្នកដែលនៅតាមទីរួមខេត្ត និងទីក្រុង ។

**រូបភាពទី១៧ : កំរិតសមាជិកភាពនៅក្នុងអង្គការសង្គមស៊ីវិល**




ប្រភព : CAS/WB, 2007

**រូបភាពទី១៨ : សមាជិកភាពរបស់អង្គការសង្គមស៊ីវិលតាមអាយុ**




ប្រភព : CAS/WB, 2007

**រូបភាពទី១៩ : សមាជិកភាពរបស់អង្គការសង្គមស៊ីវិលតាមតំបន់**




ប្រភព : CAS/WB, 2007

៩៣. **ក្នុងចំណោមប្រជាពលរដ្ឋដែលជាសមាជិករបស់អង្គការ មានភាគច្រើន (៦៦,២%) គឺជាសមាជិករបស់សមាគមបែបប្រពៃណី ។** ដូចមានបង្ហាញក្នុងរូបភាពទី ១៩ ហើយ ចំនួននេះមិនមានភាពខុសគ្នាទេរវាងអ្នកវ័យក្មេង និងវ័យចំណាស់ ។ ជីវភាពសមាគមបែបប្រពៃណីនៅកម្ពុជា មានលក្ខណៈធូររលុង និងមានរចនាសម្ព័ន្ធចាត់ចែងមិនផ្លូវការ ដែលជាញឹកញាប់សមាគមនោះតែងកើតឡើងដោយភ្ជាប់ខ្លួនទៅនឹងវត្តអារ៉ាម ហើយមានគោលបំណងបំរើសេចក្តីត្រូវការរបស់សហគមន៍ក្រោមគោលការណ៍នៃព្រះពុទ្ធសាសនា បង្កើតបុណ្យកុសល (រួមទាំងសប្បុរសធម៌ និងក្រមសីលធម៌) និងកម្មផល ។ វត្តអារ៉ាម ព្រមទាំងគណៈកម្មាធិការ និងសមាគមដែលភ្ជាប់ខ្លួនទៅនឹងវត្តអារ៉ាម ជាទូទៅពុំមានលក្ខណៈនយោបាយឡើយ ហើយភាពសំខាន់របស់សមាគមទាំងនោះ (បើផ្តើមចេញពីទស្សនៈនៃការទទួលខុសត្រូវសង្គម) គឺជាយានសំខាន់មួយឆ្ពោះទៅការកសាងមូលធនសង្គម ។ សមាគមបែបនេះលើកកំពស់ *ចំណង* ទាក់ទងក្នុងចំណោមសមាជិក និង*ការភ្ជាប់ជាស្ពាន* ពីសមាគមមួយទៅមួយទៀត ប៉ុន្តែតាំងពីយូរយារណាស់មកហើយ តែងមានទំនាក់ទំនងតិចតួចជាមួយអាជ្ញាធរមូលដ្ឋាន (Pellini/Ayres, 2005:15) ហើយពុំមានបណ្តាញសំរាប់ការទាមទារអ្វីមួយពីរដ្ឋាភិបាលឡើយ (Hughes/Conway 2004:28) ។

៩៤. បើទោះបីដំណើរការនៃវិមជ្ឈការនាពេលបច្ចុប្បន្ន ពុំពាក់ព័ន្ធដោយផ្ទាល់ក្នុងបញ្ហាអភិបាលកិច្ច និងការទទួលខុសត្រូវសាធារណៈក៏ដោយ ក៏**ដំណើរការនេះបង្កើតនូវវិសាលភាពដ៏មានសក្តានុពល សំរាប់អភិវឌ្ឍតួនាទីរបស់សមាគមប្រពៃណីបែបនេះអោយក្លាយជាអ្នកប្រមូលផ្តុំមតិ និងជាអ្នកសំរបសំរួលទំនាក់ទំនងរវាងប្រជាពលរដ្ឋនិងក្រុមប្រឹក្សាឃុំ-សង្កាត់ដែរ ។** ឧទាហរណ៍ : ក្រុមស្រាវជ្រាវបានជួបប្រទះយ៉ាងហោចណាស់ករណីមួយចំនួន ដែលសមាគមបែបប្រពៃណីបានដើរតួនាទីយ៉ាងដូច្នេះ ជាពិសេសនៅតាមតំបន់ដែលមានប្រពៃណីរឹងមាំក្នុងការចងក្រងសមាគម[៣៧] ។ ឧទាហរណ៍ នៅក្នុងខេត្តកំពង់ធំ ( *ស្រុកស្ទោង* ) សមាជិកសហគមន៍ម្នាក់បានលើកឡើងថា :

"នៅក្នុងភូមិរបស់ពួកយើង មានសមាគមបែបប្រពៃណីដ៏រឹងមាំចំនួនបីតាំងពីទសវត្សឆ្នាំ ១៩៥០ មក ដែលផ្តួចផ្តើម និងសំរបសំរួលដោយគណៈកម្មការវត្ត ក្នុងនោះយើងមានសមាគមស្រូវ សមាគមថវិកា និងសមាគមសាលារៀន ។ អ្នកភូមិស្ទើរគ្រប់គ្នាតែងផ្តល់វិភាគទានយ៉ាងទៀងទាត់ដល់សមាគមទាំងនេះ លើកលែងតែប្រជាជនដែលក្រីក្រខ្លាំងពេកដែលគ្មានលទ្ធភាពធ្វើវិភាគទាន ។ ប៉ុន្តែប្រសិនបើ ក្រុមប្រឹក្សាឃុំស្នើសុំអោយមានការផ្តល់វិភាគទានសំរាប់ការអនុវត្តន៍គំរោងអភិវឌ្ឍន៍ក្នុងឃុំ សមាគមថវិកាជាអ្នកផ្តល់ថវិកាជំនួសអោយប្រជាពលរដ្ឋគ្រប់រូបក្នុងភូមិ មិនចំពោះថាពួកគេបាន ឬមិនបានផ្តល់វិភាគទានទៅអោយសមាគមនោះទេ ។"

**រូបភាពទី ២០ : សមាជិកភាពរបស់អង្គការសង្គមស៊ីវិលតាមប្រភេទអង្គការ និងអាយុ**




ប្រភព : CAS/WB, 2007

៩៥. ប្រភេទដទៃទៀតនៃអង្គការសហគមន៍បែប "ទំនើប" (ដូចជា សមាគមស្ត្រី សមាគមកសិករ ឬសមាគមអ្នកនេសាទ) ភាគច្រើនគឺជាបាតុភូតថ្មីៗ ហើយជាទូទៅត្រូវបានបង្កើតឡើងក្រោមការគាំទ្រពីខាងក្រៅ (ដូចជា NGOs) និងជាញឹកញាប់តែងពឹងផ្អែក

[៣៧] ការស្រាវជ្រាវនេះបានរកឃើញថា តំបន់ខ្លះមានប្រពៃណីផ្តួចផ្តើមអោយមានសមាគម ច្រើនជាងតំបន់ដទៃទៀត។ ជីវភាពសមាគមបែបប្រពៃណីដ៏រឹងមាំនៅខេត្តកំពង់ធំមិនមានលក្ខណៈតំណាងអោយតំបន់ដទៃទៀតនៅទូទាំងប្រទេសនោះទេ មានន័យថាមិនមែនគ្រប់តំបន់សុទ្ធតែមានប្រពៃណីបែបនេះឡើយ ។

លើការផ្ដល់ធនធាន និងគ្រឿងលើកទឹកចិត្តជាបន្តបន្ទាប់ពីខាងក្រៅដើម្បីដំណើរការទៅបាន ។ ចាប់តាំងពីដើមទសវត្សឆ្នាំ ១៩៩០ មកម្ចាស់ជំនួយ ក្រោមកិច្ចសហការជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក បានខិតខំលើកកំពស់ការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន តាមបែបចូលរួម ដោយគាំទ្រការបង្កើតឡើង និងការអភិវឌ្ឍន៍សមាគម និងអង្គការសហគមន៍ ។ **បើទោះជាយ៉ាងនេះក្តី ការស្រាវជ្រាវនេះបានរកឃើញថា វិសាលភាព និងឥទ្ធិពលរបស់អង្គការសហគមន៍បែប "ទំនើប" ទាំងនោះនៅមានកំរិតទាបនៅឡើយ ដោយអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិសាធារណៈត្រឹមតែ១២,៣%ប៉ុណ្ណោះ បាននិយាយថាគេជាសមាជិករបស់ក្រុមបែបនេះ ។** លើកលែងតែករណីគួរអោយកត់សំគាល់មួយចំនួន (ដូចមានពិភាក្សាខាងក្រោម) ការស្រាវជ្រាវនេះបានរកឃើញនូវភស្តុតាងតិចតួច ដែលក្រុមទាំងនេះមានពាក់ព័ន្ធការងារជាមួយអាជ្ញាធរមូលដ្ឋាន ឬសំរបសំរួលដល់ការទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល ។ ឧទាហរណ៍ ការស្ទាបស្ទង់មតិសាធារណៈបានរកឃើញថា ជាទូទៅប្រជាជនដែលជាសមាជិករបស់អង្គការសង្គមស៊ីវិល ក៏មិនមានព័ត៌មានអំពីថវិកាឃុំ-សង្កាត់អ្វីច្រើនជាងអ្នកដែលមិនមែនសមាជិកនោះទេ [៣៨] ហើយក្នុងចំណោមប្រជាពលរដ្ឋដែលបានចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ មានតែ ១២% ប៉ុណ្ណោះដែលចូលរួមក្នុងនាមជាតំណាងអោយសមាគម ឬ អង្គការរបស់ខ្លួន ។

៩៦. **ដោយសារមូលធនសង្គមមានកំរិតទាប និងដោយមានចេតនាចង់បញ្ចៀសទំនាស់ ប្រជាពលរដ្ឋមិនមានចិត្តចង់ចូលរួមក្នុងក្រុមមួយដែលគេយល់ថាមានរចនាសម្ព័ន្ធ និងបទបញ្ជា "តឹងរ៉ឹង"និង "ផ្លូវការ"នោះទេ ។** គេចូលចិត្តពាក់ព័ន្ធតែជាមួយមនុស្សដែលពួកគេស្គាល់ជាលក្ខណៈបុគ្គលនិងទុកចិត្តប៉ុណ្ណោះ ជាពិសេសនៅក្នុងបរិបទដែលគេអាចបត់បែនក្នុងការដកខ្លួនចេញ ឬដកថយពីសកម្មភាពរបស់ក្រុមនោះដោយសំងាត់ និងដោយមិនធ្វើអោយប៉ះពាល់ដល់អ្នកដទៃ ។ ឥរិយាបថបែបនេះត្រូវបានជួបប្រទះទាំងនៅថ្នាក់ភូមិ (ទាក់ទងទៅនឹងសមាគមថ្នាក់មូលដ្ឋាន) និងនៅក្នុងបរិបទនៃអង្គការនៅថ្នាក់ខ្ពស់ជាងនេះ ។ ឧទាហរណ៍ ប្រធានសហជីពម្នាក់ នៅក្នុងរោងចក្រកាត់ដេរមួយនៅទីរួមខេត្តកំពង់ចាមបានរៀបរាប់អំពីការលំបាកក្នុងការគៀងគរ និងរក្សាសមាជិករបស់សហជីពគាត់ ។ បើទោះបីជាមានសមាជិកប្រមាណ៣០០នាក់បានចុះឈ្មោះជាសមាជិកត្រឹមត្រូវហើយក៏ដោយ ក៏ជាក់ស្តែងមានតែអ្នកដែលមានទំនាក់ទំនងផ្ទាល់ខ្លួន និងការជាប់ពាក់ព័ន្ធជាលក្ខណៈរូបវ័ន្តទៀងទាត់ជាមួយប្រធានសហជីពប៉ុណ្ណោះដែលហ៊ានចូលរួមសកម្ម ។ កម្មករដែលមិនស្គាល់ប្រធានសហជីពជាលក្ខណៈបុគ្គល បើទោះបីជាគេមានប័ណ្ណសមាជិកក៏ដោយ ក៏នៅតែមិនមានភាពសកម្មដដែល ។

៩៧. **ក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលអាជីព (តំណាងអោយអង្គការសង្គមស៊ីវិលជាច្រើនដែលបានចុះបញ្ជិកានៅកម្ពុជា) កំរមានអង្គការសមាជិកភាពណាស់ ហើយភាគច្រើនខ្វះការផ្សារភ្ជាប់ទៅនឹងសហគមន៍មូលដ្ឋាន ។** ជាទូទៅ អង្គការក្រៅរដ្ឋាភិបាលមានបុគ្គលិកដែលមានប្រាក់បៀវត្សរ៍តិចតួចហើយធ្វើការដើម្បីបុព្វហេតុជាក់លាក់ណាមួយ ឬធ្វើការតស៊ូមតិ"ជំនួសអោយ" ក្រុមគោលដៅណាមួយ (ដូចជាក្រុមស្ត្រី កុមារ ឬប្រជាពលរដ្ឋក្រីក្រ) ប៉ុន្តែពុំសូវមានការផ្សារភ្ជាប់ស្អិតរមួត និងជានិរន្តរ៍ជាមួយអ្នកទាំងនោះនៅឡើយ ។ ឧទាហរណ៍ ការស្ទាបស្ទង់មតិសាធារណបានរកឃើញថា ប្រជាពលរដ្ឋមិនដល់ ៣% ផងបាននិយាយថាគេជាសមាជិករបស់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកណាមួយ (ជាបុគ្គលិក អ្នកស្ម័គ្រចិត្ត ឬអ្នកពាក់ព័ន្ធក្រៅផ្លូវការ) ។

---

[៣៨] បើទោះបីសមាជិករបស់ "NGO" ក្នុងស្រុកមានលទ្ធភាពបីដងច្រើនជាង "សមាគមបែបប្រពៃណី" ក្នុងការដឹងអំពីថវិកាក្រុមប្រឹក្សាឃុំ-សង្កាត់ ។

៩៨. **បើទោះបីអង្គការសហគមន៍បែប "ទំនើប" មានវិសាលភាពតូច និងមានប្រសិទ្ធិភាពតិចតួចក៏ដោយ ក៏មានឧទាហរណ៍ល្អៗមួយចំនួនសំរាប់យកមកស្វែងយល់ ធ្វើជាគំរូ និងពង្រីកបន្ថែមទៀត ។** តាមរយៈសមាគមកសិកររបស់អង្គការសេដាក (ដូចមានរៀបរាប់ក្នុងប្រអប់ទី៨ខាងក្រោម) និងសហជីពក្នុងស្រុកមួយចំនួនបានស្តែងអោយឃើញពី**ភាពចាំបាច់ក្នុងការដោះស្រាយបញ្ហាផលប្រយោជន៍ និងសេចក្តីត្រូវការផ្នែកជីវភាពជាក់ស្តែងរបស់សមាជិក ព្រមទាំងពីសារៈសំខាន់នៃការគាំទ្រព្រមគ្នាទៅលើការផ្តល់អំណាចផ្នែកនយោបាយនិងសេដ្ឋកិច្ច ។** ឧទាហរណ៍ទាំងនេះចង្អុលបង្ហាញអំពីសេចក្តីត្រូវការក្នុងការជំរុញកិច្ចខិតខំប្រឹងប្រែងផ្នែកពង្រឹងអំណាចដល់ប្រជាពលរដ្ឋអោយបានទូលំទូលាយនិងស៊ីជំរៅបន្ថែមទៀត ។ ដោយសារកង្វះមូលធនសង្គម ហើយសមត្ថភាពគ្រប់គ្រង និងចាត់ចែងនៅថ្នាក់មូលដ្ឋាននៅមានកំរិត គំនិតផ្តួចផ្តើមផ្នែកគៀងគរ និងផ្តល់អំណាច តំរូវអោយមានសំរបសំរួលអោយបានជិតស្និទ្ធ មានការវិនិយោគលើការអភិវឌ្ឍន៍សមត្ថភាព ការកសាងជំនាញ និងការប្តេជ្ញាចិត្តរយៈពេលវែង ។

**ប្រអប់ទី៨ : សមាគមកសិកររបស់អង្គការសេដាក**

ចាប់តាំងពីឆ្នាំ១៩៩៨មក កសិករបានចាប់ផ្តើមចងក្រងបង្កើតជាសមាគម និងបណ្តាញតាមភូមិ ដោយមានការគាំទ្រពីអង្គការសេដាក ។ សមាគមទាំងនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកំពស់ការជួយគ្នាទៅវិញទៅមក សាមគ្គីភាព និងការសហការគ្នា ព្រមទាំងដើម្បីសំរបសំរួលនិងធ្វើសកម្មភាពជាសមូហភាពក្នុងការងារអភិវឌ្ឍន៍កសិកម្មតាមបែបធម្មជាតិ ការគ្រប់គ្រងធនធានធម្មជាតិ និងការសហការអភិវឌ្ឍអាជីវកម្ម និងសហគមន៍ ។ សកម្មភាពជាទូទៅរបស់សមាគមទាំងនេះរួមមានការផ្សព្វផ្សាយកសិកម្ម ការសន្សំប្រាក់និងឥណទានដែលដឹកនាំដោយសហគមន៍ ការស្វែងរកទីផ្សារជាក្រុម ការបណ្តុះបណ្តាលកសិករក្មេងៗ ការកសាងសមត្ថភាពសំរាប់ក្រុមស្ត្រី ការគាំទ្រដល់គ្រួសារដែលក្រីក្របំផុត និងការលើកកំពស់ការយល់ដឹងអំពីបញ្ហានានាពាក់ព័ន្ធនឹងការអភិរក្សធនធានធម្មជាតិ ។ សមាគមកសិករខ្លះក៏បានចាប់ផ្តើមដើរតួធ្វើអោយមានឥទ្ធិពលទៅលើផែនការអភិវឌ្ឍន៍មូលដ្ឋាន និងជំរុញអាជ្ញាធរមូលដ្ឋានអោយកាន់តែមានប្រសិទ្ធិភាពជាងមុននៅក្នុងការអភិវឌ្ឍន៍សហគមន៍ និងការគ្រប់គ្រងធនធានធម្មជាតិ ។ ពួកគេបានចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំជាទៀងទាត់ ដើម្បីសួរសំណួរ និងលើកសំណើអំពីគំនិតផ្តួចផ្តើមនិងសកម្មភាពនានាដែលត្រូវអនុវត្តដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ។ រហូតមកដល់បច្ចុប្បន្ននេះ មានសមាគមកសិករតាមភូមិចំនួន ១.០១៧ ត្រូវបានបង្កើតនៅក្នុងខេត្តចំនួន ១១ ដែលតំណាងអោយគ្រួសារប្រមាណ ២៧.៥០០ ។ សមាគមភាគច្រើនកំពុងស្ថិតនៅក្នុងដំណាក់កាលរៀនសូត្រ និងដកពិសោធន៍ជាមួយនឹងគោលការណ៍ជាមូលដ្ឋាន គឺការគ្រប់គ្រងរួមគ្នា និងកសាងចំណេះដឹងរបស់ពួកគេ អំពីបច្ចេកទេសកសិកម្មទំនើបៗ យុទ្ធសាស្ត្រទីផ្សារ និងបញ្ហាពាក់ព័ន្ធផ្សេងទៀតដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ ។ ការមានកំរិតវប្បធម៌ទាប និងកង្វះបទពិសោធន៍ក្នុងការពិនិត្យពិច័យ និងធ្វើអ្វីៗដើម្បីប្រយោជន៍រួម ដោយប្រើរចនាសម្ព័ន្ធសមាគមបែបផ្លូវការនោះ ធ្វើអោយជីវភាពជាសមាគមជួបប្រទះនូវបញ្ហាប្រឈម ។ ប៉ុន្តែការស្រាវជ្រាវបែបគុណភាព (លើសមាគមល្អៗចំនួន៣) បានបង្ហាញអោយឃើញពីសមត្ថភាពស្វ័យគ្រប់គ្រងគួរអោយចាប់អារម្មណ៍ ជំនឿទុកចិត្តទៅលើអ្នកដឹកនាំ និងការជឿជាក់លើសមត្ថភាពរបស់ក្រុមខ្លួនក្នុងការលើកកំពស់នូវផលប្រយោជន៍របស់សមាជិក ។ កំណើនផលិតកម្មកសិកម្ម (ដោយសារបច្ចេកទេសល្អៗដែលណែនាំដោយអង្គការសេដាក) បានកែលំអស្ថានភាពសេដ្ឋកិច្ចរបស់កសិករដែលជាសមាជិក និងរួមចំណែកដល់ការកសាងជំនឿទុកចិត្ត និងភាពកក់ក្តៅ ។ បន្តិចម្តងៗ សមាគមមួយចំនួន

បានចូលរួមកាន់តែច្រើនឡើងៗនៅក្នុងការងារអភិវឌ្ឍន៍មូលដ្ឋាន (ដូចជាតាមរយៈការរួមចំណែកនៅក្នុងគំរោងអភិវឌ្ឍន៍ឃុំ ដូចជាការជួសជុលផ្លូវ ឬការជីកស្រះជាដើម) ។ នៅខេត្តតាកែវ សមាជិករបស់សមាគមខ្លះដែលមិនពេញចិត្តនឹងគុណភាពមិនល្អនៃផ្លូវដែលភ្ជាប់ពីភូមិរបស់ពួកគេទៅផ្សារដែលនៅជិតបំផុតនោះ បានផ្តួចផ្តើមគំនិតប្រមូលថវិកា(ពីសមា-ជិកសមាគមនិងអ្នកភូមិដទៃទៀត) ហើយជំរុញអោយឃុំជួសជុលផ្លូវនោះ ។ អង្គការសេដាកក៏បានដើរតួនាទីយ៉ាងជោគជ័យនៅក្នុងការជួយសមាគមកសិករអោយរៀបចំកិច្ចប្រជុំជាមួយក្រុមប្រឹក្សាឃុំ និងនៅក្នុងការសំរបសំរួលអោយមានការពិគ្រោះយោបល់ជាមួយតំណាងរដ្ឋាភិបាលផ្សេងៗទៀត (ដូចជាកិច្ចប្រជុំរវាងក្រុមស្ត្រី និងក្រសួងកិច្ចការនារី មន្ត្រីសុខាភិបាល ។ល។) ។ បើទោះបីជាមានឧទាហរណ៍ជោគជ័យបែបនេះក៏ដោយ ក៏ទំនាក់ទំនងរវាងសមាគមនិងអាជ្ញាធរមូលដ្ឋាននៅមានភាពក្មេងខ្ចីនៅឡើយ ហើយត្រូវការអោយមានការគាំទ្រជាច្រើនថែមទៀតពីអង្គការសេដាក និងដៃគូរបស់ខ្លួន ។

*ប្រភព: CAS/WB, ២០០៧b*

## ២.គ.២. បញ្ហាប្រឈមផ្ទៃក្នុងផ្នែកអភិបាលកិច្ចរបស់សង្គមស៊ីវិល

៩៩. **អង្គការសង្គមស៊ីវិល ចាប់ពីកំរិតសហគមន៍រហូតដល់ថ្នាក់ជាតិ មានបញ្ហាប្រឈមផ្នែកអភិបាលកិច្ច និងការទទួលខុសត្រូវផ្ទៃក្នុងរបស់ខ្លួន ។** ការចុះសំភាសន៍ផ្ទាល់តាមមូលដ្ឋាន និងការស្រាវជ្រាវបែបគុណភាពបានរកឃើញថា បញ្ហាផ្នែកអភិបាលកិច្ច និងការទទួលខុសត្រូវ ដូចដែលស្ថាប័នរដ្ឋកំពុងប្រឈមមុខនោះ ក៏កើតមានដូចគ្នានៅក្នុងរង្វង់អង្គការសង្គមស៊ីវិលដែរ ។ សំរាប់អង្គការសង្គមស៊ីវិលថ្នាក់មូលដ្ឋាន ការមានសមត្ថភាព និងជំនាញផ្នែករៀបចំនិងគ្រប់គ្រងតិចតួច ជាកត្តាធ្វើអោយប៉ះពាល់ដល់ដំណើរការប្រព្រឹត្តទៅប្រចាំថ្ងៃរបស់អង្គការ ហើយបានកំរិតលទ្ធភាពអភិវឌ្ឍ និងការពង្រីកអង្គការ ។ ការមានទំនុកចិត្ត និងមូលធនសង្គមតិចតួចនិងទំរង់ដឹកនាំបែបបិតុនិយម (ជាជាងបែបប្រជាធិបតេយ្យ) គឺជាកត្តារាំងស្ទះដ៏ចំបងផងដែរ ។ ដោយសារប្រជា-ពលរដ្ឋមានភាពស៊ាំទៅនឹងការទំនាក់ទំនងក្រៅផ្លូវការ មានលក្ខណៈជាបុគ្គល (ផ្អែកលើឋានានុក្រមនិងឋានៈផ្ទាល់ខ្លួន) ការណែនាំអោយអនុវត្តនូវវិធាននិងនីតិវិធីជាលក្ខណៈស្ថាប័ន ជំនួសអោយរចនាសម្ព័ន្ធបែបឋានានុក្រម និងមានលក្ខណៈជាបុគ្គលនោះ គឺជាគំនិតមួយថ្មី និងជាបញ្ហាប្រឈមមួយ ។ ការចុះសំភាសន៍ផ្ទាល់តាមមូលដ្ឋានតែងបង្ហាញអោយឃើញអំពីកង្វះបទពិសោធន៍ និងការលំបាកក្នុងការគ្រប់គ្រងសមាគមដែលមានទ្រង់ទ្រាយធំ និងមានលក្ខណៈផ្លូវការ ។

"ប្រធានសហគមន៍មិនចង់មានសមាជិកច្រើនទេ ព្រោះវាធ្វើអោយពិបាកគ្រប់គ្រង ។ ប្រសិនបើគ្មានឧបសគ្គនេះទេ [ចំនួន] សមាជិករបស់សហគមន៍យើងនឹងច្រើនជាងនេះ ។" *សមាជិកពីរូបនៃសហគមន៍ (ដែលគាំទ្រដោយអង្គការអាដហុក) ដើម្បីលើកកំពស់ និងការពារសិទ្ធិមនុស្ស ក្នុងខេត្តកំពង់ចាម (ស្រុកព្រៃឈរ)*

"ចាប់តាំងពីក្រុមរបស់ខ្ញុំត្រូវបានបង្កើតមក មានគ្រួសារជាច្រើនចាប់អារម្មណ៍ចូលរួម ប៉ុន្តែពួកគេមិនត្រូវបានអនុញ្ញាតអោយចូលជាសមាជិកក្រុមទេ ដោយសារតែមានការលើកឡើងថា ប្រសិនបើក្រុមធំពេក វានឹងពិបាកគ្រប់គ្រង ។ គ្រួសារទាំងនោះត្រូវបានផ្តល់យោបល់អោយបង្កើតក្រុមដោយខ្លួនឯង ។"

*ប្រធានក្រុមស្ត្រីនៅក្នុងសមាគមកសិករមួយ (គាំទ្រដោយអង្គការសេដាក) ក្នុងខេត្តកំពង់ចាម (ស្រុកជើងព្រៃ)*

១០០. ដើម្បីអោយសង្គមស៊ីវិលដើរតួនាទីបានកាន់តែល្អប្រសើរក្នុងការជួយរដ្ឋាភិបាលអោយមានតម្លាភាព និងមានការទទួលខុសត្រូវ អង្គការសង្គមស៊ីវិលខ្លួនឯងផ្ទាល់ត្រូវខិតខំធ្វើជាគំរូគេទាំងផ្នែកគុណតំលៃ និងការអនុវត្តជាក់ស្តែង នូវអ្វីដែលខ្លួនឯងចង់អោយគេធ្វើ ។ ជាអកុសល អង្គការសង្គមស៊ីវិលជាច្រើននៅគ្រប់កំរិតថ្នាក់នៅកម្ពុជា ពុំសូវប្រកាន់យកលទ្ធិប្រជាធិបតេយ្យ ការចូលរួម និងការទទួលខុសត្រូវចំពោះ "ថ្នាក់ក្រោម" នៅក្នុងផ្ទៃក្នុងរបស់ខ្លួនទេ ។ អង្គការសង្គមស៊ីវិលកម្ពុជាជាច្រើន រាប់បញ្ចូលទាំងអង្គការក្រៅរដ្ឋាភិបាលអាជីពផង ត្រូវបានបង្កើតដោយប្រធានដែលមានប្រជាប្រិយភាព (ច្រើនតែជាស្ថាបនិក) ហើយដែលជោគជ័យ និងភាពគង់វង្សនៃអង្គការ តែងពឹងផ្អែកយ៉ាងខ្លាំងទៅលើអ្នកទាំងនោះ ។ អ្នកដឹកនាំទាំងនោះ (ចាប់តាំងពីថ្នាក់សហគមន៍រហូតដល់ថ្នាក់ជាតិ) ដើរតួនាទីយ៉ាងសំខាន់ ប៉ុន្តែក្នុងចំណោមនោះ មានបុគ្គលមួយចំនួនតូចប៉ុណ្ណោះដែលមានឱកាសរៀនសូត្រ និងអភិវឌ្ឍជំនាញដឹកនាំដែលមានលក្ខណៈតម្លាភាព ប្រជាធិបតេយ្យ ការចូលរួម និងការទទួលខុសត្រូវ ។ ខណៈដែលគំរូដឹកនាំបែប "ថ្នាក់លើ-ថ្នាក់ក្រោម" និងឥរិយាបថបែបបិតុនិយមកើតមានព្រោងព្រាតនៅកម្ពុជា អ្នកដឹកនាំក្នុងសង្គមស៊ីវិល (រួមទាំងសមាជិកផង) តែងបែរទៅប្រកាន់យកគំរូអភិបាលកិច្ចម្យ៉ាងដែលពឹងផ្អែកលើអ្នកដទៃ ដោយមិនដឹងខ្លួន ហើយលើសពីនេះទៀតខកខានមិនបានលើកទឹកចិត្ត និងផ្តល់អំណាចដល់សមាជិកខ្លួនអោយហ៊ាននិយាយ និងធ្វើអ្វីៗជំនួសខ្លួន ឬចូលរួមនៅក្នុងការសំរេចចិត្ត និងទាមទារអោយមានការទទួលខុសត្រូវឡើយ [៣៩] ។ ឧទាហរណ៍ កិច្ចសំភាសន៍ ជាមួយសមាជិកសមាគមបែបប្រពៃណីនៅក្នុងខេត្តកំពង់ធំ (*ស្រុកស្ទោង*) បានអោយដឹងថា គុណភាពនៃជីវភាពសមាគម ពឹងផ្អែកយ៉ាងខ្លាំងទៅលើបុគ្គលិកលក្ខណៈរបស់ប្រធានសមាគម ដែលគិតថាខ្លួនគាត់មានសិទ្ធិអំណាចបញ្ចេញមតិជំនួសអោយសមាគម ដោយផ្អែកលើភាពសមស្របផ្ទាល់ខ្លួន និងសមិទ្ធិផលផ្ទាល់ខ្លួនគាត់ ជាជាងក្នុងនាមជាអ្នកតំណាង និងជាអ្នកការពារប្រយោជន៍ និងសិទ្ធិរបស់សមាជិក (ដែលទាំងនេះត្រូវបានព្រមព្រៀងតាមបែបប្រជាធិបតេយ្យនោះ) ។ សមាជិកសមាគមតែងត្រូវបានទាក់ទាញដោយក្រមសីលធម៌ និង/ឬ សមត្ថភាពរបស់អ្នកដឹកនាំក្នុងការផ្តល់ប្រយោជន៍ ។ នៅក្នុងបរិបទបែបនេះ សមាជិកពុំទាមទារអោយចែករំលែកការគ្រប់គ្រង ឬអោយមានការទទួលខុសត្រូវពីប្រធានឡើយ ហើយផ្ទុយទៅវិញគឺពឹងផ្អែកទៅលើអ្នកដឹកនាំអោយដោះស្រាយបញ្ហាដែលកើតមាន ។ នៅក្នុងកិច្ចសំភាសន៍និងការពិភាក្សាតាមក្រុម អ្នកដឹកនាំក្នុងមូលដ្ឋានមួយចំនួនបានត្អូញត្អែរអំពីចំណូលចិត្តរបស់សមាជិកក្នុងការពឹងផ្អែកទៅលើអ្នកដឹកនាំទាំងស្រុងពេក ជាជាងការចាត់វិធានការណ៍ដោយខ្លួនឯង ។ ក្នុងពេលជាមួយគ្នានេះដែរ ការស្រាវជ្រាវនេះបានរកឃើញថា អ្នកដឹកនាំមិនសូវទុកឱកាសអោយសមាជិករបស់ខ្លួនបញ្ចេញមតិយោបល់អំពីក្តីបារម្ភរបស់ពួកគេ ឬបានអភិវឌ្ឍសមត្ថភាពរបស់គេទេ ។ ឧទាហរណ៍ ការពិភាក្សាតាមក្រុមជាមួយសមាជិកសមាគមកសិករក្នុងខេត្តតាកែវ (*ស្រុកត្រាំកក់*) ត្រូវបានគ្របដណ្តប់យ៉ាងលើសលប់ដោយមេដឹកនាំ ដែលមានឥទ្ធិពល និងមានសមត្ថភាពខ្ពស់ ឯសមាជិកវិញមិនសូវបានបញ្ចេញមតិយោបល់ និងបទពិសោធន៍ផ្ទាល់ខ្លួនឡើយ ។ អ្នកចូលរួមជាច្រើនហាក់មានអារម្មណ៍ថាត្រូវបានរារាំងហើយពេញចិត្តក្នុងការផ្តល់ឱកាសទៅអោយអ្នកដឹកនាំរបស់ខ្លួន ដែលទំនងមានទំលាប់និយាយជំនួសសមាជិក ហើយដែលមិនបានលើកទឹកចិត្ត និងផ្តល់អំណាចអោយសមាជិកនិយាយនោះជាអ្នកនិយាយជំនួសខ្លួនវិញ ។

១០១. ការស្រាវជ្រាវបែបគុណភាពបង្ហាញអោយដឹងថា **អង្គការសង្គមស៊ីវិលបែប "ទំនើប" ហើយដែលមានរចនាសម្ព័ន្ធផ្លូវការច្បាស់លាស់ ដោយរាប់បញ្ចូលទាំងអង្គការក្រៅរដ្ឋាភិបាលដែលបុគ្គលិកមានប្រាក់បៀវត្សរ៍ផងនោះ តែងស្តែងអោយឃើញពីបែបផែនដឹកនាំម្យ៉ាងដែលយកអ្នកដឹកនាំជាសំខាន់ មានការគ្រប់គ្រងបែបបុគ្គលនិយម កង្វះការប្រកាន់ខ្ជាប់នូវអភិបាលកិច្ចបែបប្រជា**

[39] សូមមើល O'Leary and Meas, 2001.

**ធិបតេយ្យ និងការចូលរួម ។** ទំនាក់ទំនងជាមួយស្ថាប័នម្ចាស់ជំនួយក៏ស្តែងអោយឃើញនូវបញ្ហាប្រឈមដែរ ដោយសារជាញឹកញយអង្គការសង្គមស៊ីវិលប្រកាន់យកនូវទំនាក់ទំនងបែប "ថ្នាក់លើ-ថ្នាក់ក្រោម" និងផ្តោតការយកចិត្តទុកដាក់ច្រើនទៅលើការទទួលខុសត្រូវចំពោះ "ថ្នាក់លើ" (ចំពោះម្ចាស់ជំនួយ) ច្រើនជាង "ការទទួលខុសត្រូវចំពោះថ្នាក់ក្រោម" (អតិថិជន សមាជិកប្រជាពរលដ្ឋគោលដៅ) ។ បើទោះបីជាទូទៅសមាគមបែបប្រពៃណីចាត់ទុកការស្ម័គ្រចិត្តជាផ្នែកមួយដ៏ចំបង ហើយតែងពឹងផ្អែកលើការគៀងគរធនធានពីសមាជិកភាព និងលើគុណតំលៃល្អ (ដូចជាក្រមសីលធមិរបស់អ្នកដឹកនាំជាដើម)របស់ខ្លួនយ៉ាងណាក្តីក៏ការស្រាវជ្រាវនេះបានរកឃើញថា អ្នកដឹកនាំអង្គការក្រៅរដ្ឋាភិបាលហាក់ដូចជាបានគិតថាខ្លួនមិនសូវមានកាតព្វកិច្ចក្នុងការពិគ្រោះយោបល់ជាមួយ ឬរាយការណ៍ជូនបុគ្គលិករបស់ខ្លួនឡើយ តែបែរជាយល់ថាគាត់មានករណីយកិច្ច និងការទទួលខុសត្រូវចំពោះម្ចាស់ជំនួយច្រើនជាងចំពោះបុគ្គលិករបស់គាត់ទៅវិញ ។ ឧទាហរណ៍ ការវាយតំលៃមួយទៅលើអង្គការសង្គមស៊ីវិលក្នុងឆ្នាំ ២០០៦ បានរកឃើញថា "បើទោះបីអង្គការសង្គមស៊ីវិលភាគច្រើនកំពុងខិតខំតស៊ូមតិដើម្បីលើកដំកើងគុណតំលៃដូចជាលទ្ធិប្រជាធិបតេយ្យ តម្លាភាព ការទទួលខុសត្រូវ ការចូលរួម [...] យ៉ាងណាក៏ដោយ ក៏មានតែគុណតំលៃមួយចំនួនប៉ុណ្ណោះ ដែលអង្គការទាំងនោះប្រកាន់យកដោយខ្លួនឯង" (SIDA, 2006) ។ បើទោះបីជាមានការទទួលស្គាល់នូវបញ្ហាប្រឈម និងចំណុចខ្សោយបែបនេះក៏ដោយ (ដូចមានបង្ហាញជូនក្នុងរូបភាពទី២០) អ្នកចូលរួមនៅក្នុងការអង្កេតលើអង្គការក្រៅរដ្ឋាភិបាលនោះ ច្រើនតែផ្តល់ចំណាត់ថ្នាក់យ៉ាងខ្ពស់ទៅលើការអនុវត្តអភិបាលកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដែលចំណុចនេះបង្ហាញអោយឃើញពីការបដិសេធន៍ចំពោះបញ្ហាប្រឈមផ្ទៃក្នុង និង/ឬភាពស្ទាក់ស្ទើរក្នុងការសារភាពជាសាធារណៈអំពីចំណុចខ្វះខាតរបស់ខ្លួន (ខ្លាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះអង្គការ ឬឱកាសស្វែងរកមូលនិធិ) ។

១០២. **ការសិក្សាស្រាវជ្រាវនេះបានរកឃើញឧទាហរណ៍មួយចំនួនគួរជាទីពេញចិត្ត ទាំងនៅថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ ដែលនោះគឺជាកិច្ចខិតខំប្រឹងប្រែងបង្កើតនូវគំរូដឹកនាំដែលមានលក្ខណៈឆ្លើយតប មានការចូលរួម និងការទទួលខុសត្រូវ ។** ឧទាហរណ៍ អង្គការសេដាក មិនត្រឹមតែផ្តល់ការបណ្តុះបណ្តាលផ្នែកបច្ចេកទេសកសិកម្ម ដើម្បីឆ្លើយតបទៅនឹងផលប្រយោជន៍ផ្នែកជីវភាពរបស់កសិករប៉ុណ្ណោះទេ ប៉ុន្តែក៏បានយកចិត្តទុកដាក់លើការអភិវឌ្ឍន៍សមត្ថភាពផ្នែកដឹកនាំ និងគ្រប់គ្រងរបស់ប្រធានសមាគមកសិករផងដែរ ។ ប្រធានសមាគមកសិករ (ជោគជ័យ) ដែលត្រូវបានសំភាសន៍ បានសង្កត់ធ្ងន់ពីសារៈសំខាន់ក្នុងការដែលគាត់បានអនុវត្តទៅតាមនីតិវិធីគ្រប់គ្រងដែលប្រកបដោយតម្លាភាព យុត្តិធម៌ ហើយត្រូវបានសមាជិកទាំងអស់យល់ និងទទួលស្គាល់ពីរូបគាត់នោះ ។ ពួកគាត់ក៏បានសង្កត់ធ្ងន់អំពីសារៈសំខាន់ក្នុងការធ្វើយ៉ាងណាអោយសមាជិកគ្រប់រូបមានអារម្មណ៍ថាពួកគេមានអ្នកតំណាង និងមានការគាំទ្រក្នុងកិច្ចខិតខំប្រឹងប្រែងកែលំអមុខរបរចិញ្ចឹមជីវិតពួកគេនោះ ។ ដូចដែលប្រធានសមាគមកសិករម្នាក់ក្នុងខេត្តកំពង់ចាម (*ស្រុកជើងព្រៃ*) បាននិយាយថា "កសិករតែងខ្វះទំនុកចិត្ត ហើយដំបូងមិនសូវចាប់អារម្មណ៍ចូលរួមក្នុងក្រុមដែលមានលក្ខណៈផ្លូវការទេ" ។ ជាមួយនឹងជំនាញឯកទេស និងការគាំទ្ររបស់អង្គការ ប្រធានសមាគមកសិករត្រូវបានលើកទឹកចិត្តអោយកសាងទំនុកចិត្ត និងបង្កើតជាគំរូបែបប្រជាធិបតេយ្យមួយ ដោយការចែករំលែកព័ត៌មានជាទៀងទាត់ ទទួលយកការចូលរួមយោបល់ និងលើកទឹកចិត្តអោយសមាជិកចូលរួមក្នុងដំណើរការសំរេចចិត្ត តាមរយៈការពិគ្រោះយោបល់ជាទៀងទាត់ ។ តម្លាភាពនៅក្នុងការដឹកនាំ ជាពិសេសទាក់ទងទៅនឹងបញ្ហាហិរញ្ញវត្ថុគឺជាបញ្ហាសំខាន់បំផុត ។ បើតាមប្រធានសមាគមកសិករដដែលនៅក្នុងខេត្តកំពង់ចាមនោះបានអោយដឹងថា "ប្រសិនបើពុំមានភាពច្បាស់លាស់អំពីការប្រើប្រាស់វិភាគទានរបស់សមាជិកទេនោះ សមាគមនឹងគ្មានសមាជិកឡើយ" ។ តែទោះជាយ៉ាងណាក្តី ដើម្បីក្លាយខ្លួនជាអ្នកមានបទពិសោធន៍ និងដើម្បីកែលំអ

សមត្ថភាពផ្ទៃក្នុងគ្រប់គ្រង វាត្រូវការដំណើរការមួយយូរអង្វែង ជាពិសេសទាក់ទងទៅនឹងគុណភាពនៃការដឹកនាំ និងការបង្កើតបណ្តាញអោយបានរឹងមាំថែមទៀត ។ អនន្តរកម្មក្នុងចំណោមប្រជាកសិករ មានន័យថាវាតំរូវអោយមានការទំនាក់ទំនងផ្ទាល់មាត់ច្រើនរវាងអ្នកដឹកនាំនិងសមាជិក ដើម្បីធានាអោយមានការយល់ដឹងច្បាស់លាស់អំពីលក្ខន្តិកៈ បទបញ្ជា និងនីតិវិធីផ្ទៃក្នុង ។

**រូបភាពទី ២១ : ស្វ័យវាយតំលៃរបស់អង្គការក្រៅរដ្ឋាភិបាលអំពីការគ្រប់គ្រងផ្ទៃក្នុង**




ប្រភព : CAS/WB, 2007a

១០៣. ក្នុងពេលពិភាក្សាជាមួយសមាជិករបស់សហព័ន្ធទេសចរណ៍ និងបុគ្គលិកផ្តល់សេវាកម្ពុជា (CTSWF) ក្នុងខេត្តសៀមរាប អ្នកចូលរួមក្នុងការពិភាក្សាមួយចំនួនបានសង្កត់ធ្ងន់ថា អតីតអនុប្រធានសហព័ន្ធ CTSWF ប្រចាំខេត្តសៀមរាប (បច្ចុប្បន្នជាប្រធានរបស់ CTSWF) បានដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងការបង្កើតសហជីពក្នុងមូលដ្ឋាន ដោយការប្រើប្រាស់នូវការដឹកនាំដ៏ល្អ (ដូចជាប្រជាប្រិយភាព និងសមត្ថភាពក្នុងការរៀបចំ) ជាមួយនឹងអាកប្បកិរិយាប្រកបដោយការឆ្លើយតប និងការចូលរួម ។ ការប្តេជ្ញាចិត្តរបស់គាត់ក្នុងការដឹកនាំសកម្មភាពកូដកម្ម និងការជូនដំណឹងដល់សមាជិកអំពីដំណើរការចរចាររបស់គាត់ ព្រមទាំងការសំរេចចិត្តបែបចូលរួម គឺជាកត្តាបានលើកទឹកចិត្តអោយសមាជិកបន្តធ្វើកូដកម្មរហូតដល់ទីបញ្ចប់នៃវិវាទ ។ នៅក្នុងការពិភាក្សាតាមក្រុម និងកិច្ចសំភាសន៍**សមាជិកសហជីពបានលើកឡើងថា ការទំនាក់ទំនងជាប្រចាំជាមួយអ្នកដឹកនាំ និងការដែលបានចូលរួមនៅក្នុងដំណើរការសំរេចចិត្ត គឺជាកត្តាលើកទឹកចិត្តដ៏ខ្លាំង ។** សមាជិកសហជីពក៏បានបង្ហាញពីការយល់ដឹងក្នុងកំរិតខ្ពស់អំពីបញ្ហាផ្នែកការងារ ច្បាប់ និងទំនុកចិត្តក្នុងការដឹកនាំក្រុមរបស់ខ្លួន ។

“សមាជិកភាពគឺជាកត្តាដែលធ្វើអោយសហជីពមានជីវិត និងជោគជ័យ មិនមែនខ្ញុំទេ [អ្នកដឹកនាំ]។ ខ្ញុំគ្រាន់តែទទួលខុសត្រូវសំរបសំរួលសកម្មភាពរបស់សមាជិកនៅក្នុងបែបផែនមួយដែលអាចដោះស្រាយរាល់ទំនាស់ ដើម្បីជាប្រយោជន៍ដល់ភាគីទាំងពីរ ដោយតែងព្យាយាមបង្កើតនូវស្ថានភាពឈ្នះ-ឈ្នះមួយប៉ុណ្ណោះ ។ នេះមិនមែនមានន័យថាជៀសវាងមិនការពារប្រយោជន៍របស់យើងនោះទេ ។ ប្រសិនបើមិនអាចចរចាររកដំណោះស្រាយបានទេ នោះយើងនឹងត្រូវបង្ខំចិត្តធ្វើ

កូដកម្ម ប៉ុន្តែទង្វើនេះអាចធ្វើទៅបានលុះត្រាណាតែវាជាការសំរេចចិត្តរបស់សមាជិក និងបន្ទាប់ពីឆ្លងកាត់ដំណើរការពិភាក្សាយ៉ាងល្អិតល្អន់ និងបានថ្លឹងថ្លែងអំពីផលវិបាកសំរាប់ភាគីទាំងសង្ខាងរួចរាល់។" *ប្រធាន CTSWF ខេត្តសៀមរាប*

### ២.គ.៣. ការកសាងបណ្តាញ និងសម្ព័ន្ធភាពរបស់សង្គមស៊ីវិល

១០៤. **បើទោះបីក្នុងទសវត្សកន្លងមកមានកិច្ចខិតខំគួរអោយចាប់អារម្មណ៍ ក្នុងការលើកកំពស់ការចែករំលែកព័ត៌មាន និងការចងក្រងបណ្តាញក្នុងចំណោមអង្គការសង្គមស៊ីវិលនៅគ្រប់កំរិតថ្នាក់ក៏ដោយ ក៏ប្រសិទ្ធិភាព និងឥទ្ធិពលនៃបណ្តាញទាំងនោះនៅមានកំរិតទាបនៅឡើយ ។** មានបណ្តាញតែមួយចំនួនតូចប៉ុណ្ណោះដែលកំពុងប្រតិបត្តិនៅថ្នាក់ជាតិ (ដូចជាអង្គការ CCC អង្គការ NGO Forum អង្គការស្តារកម្ពុជា អង្គការ MediCam និង NEP) ដែលបានបង្កើតនូវប្រព័ន្ធ និងរចនាសម្ព័ន្ធរៀបរយល្អសំរាប់ការសំរបសំរួល និងការចែករំលែកព័ត៌មានបានទៀងទាត់ ។ ឯបណ្តាញថ្នាក់ខេត្តទើបត្រូវបានបង្កើតឡើង ហើយច្រើនតែជួបប្រទះការលំបាកដោយសារខ្វះជំនួយ (ថវិកា និងបច្ចេកទេស) ។ ការសំភាសន៍ផ្ទាល់តាមមូលដ្ឋាននៅក្នុងខេត្តចំនួនបួន បានរកឃើញថាអង្គការដែលជាសមាជិកបណ្តាញភាគច្រើនមានការយល់ដឹងតិចតួចអំពីអត្តសញ្ញាណ ឬគោលបំណងរួមរបស់ខ្លួន ដែលហេតុនេះហើយ ពួកគេពុំសូវមើលឃើញពីអត្ថប្រយោជន៍នៃការសំរបសំរួល និងកិច្ចសហការឡើយ ។ ដូចមានរៀបរាប់ នៅក្នុងប្រអប់ ទី៩ ខាងក្រោម ការគ្រប់គ្រងដែលមានលក្ខណៈទន់ខ្សោយ និងមិនផ្លូវការ និងការក្តោបក្តាប់តួនាទីដឹកនាំជាលក្ខណៈបុគ្គល (ជាជាងជាលក្ខណៈស្ថាប័ន) ព្រមទាំងផ្នត់គំនិតប្រកួតប្រជែងរវាងអង្គការសង្គមស៊ីវិល (ឧទាហរណ៍ ដើម្បីទាក់ទាញមូលនិធិពីម្ចាស់ជំនួយ) គឺជាបញ្ហាប្រឈមដ៏ចំបងចំពោះការភ្ជាប់បណ្តាញ និងការកសាងសម្ព័ន្ធភាពអោយមានប្រសិទ្ធិភាព ។ នៅក្នុងខេត្តមួយចំនួន ក្រុមស្រាវជ្រាវបានរកឃើញឧទាហរណ៍ខ្លះដែលបណ្តាញអង្គការសង្គមស៊ីវិលគ្មានធ្វើសកម្មភាព ឬមិនដំណើរការតែម្តង ដោយសារប្រធានបណ្តាញដែលគេទុកចិត្តបានលាឈប់ ឬដោយសារសមាជិកមិនមានសមត្ថភាពធ្វើការសំរេចចិត្តរួមគ្នា ឬដោះស្រាយបញ្ហាបាន ។ ការស្រាវជ្រាវនេះបានរកឃើញថា ក្នុងករណីមានបញ្ហា ឬការខ្វែងគំនិតគ្នា សមាជិកច្រើនតែដកខ្លួនថយពីសកម្មភាពបណ្តាញ ជាជាងស្វែងរកការពិភាក្សា និងដោះស្រាយបញ្ហាដែលមិនឯកភាពគ្នានេះ ។

**ប្រអប់ទី៩ : បណ្តាញតស៊ូមតិនៃអង្គការក្រៅរដ្ឋាភិបាលប្រចាំខេត្តកំពង់ចាម (K-NAN)**

ដោយត្រូវបានបង្កើតឡើងមុនការបោះឆ្នោតជាតិឆ្នាំ ១៩៩៨ បន្តិច K-NAN គឺជាបណ្តាញអង្គការក្រៅរដ្ឋាភិបាលមួយដែលមានវ័យចំណាស់ និងល្បីល្បាញមួយនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងឆ្នាំ ១៩៩៩ សមាជិកស្ថាបនិករបស់បណ្តាញនេះបានព្រាងគោលការណ៍ លក្ខន្តិកៈ និងបទបញ្ជារបស់ខ្លួន ហើយបានបោះឆ្នោតជ្រើសរើសគណៈកម្មការសំរបសំរួលមួយ ។ អង្គការ*ស្តារកម្ពុជា* ដែលជាអង្គការក្រៅរដ្ឋាភិបាលនៅភ្នំពេញបានផ្តល់ថវិកាដើម្បីចាប់ផ្តើមសកម្មភាពបណ្តាញ និងបន្តផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសទៀត ។ អ្នកសំរបសំរួលស្ថាបនិករបស់បណ្តាញនេះ (ជាអ្នកសំរបសំរួលថ្នាក់ខេត្តរបស់អង្គការអាដហុក) មានតួនាទីយ៉ាងសំខាន់ ។ សមាជិករបស់បណ្តាញបានកោតសរសើរពីជំនាញរៀបចំចាត់ចែង តម្លាភាព និងភាពស្មោះត្រង់ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុរបស់គាត់ និងចំពោះកិច្ចខិតខំរបស់គាត់ដើម្បីពិគ្រោះយោបល់ និងធ្វើអោយមានការចូលរួមពីគ្រប់សមាជិកទាំងអស់ ។ សមត្ថភាពរបស់គាត់ក្នុងការខិតខំបង្កើតទំនាក់ទំនងផ្ទាល់ខ្លួនជាមួយគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គមបានធ្វើអោយ K-NAN អាចធ្វើការចរចារប្រកបដោយជោគជ័យជាមួយនឹងអាជ្ញាធរមូលដ្ឋាន រួមទាំងនគរបាល និងយោធា អំពីទំនាស់ដីធ្លីធ្ងន់ធ្ងរនៅក្នុងតំបន់នោះ និងអាចបង្ការការបណ្តេញអ្នកភូមិដែលប៉ះពាល់ក្នុងទ្រង់ទ្រាយធំបាន ។ ប៉ុន្តែជាច្រើនអាណត្តិក្រោយមក អ្នកសំរបសំរួលថ្មីម្នាក់ត្រូវបានតែងតាំងជំនួស ។ ចាប់តាំងពីពេលនោះមក បណ្តាញនេះមានការលំបាកនៅក្នុងការរក្សាសមាជិកភាព និងបន្តសកម្មភាពរបស់ខ្លួន ។ អ្នកដែលត្រូវបានសំភាសន៍បានលើកឡើងពីការមិនពេញចិត្តរបស់សមាជិកមួយចំនួនទៅលើរបៀបគ្រប់គ្រង និងរបៀបធ្វើការរបស់អ្នកគ្រប់គ្រងថ្មី ។ ការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មានលែងមានភាពទៀងទាត់ដូចមុន ហើយសមាជិកខ្លះចាប់ផ្តើម (ជាលក្ខណៈឯកជន) ចោទសួរអំពីកម្មវិធី និងការសំរេចចិត្តលើការប្រើប្រាស់ធនធាន ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន (ក្នុងចំណោមអង្គការជាសមាជិកប្រមាណជា២០) បានដកខ្លួនចេញពីកម្មវិធីមួយចំនួន ហើយការបែកបាក់គ្នាបានចាប់ផ្តើមកើតមានឡើង ។ ជាជាងការលើកបញ្ហាមកពិភាក្សាដោយចំហនៅក្នុងកិច្ចប្រជុំផ្លូវការរបស់បណ្តាញ និងព្យាយាមដោះស្រាយបញ្ហាទាំងនោះ (ផ្អែកតាមនីតិវិធីដែលបានកំណត់) សមាជិកច្រើនតែរក្សាភាពស្ងប់ស្ងៀមដកខ្លួនចេញបន្តិចម្តងៗ ឬចាកចេញពីបណ្តាញ (ឧទាហរណ៍ ដោយយកលេសថាមមាញឹកខ្លាំងពេក)។ ជាលទ្ធផលមកដល់បច្ចុប្បន្ននេះ មានសមាជិកតែមួយចំនួនតូចប៉ុណ្ណោះដែលនៅសកម្មចូលរួមក្នុងសកម្មភាពរបស់បណ្តាញ ។ អ្នកផ្តល់បទសំភាសន៍ម្នាក់សំដែងនូវការសោកស្តាយដោយបាននិយាយថា "ការលាលែងរបស់អង្គការក្រៅរដ្ឋាភិបាលជាច្រើនពី K-NAN បានធ្វើអោយបណ្តាញនេះចុះខ្សោយ លែងជាកំលាំងដ៏មានប្រសិទ្ធិភាពមួយដើម្បីធ្វើការចរចារជាមួយអាជ្ញាធរសាធារណៈទៀត"។

*ប្រភព: CAS/WB, ២០០៧b*

១០៥. **នៅថ្នាក់ឃុំ ការផ្សារភ្ជាប់រវាង និងក្នុងចំណោមអង្គការសហគមន៍ និងអង្គការសង្គមស៊ីវិល ក៏នៅមានកំរិតតិចតួចដែរ ហើយក្រុមទាំងនេះក៏ប្រឈមនឹងបញ្ហាកង្វះសមត្ថភាព និងធនធានកាន់តែធ្ងន់ធ្ងរថែមទៀត ។ តែទោះជាយ៉ាងណាក្តី ការស្រាវជ្រាវបានរកឃើញនូវឧទាហរណ៍ជោគជ័យមួយចំនួន ដែលទាក់ទងនឹងការកសាងបណ្តាញនៅថ្នាក់មូលដ្ឋានបែបនេះ ។** ឧទាហរណ៍ នៅក្នុង

ខេត្តកំពង់ធំ គំរោង "បណ្តាញអ្នកភូមិ" ដែលគាំទ្រដោយអង្គការ GTZ បានខិតខំកសាងទំនាក់ទំនងក្នុងចំណោម និងរវាងអង្គការសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ។ ដូចដែលមានរៀបរាប់នៅក្នុងប្រអប់ ទី១០ ខាងក្រោម គំរោងនេះទទួលបានលទ្ធផលគួរជាទីពេញចិត្តទាក់ទងទៅនឹងការទំនាក់ទំនង ការលើកកំពស់ការយោគយល់គ្នាទៅវិញទៅមក និងឆន្ទៈក្នុងការធ្វើការជាមួយគ្នា ។ អង្គការសេដាកក៏ប្រកាន់យកវិធីសាស្រ្តគួរជាទីទុកចិត្តដែរ ដោយលើកទឹកចិត្តសមាគមកសិករអោយកសាងទំនាក់ទំនងក្នុងលក្ខណៈជាប្រព័ន្ធដើម្បីផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍រវាងគ្នាទៅវិញទៅមក ។ តាមរយៈការផ្លាស់ប្តូរនិងការធ្វើទស្សនៈកិច្ចសិក្សាតាមបណ្តាខេត្តដទៃ សមាជិកនិងប្រធានសមាគមអាចរៀនសូត្រពីគ្នាទៅវិញទៅមក ព្រមទាំងកំណត់រក និងពិភាក្សាអំពីក្តីបារម្ភរួម ។ ជាងនេះទៀត សមាគមដែលជោគជ័យបានចាប់ផ្តើមទាក់ទងកសិករនៅក្នុងភូមិ និងឃុំដទៃទៀតដែលមានចំណាប់អារម្មណ៏ដើម្បីចែករំលែកព័ត៌មាន ចំណេះដឹង និងបទពិសោធន៍ព្រមទាំងលើកទឹកចិត្តអោយមានការបង្កើតសមាគមឆ្លងឃុំទៀតផង ។ នៅក្នុងឃុំមួយចំនួន (ដូចជាឃុំអង្គតាសោម ស្រុកត្រាំកក់ ក្នុងខេត្តតាកែវ ជាដើម) កំរងសមាគមភូមិបានចាប់ផ្តើមដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងជីវភាពរបស់សមាគមថ្នាក់ឃុំ និងប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរដែនដី ។ តែទោះជាយ៉ាងណាក្តី នេះជាដំណើរការរយៈពេលវែង ព្រោះអង្គការសហគមន៍ត្រូវដកបទពិសោធន៍ និងកសាងទំនុកចិត្តលើខ្លួនឯងផ្នែកគ្រប់គ្រង ព្រមទាំងធ្វើអោយក្រុមមាននិរន្តរភាព និងឯករាជ្យភាពផ្នែកមូលនិធិ ។

**ប្រអប់ទី១០ : គំរោង "បណ្តាញអ្នកភូមិ" ដែលគាំទ្រដោយអង្គការ GTZ**

ជាច្រើនឆ្នាំកន្លងមកនេះ អង្គការក្រៅរដ្ឋាភិបាលនៅក្នុងខេត្តកំពង់ធំបានទទួលការគាំទ្រពីអង្គការ GTZ ដើម្បីធ្វើការងារជាមួយសមាគមបែបប្រពៃណី ដោយផ្សារភ្ជាប់ទៅនឹង "បណ្តាញអ្នកភូមិ" សំដៅជំរុញការប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរមូលដ្ឋានអោយកាន់តែល្អប្រសើរឡើង ។ បណ្តាញទាំងនេះបានបង្កលក្ខណៈសំរាប់ការផ្លាស់ប្តូរព័ត៌មាន ហើយក្នុងករណីខ្លះបានធ្វើអោយកិច្ចសហការរវាងអង្គការសហគមន៍ និងអាជ្ញាធរមូលដ្ឋានមានលក្ខណៈល្អប្រសើរជាងមុន ប៉ុន្តែបណ្តាញទាំងនេះនៅតែជួបបញ្ហាប្រឈមធំៗក្នុងការអភិវឌ្ឍន៏សមត្ថភាពផ្នែកគ្រប់គ្រង និងស្វ័យនិរន្តរភាពរបស់ខ្លួន នៅពេលលែងមានការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល ។ ក្រៅពីការជូនដំណឹងដល់ក្រុមប្រឹក្សាឃុំអំពីសេចក្តីត្រូវការ និងការព្រួយបារម្ភជាអាទិភាពរបស់ប្រជាពលរដ្ឋតាមមូលដ្ឋាន បណ្តាញភូមិក៏មានការប្តេជ្ញាចិត្តកសាងចំណេះដឹង និងសមត្ថភាពរបស់សមាជិកសហគមន៍ និងគៀងគរពួកគេអោយចូលរួមនៅក្នុងការរៀបចំផែនការរបស់ក្រុមប្រឹក្សាឃុំផងដែរ ។ អ្នកផ្តល់បទសំភាសន៏តែងបាននិយាយថា បើទោះបីមានការលំបាកក្នុងរក្សាអោយអ្នកភូមិចូលរួមយ៉ាងសកម្ម និងអោយមានការប្រាស្រ័យទាក់ទងជាលក្ខណៈប្រព័ន្ធជាមួយអាជ្ញាធរមូលដ្ឋានយ៉ាងណាក្តី ក៏បណ្តាញអ្នកភូមិទាំងនេះបានដើរតួដ៏សំខាន់ក្នុងការពាំនាំពីសេចក្តីត្រូវការ ការព្រួយបារម្ភ និងការស្នើសុំនានាអោយមន្ត្រីសាធារណៈបានដឹង ហើយមន្ត្រីទាំងនោះបានទទួលស្គាល់ថា ឥឡូវនេះពួកគេបានទទួលដំណឹងច្រើនជាងមុនពីអ្វីដែល កំពុងកើតឡើងនៅក្នុងភូមិ ។ ឧទាហរណ៏ មេឃុំរុងរឿងបានទទួលស្គាល់ថា បន្ទាប់ពីមានការពិភាក្សាជាច្រើនលើកច្រើនសារ និងការបន្តគាំទ្រសំរបសំរួលពីអង្គការក្រៅរដ្ឋាភិបាលថ្នាក់មូលដ្ឋានរួចមក ទំនាក់ទំនងដែលមានលក្ខណៈស្ថាបនា និងដែលមានប្រយោជន៏ដល់គ្នាទៅវិញទៅមក បានកើតមានជាមួយនឹងសមាគមបែបប្រពៃណី តាមរយៈគណៈកម្មការសំរបសំរួលវត្តនៅថ្នាក់មូលដ្ឋាន (PaCoCo) និងបណ្តាញភូមិ ។ តំណាងរបស់បណ្តាញ និងប្រធានសមាគមបានអះអាងថាកាល

ពីមុន គ្មាននរណាម្នាក់នៅក្នុងភូមិត្រូវបានគេអញ្ជើញអោយចូលរួមនៅក្នុងការដេញថ្លៃធ្វើសកម្មភាពអភិវឌ្ឍន៍ឃុំឡើយ ប៉ុន្តែចាប់តាំងពីឆ្នាំ ២០០៥មក ចាស់ទុំក្នុងភូមិ និងប្រធានសមាគមតែងត្រូវបានអញ្ជើញអោយចូលរួម បើទោះបីជាគំរោងនោះអាជ្ញាធរខេត្តជាអ្នកអនុវត្តក៏ដោយ ។ តាមរយៈបណ្តាញអ្នកភូមិ ប្រជាពលរដ្ឋក្នុងភូមិ និងប្រធានសមាគមមានទំនុកចិត្តច្រើនជាងមុនក្នុងការលើកឡើងពីការមិនឯកភាពណាមួយ និងការស្នើសុំអោយមានអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋានក្នុងករណីចាំបាច់ ។ ឧទាហរណ៍ នៅក្នុងឃុំដងកាំបិត អ្នកភូមិដែលមិនពេញចិត្តជាមួយនឹងគុណភាពនៃការសាងសង់ផ្លូវ បានប្រាប់ពីការព្រួយបារម្ភរបស់ពួកគេអោយក្រុមប្រឹក្សាឃុំបានដឹង ។ ជាលទ្ធផល អាជ្ញាធរមូលដ្ឋានអាចធ្វើការចរចារជាមួយអ្នកម៉ៅការ ដើម្បីអោយមានការកែលំអ ។

*ប្រភព: CAS/WB, ២០០៧b*

### ២.គ.៤. អនុសាសន៍ និងសកម្មភាពដែលគួរអនុវត្ត

១០៦. ការរួបរួមជាសកមាគមក្នុងចំណោមប្រជាពលរដ្ឋគឺជាមូលដ្ឋានគ្រឹះនៃសង្គមស៊ីវិល និងជាជំហានដ៏សំខាន់ឆ្ពោះទៅរកការទទួលខុសត្រូវសង្គម ។ ការស្រាវជ្រាវនេះបានរកឃើញថាការដែលប្រជាពលរដ្ឋពុំសូវមានការរួបរួមគ្នានោះ ជាភាពទន់ខ្សោយដ៏ចំបងមួយនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ហើយបានរកឃើញទៀតថាការមិនសូវទុកចិត្តគ្នា និងកង្វះមូលធនសង្គម គឺជាកត្តារួមចំណែកដ៏ចំបង ។ ម្ចាស់ជំនួយទើបតែបានចាប់ផ្តើមផ្តល់ជំនួយដល់សមាគមមូលដ្ឋានក្នុងពេលថ្មីៗនេះប៉ុណ្ណោះ ហើយការផ្តល់នេះទៀតសោតភាគច្រើនគឺធ្វើឡើង តាមរយៈអង្គការក្រៅរដ្ឋាភិបាលដែលជាអន្តរការីប៉ុណ្ណោះ ។ ក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលទាំងនោះ មានតែអង្គការមួយចំនួនតូចប៉ុណ្ណោះដែលមានការផ្សារភ្ជាប់ ឬមានវត្តមាន និងជំនាញនៅមូលដ្ឋាន ។ ផ្តើមចេញពីទស្សនៈនៃការទទួលខុសត្រូវសង្គម អង្គការសង្គមស៊ីវិលមានតួនាទីដ៏សំខាន់មិនត្រឹមតែក្នុងការធ្វើអោយរដ្ឋាភិបាលមានការទទួលខុសត្រូវប៉ុណ្ណោះទេ ប៉ុន្តែអង្គការទាំងនោះក៏ត្រូវធ្វើជាគំរូគេ ថាអភិបាលកិច្ចដែលប្រកបដោយតម្លាភាព មានការឆ្លើយតប មានការចូលរួម និងមានការទទួលខុសត្រូវនោះមានរូបភាពយ៉ាងណា ។ ជាអកុសល ការស្រាវជ្រាវនេះបានរកឃើញថា អង្គការសង្គមស៊ីវិលនៅគ្រប់កំរិតថ្នាក់ច្រើនមានបញ្ហាផ្នែកអភិបាលកិច្ចដូចដែលមានប្រទះឃើញនៅក្នុងរង្វង់រដ្ឋាភិបាលដែរ ហើយការបង្កើតសម្ព័ន្ធភាព និងការធ្វើការជាមួយគ្នា ក៏ពុំមានប្រសិទ្ធិភាពដែរ (ជាពិសេសនៅថ្នាក់ក្រោមជាតិ) ។

១០៧. អនុសាសន៍ចំនួនបីត្រូវបានស្នើឡើងដើម្បីដោះស្រាយបញ្ហាចំបងៗទាំងនេះ ។ អនុសាសន៍ទី១ (ជាពិសេសសំរាប់អង្គការសង្គមស៊ីវិល អង្គការដែលគាំទ្រអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងស្ថាប័នស្រាវជ្រាវ) គឺ **(១) លើកកំពស់ និងគាំទ្រការកកើតឡើងនៃសមាគមប្រជាពលរដ្ឋនៅមូលដ្ឋាន** (ជាពិសេសសមាគមដែលមានសមាជិកជាស្ត្រី យុវជន និងប្រជាជនក្រីក្រ) ដែលមានបែបបទធ្វើការសមស្របទៅតាមស្ថានភាពក្នុងមូលដ្ឋាន (ដើម្បីផលប្រយោជន៍) និងជំរុញអោយមាននូវដែន និងលក្ខខ័ណ្ឌចាំបាច់នានាដែលបង្កលក្ខណៈងាយស្រួលដល់ការរួបរួមជាសកមាគមនៅថ្នាក់មូលដ្ឋាន ។ អនុសាសន៍ទី២ (ជាពិសេសសំរាប់អង្គការសង្គមស៊ីវិល បណ្តាញអង្គការសង្គមស៊ីវិល អង្គការដែលផ្តល់ការគាំទ្រ និងដៃគូអភិវឌ្ឍន៍) គឺ **(២) ជួយ និងគាំទ្រអង្គការសង្គមស៊ីវិល (គ្រប់កំរិតថ្នាក់) អោយក្លាយជាគំរូនៃអភិបាលកិច្ចដែលប្រកបដោយតម្លាភាព មានការឆ្លើយតប និងទទួលខុសត្រូវ** ។ អនុសាសន៍ទី៣គឺសំរាប់អង្គការសង្គមស៊ីវិល (ដោយមានជំនួយពីបណ្តាញអង្គការសង្គមស៊ីវិល អង្គការដែលផ្តល់ការគាំទ្រ និងដៃគូ

អភិវឌ្ឍន៍) ដើម្បី (៣) **បង្កើតយន្តការនិងដំណើរការដែលមានប្រសិទ្ធិភាពសំរាប់ការចែករំលែកព័ត៌មាន ការបង្កើតបណ្តាញ និងការកសាងសមត្ថភាព ។**

១០៨. *អនុសាសន៍គ.១- ឧបត្ថម្ភគាំទ្រដល់ការកើតឡើងនៃសមាគមប្រជាពលរដ្ឋនៅមូលដ្ឋាន ។ (សកម្មភាពតំរូវទៅខាងអង្គការសង្គមស៊ីវិលថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ព្រមទាំងអ្នកឯកទេស និងអ្នកស្រាវជ្រាវដែលពាក់ព័ន្ធ ដោយមានជំនួយពីដៃគូអភិវឌ្ឍន៍) ។*

ក) រៀបចំអោយអ្នកដឹកនាំ និងតំណាងប្រជាពលរដ្ឋនៅមូលដ្ឋានបានជួបគ្នាជាមួយប្រតិបត្តិករ និងអ្នកឯកទេសដែលពាក់ព័ន្ធ ដើម្បីបានឆ្លុះបញ្ចាំងទៅលើមូលហេតុនៃកង្វះសមាគមមូលដ្ឋាននៅកម្ពុជា រួចហើយបំផុសគំនិតរកវិធីជំរុញអោយមានការរួបរួមជាសមាគមនៅក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា ។

ខ) ធ្វើការសិក្សាទៅលើគំនិតផ្តួចផ្តើមដែលមានស្រាប់ (ដូចជាសមាគមកសិកររបស់សេដាក សហគមន៍អាដហុក សហជីពកម្មករ និងបណ្តាញអ្នកភូមិ) ដើម្បីស្វែងយល់ ថាតើវិធីសាស្រ្តណាខ្លះដែលមានជោគជ័យ ឬមាននិរន្តរភាពបំផុត ។ (ការចង្អុលបង្ហាញនៅដំណាក់កាលដំបូងថា វិធីសាស្រ្តដែល "ផ្តោតលើផលប្រយោជន៍" ជាជាង "ផ្តោតទៅលើទស្សនាទាន" មានជោគជ័យច្រើន ។ ការផ្សារភ្ជាប់ការផ្តល់អំណាចផ្នែកសេដ្ឋកិច្ចនិងនយោបាយទៅនឹងតំរូវការអោយមានការចូលរួម និងការសហការគ្នាយូរអង្វែង ក៏មានអត្ថប្រយោជន៍ និងចាំបាច់ផងដែរ) ។

គ) ផ្អែកលើបទពិសោធន៍ទាំងនេះ គប្បីរិះរកយន្តការសំរាប់ផ្តល់ជំនួយ និងធនធានបន្ថែមទៀតទៅអោយអង្គការសហគមន៍ និងអង្គការសង្គមស៊ីវិលដែលធ្វើការផ្ទាល់ផ្នែកការពង្រឹងអំណាចនៅថ្នាក់មូលដ្ឋាន (ឬអ្នកមានសក្តានុពលក្នុងការអនុវត្តន៍សកម្មភាពទាំងនេះ) និងទៅអោយគំនិតផ្តួចផ្តើមទាំងឡាយណាដែលមានបំណងបង្កើតនូវឱកាស និងលក្ខខ័ណ្ឌចាំបាច់សំរាប់ការរួបរួមជាសមាគមនៅថ្នាក់មូលដ្ឋាន ។ សំរាប់រាជរដ្ឋាភិបាលនិងម្ចាស់ជំនួយ កិច្ចការនេះរួមមានការលើកទឹកចិត្ត និងការបង្កលក្ខណៈងាយស្រួលអោយអង្គការសង្គមស៊ីវិល និងអង្គការសហគមន៍បានចូលរួមក្នុងការរៀបចំគំរោង និងការបង្កើតយុទ្ធសាស្រ្តអភិវឌ្ឍន៍ព្រោះការធ្វើបែបនេះនឹងអាចជួយពង្រឹងដល់ភាពជាម្ចាស់ និងសេចក្តីក្លាហានរបស់សមាគមទាំងនោះ។ ដើម្បីអោយមានការចូលរួមបានច្រើនពីមូលដ្ឋាន វាជាប្រការល្អបំផុតដែលម្ចាស់ជំនួយត្រូវធ្វើអោយនីតិវិធីស្នើសុំមូលនិធិរបស់ខ្លួនមានលក្ខណៈសាមញ្ញ (ដូចជាគំរោងស្នើសុំ ពាក្យសុំ និងនីតិវិធីធ្វើរបាយការណ៍)។ ជាទូទៅអង្គការសហគមន៍ច្រើនតែជួបការលំបាកផ្នែកភាសា ហើយសមត្ថភាពផ្នែកចាត់ចែង និងគ្រប់គ្រងក៏ពុំសូវមានភាពរឹងមាំដែរ ។ អង្គការក្រៅរដ្ឋាភិបាលអាជីព មានតួនាទីជួយសំរបសំរួលអោយអង្គការសហគមន៍ទាំងនោះ អាចស្នើសុំមូលនិធិពីខាងក្រៅបាន ។

១០៩. *អនុសាសន៍ គ.២ - គាំទ្រអង្គការសង្គមស៊ីវិលអោយក្លាយជាគំរូនៃអភិបាលកិច្ចដែលប្រកបដោយតម្លាភាព មានការឆ្លើយតប និងទទួលខុសត្រូវ ។*

ក) គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនាពេលបច្ចុប្បន្នរបស់អង្គការសង្គមស៊ីវិលកម្ពុជា (ដូចជាកិច្ចខិតខំដែលដឹកនាំដោយ អង្គការ CCC) ដើម្បីបង្កើតក្រមសីលធម៌រួម និងប្រព័ន្ធស្វ័យនិយតកម្ម ។

ខ) គាំទ្រគំនិតផ្តួចផ្តើមអភិវឌ្ឍន៍អង្គការ និងការកសាងសមត្ថភាពណាដែលមានបំណងកែលំអអភិបាលកិច្ចផ្ទៃក្នុង និងការគ្រប់គ្រងរបស់អង្គការសង្គមស៊ីវិល (រួមទាំងយន្តការធ្វើអោយមានតម្លាភាពជាសាធារណៈ និងការទទួលខុសត្រូវចំពោះ "ថ្នាក់ក្រោម") ។ ក្នុងនេះរួមទាំងការជួយ និងលើកទឹកចិត្តអង្គការសង្គមស៊ីវិល (រាប់ទាំងអង្គការក្រៅរដ្ឋាភិបាលផង) អោយពង្រឹងការដឹកនាំរបស់ខ្លួន ប្រកាន់យកនូវអភិបាលកិច្ចដែលមានលក្ខណៈប្រជាធិបតេយ្យ និងមានការចូលរួម ដោយចាត់ទុកតួនាទីរបស់អង្គការសង្គមស៊ីវិលថាជាការបំរើប្រជាពលរដ្ឋតាមរយៈការធ្វើជាតំណាងដោយស្មោះស្ម័គ្រអោយក្តីបារម្ភ និងតំរូវការអាទិភាពរបស់ពួកគេ ។ កិច្ចការនេះអាចរួមបញ្ចូលនូវការគិតឡើងវិញទៅលើតួនាទី និងអាណត្តិរបស់គណកម្មការនាយក និងរបស់នាយកប្រតិបត្តិរបស់អង្គការ ។

គ) ដើម្បីទ្រទ្រង់ដល់ការកែលំអអភិបាលកិច្ចផ្ទៃក្នុង និងភាពជាម្ចាស់ អង្គការសង្គមស៊ីវិល (ជាពិសេសអង្គការក្រៅរដ្ឋាភិបាលអាជីព) គប្បីខិតខំអោយអស់ពីសមត្ថភាពស្វែងរកឱកាសផ្តល់ហិរញ្ញប្បទាននៅក្នុងស្រុក (ដូចជាការរៃអង្គាសពីជនកម្ពុជាដែលមានជីវភាពធូរធារ ឬការយកកំរៃពីសេវាដែលបានផ្តល់) ដើម្បីកាត់បន្ថយការពឹងផ្អែកលើការផ្តល់មូលនិធិពីបរទេស ។

ឃ) ម្ចាស់ជំនួយត្រូវ "ធ្វើនូវអ្វីដែលខ្លួនប្រាប់អោយគេធ្វើ" និង "ធ្វើខ្លួនជាគំរូ" ដោយលើកកំពស់នូវការទទួលខុសត្រូវរបស់ខ្លួន (ដូចជា ធានាថាគំរោង និងកម្មវិធីដែលខ្លួនផ្តល់មូលនិធិ មានបញ្ចូលនូវយន្តការនៃការឆ្លើយតបរបស់អតិថិជន តម្លាភាពការរាយការណ៍ជាសាធារណៈ និងការទទួលខុសត្រូវចំពោះអតិថិជន ឬប្រជាពលរដ្ឋ ដែលនៅ "ថ្នាក់ក្រោម" ប្រកបដោយប្រសិទ្ធិភាព) និងដោយលើកទឹកចិត្ត ឬតំរូវអោយដៃគូ (នៅក្នុងជួររដ្ឋាភិបាល និងសង្គមស៊ីវិល) មានការឆ្លើយតប និងការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ ឬអតិថិជនអោយបានច្រើនជាងការឆ្លើយតប និងការទទួលខុសត្រូវចំពោះ "ថ្នាក់លើ" ដែលជាម្ចាស់ជំនួយ[៤០] ។ ម្ចាស់ជំនួយក៏គួរមានការបើកចំហ និងមានការឆ្លើយតបចំពោះកិច្ចខិតខំរបស់អង្គការសង្គមស៊ីវិលក្នុងការត្រួតពិនិត្យ និងវាយតំលៃសកម្មភាព ឬការអនុវត្តការងាររបស់ខ្លួនដែរ ។

១១០. *អនុសាសន៍ គ.៣ - គាំទ្រ និងសំរបសំរួលដល់ការចែករំលែកព័ត៌មាន ការបង្កើតបណ្តាញ និងការកសាងសម្ព័ន្ធភាពក្នុងចំណោមអង្គការសង្គមស៊ីវិលអោយមានប្រសិទ្ធិភាព ។*

ក) គាំទ្រដំណើរការដែលអនុញ្ញាតិអោយអង្គការសង្គមស៊ីវិល (ជាពិសេសអង្គការនៅថ្នាក់ក្រោមជាតិ) ធ្វើការវិភាគ និងឆ្លុះបញ្ចាំងរួមគ្នាទៅលើចំណុចខ្លាំង និងចំណុចខ្សោយនៃការចែករំលែកព័តិមាន ការចងក្រងបណ្តាញ និងការកសាងសម្ព័ន្ធភាពនាពេលបច្ចុប្បន្ន ព្រមទាំងលើវិធីសាស្រ្តកែលំអសំរាប់ពេលខាងមុខ ។ ការផ្សារភ្ជាប់អង្គការសហគមន៍ និងអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិជាមួយនឹងអង្គការផ្អែកតស៊ូមតិនៅថ្នាក់ជាតិ គឺជាប្រការចាំបាច់ណាស់ ។ ការធ្វើបែបនេះបាននឹងធ្វើអោយអង្គការដែលនៅថ្នាក់ជាតិមានភាពកក់ក្តៅអំពីប្រជាពលរដ្ឋដែលខ្លួនកំពុងតស៊ូមតិជំនួស ។

ខ) គាំទ្រដល់ឱកាសសំរាប់អ្នកដឹកនាំ និងបុគ្គលិកអង្គការសង្គមស៊ីវិល (ជាពិសេសសំរាប់អ្នកនៅថ្នាក់ក្រោមជាតិ) បានរៀនសូត្រពីបទពិសោធន៍ល្អៗនៅក្នុងផ្នែកនេះ និងដកពិសោធន៍ជាមួយវិធីសាស្រ្ត និងបច្ចេកទេសថ្មីៗ លើផ្នែកចែករំលែកព័តិមាន ការចងក្រងបណ្តាញ និងការកសាងសម្ព័ន្ធភាពនេះ ។

---

[៤០] ឧទាហរណ៍ បច្ចុប្បន្ននេះមានម្ចាស់ជំនួយជាច្រើន (រួមមាន ធនាគារពិភពលោក ADB, UNDP, DfID, DANIDA, TAF) កំពុងបង្វែរមូលនិធិជំនួយ មកជាគាំទ្រដល់សកម្មភាពនៅថ្នាក់ឃុំ ។ កម្មវិធីទាំងនេះ គឺជាឱកាសដ៏ល្អដើម្បីកសាងភាពជាម្ចាស់កម្មសិទ្ធ និងការឃ្លាំមើលដ៏សកម្មពីសំណាក់ប្រជាពលរដ្ឋ ដោយការធានាអោយមាននូវតម្លាភាព និងការទទួលខុសត្រូវចំពោះ "ថ្នាក់ក្រោម" ។

គ) ផ្តល់ធនធាន និងការគាំទ្រទាំងចំពោះបណ្តាញថ្មី និងបណ្តាញចាស់ ព្រមទាំងសម្ព័ន្ធភាពដែលកំពុងធ្វើសកម្មភាព (ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ក៏ដូចជាបណ្តាញថ្មីផ្នែកការទទួលខុសត្រូវសង្គម ។ ជាពិសេសពង្រឹង និងអភិវឌ្ឍន៍បណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្ត ការផ្សារភ្ជាប់ទំនាក់ទំនងក្នុងចំណោមសមាគម និងក្រុមនានានៅថ្នាក់មូលដ្ឋាន និងរវាងក្រុមសហគមន៍ជាមួយនឹងអង្គការសង្គមស៊ីវិលដែលធ្វើការនៅថ្នាក់ស្រុក ខេត្ត និងថ្នាក់ជាតិ ។ អ្វីដែលគួរធ្វើគឺការប្រើប្រាស់ភស្តុតាងដែលរកឃើញនៅថ្នាក់មូលដ្ឋានសំរាប់ការចរចារ និងការតស៊ូមតិនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ (ឧទាហរណ៍ តាមរយៈដំណើរការវាយតំលៃតាមបែបចូលរួម ការស្ទាបស្ទង់មតិសាធារណៈ ការត្រួតពិនិត្យ និងវាយតំលៃតាមបែបចូលរួមទៅលើសេវាសាធារណៈ) ។

## ២.ឃ. ការចូលរួមនិងការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា

១១១. ផ្នែកចុងក្រោយដ៏សំខាន់បំផុតនៃការទទួលខុសត្រូវសង្គម គឺអំពីសមត្ថភាពរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងការចូលរួមនៅក្នុងការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនាជាមួយនឹងរដ្ឋាភិបាល និងការចូលរួមយ៉ាងពេញលក្ខណៈនៅក្នុងការពិចារណា និងការសំរេចចិត្តអំពីកិច្ចការសាធារណៈ ។ គោលបំណងចុងក្រោយនៃការទទួលខុសត្រូវសង្គម គឺមិនត្រឹមតែធ្វើអោយប្រជាពលរដ្ឋមានព័ត៌មាន និងមានការសំដែងមតិប៉ុណ្ណោះទេ ប៉ុន្តែក៏ជំរុញអោយមន្ត្រីសាធារណៈមានការឆ្លើយតប និងធ្វើសកម្មភាពដើម្បីលើកកំពស់ប្រសិទ្ធិភាព និងការទទួលខុសត្រូវរបស់រដ្ឋាភិបាលផងដែរ ។ ដើម្បីមានឥទ្ធិពលទៅលើការសំរេចចិត្ត និងសកម្មភាពរបស់រដ្ឋាភិបាល អង្គការសង្គមស៊ីវិលច្រើនតែពឹងផ្អែកលើយុទ្ធសាស្ត្រិះគន់ ការបញ្ចុះបញ្ចូល និងដាក់សំពាធជាឯកតោភាគី ដូចជាការតស៊ូមតិ ការបញ្ចុះបញ្ចូល ការធ្វើបាតុកម្មជាសាធារណៈ ការតវ៉ា ឬការប្រកាសបដិសេធជាដើម ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ឱកាសធ្វើអោយមានការផ្លាស់ប្តូរពិតប្រាកដអាចមានច្រើនជាងនេះប្រសិនបើប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលអាចប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយសមភាគីរដ្ឋាភិបាល និងចូលរួមនៅក្នុងកិច្ចពិភាក្សាយ៉ាងពិតប្រាកដនោះ ។ វាមិនខុសអ្វីពីភាពជាដៃគូរវាងរដ្ឋាភិបាលនិងវិស័យឯកជន ដែលធ្វើអោយរដ្ឋាភិបាលមានថវិកាសំរាប់គំរោងផ្នែកសេដ្ឋកិច្ចរបស់ខ្លួន ដែលតាមធម្មតារដ្ឋមិនមានហិរញ្ញប្បទានគ្រប់គ្រាន់នោះទេ ។ កិច្ចសហការរវាងរដ្ឋាភិបាល និងសង្គមស៊ីវិលក៏ដូចគ្នាដែរ គឺអាចធានាថាគោលនយោបាយផ្នែកសេដ្ឋកិច្ច និងសង្គមអាចត្រូវរៀបចំឡើងបានល្អ និងទទួលយកបានពីប្រជាពលរដ្ឋ ហើយការអនុវត្តន៍គោលនយោបាយនោះអាចមានប្រសិទ្ធិភាពជាងការពឹងផ្អែកទាំងស្រុងទៅលើការិយាល័យធិបតេយ្យ និងប្រព័ន្ធទំនាក់ទំនងផ្លូវការនោះ ។ ឱកាស និងយន្តការសំរាប់កិច្ចពិភាក្សារវាងប្រជាពលរដ្ឋនិងរដ្ឋាភិបាល និងការចូលរួមរបស់ប្រជាពលរដ្ឋកំពុងកើតមានជាបណ្តើរៗហើយនៅកម្ពុជា ប៉ុន្តែវិសាលភាព និងប្រសិទ្ធិភាពនៅមានកំរិតតិចតួចនៅឡើយ ។ បទពិសោធន៍អន្តរជាតិ (ឧទាហរណ៍ មូលនិធិកិច្ចការសាធារណៈ ២០០៧; McNeil និង Mumvuma, ២០០៦ ; Malena et. al., ២០០៧) បង្ហាញថាដំណើរការនៃកិច្ចពិភាក្សា និងការចូលរួមមានប្រសិទ្ធិភាពបំផុតនៅពេលដែលដំណើរការទាំងនេះ ១) **ត្រូវបានគាំទ្រដោយបរិយាកាសគោលនយោបាយអំណោយផលមួយ ដែលផ្អែកលើការយល់ដឹងរួមរបស់ប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិលអំពីសិទ្ធិ (២) មានលក្ខណៈស្ថាបនា ប្រាកដប្រជា ផ្អែកលើភស្តុតាង និងយកការដោះស្រាយជាចំបង ៣) ប្រើប្រាស់ និងពង្រឹងបន្ថែមនូវប្រព័ន្ធ និងយន្តការទទួលខុសត្រូវដែលមានស្រាប់ និង ៤) មានការប្រាស្រ័យទាក់ទង និងកិច្ចពិភាក្សាដោយផ្ទាល់ជាប្រចាំ** ។

## ២.ឃ.១. ការបង្កើតបរិយាកាសអំណោយផលនិងស្ថាប័ននីយកម្មនៃសិទ្ធិរបស់ប្រជាពលរដ្ឋ-អង្គការសង្គមស៊ីវិល

១១២. ការស្រាវជ្រាវបែបគុណភាពរកឃើញថា មានការយល់ដឹងតិចតួចអំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ ទាំងក្នុងចំណោមប្រជាពលរដ្ឋ និងតួអង្គនានារបស់រដ្ឋាភិបាល ។ ទាក់ទងនឹងការទទួលខុសត្រូវសង្គម គោលការណ៍ជាមូលដ្ឋានអំពីសិទ្ធិ (និងករណីយកិច្ច) របស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានអំពីការសំរេចចិត្ត និងសកម្មភាពនានារបស់រដ្ឋាភិបាល ការផ្តល់ព័ត៌មានត្រលប់អំពីការងាររបស់រដ្ឋាភិបាល ការទាមទារសិទ្ធិស្របច្បាប់ និងការទាមទារអោយមានការទទួលខុសត្រូវនោះ ហាក់បីដូចជាមិនត្រូវបានយល់ដឹងបានទូលំទូលាយទេ ហើយក៏មិនឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយ បទបញ្ញត្តិ ឬវិធាននានានៅឡើយដែរ ។ ដោយសារតែកង្វះការយកចិត្តទុកដាក់ទៅលើសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋបែបនេះ និងដោយសារតែទំនាក់ទំនងរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋមានលក្ខណៈបែបបិតុនិយម និងការទំនាក់ទំនងបែបចៅហ្វាយនាយ-កូនចៅនោះប្រជាពលរដ្ឋសាមញ្ញមានការរំពឹងតិចតួចណាស់ ថាអាជ្ញាធរនឹងយកចិត្តទុកដាក់លើសំណើរបស់ខ្លួននោះ កុំថាឡើយដល់ទៅដោះស្រាយ "ការទាមទារ" ជាក់លាក់ណាមួយ ឬមានចេតនាចង់មានឥទ្ធិពលទៅលើការសំរេចចិត្តនិងស្វែងរកការទទួលខុសត្រូវនោះ[៤១] ។ ប្រសិនបើបញ្ហាមានភាពធ្ងន់ធ្ងរ មិនអាចមានជំរើសណាក្រៅពីទៅទាក់ទងជាមួយអាជ្ញាធរនោះ ប្រជាពលរដ្ឋប្រកាន់យកជំហរសំរបខ្លួនតាម និងធ្វើការ "អង្វរករ" ហើយប្រសិនបើអាចគឺតាមរយៈអន្តរការី ជាជាងធ្វើការ "ទាមទារ" ដោយផ្អែកលើភ័ស្តុតាង និងសិទ្ធិជាលក្ខណៈស្ថាប័ន ។

១១៣. ការស្រាវជ្រាវក៏បានរកឃើញផងដែរអំពី**កង្វះការឯកភាពគ្នា អំពីថាតើអ្វីទៅជាតួនាទីស្របច្បាប់ និង "សមស្រប" របស់សង្គមស៊ីវិល** ។ បើទោះបីតួអង្គនានានៅក្នុងជួររដ្ឋាភិបាលហាក់ដូចជាទទួលស្គាល់ និងកោតសរសើរដល់តួនាទីផ្នែកកិច្ចការសង្គម ក្នុងការ "ផ្តល់សេវា" ផ្នែកសុខុមាលភាពរបស់អង្គការសង្គមស៊ីវិលក៏ដោយ ក៏អ្នកទាំងនោះហាក់មិនសូវទទួលយកភាពស្របច្បាប់នៃសកម្មភាពរបស់អង្គការសង្គមស៊ីវិលដែលធ្វើការងារផ្នែកសិទ្ធិនិងការតស៊ូមតិនោះដែរ ។ ជាញឹកញាប់ ការងារតស៊ូមតិ (ជាធម្មតាគឺដើម្បីដោះស្រាយកង្វះខាត ឬសកម្មភាពមិនសមស្របរបស់រដ្ឋាភិបាល) ត្រូវបានរដ្ឋាភិបាលចាត់ទុកថាជាការវាយប្រហារដោយផ្ទាល់លើអាជ្ញាធររបស់ពួកគេហើយចាត់ទុកថាជាការប្រឆាំង "ដោយមិនស្របច្បាប់" ចំពោះរដ្ឋាភិបាល ។ បើតាម Un (២00៤: ២៥៨) ការធ្វើបែបនេះនាំអោយមានស្ថានភាពមួយដែល "រដ្ឋាភិបាលមិនទទួលស្គាល់ភាពស្របច្បាប់របស់អង្គការក្រៅរដ្ឋា-ភិបាល ហើយអង្គការក្រៅរដ្ឋាភិបាលចាត់ទុកថារដ្ឋាភិបាលក៏មិនមានភាពស្របច្បាប់ពេញលេញ ដែរ...យើង [អង្គការក្រៅរដ្ឋាភិបាល] និងរដ្ឋាភិបាលហាក់បីដូចជាមើលងាយគ្នាទៅវិញទៅមក" ។ សំរាប់មនុស្សជាច្រើននៅក្នុងជួររដ្ឋាភិបាល ផ្នត់គំនិតនេះធ្វើអោយមានការគូសបន្ទាត់យ៉ាងច្បាស់ខណ្ឌចែករវាងអង្គការក្រៅរដ្ឋាភិបាលដែល "ល្អ" (ដែលខិតខំជួយនិងសហការជាមួយរដ្ឋា-ភិបាល) និងអង្គការក្រៅរដ្ឋាភិបាលដែល "អាក្រក់" (ដែលបានតែរិះគន់ ឬតតាំងជាមួយរដ្ឋាភិបាល) ។ យោងទៅតាមការសំភាសន៍ជាមួយប្រតិបត្តិករនៅក្នុងអង្គការសង្គមស៊ីវិល ការខណ្ឌចែកបែបនេះក៏កើតមាននៅក្នុងជួរសង្គមស៊ីវិលផងដែរ ដោយ

---

[៤១] ឧទាហរណ៍ ប្រធានក្រុមស្ត្រីនៃសមាគមកសិករ (ដែលគាំទ្រដោយអង្គការសេដាក) នៅក្នុងខេត្តកំពង់ចាម *(ស្រុកជើងព្រៃ)* បានលើកឡើងថា "ប្រសិនបើមានបញ្ហានៅក្នុងភូមិ ក្រុមរបស់ខ្ញុំ ឬសមាគមកសិករនឹងព្យាយាមដោះស្រាយបញ្ហាដោយខ្លួនឯង ។ ជាធម្មតា យើងមិនគិតថានឹងយកបញ្ហាទាំងនេះទៅអោយអាជ្ញាធរជួយដោះស្រាយយើងនោះទេ" ។

បុគ្គល ឬក្រុមខ្លះគិតថាខ្លួនត្រូវបង្ខំចិត្តឈប់ពាក់ព័ន្ធជាមួយអង្គការដែល "បង្កបញ្ហា" និងអង្គការ ក្រៅរដ្ឋាភិបាល "ខាងតស៊ូមតិ" មួយចំនួនដែលត្រូវដៃគូខ្លួនឯងរិះគន់ ឬលែងទទួលស្គាល់ ប្រសិនបើអង្គការទាំងនេះត្រូវគេដឹងថា ផ្តល់ការសំរបសំរួល ឬសហការខ្លាំងហួសហេតុពេក[៤២] ។

## ២.ឃ.២. ពី "ការតស៊ូមតិ" ទៅជាការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា

១១៤. ដោយសារតែមានកត្តាបរិបទដូចបានរៀបរាប់ខាងលើ ការងារ "តស៊ូមតិ" ជាច្រើននៅកម្ពុជាមានលក្ខណៈប្រឈមមុខច្រើន ដោយសារកិច្ចខិតខំប្រឹងប្រែងទាំងនោះច្រើនតែផ្អែកលើការរិះគន់រដ្ឋាភិបាលជាសាធារណៈ និងការ "បង្ខំ" អោយមានការឆ្លើយតប ។ បើតាម Un (២០០៤: ២៤៣) **ការតស៊ូមតិត្រូវបានគេយល់ជាទូទៅថាជាការរិះគន់ និងវាយប្រហាររដ្ឋាភិបាល** (ជាជាងការផ្តល់ព័ត៌មានប្រកបដោយលក្ខណៈស្ថាបនា ឬអំពាវនាវអោយមានសកម្មភាពរួមដើម្បីដោះស្រាយបញ្ហាជាប្រយោជន៍សាធារណៈណាមួយ) ។ សកម្មភាពតស៊ូមតិភាគច្រើននៅកម្ពុជាផ្តោតលើបញ្ហាដែលមានលក្ខណៈនយោបាយខ្ពស់ និងបញ្ហាដែលប៉ះពាល់អារម្មណ៍ខ្លាំង ដូចជាការរំលោភសិទ្ធិមនុស្ស និងការបណ្តេញប្រជាពលរដ្ឋពីដីធ្លីជាដើម ។ ដោយសារតែសកម្មភាពទាំងនេះមានហានិភ័យច្រើន កិច្ចខិតខំទាំងនេះភាគច្រើនត្រូវបានធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាល ដែលមានមូលដ្ឋាននៅក្រុងភ្នំពេញដែលជាអ្នកទទួលបាន "ការការពារ" ពីអន្តរជាតិ ។ ប្រជាពលរដ្ឋសាមញ្ញ និងអង្គការសង្គមស៊ីវិលថ្នាក់មូលដ្ឋាន និងថ្នាក់ក្រោមជាតិ មិនចង់ប្រើប្រាស់វិធីសាស្ត្រប្រឈមមុខដាក់គ្នាបែបនេះឡើយ ហើយជាទូទៅពួកគេនឹងចូលរួមតែនៅពេលដែលមានការគំរាមកំហែងធ្ងន់ធ្ងរ ហើយដែលពួកគេមិនមានជំរើសអ្វីផ្សេងទៀតប៉ុណ្ណោះ ។ កិច្ចខិតខំប្រឹងប្រែងតស៊ូមតិនាពេលបច្ចុប្បន្ននេះច្រើនតែពឹងផ្អែកយ៉ាងខ្លាំងលើឥទ្ធិពលរបស់អ្នកផ្តល់ជំនួយពីខាងក្រៅ (ទាំងការបង្កើតយុទ្ធសាស្ត្រ និងការដាក់សំពាធលើរដ្ឋាភិបាល) ជាជាងលើវិធីសាស្ត្រតស៊ូមតិ "ដែលយកប្រជាពលរដ្ឋជាចំបង" ។ វិធីសាស្ត្រនេះលើកស្ទួយការសំដែងមតិរបស់ប្រជាពលរដ្ឋ និងបង្កើនសំពាធពីសាធារណៈ តាមរយៈយុទ្ធសាស្ត្ររួមនៃការអប់រំ ការគៀងគរ និងផ្តល់អំណាចដល់ប្រជាពលរដ្ឋ ។

១១៥. នៅក្នុងករណីខ្លះ វិធីសាស្ត្រតស៊ូមតិបែបនេះទទួលបានជោគជ័យក្នុងការដោះស្រាយការរំលោភបំពានសិទ្ធិ ដូចជាសិទ្ធិចំពោះបញ្ហាដីធ្លីជាដើម ។ តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងស្ថានភាពទូទៅ (ដូចដែលបង្ហាញនៅក្នុងរូបភាពទី២១) លទ្ធផលនៃការស្ទាបស្ទង់មតិសាធារណៈ និងលទ្ធផលនៃការស្រាវជ្រាវបែបគុណភាពបង្ហាញថា**តួអង្គជាច្រើននៅក្នុងសង្គមស៊ីវិលដែលពាក់ព័ន្ធក្នុងការងារតស៊ូមតិ យល់ថាលទ្ធផលតស៊ូមតិរបស់ពួកគេ "នៅមានកំរិត" ជាពិសេសបើនិយាយពីការជះឥទ្ធិពលទៅលើសកម្មភាពជាក់លាក់មួយចំនួន ដូចជាការអនុវត្តន៍គោលនយោបាយ ការរៀបចំថវិកា និងការចំណាយ ហើយគិតថាពួកគេមិនទទួលបានជោគជ័យជាដុំកំភួន ឬ ធ្វើអោយមានការកែទំរង់ជាលក្ខណៈរចនាសម្ព័ន្ធទេ** ។ ដូចដែលបានរៀបរាប់នៅក្នុងប្រអប់ទី ១១ ហើយដោយសារវិធីសាស្ត្រតស៊ូមតិនោះមានលក្ខណៈប្រឈមមុខ និងផ្តោតតែលើស្ថានភាពមានវិបត្តិ ទើបកិច្ចខិតខំប្រឹងប្រែងស៊ូមតិនៅ

---

[៤២] ជាពិសេស បណ្តាញអង្គការក្រៅរដ្ឋាភិបាល ត្រូវតែដោះស្រាយបញ្ហាប្រឈមនេះ ។ ឧទាហរណ៍ ការមិនយល់ស្របទៅនឹងការ "គាំទ្ររដ្ឋាភិបាលពេក" គឺជាមូលហេតុមួយដែលអង្គការក្រៅរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្ស និងតស៊ូមតិមួយចំនួន បានចាកចេញពីបណ្តាញអង្គការក្រៅរដ្ឋាភិបាលថ្នាក់ខេត្ត នៅខេត្តកំពង់ធំ ។ ស្រដៀងគ្នានេះផងដែរ ដោយសារតែអង្គការ NGO Forum បានបង្កើនការខិតខំប្រឹងប្រែងពិភាក្សាជាមួយមន្ត្រីកំពូល១ អង្គការក្រៅរដ្ឋាភិបាលមួយចំនួនដែលជាសមាជិក បានសំដែងនូវការភ័យខ្លាចថា ការធ្វើបែបនេះ "ជាការប្រថុយប្រថានធ្លាក់ក្នុងកណ្តាប់ដៃរបស់រដ្ឋាភិបាល" ដែលអាចធ្វើអោយបាត់បង់នូវឯករាជ្យភាព និងការរិះគន់របស់ខ្លួន។

កម្ពុជាមិនសូវទទួលបានជោគជ័យក្នុងការពង្រីកដែនសាធារណៈសំរាប់ការពិភាក្សា ឬជំរុញអោយអាជ្ញាធរសាធារណៈមានការប្រាស្រ័យទាក់ទងជាលក្ខណៈប្រព័ន្ធ ឬប្រកបដោយលក្ខណៈស្ថាបនាជាមួយសង្គមស៊ីវិលទេ។ ផ្ទុយទៅវិញប្រតិបត្តិករនៅក្នុងសង្គមស៊ីវិលសំដែងនូវការមិនពេញចិត្តថា **កិច្ចខិតខំប្រឹងប្រែងតស៊ូមតិរបស់គេច្រើនតែជួបប្រទះនឹងការជំទាស់ពីរដ្ឋាភិបាល (ជាជាងការឆ្លើយតបទៅនឹងអ្វីដែលគេទាមទារ) ហើយច្រើនតែនាំអោយមានភាពតានតឹង និងការមិនជឿទុកចិត្តគ្នារវាងសង្គមស៊ីវិល និងតួអង្គនៅក្នុងរដ្ឋាភិបាលកាន់តែច្រើនឡើង** ។ បើសូម្បីតែនៅក្នុងករណីដែលការតស៊ូមតិទទួលបានជោគជ័យក្នុងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋយ៉ាងណាក្តី (ដូចជាការការពារមិនអោយមានការបណ្តេញប្រជាពលរដ្ឋចេញពីដីកសិកម្ម) ក៏លទ្ធផលនោះនាំអោយទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាលកាន់តែមានភាពប្រេះឆាធ្ងន់ធ្ងរឡើង ដោយសារតែការអូសបន្លាយនូវអរិភាពរវាងគ្នានិងគ្នា និងការ "បាក់មុខមាត់" និង "ភាពអាម៉ាស់" របស់ "អ្នកចាញ់" ( J4P, ២០០៦:៣២-៣៣) ។ ដូចមានបង្ហាញនៅក្នុងរូបភាពទី ២២ ហើយថា យោងតាមលទ្ធផលនៃការស្ទាបស្ទង់មតិសាធារណៈ អង្គការក្រៅរដ្ឋាភិបាលចាត់ទុក "កង្វះឆន្ទៈនយោបាយ" ថាជាឧបសគ្គចំបងជាងគេចំពោះសកម្មភាពទទួលខុសត្រូវសង្គម ហើយក៏បានចាត់ទុក "ទំនាក់ទំនងតានតឹងរវាងសង្គមស៊ីវិល និងរដ្ឋាភិបាល" ថាជាឧបសគ្គចំបងមួយផងដែរ ។

**រូបភាពទី២២ : ឥទ្ធិពលរបស់អង្គការក្រៅរដ្ឋាភិបាលតាមការយល់ឃើញរបស់ខ្លួនទៅលើដំណើរការអភិបាលកិច្ច**




ប្រភព : CAS/WB, 2007a

**ប្រអប់ទី១១ : ការលំបាកនៅក្នុងការផ្លាស់ប្តូរពី "ស្ថានភាពសង្គមបច្ចុប្បន្ន" អោយទៅជា "ចលនាសង្គម"**

ADHOC ដែលជាអង្គការក្រៅរដ្ឋាភិបាលល្បីល្បាញមួយ បានជួយប្រជាពលរដ្ឋក្នុងការការពារសិទ្ធិរបស់ពួកគេជាសមូហភាពតាមរយៈការបង្កើតសមាគមប្រជាពលរដ្ឋ ឬ "សហគមន៍"នៅក្នុងឃុំចំនួន ២៨ ក្នុងខេត្តចំនួន ១៤ នៅកម្ពុជា ។ ឧទាហរណ៍ នៅឆ្នាំ ២០០៥ អង្គការនេះបានសំរបសំរួលបង្កើតសមាគមប្រជាពលរដ្ឋមួយដែលមានសមាជិកមកពីភូមិផ្សេងៗគ្នាដែលពាក់ព័ន្ធនៅក្នុងវិវាទដីធ្លីដ៏ក្តៅគគុកមួយជាមួយមន្ត្រីរបស់ក្រសួងកសិកម្ម ។ មន្ត្រីនោះបានបញ្ជាអោយអ្នកភូមិចាកចេញពីដីធ្លី ដែលជាប្រភពនៃមុខរបរចិញ្ចឹមជីវិតរបស់ពួកគេជាយូរមកហើយនោះ ។ តែនៅចំពោះមុខការតវ៉ាជាសមូហភាពរបស់អ្នកភូមិ រដ្ឋាភិបាលបានផ្អាកការគំរាមបណ្តេញចេញនោះ ប៉ុន្តែមិនបានចេញប័ណ្ណកម្មសិទ្ធិដីដែលមានវិវាទនោះទៅអោយប្រជាពលរដ្ឋទេ ។ បើទោះបីជាវិបត្តិនោះបានកន្លងហួសទៅហើយក្តី ក៏វិវាទនោះមិនទាន់ត្រូវបានដោះស្រាយនៅឡើយដែរ ហើយអារម្មណ៍សង្ស័យ និងមិនជឿទុកចិត្តគ្នារវាងអ្នកភូមិ និងអាជ្ញាធរសាធារណៈនៅតែបន្តកើតមាន ។ នៅក្នុងកាលៈទេសៈបែបនេះ វាមានការពិបាកក្នុងការគៀងគរ ឬធ្វើសកម្មភាពរួមគ្នាណាស់ ។ សមាជិករបស់សមាគមមិនចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំទេព្រោះពួកគេគិតថា នឹងគ្មានអ្នកណាស្តាប់ការនិយាយរបស់ពួកគេឡើយ ហើយពួកគេមិនជឿថាមេឃុំអាចជួយដោះស្រាយស្ថានភាពនោះបានឡើយ បើទោះបីជាគាត់ព្យាយាមជួយក៏ដោយ ។ ប្រធានសមាគមយល់ថា អាជ្ញាធរមូលដ្ឋានអត់ធ្មត់ជាមួយនឹងក្រុមរបស់ពួកគាត់ ក៏ដោយសារតែឥទ្ធិពល និងសំពាធរបស់ ADHOC តែប៉ុណ្ណោះ ។ អាជ្ញាធរមូលដ្ឋានមានការសង្ស័យថា សមាគមនេះគឺជាភ្នាក់ងាររបស់គណបក្សប្រឆាំងនិងកំពុងព្យាយាមញុះញង់ប្រជាពលរដ្ឋអោយប្រឆាំងនឹងរដ្ឋាភិបាល[៤៣] ។ ដោយសារតែមានការមិនជឿទុកចិត្តគ្នាទៅវិញទៅមក និងភាពតានតឹងជាមួយអាជ្ញាធរមូលដ្ឋាន កិច្ចខិតខំប្រឹងប្រែងរបស់ប្រធានសមាគមក្នុងការដោះស្រាយបញ្ហាផ្សេងទៀត (ដូចជា បញ្ហាជួសជុល និងស្នើសុំអោយឃុំគ្រប់គ្រងស្ថានីយវារីអគ្គិសនីខ្នាតតូចមួយក្នុងមូលដ្ឋាន ដែលសាងសង់ក្រោមការឧបត្ថម្ភពីម្ចាស់ជំនួយ ប៉ុន្តែឥឡូវនេះខូចខាតលែងដំណើរការ និងស្ថិតក្រោមការទទួលខុសត្រូវរបស់មន្ទីររ៉ែ និងថាមពលនោះ) លែងបានផលដូចមុនទៀតហើយ ។ ហេតុដូច្នេះហើយ អ្នកភូមិគ្មានទំនុកចិត្តលើសមាគម និងសមត្ថភាពរបស់សមាគមក្នុងការសំរេចការងារ ឬធ្វើអោយមានការផ្លាស់ប្តូរណាមួយទេ ។ បើទោះបីជាសមាគមនោះទទួលបានជោគជ័យនៅក្នុងការគៀងគរអ្នកភូមិ និងបង្ការមិនអោយបាត់បង់ដីធ្លី (នាពេលបច្ចុប្បន្ន) ដែលពួកគេកំពុងប្រើប្រាស់ក៏ដោយ ក៏វាពិបាកក្នុងការរក្សាប្រជាជនអោយនៅរួមគ្នា និងរក្សាទឹកចិត្តអោយពួកគេនៅបន្តប្រាស្រ័យទាក់ទងជាសមូហភាពជាមួយអាជ្ញាធរណាស់ ។ ឧទាហរណ៍នេះក៏បង្ហាញផងដែរថា នៅក្នុងស្ថានភាពមានវិវាទរួមដ៏ធ្ងន់ធ្ងរជាមួយអាជ្ញាធរ វាមិនសូវមានឱកាសល្អនៅថ្នាក់ភូមិ ឬឃុំដើម្បីអោយប្រជាពលរដ្ឋសំដែងពីការជំទាស់ និងមានឥទ្ធិពលអ្វីលើការសំរេចចិត្តឡើយជាពិសេសនៅពេលដែលការសំរេចចិត្តនោះធ្វើឡើងដោយមន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់ ។

*ប្រភព: CAS/WB, ២០០៧b*

[៤៣] ព័ត៌មាននេះទទួលបានពីការពិភាក្សាតាមក្រុមជាមួយនឹងប្រធានសហគមន៍ និងការសំភាសន៍ជាមួយនឹងសមាជិករបស់ក្រុមប្រឹក្សាឃុំ និងមេភូមិ ។

**រូបភាពទី២៣ : ការយល់ឃើញរបស់អង្គការក្រៅរដ្ឋាភិបាលអំពីឧបសគ្គចំពោះគំនិតផ្តួចផ្តើមផ្នែកទទួលខុសត្រូវសង្គម**




ប្រភព : CAS/WB, 2007a

១១៦. **នៅក្នុងប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ននេះ មានគំលាតដ៏ធំមួយរវាងអង្គការដែលមិនប្រកាន់នយោបាយ និងមិនសួរចេះដេញដោល (ធ្វើការផ្តោតតែលើការផ្តល់សេវាកម្ម) នៅផ្នែកម្ខាងនៃវិសាលគម និងអង្គការសង្គមស៊ីវិលមួយក្រុមទៀតដែល "ដែលវាយប្រហារ" (ធ្វើការផ្តោតលើការតស៊ូមតិ) នៅផ្នែកម្ខាងទៀតនៃវិសាលគម ។ វិធីសាស្ត្រនៃការធ្វើកិច្ចការទទួលខុសត្រូវសង្គមផ្តល់នូវឱកាសដ៏សំបូរបែបដើម្បីពង្រីកនិងពង្រឹងនូវសកម្មភាពតស៊ូមតិ និងដើម្បីបំពេញបន្ថែមនូវ "ចន្លោះកណ្តាល" នៃវិសាលគមនេះ ជាមួយនឹងសកម្មភាពដែលព្យាយាមប្រាស្រ័យទាក់ទង (និងអាចចោទសួរ រិះគន់ និងដេញដោល) ជាមួយតួអង្គក្នុងរដ្ឋាភិបាល ប៉ុន្តែតាមរបៀបមួយដែលមានលក្ខណៈស្ថាបនា ជាក់លាក់ ផ្អែកលើភស្តុតាង និងផ្តោតលើដំណោះស្រាយជាធំ ។** នាពេលបច្ចុប្បន្ននេះ គំរោងដែលខិតខំលើកកំពស់ការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋ និងសង្គមស៊ីវិលជាមួយនឹងរដ្ឋាភិបាលដោយលក្ខណៈស្ថាបនាបែបនេះមានតិចតួចណាស់ ។ ដូចដែលបង្ហាញនៅក្នុងរូបភាពទី ២៣ ហើយថា នៅពេលដែលអង្គការក្រៅរដ្ឋាភិបាលកម្ពុជាត្រូវបានស្នើអោយបង្ហាញពីប្រភេទសកម្មភាព ផ្នែកការទទួលខុសត្រូវសង្គមដែលពួកគេបានអនុវត្តរហូតមកដល់ពេលបច្ចុប្បន្ននេះ ចំលើយភាគច្រើនជាងគេបំផុតគឺ "ការតស៊ូមតិ" ។ មានតែអង្គការមួយចំនួនតូចប៉ុណ្ណោះដែលបានបង្ហាញថាពួកគេធ្លាប់ដកពិសោធន៍ ឬប្រើប្រាស់វិធីសាស្ត្រផ្សេងទៀត (ដែលភាគច្រើនផ្អែកលើភស្តុតាងឬផ្អែកតាមការបំពេញការងារជាក់ស្តែង ឬយកការពិភាក្សា និងការចរចារជាធំ) ដូចជាការគាំទ្រការចូលរួមរបស់ប្រជាពលរដ្ឋក្នុងក្រុមប្រឹក្សាឃុំ (១០%) ការឃ្លាំមើលការចំណាយសាធារណៈ (៣%) ឬការពាក់ព័ន្ធ ជាមួយនឹងបញ្ហាថវិកា (១,៦%) ។

**រូបភាពទី២៤ : ប្រភេទគំនិតផ្តួចផ្តើមផ្នែកការទទួលខុសត្រូវសង្គមនៅកម្ពុជានាពេលបច្ចុប្បន្ន**




ប្រភព : CAS/WB, 2007a

១១៧. បទពិសោធន៍ជាសាកលបង្ហាញថា វិធីសាស្ត្រនៃការងារទទួលខុសត្រូវសង្គមអាចជួយរដ្ឋាភិបាលអោយកាន់តែមានប្រសិទ្ធិភាព និងកាន់តែមានការទទួលខុសត្រូវ ហើយក្នុងពេលជាមួយគ្នានោះ ក៏រួមចំណែកធ្វើអោយទំនាក់ទំនងរវាងសង្គមស៊ីវិល និងតួអង្គនានាក្នុងរដ្ឋាភិបាលកាន់តែល្អប្រសើរជាងមុនដែរ (ឧទាហរណ៍ មូលនិធិកិច្ចការសាធារណៈ ២០០៧; Malena et. al., ២០០៤) **នៅក្នុងបរិបទប្រទេសកម្ពុជា ការងាកចេញពីវិធីសាស្ត្រតស៊ូមតិជាឯកតោភាគី និងបែបប្រឈមមុខ ទៅជាការបង្កើតនូវលទ្ធភាពសំរាប់អោយមានកិច្ចពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា និងការចូលរួមនោះ គឺជាបញ្ហាប្រឈមមួយដ៏ចំបង** ។ ដំបូង ការបង្កើតនូវលទ្ធភាពបែបនេះតំរូវអោយទាំងអង្គការសង្គមស៊ីវិល និងមន្ត្រីរដ្ឋាភិបាលប្រកាន់នូវឥរិយាបថបែបយោគយល់ និងត្រូវមានឆន្ទៈប្រាស្រ័យទាក់ទងគ្នា បើទោះបីជាពួកគេមានមានគំនិតខុសគ្នា មានការសង្ស័យ និងមិនជឿជាក់គ្នាក៏ដោយ ។ វាតំរូវអោយអង្គការសង្គមស៊ីវិលជានិច្ចជាកាល ត្រូវមានអំណះអំណាង ព្រមជាមួយនឹងភស្តុតាងពិតប្រាកដ និងព្យាយាមរិះរកដំណោះស្រាយ ជាជាងគ្រាន់តែចង្អុលបង្ហាញពីបញ្ហា ។ ដើម្បីឈានចេញពីការប្រឈមមុខដាក់គ្នាមកជាការចូលរួមប្រកបដោយលក្ខណៈវិជ្ជាជីវៈ និងស្ថាបនា ជាសំខាន់ត្រូវប្រើប្រាស់យុទ្ធសាស្ត្រច្រើនប្រភេទ និងមានការថ្លឹងថ្លែងអោយបានល្អ ។ តំណាងម្នាក់មកពីអង្គការ NGO Forum បានលើកឡើងថា "ការប្រើប្រាស់លទ្ធផលស្រាវជ្រាវ និងការប្រមូលព័ត៌មានអោយបានហ្មត់ចត់ គឺមានសារៈប្រយោជន៍ជាងការដែលគ្រាន់តែប្រើអារម្មណ៍មួរម៉ៅ ហើយចោទប្រកាន់រដ្ឋាភិបាល ។ បើគ្មានភស្តុតាងទេ មន្ត្រីទាំងនោះងាយបដិសេធណាស់" ។

១១៨. **ការប្រមូល និងវិភាគទិន្នន័យ ការបង្កើតនូវអំណះអំណាងច្បាស់លាស់ និងការស្នើឡើងនូវដំណោះស្រាយប្រាកដប្រជា តំរូវអោយមានចំណេះដឹង និងជំនាញខ្ពស់** ។ អង្គការក្រៅរដ្ឋាភិបាលដែលចូលរួមក្នុងការស្ទាបស្ទង់មតិបានសារភាពថា សមត្ថភាពបែបនេះនៅមានកំរិតតិចតួចនៅឡើយក្នុងពេលបច្ចុប្បន្ននេះ ។ ដូចមានបង្ហាញជូននៅក្នុងរូបភាពទី ២៤ អ្នកចូលរួមទាំងនេះបានកំណត់ (១) ការបណ្តុះបណ្តាលជំនាញ និង (២) ព័ត៌មានបន្ថែមអំពីវិធីសាស្ត្រ និងឧបករណ៍អនុវត្តជាក់ស្តែង ថាជាយុទ្ធសាស្ត្រអាទិភាពក្នុងការបង្កើនសមត្ថភាពរបស់ពួកគេសំរាប់លើកកំពស់ និងអនុវត្តកិច្ចការទទួលខុសត្រូវសង្គម ។ ក្រុមដែលមានចំណេះដឹង និង

ជំនាញឯកទេស ដូចជាក្រុមអ្នកឯកទេសផ្នែកផ្តល់ប្រឹក្សា វិទ្យាស្ថានស្រាវជ្រាវ សកលវិទ្យាល័យ សមាគមវិជ្ជាជីវៈ សហជីព សមាគមប្រព័ន្ធផ្សព្វផ្សាយ មានតួនាទីយ៉ាងសំខាន់ ក្នុងការបង្កើតភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលដើម្បី "បំពេញគំលាត រវាងវិសាលគមទាំងពីរនេះ" តាមរយៈការចូលរួមនៅក្នុងការជជែកវែកញែក ការពិភាក្សា និងការបង្កើតទំនាក់ទំនងការងារ ប្រកបដោយលក្ខណៈស្ថាបនាជាមួយរដ្ឋាភិបាល ។

**រូបភាពទី ២៩ : តំរូវការសមត្ថភាពរបស់អង្គការក្រៅរដ្ឋាភិបាលដើម្បីកែលំអសកម្មភាពទទួលខុសត្រូវសង្គម**




ប្រភព : CAS/WB, 2007a

## ២.ឃ.៣. ការលើកកំពស់ប្រសិទ្ធិភាពយន្តការទទួលខុសត្រូវដែលមានស្រាប់តាមរយៈការចូលរួម របស់ប្រជាពលរដ្ឋ

១១៩. នៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់អោយប្រើប្រាស់នូវយន្តការមួយចំនួនក្នុងបំណងសំរបសំរួលអោយមានការចូលរួមរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវ - ដូចជាក្រុមប្រឹក្សាឃុំ បំណងធ្វើវិសហមជ្ឈការនៃការផ្តល់សេវាសាធារណៈ គណៈកម្មការទ្រទ្រង់សាលារៀន គណៈកម្មការគណនេយ្យភាពខេត្ត ("ប្រអប់គណនេយ្យភាព") និងការសាកល្បងនូវការិយាល័យប្រជាពលរដ្ឋ (មានទីតាំងនៅក្នុងការិយាល័យច្រកចេញចូលតែមួយនៅក្នុងស្រុកពីរ) ។ បើទោះបីរបៀបទំនាក់ទំនងល្អៗខ្លះរវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំត្រូវបានលើកយកមកពិភាក្សារួចហើយក្តី ក៏ការស្រាវជ្រាវនេះបានបង្ហាញថា **ចំណេះដឹងរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលអំពីយន្តការទទួលខុសត្រូវដែលមានស្រាប់ និងការប្រើប្រាស់យន្តការទាំងនេះ គឺនៅមានកំរិតតិចតួចយ៉ាងខ្លាំង** ។ បើសូម្បីតែអង្គការក្រៅរដ្ឋាភិបាលអាជីពក៏នៅបានយកចិត្តទុកដាក់តិចតួចបំផុតចំពោះយន្តការទទួលខុសត្រូវទាំងនេះរបស់រដ្ឋាភិបាល បើទោះបីតាមទ្រឹស្តីយន្តការទាំងនេះមានបំណងអោយតួអង្គនានាក្នុងសង្គមស៊ីវិលបានចូលរួមក្នុងកិច្ចខំប្រឹងប្រែងដើម្បីបង្កើនប្រសិទ្ធិភាពការងារ និងការផ្តល់សេវាក្នុងវិស័យសាធារណៈក៏ដោយ ។ ការសំភាសន៏បានរកឃើញថាអង្គការសង្គមស៊ីវិល (ជាពិសេសអង្គការផ្នែកតស៊ូមតិ និងសិទ្ធិមនុស្ស) មានការស្ទាក់ស្ទើរក្នុងការចូលរួមក្នុងគំនិតផ្តួចផ្តើម

ឬយន្តការនានាដែលរដ្ឋាភិបាលបានផ្តួចផ្តើមឡើង ដោយភ័យខ្លាចថាពួកគេនឹង "ត្រូវបានស្រូបយក " "លែងមានប្រសិទ្ធិភាព" ឬ "ត្រូវបានបង្វែតួនាទី "[៤៤] ។

១២០. *វចនាសម្ព័ន្ធវិមជ្ឈការរបស់រដ្ឋាភិបាល* — នៅផ្នែកខាងដើមនៃរបាយការណ៍នេះ យើងបានពិភាក្សារួចហើយថា ប្រជាពលរដ្ឋមានព័ត៌មានកាន់តែច្រើនគួរជាទីពេញចិត្តអំពីក្រុមប្រឹក្សាឃុំ ហើយគេបានចូលរួមច្រើននៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ (បើទោះបីការចូលរួមនោះមានភាពអកម្ម និងមិនមានការរៀបរយល្អក៏ដោយ)។ **ស្ថានភាពបែបនេះជាសញ្ញាណបង្ហាញថា ក្រុមប្រឹក្សាឃុំ-សង្កាត់អាចជាយន្តការមួយដ៏ល្អសំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវសង្គម (បើទោះបីទំនាក់ទំនងបែបនេះនៅមានភាពថ្មីថ្មោងនិងនៅផុយស្រួយនៅឡើយក៏ដោយ)។** នៅពេលណាដែលអង្គការក្រៅរដ្ឋាភិបាលបានផ្តល់នូវការគាំទ្រ និងការសំរបសំរួលដល់ការប្រាស្រ័យទាក់ទងគ្នា (ដូចជាតាមរយៈ CCSP ជាដើម, សូមមើលប្រអប់ទី ១២) ការស្រាវជ្រាវនេះបានរកឃើញនូវភស្តុតាង នៃការមានទំនាក់ទំនង និងការសហការគ្នាល្អរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាលកំពុងកើតមានឡើង ។ ឧទាហរណ៍ដូចជានៅខេត្តកំពង់ធំ អ្នកដែលត្រូវបានសំភាសន៍ជាច្រើននាក់បានអោយដឹងថា បន្ទាប់ពីទទួលបានបណ្តុះបណ្តាល ការកសាងសមត្ថភាព និងការសំរបសំរួលពីអង្គការក្រៅរដ្ឋាភិបាលរួចមក ទំនាក់ទំនងរវាងអាជ្ញាធរមូលដ្ឋាន និងសមាគមមានភាពល្អប្រសើរជាងមុន ហើយប្រធានសមាគមមានអារម្មណ៍ថាខ្លួនគាត់មានសមត្ថភាពពិនិត្យពិច័យពីព័ត៌មានត្រលប់ និងសំណើនានាដែលពាក់ព័ន្ធនឹងការបំពេញការងាររបស់រដ្ឋាភិបាល[៤៥] ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ការស្រាវជ្រាវបែបគុណភាពក៏បានរកឃើញដែរថា ការចូលរួមនេះគឺកើតមានដោយអន្លើ ពោលគឺបើមាន "ការអំពាវនាវ" និង "ការស្នើសុំ" តែប៉ុណ្ណោះ ហើយសំណើនោះត្រូវបានគេបោះបង់ចោលយ៉ាងឆាប់រហ័ស និងយ៉ាងស្ងប់ស្ងាត់ប្រសិនបើមានការឆ្លើយតបអវិជ្ជមាននោះ ។ ជារួមទៅ ប្រជាពលរដ្ឋមានការយល់ឃើញថា ការបំពេញការងារ និងការឆ្លើយតបរបស់ក្រុមប្រឹក្សាឃុំ គឺមានភាពល្អប្រសើរ ។ ដូចមានបង្ហាញនៅក្នុងរូបភាពទី ២៥ ហើយ នៅពេលដែលត្រូវបានសាកសួរថាតើការឆ្លើយតបរបស់អាជ្ញាធរឃុំមានភាពល្អប្រសើរដែរឬទេបន្ទាប់ពីការបោះឆ្នោតឃុំ-សង្កាត់អាណត្តិទីមួយ (២០០២) បើធៀបទៅនឹងស្ថានភាពពីមុន ដែលមេឃុំ-ចៅសង្កាត់ត្រូវបានតែងតាំងនោះ អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិភាគច្រើន (៥៤%) ឆ្លើយថាមានភាពល្អប្រសើរជាងមុន ។ ការអង្កេតមួយទៀតនៅឆ្នាំ ២០០៤ ក៏បានរកឃើញស្រដៀងគ្នានេះផងដែរថាក្រុមប្រឹក្សាឃុំអាចជាទីទុកចិត្តបានច្រើនជាងរដ្ឋាភិបាលនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ហើយបានរកឃើញថា ការបំពេញការងារ (ក្នុងរយៈពេលពីរឆ្នាំដំបូង) មានភាពវិជ្ជមានច្រើន ។ ទាំងអ្នកបោះឆ្នោតក៏ដូចជាសមាជិកក្រុមប្រឹក្សាឃុំខ្លួនឯងមានអារម្មណ៍ថា រដ្ឋបាលឃុំ-សង្កាត់មានការរីកចំរើនប្រសើរជាងមុនចាប់តាំងពីមានការបោះឆ្នោតឃុំ — សង្កាត់ រួចមក (TAF ក្រុមប្រឹក្សាឃុំនៅក្នុងប្រទេសកម្ពុជា ២០០៥:១៨-២០)។

១២១. បើទោះបីជាតួនាទីដ៏សំខាន់បំផុតរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់គឺការធ្វើតំណាងអោយ "ប្រជាពលរដ្ឋ" ជាជាងតំណាងអោយរដ្ឋាភិបាលថ្នាក់កណ្តាលយ៉ាងណាក្តី ក៏មានសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់តែមួយចំនួនតូចប៉ុណ្ណោះ ដែលមានទំនុកចិត្តលើខ្លួនឯង

---

[៤៤] ឧទាហរណ៍ អ្នកសំរបសំរួលថ្នាក់ខេត្តរបស់អង្គការក្រៅរដ្ឋាភិបាលធំមួយនៅក្នុងខេត្តសៀមរាបបានពន្យល់ថា ដោយសារតែអង្គការរបស់គាត់មានអាណត្តិការពារសិទ្ធិប្រជាពលរដ្ឋ ដែលត្រូវបានមន្ត្រីសាធារណៈរំលោភបំពាននោះ គាត់មិនអាច "ចូលរួម" នៅក្នុងគំនិតផ្តួចផ្តើមរបស់រដ្ឋបានឡើយ ។

[៤៥] ប្រតិបត្តិករនានាដែលអនុវត្តគំរោងកសាងសមត្ថភាពក្រុមប្រឹក្សាឃុំ-សង្កាត់ក៏បានរាយការណ៍ផងដែរថា ជាទូទៅសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់មានភាពវិជ្ជមាន និងសាទរចំពោះការរៀនសូត្រ និងការប្រើប្រាស់បច្ចេកទេសបែបចូលរួមព្រោះពួកគាត់អាចទំនាក់ទំនងជាមួយប្រជាពលរដ្ឋបានដោយស្រួល ។

ហ៊ានការពារនូវសេចក្តីសំរេចរបស់ឃុំ-សង្កាត់ប្រឆាំងនឹងអាជ្ញាធរថ្នាក់លើ ។ **សមាជិករបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ក៏បានបង្ហាញផងដែរនូវអារម្មណ៍ដែលថា សមត្ថភាពរបស់គេក្នុងការឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដែលបានបោះឆ្នោតជ្រើសរើសពួកគេនោះ ត្រូវបានបន្ទុចបង្អាក់ដោយសារតែសមត្ថកិច្ច និងធនធានរបស់ពួកគេនៅមានកំរិត និងដោយសារតែមានបញ្ហាពីថ្នាក់លើក្នុងជួររដ្ឋាភិបាល ឬក្នុងជួរណបក្ស** ។ ការស្រាវជ្រាវនេះក៏បានបង្ហាញផងដែរថា ប្រជាពលរដ្ឋក៏ដឹងពីការដែលសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់មានឥទ្ធិពលតិចតួចនោះដែរ ។

**ប្រអប់ទី ១២ : គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់**

គំរោងគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ (CCSP) ដែលបានបង្កើតឡើងនៅឆ្នាំ ២000 ជាគំនិតផ្តួចផ្តើមរួមរបស់អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិចំនួន៩ គឺ ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍, Church World Service, CIDSE, COMFREL, Concern Worldwide, NGO Forum, Oxfam GB, SEDOC និងអង្គការទស្សនៈពិភពលោកកម្ពុជា ។ CCSP គាំទ្រអោយមានការចូលរួមស្មើភាពគ្នារវាងស្ត្រី និងបុរសនៅក្នុងកំណែទំរង់អភិបាលកិច្ចមូលដ្ឋាន ដើម្បីជាប្រយោជន៍របស់ប្រជាពលរដ្ឋក្រីក្រ ។ CCSP ក៏ធ្វើការដើម្បីបង្កើនការយល់ដឹងរបស់សង្គមស៊ីវិលអំពីផលនៃវិមជ្ឈការ និងកសាងសមត្ថភាពអង្គការសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាលដើម្បីចូលរួមជាមួយនឹងស្ថាប័នរដ្ឋដែរ ។ ក្រៅពីការផ្សព្វផ្សាយព័ត៌មាន CCSP មានកម្មវិធីកសាងសមត្ថភាព តស៊ូមតិផ្នែកគោលនយោបាយ និងរក្សាការសហការគ្នារវាងរដ្ឋ និងសង្គមស៊ីវិល ។ CCSP មានបណ្តាញនៅក្នុងគ្រប់ខេត្តក្រុងទាំង២៤ ហើយគឺជាអ្នកផ្តួចផ្តើមបង្កើតការិយាល័យទំនាក់ទំនងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងក្រសួងមហាផ្ទៃ ។ CCSP ក៏ត្រូវបានគេស្គាល់ផងដែរដោយសារកម្មវិធីផ្តល់រង្វាន់របស់ខ្លួនដែលបានផ្តួចផ្តើមផ្តល់អំណាចដល់ប្រជាពលរដ្ឋ ភាពជាដៃគូរវាងសង្គមស៊ីវិលនិងក្រុមប្រឹក្សាឃុំ-សង្កាត់ ព្រមទាំងតម្លាភាព និងការទទួលខុសត្រូវនៅថ្នាក់មូលដ្ឋាន ។

*ប្រភព: http://www.ipd.ph/CPLG/partners/partners.html*

**រូបភាពទី ២៦ : ការរីកចំរើនជុំវិញការឆ្លើយតបរបស់អាជ្ញាធរឃុំ-សង្កាត់**




ប្រភព : CAS/WB, 2007

១២២. **ដំណើរការវិមជ្ឈការ និងវិសហមជ្ឈការនាពេលបច្ចុប្បន្ន ក៏បង្កើតនូវឱកាសសំខាន់ៗ (ប៉ុន្តែនៅមិនទាន់ត្រូវបានពង្រីកអោយបានទូលំទូលាយនៅឡើយ) ដើម្បីអោយប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលចូលរួមជាមួយនឹងអាជ្ញាធររបស់រដ្ឋាភិបាល និងអ្នកផ្តល់សេវាសាធារណៈថ្នាក់ស្រុក និងខេត្ត ។** ឧទាហរណ៍មួយអំពីសមាគមថ្នាក់មូលដ្ឋាន ដែលចូលរួមជាមួយនឹងអ្នកផ្តល់សេវាសុខភាពនៅថ្នាក់ស្រុកនិងថ្នាក់ខេត្ត ត្រូវបានរៀបរាប់នៅក្នុងប្រអប់ទី ៤ ។ មានលទ្ធភាពជាច្រើនក្នុងការពង្រីកការចូលរួមរបស់ប្រជាពលរដ្ឋតាមរូបភាពបែបនេះជាមួយនឹងរចនាសម្ព័ន្ធរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិដទៃទៀត (ឧទាហរណ៍ នៅក្នុងវិស័យអប់រំ កសិកម្ម ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ) ។

១២៣. *គណៈកម្មការទ្រទ្រង់សាលារៀន (SSC)* – ការចូលរួមរបស់សហគមន៍នៅក្នុងបញ្ហាសាលារៀន ធ្លាប់មានតាំងពីយូរណាស់មកហើយនៅក្នុងប្រទេសកម្ពុជា ក្នុងរូបភាពជាសមាគមទ្រទ្រង់សាលារៀនបែបប្រពៃណី (មានការផ្សារភ្ជាប់ទៅនឹងវត្តអារាម) ដែលតែងរៃអង្គាសប្រាក់សំរាប់ថែទាំអាគារសាលារៀន និងឧបត្ថម្ភដល់គ្រូបង្រៀន ។ ដើម្បីស្តារវិស័យអប់រំឡើងវិញបន្ទាប់ពីការបំផ្លិចបំផ្លាញដោយរបបខ្មែរក្រហម រដ្ឋាភិបាលបានលើកទឹកចិត្តជាផ្លូវការអោយមានការចូលរួមពីប្រជាពលរដ្ឋ និងសហគមន៍ដោយបានណែនាំអោយគ្រប់សាលារៀនសាធារណៈទាំងអស់ បង្កើតនូវគណៈកម្មការទ្រទ្រង់សាលារៀន (ដំបូងឡើយមានឈ្មោះថា "សមាគមមាតាបិតាសិស្ស")... ជាគោលការណ៍ គណៈកម្មការទាំងនេះបើកចំហចំពោះប្រជាពលរដ្ឋគ្រប់រូបដែលមានការចាប់អារម្មណ៍ចំពោះកិច្ចការអប់រំ ហើយថ្មីៗនេះត្រូវបានផ្តល់អណត្តិអោយត្រួតពិនិត្យ និងធានាថាថវិកាប្រចាំឆ្នាំដែលក្រសួងអប់រំយុវជន និងកីឡាបានផ្តល់ជូនសាលារៀន (ក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពអាទិភាព ឬ PAP) ត្រូវបានប្រើប្រាស់ និងគ្រប់គ្រងយ៉ាងត្រឹមត្រូវ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការស្រាវជ្រាវនេះបានរកឃើញថា **បើទោះបីជា SSCs ត្រូវបានគេស្គាល់យ៉ាងទូលំទូលាយក៏ដោយ ក៏ប្រជាជននៅមិនទាន់យល់ច្បាស់អំពីស្ថានភាព និងអាណត្តិការងាររបស់គណៈកម្មការនេះឡើយ** ហើយគណៈកម្មការនេះគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកសាលា តាមរបៀបផ្សេងៗគ្នាទៅតាមបរិបទជាក់លាក់ក្នុងមូលដ្ឋាន ។ ដូចដែលមានបង្ហាញនៅក្នុងរូបភាពទី ២៦ ហើយ បើតាមការស្ទាបស្ទង់មតិសាធារណៈ ប្រជាពលរដ្ឋភាគច្រើនដែលស្គាល់ SSCs បានសារភាពថា ពួកគេដឹងតិចតួច ឬមិនដឹងសោះអំពីគោលបំណង និងមុខងាររបស់គណៈកម្មការទាំងនេះ (រួមទាំងការពិតដែលថា គណៈកម្មការទាំងនេះមានមុខងារជាអ្នកត្រួតពិនិត្យការចំណាយថវិកាសាលារៀនផង) ។ ការចូលរួមរបស់មាតាបិតាសិស្សនៅក្នុងការងារអប់រំ គឺបានត្រឹមតែជាការឆ្លើយតបទៅនឹងការស្នើសុំនូវការរួមវិភាគទានជាថវិកាម្តងម្កាលប៉ុណ្ណោះ (ឧទាហរណ៍ សំរាប់ថែទាំហេដ្ឋារចនាសម្ព័ន្ធសាលារៀន) ហើយកំរមានការទាក់ទងដ៏សកម្មជាមួយគណៈកម្មការទ្រទ្រង់សាលារៀនណាស់ (ដូចជាសាកសួរអំពីថវិការបស់សាលារៀន ឬការទទួលខុសត្រូវរបស់ SSC ឬរបស់នាយកសាលា) ។ ឧទាហរណ៍ ការអង្កេតលើការចំណាយសាធារណៈ (PETS) ក្នុងវិស័យអប់រំកាលពីពេលថ្មីៗនេះដោយធនាគារពិភពលោក (WB ២០០៥) បានរកឃើញថាមានមាតាបិតាសិស្សតែប្រមាណ ៩% ប៉ុណ្ណោះដែលដឹងពី PAP ។ ការអង្កេតនោះក៏បានរកឃើញផងដែរថាបើទោះបីជា SSCs ជាតំណាងអោយសហគមន៍ ក៏ដោយ ក៏ប្រសិទ្ធិភាពនៃភាពជាតំណាងរបស់មាតាបិតាសិស្សនេះនៅមានកំរិតទាបនៅឡើយ ។

**រូបភាពទី ២៧ : ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីគណៈកម្មការទ្រទ្រង់សាលារៀន**




ប្រភព : CAS/WB, 2007

១២៤. ការស្រាវជ្រាវបែបគុណភាពបានរកឃើញថា **សូម្បីតែសមាជិករបស់ SSCs ក៏មិនសូវដឹងពីអាណត្តិ និងអំណាចរបស់គណៈកម្មការនេះដែរ** ។ របកគំហើញនេះស្របគ្នាទៅនឹងការអង្កេតលើការចំណាយសាធារណៈ (PETS) ក្នុងវិស័យអប់រំ ដែលបានរកឃើញថា បើទោះបីសមាជិក SSC ប្រមាណ ៨៣% ដឹងថាអ្វីជា PAP នោះក៏ដោយ ក៏មានអ្នកចូលរួមក្នុងការអង្កេតត្រឹមតែ ១៤% ប៉ុណ្ណោះ ដែលដឹងពីចំនួនថវិកាដែលសាលារៀនទទួលបាន ហើយ ៧% ទៀតដឹងពីគោលការណ៍ណែនាំអំពីការចំណាយ ។ ឧទាហរណ៍មួយ ដែលត្រូវបានសិក្សានៅក្នុងខេត្តកំពង់ចាម ( *ស្រុកជើងព្រៃ*) បានរកឃើញថា SSC បានដើរតួនាទីយ៉ាងសកម្មនៅក្នុងការមើលការខុសត្រូវលើការងារជួសជុលនិងសាងសង់ និងសូម្បីនៅក្នុងការវិនិច្ឆ័យលើការផ្តល់អាហារូបករណ៍ដល់សិស្សានុសិស្សផង ប៉ុន្តែ SSC មិនដែលចូលរួមនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ឬតាមដានមើលការចំណាយរបស់សាលារៀនឡើយ ដោយសារពួកគេយល់ឃើញថាការងារនេះ "ហួសពីសមត្ថភាពរបស់ពួកគេ" ។ មានការយល់ឃើញថា ដោយសារតែថវិកា PAP ត្រូវបានផ្តល់ដោយក្រសួង ម្ល៉ោះហើយនាយកសាលាគឺជាអ្នកទទួលខុសត្រូវអំពីចំណាយនោះចំពោះក្រសួង ។ លើសពីនេះទៀត សមាជិកណាដែលមិនសូវយល់ដឹងអំពីវិស័យអប់រំ ជាធម្មតាមិនសូវមានទំនុកចិត្តលើខ្លួនឯងទេពេលចូលរួមក្នុងកិច្ចប្រជុំ ដោយសារតែពាក្យពេចន៍ដែលបានប្រើប្រាស់នៅក្នុងការពិភាក្សាមានលក្ខណៈបច្ចេកទេសពេក និងធ្វើអោយគេពិបាកយល់ ។ ពួកគេយល់ថាខ្លួនគេពុំសូវមានសមត្ថភាពក្នុងការត្រួតពិនិត្យ ឬស្នើសុំព័ត៌មានអំពីថវិការបស់សាលារៀនឡើយ ។ ស្រដៀងគ្នានេះដែរ នៅខេត្តកំពង់ធំ ( *ស្រុកស្ទោង*) តួនាទីរបស់ SSC ក៏មិនសូវមានភាពច្បាស់លាស់ដែរ ប៉ុន្តែការស្រាវជ្រាវនេះបានរកឃើញថា ក្រុមអ្នកភូមិបានចូលរួមយ៉ាងសកម្មក្នុងកិច្ចការសាលារៀន ដែលទង្វើនេះគឺជាទំលាប់របស់សមាគមសាលារៀនដែលមានតាំងពីទសវត្សឆ្នាំ ១៩៥០ មកនោះ ។ បើទោះបីជាមិនមានសមាជិកភាពជាផ្លូវការក៏ដោយ ក៏អ្នកភូមិភាគច្រើនបានចូលរួមចំណែកនៅក្នុងសមាគមសាលារៀន ប៉ុន្តែបានទុកកិច្ចការដូចជាការត្រួតពិនិត្យថវិកា PAP ជាដើមអោយប្រធានរបស់គេទាំងស្រុង ។ ប្រធានសមាគមសាលារៀនមួយចំនួនបានត្អូញត្អែរ អំពីការដែលប្រជាពលរដ្ឋមិនសូវចាប់អារម្មណ៍ ក្នុងការស្វែងយល់អំពីការងាររបស់ SSC និងការចំណាយនានារបស់សាលារៀន ។ "ប្រជាពលរដ្ឋមិនដែលសួរថាតើថវិកា PAP ត្រូវបានចំណាយយ៉ាងដូចម្តេចនោះឡើយ ។ ពួកគេមិនសូវយកចិត្តទុកដាក់ពីថវិកាឡើយ ព្រោះគេពឹងផ្អែកលើប្រធានសមាគមសាលារៀនអោយធ្វើកិច្ចការទាំងនេះ" ។ ប៉ុន្តែទោះជា

យ៉ាងណាក្តី សូម្បីតែប្រធានរបស់សមាគមសាលារៀនដែលល្បីជាងគេនោះក៏ដោយ ក៏យល់ថាវាមិនមែនជាការងាយស្រួលសំរាប់គាត់ឡើយក្នុងការបំពេញការងារត្រួតពិនិត្យថវិកា PAP ឬអោយនាយកសាលាទទួលខុសត្រូវលើការចំណាយនោះ ។ ហិរញ្ញិករបស់ SSC មួយនៅក្នុងស្រុកស្មោង (ហើយក៏ជាសមាជិករបស់គណៈកម្មការវត្ត និងបណ្ណាញភូមិផងដែរនោះ) បានអោយដឹងថារូបគាត់ និងអ្នកដទៃទៀតមានការពិបាកក្នុងការស្នើសុំព័ត៌មានអំពីការចំណាយ PAP ពីនាយកសាលា បើទោះបីជាពួកគេមានអាណត្តិត្រូវធ្វើដូច្នេះក៏ដោយ ។ សមាជិកសមាគមសាលារៀនមិនដែលស្នើសុំរបាយការណ៍ពីការចំណាយទាំងនោះឡើយ ព្រោះពួកគេខ្លាចការស្នើសុំនេះធ្វើអោយនាយកសាលាអាម៉ាស់មុខ ឬជាសញ្ញាណនៃការមិនជឿទុកចិត្ត ដែលនេះអាចប៉ះពាល់ធ្ងន់ធ្ងរដល់ទំនាក់ទំនងរបស់ពួកគេ និងបង្កអោយមានការលំបាកដល់កូនៗរបស់គេដែលរៀននៅក្នុងសាលានោះ ។ ដូចដែលបានរៀបរាប់នៅក្នុងប្រអប់ទី ១៣ ការសំភាសន៍តាមមូលដ្ឋានបង្ហាញថា ការចូលរួមរបស់ SSC នៅក្នុងការត្រួតពិនិត្យថវិកា គឺអាស្រ័យយ៉ាងខ្លាំងទៅលើឆន្ទៈរបស់នាយកសាលា (ក្នុងការចែករំលែកព័ត៌មានអំពីថវិកា) និងការជួយសំរបសំរួលពីអង្គការក្រៅរដ្ឋាភិបាល ។

**ប្រអប់ទី១៣ : បទពិសោធន៍របស់សមាគមទ្រទ្រង់សាលារៀន និងគណៈកម្មការទ្រទ្រង់សាលារៀនខេត្តកំពង់ធំ**

នៅក្នុងខេត្តកំពង់ធំ ប្រធានសមាគមទ្រទ្រង់សាលារៀននៅក្នុងឃុំមួយ បានរាយការណ៍ថា នៅក្នុងឆ្នាំថ្មីៗកន្លងទៅនេះគាត់មានទំនាក់ទំនងល្អជាមួយនាយកសាលាក្នុងមូលដ្ឋាន ដែលតែងជូនដំណឹងជាប្រចាំដល់សហគមន៍ អំពីគ្រប់បញ្ហាទាំងអស់ដែលទាក់ទងទៅនឹងសាលារៀន ។ ដោយសារតែមានការគាំទ្រផ្នែកកសាងសមត្ថភាពពី GTZ និងអង្គការក្រៅរដ្ឋាភិបាលជាដៃគូក្នុងមូលដ្ឋាន ប្រធានសមាគមទ្រទ្រង់សាលារៀន និងសមាជិករបស់ SSC បានចាប់ផ្តើមដើរតួនាទីយ៉ាងសកម្មនៅក្នុងការគ្រប់គ្រងការប្រើប្រាស់ធនធាន PAP ។ ការអនុវត្តន៍នូវការសម្រេចចិត្ត និងការត្រួតពិនិត្យថវិកាតាមបែបចូលរួមពីសំណាក់ SSC បានធ្វើអោយសាលាទទួលបានធនធានបន្ថែមទៀតពី GTZ សំរាប់ធ្វើសកម្មភាពនានាដែលពាក់ព័ន្ធនឹងសាលារៀន ។ ប៉ុន្តែចាប់តាំងពីពេលដែលនាយកសាលាថ្មីមកដល់ក្នុងឆ្នាំ ២០០៦ ទាំង SSC និងសមាគមទ្រទ្រង់សាលារៀននៅក្នុងភូមិ ក៏លែងបានទទួលព័ត៌មានអំពីការប្រើប្រាស់ធនធាន PAP ដូចមុនទៀត ។ សមាជិកគណៈកម្មការ ក៏លែងត្រូវបានអញ្ជើញអោយចូលរួមក្នុងកិច្ចប្រជុំរៀបចំផែនការសាលារៀនសំរាប់ឆ្នាំសិក្សា ២០០៦-២០០៧ ដូចមុនទៀត ។ ការស្នើសុំក្រៅផ្លូវការជាបន្តបន្ទាប់ទៅកាន់នាយកសាលាថ្មីនេះ សុំអោយគាត់រៀបចំកិច្ចប្រជុំមួយនៅមិនទាន់មានការឆ្លើយតបនៅឡើយ ហើយប្រធានសមាគមទ្រទ្រង់សាលារៀន បានបាក់ទឹកចិត្តដោយសារតែមានពាក្យចចាមអារ៉ាមថាថវិកា PAP ត្រូវបានចំណាយអស់ហើយ បើទោះបីជាគ្មាននរណាម្នាក់ដឹងថាចំណាយទៅលើអ្វីក៏ដោយនោះ ។ ដោយសារតែពាក្យចចាមអារ៉ាមលេចឮថា នាយកសាលាថ្មីនេះមានទំនាក់ទំនងជិតស្និទ្ធជាមួយការិយាល័យអប់រំស្រុក គ្មាននរណាម្នាក់នៅក្នុងភូមិហ៊ានប្រឈមមុខជាមួយគាត់ដោយចំហឡើយ ។ ប៉ុន្តែ ដោយមានការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលមួយ ប្រធានសមាគមបានចាប់ផ្តើមពិភាក្សារិះរកវិធីដាក់ពាក្យបណ្តឹងទៅកាន់ការិយាល័យអប់រំស្រុក ទាមទារអោយមានតម្លាភាពអំពីការចំណាយថវិកា PAP ។ ពួកគេក៏ចង់ទាមទារអោយនាយកសាលាចេញសងថវិកាពីឆ្នាំទៅផងដែរប្រសិនបើគាត់មិនអាចផ្តល់ភស្តុតាងគ្រប់គ្រាន់ពីរបៀបចំណាយថវិកានោះទេ ។

*ប្រភព : CAS/WB, ២០០៧b*

១២៥. *គណៈកម្មការគណនេយ្យភាពថ្នាក់ខេត្ត និងប្រអប់គណនេយ្យភាព* - នៅក្នុងឆ្នាំ ២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយន្តការទទួលខុសត្រូវមួយសំរាប់អោយប្រជាពលរដ្ឋប្រើប្រាស់ដើម្បីត្រួតពិនិត្យការប្រើប្រាស់មូលនិធិក្រុមប្រឹក្សាឃុំ-សង្កាត់ ។ "ប្រអប់គណនេយ្យភាព" ត្រូវបានចែកចាយទូទាំងប្រទេស ដែលក្នុងនោះប្រជាពលរដ្ឋណាដែលមិនសប្បាយចិត្តនឹងការប្រើប្រាស់ថវិកាមិនត្រឹមត្រូវ ឬអំពីគុណភាពគំរោងណាមួយមិនល្អ អាចដាក់បណ្តឹងអនាមិកក្នុងប្រអប់នោះ ។ ប៉ុន្តែ**ការស្រាវជ្រាវនេះបានរកឃើញថា ប្រជាពលរដ្ឋមានការយល់ដឹងនិងការប្រើប្រាស់យន្តការនេះតិចតួចបំផុត**។ បើតាមការស្ទាបស្ទង់មតិសាធារណៈ អ្នកចូលរួមប្រមាណ ២២% ដឹងថាមានប្រអប់ទាំងនេះ ប៉ុន្តែមានមនុស្សតែពីរនាក់ប៉ុណ្ណោះ (០,២% នៃចូលរួមក្នុងការស្ទាបស្ទង់មតិ) ធ្លាប់បានប្រើប្រាស់ប្រអប់នេះ ហើយមានមនុស្សតែម្នាក់ប៉ុណ្ណោះដែលរាយការណ៍ថាបណ្តឹងរបស់គាត់ត្រូវបានដោះស្រាយ[៩៦] ។ ទាក់ទងនឹងគណៈកម្មការគណនេយ្យភាពថ្នាក់ខេត្ត ដែលជាគណៈកម្មការទទួលខុសត្រូវលើការប្រមូលស៊ើបអង្កេត និងដោះស្រាយបណ្តឹងដែលទទួលបាននោះ មានអ្នកចូលរួមមិនដល់ ៨% ផងបានលើកឡើងថា ធ្លាប់បានឮពីគណៈកម្មការនេះ ហើយមានតែ ៣% ប៉ុណ្ណោះដែលដឹងពីមុខងាររបស់គណៈកម្មការនេះ ។

១២៦. ការស្រាវជ្រាវបែបគុណភាពបង្ហាញថា **ប្រជាពលរដ្ឋមិនហ៊ានរិះគន់ ឬប្តឹងជំទាស់នឹងអាជ្ញាធរទេនោះ ព្រោះពួកគេខ្លាចមានការតបតវិញពីអាជ្ញាធរ** ។ អ្នកផ្តល់បទសំភាសន៍ជាច្រើននាក់បានបង្ហាញពីភាពមិនច្បាស់លាស់ថា មិនដឹងបណ្តឹងតវ៉ារបស់ពួកគេនឹងធ្លាក់ដល់ដៃនរណា និងក្នុងស្ថានភាពបែបណាទើបបណ្តឹងនោះត្រូវបានគេទទួល ។ ពួកគេក៏បង្ហាញពីកង្វះលទ្ធភាពក្នុងការបំភ្លឺ ឬបង្ហាញហេតុផលពីគោលជំហររបស់ពួកគេអំពីបណ្តឹងនោះ ។ "ប្រជាពលរដ្ឋមិនហ៊ានប្រើប្រាស់ប្រអប់គណនេយ្យភាពឡើយ ព្រោះពួកគេមិនមានអារម្មណ៍ថាមានសុវត្ថិភាពឡើយ ហើយគេមានការសង្ស័យខ្លាចមិនមានអនាមិកភាពពិតប្រាកដ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏មានប្រជាពលរដ្ឋខ្លះហ៊ាននិយាយដោយចំហអំពីបញ្ហានានាទៅកាន់អាជ្ញាធរនៅក្នុងវេទិកាសាធារណៈ" (*ប្រធានគណៈកម្មការវត្តមួយនៅខេត្តកំពង់ធំ*) ។ ដោយសារប្រពលរដ្ឋកម្ពុជាជាច្រើនលើសលប់នៅតំបន់ជនបទមិនមានបទពិសោធន៍ក្នុងការសំដែងពីសារទុក្ខរបស់ខ្លួនជាលាយល័ក្ខអក្សរ និងដោយសារមានការពាក់ព័ន្ធជាមួយនឹងភាគីទីបីដោយខានមិនបាននោះ ធ្វើអោយពួកកាន់តែបាក់ទឹកចិត្តថែមទៀតក្នុងការទាញយកប្រយោជន៍ពីប្រអប់គណនេយ្យភាពនោះ ។

១២៧. ការស្រាវជ្រាវបែបគុណភាពបានរកឃើញថា **សូម្បីតែក្នុងចំណោមអ្នកដឹកនាំអង្គការសង្គមស៊ីវិល និងបុគ្គលិករបស់អង្គការក្រៅរដ្ឋាភិបាលអាជីព ក៏មានការយល់ដឹងតិចតួចបំផុតអំពីប្រអប់គណនេយ្យភាព និងគណៈកម្មការគណនេយ្យភាពថ្នាក់ខេត្តនេះ ។** នៅគ្រប់ខេត្តទាំងអស់ដែលត្រូវបានសិក្សា ការស្រាវជ្រាវនេះបានរកឃើញថា សមាជិកគណៈកម្មការមកពីអង្គការសង្គមស៊ីវិល (ជាធម្មតាមកពីអង្គការក្រៅរដ្ឋាភិបាលអាជីព) មិនបានចែករំលែកព័ត៌មានជាមួយអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតទេ កុំថាឡើយចែករំលែកជាមួយអង្គការសង្គមស៊ីវិល ឬអង្គការសហគមន៍ជាសមាជិកនោះ ។ ការវាយតំលៃកាលពីពេលថ្មីៗមួយបានរកឃើញថា ពួកគេមិនទាំងមកចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មការផង ដោយអះអាងថាមិនមានទឹកចិត្តមកចូលរួម និងជាប់រវល់ការងារស្នូលក្នុងអង្គការរបស់ខ្លួន (Knowles, ២០០៧:២២) ។ មូលហេតុនៃកង្វះការប្តេជ្ញាចិត្តរបស់សង្គមស៊ីវិល អាចដោយសារការរសាយចិត្ត ឬការយល់ឃើញថា តួនាទីរបស់ខ្លួននៅក្នុងគណៈកម្មការមិនមានភាពប្រាកដប្រជា ។ តំណាងរបស់អង្គការសង្គមស៊ីវិលម្នាក់បានអោយដឹងថាគាត់ "អស់សង្ឃឹមដោយសារចំនួនសមាជិកមកពីភាគីផ្សេងមានចំនួនច្រើនជាង" និង "មិនមាន

---

[៩៦] បើទោះបីជាការយល់ដឹងមានភាពខុសប្លែកគ្នាច្រើនទៅតាមភេទ និងអាយុក៏ដោយ ក៏បុរស និងមនុស្សក្មេងៗយល់ដឹងច្រើនជាងស្ត្រី និងមនុស្សវ័យចំណាស់ៗ។

ការការពារ" ផង ។ មានតំណាងតែម្នាក់គត់មកពីសង្គមស៊ីវិលក្នុងចំណោមសមាជិក ចំនួន ១៣ រូប មកពីខាងរដ្ឋាភិបាល ហេតុដូច្នេះហើយគាត់ចៀសវាងមិននិយាយអ្វីដោយចំហនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការឡើយ ។ នៅក្នុងការពិភាក្សាតាមក្រុមមានការលើកឡើងថា គណៈកម្មការគណនេយ្យភាពថ្នាក់ខេត្តអាចមានប្រសិទ្ធិភាពជាងមុនបាន តាមរយៈការបង្កើនចំនួនអ្នកតំណាងមកពីសង្គមស៊ីវិលក្នុងគណៈកម្មការនេះ និងតាមរយៈការធ្វើការជាមួយអង្គការសង្គមស៊ីវិលនៅថ្នាក់សហគមន៍ ឃុំ ស្រុក និងខេត្ត បង្កើតទំនាក់ទំនងជាមួយតំណាងគណៈកម្មការមកពីសង្គមស៊ីវិលដើម្បីបានការគាំទ្រពីពួកគេ ។ ក្រៅពីនេះគណៈកម្មការគួរជូនដំណឹងដល់ប្រជាពលរដ្ឋ (និងមន្ត្រីរដ្ឋាភិបាល) អំពីគោលបំណង និងដំណើរការនៃប្រអប់គណនេយ្យភាព និងគណៈកម្មការគណនេយ្យភាពនេះ ។ គណៈកម្មការគួរសំរបសំរួល និងតាមដានពាក្យបណ្តឹង ឬសំណូមពររបស់ប្រជាពលរដ្ឋ (ជាលក្ខណៈបុគ្គល ឬជាក្រុម) ដែលបានដាក់ក្នុងប្រអប់ និងផ្ញើទៅគណៈកម្មការគណនេយ្យភាព ។ បង្កើនចំនួនប្រអប់ និងទីតាំងប្រអប់ដែលអាចអោយប្រជាពលរដ្ឋប្រើប្រាស់បានដោយស្រួល ។ ម្យ៉ាងទៀត អាណត្តិនៃប្រអប់គណនេយ្យ និងរបស់គណៈកម្មការគប្បីពង្រីកអោយគ្របដណ្តប់មិនត្រឹមតែបញ្ហាថវិកាក្រុមប្រឹក្សាឃុំ-សង្កាត់ប៉ុណ្ណោះទេ ប៉ុន្តែក៏គួរគ្របដណ្តប់បញ្ហា ឬបណ្តឹងទូទៅរបស់ប្រជាពលរដ្ឋផងដែរ ។ ចំណុចមួយទៀតដែលត្រូវកែលំអដែរគឺការណែនាំអោយប្រជាពលរដ្ឋយល់ច្បាស់ពីនីតិវិធី និងយន្តការសំរាប់ផ្តល់ព័ត៌មានត្រលប់ និងការតាមដាន ។ កត្តាទាំងនេះនឹងរួមចំណែកធ្វើអោយយន្តការនេះកាន់តែមានប្រសិទ្ធិភាពឡើង ។ អង្គការសង្គមស៊ីវិលក៏គួរពិចារណាប្រើប្រាស់ប្រអប់គណនេយ្យភាពជាយន្តការដើម្បីបញ្ជូនបណ្តឹងជាក្រុម ការធ្វើញត្តិ ឬធ្វើសំណើជាសមូហភាពមកកាន់អាជ្ញាធរខេត្តដែរ ។

១២៨. *ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក* - ស្រដៀងគ្នានេះដែរ **ការយល់ដឹងអំពីសេវានៃការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក និងការប្រើប្រាស់សេវានេះ (ដែលមានទីតាំងនៅក្នុងការិយាល័យច្រកចេញចូលតែមួយក្នុងស្រុកសាកល្បងពីរ) ក៏ត្រូវបានរកឃើញថានៅមានកំរិតតិចតួចបំផុតដែរ** ទាំងក្នុងចំណោមប្រជាពលរដ្ឋ អ្នកដឹកនាំ សមាជិក និងបុគ្គលិកអង្គការសង្គមស៊ីវិល ។ ឧទាហរណ៍ បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលនៅខេត្តសៀមរាបមិនដឹងនិងមិនចាប់អារម្មណ៍ពីតួនាទីរបស់ការិយាល័យប្រជាពលរដ្ឋនោះឡើយ ។ ដូចដែលបានពិភាក្សាខាងលើរួចហើយ តួអង្គនានាក្នុងសង្គមស៊ីវិលច្រើនតែមានការសង្ស័យពីគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល និងមិនសូវជឿជាក់ថាគំនិតផ្តួចផ្តើមទាំងនោះនឹងនាំមកនូវផលប្រយោជន៍ពិតប្រាកដដល់ប្រជាពលរដ្ឋសាមញ្ញឡើយ ។ ប្រជាពលរដ្ឋដែលបានប្រើប្រាស់សេវានៅការិយាល័យច្រកចេញចូលតែមួយនៅខេត្តសៀមរាប បានសំដែងនូវការពេញចិត្តចំពោះសេវានេះ ដោយសារសេវាកម្មទាំងនោះលឿន និងអស់ថ្លៃតិច ប៉ុន្តែពួកគេមិនសូវដឹងច្រើនពីវត្តមាននៃការិយាល័យប្រជាពលរដ្ឋទេ ។ ប្រធានការិយាល័យប្រជាពលរដ្ឋក្នុងខេត្តសៀមរាបបានពន្យល់ថា មានប្រជាពលរដ្ឋមួយចំនួនតូចប៉ុណ្ណោះ ដែលប្រើប្រាស់សេវារបស់គាត់ ហើយបណ្តឹងតវ៉ារបស់ពួកគេគឺជារឿងតូចតាចប៉ុណ្ណោះ (ដូចជាការមិនពេញចិត្តនឹងការរង់ចាំយូរ ឬឥរិយាបថមិនរាក់ទាក់ ឬភាពក្រអឺតក្រទមរបស់បុគ្គលិកការិយាល័យច្រកចេញចូលតែមួយនោះ)។ ពុំធ្លាប់មានបណ្តឹងតវ៉ាអំពីភាពអយុត្តិធម៌ ឬពីអំពើពុករលួយឡើយ ។ លោកបានមានប្រសាសន៍ថា ហេតុផលមួយដែលនាំអោយមានការប្រើប្រាស់សេវាពីការិយាល័យគាត់តិចតួច គឺដោយសារតែការិយាល័យនោះមានទីតាំងនៅក្នុងការិយាល័យច្រកចេញចូលតែមួយតែម្តង ដែលនេះធ្វើអោយប្រជាពលរដ្ឋគិតថា គាត់គឺជាផ្នែកមួយរបស់អាជ្ញាធរមូលដ្ឋាន ជាជាងជាអ្នកឃ្លាំមើលដោយឯករាជ្យ[៤៧] ។ ដោយសាររដ្ឋាភិបាលកំពុង

[៤៧] នាពេលបច្ចុប្បន្ននេះ ស្រុកនេះកំពុងពិចារណាបែងចែកការិយាល័យប្រជាពលរដ្ឋ អោយនៅដាច់ឆ្ងាយពីការិយាល័យច្រកចេញចូលតែមួយ ។

ចាប់ផ្តើមបង្កើតការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុកនៅតាមស្រុកជាច្រើនបន្ថែមទៀតនោះ វាគឺជាប្រការសំខាន់ណាស់ដែលត្រូវរៀនសូត្រពីបទពិសោធន៍ក្នុងស្រុកសាកល្បងបច្ចុប្បន្ននេះ រួចហើយលើកកំពស់ប្រសិទ្ធិភាពនៃអង្គភាពអន្តរការីរវាងប្រជាពលរដ្ឋ និងរដ្ឋដ៏មានសក្តានុពលនេះ ហើយកិច្ចការនេះអាចធ្វើបានតាមរយៈការខិតខំប្រឹងប្រែងផ្សព្វផ្សាយអោយប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលបានយល់អំពីតួនាទីរបស់ការិយាល័យប្រជាពលរដ្ឋស្រុក និងរបៀបប្រើប្រាស់ការិយាល័យនេះ ដោយធានាថាការិយាល័យប្រជាពលរដ្ឋនឹងទទួលបានធនធាន និងការគាំទ្រដែលចាំបាច់សំរាប់គេផ្តល់សេវាដែលមានគុណភាព ។ កិច្ចការមួយទៀតគឺស្វះស្វែងរកលទ្ធភាពផ្សារភ្ជាប់ការងាររបស់ទីប្រឹក្សាប្រជាពលរដ្ឋ ជាមួយនឹងការងាររបស់ការិយាល័យប្រជាពលរដ្ឋ ។

## ២.ឃ.៤. ការពង្រីកឱកាស និងយន្តការសំរាប់ការពិភាក្សា និងការចូលរួម

១២៩. ក្រៅពីឧទាហរណ៍អំពីយន្តការផ្លូវការសំរាប់ការទទួលខុសត្រូវមួយចំនួនតូចនេះ (ហើយដែលមិនសូវបានយកមកប្រើប្រាស់) ការស្រាវជ្រាវនេះបានរកឃើញនូវ**សញ្ញាណ ឬឧទាហរណ៍ខ្លះអំពីឱកាស ឬយន្តការផ្សេងទៀតដែលអាចអោយប្រជាពលរដ្ឋប្រាស្រ័យទាក់ទង និងចូលរួមប្រកបដោយអត្ថន័យជាមួយនឹងអាជ្ញាធររដ្ឋាភិបាល** ។ ការពិភាក្សាតាមក្រុម និងការសំភាសន៍នៅមូលដ្ឋានបានរកឃើញថា អ្នកភូមិចូលចិត្តការប្រាស្រ័យទាក់ទងទល់មុខគ្នា (ដោយពាក្យសំដីផ្ទាល់) ព្រោះពួកគេអាចស្តាប់ស្ទង់ និងធ្វើអោយមានឥទ្ធិពលលើការពិភាក្សាបាន ហើយអាចបំភ្លឺ កែសំរួល ឬដកខ្លួនថយពីជំហររបស់គេ អាស្រ័យលើថាតើគោលជំហររបស់ពួកគេត្រូវបានគេទទួលឬយ៉ាងណា ។ ការប្រាស្រ័យទាក់ទងដោយផ្ទាល់ និងដោយផ្ទាល់មាត់បែបនេះជាមធ្យោបាយប្រសើរជាងការដាក់បណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្នុងប្រអប់គណនេយ្យភាព ព្រោះពួកគេមិនដឹងច្បាស់ថាតើអ្នកណាជាអ្នកទទួលពាក្យបណ្តឹងរបស់គេ ហើយទទួលដោយរបៀបណា ពួកគេគ្មានលទ្ធភាពផ្តល់ការបំភ្លឺ ឬផ្តល់ហេតុផលបន្ថែមឡើយ ។ មានបទពិសោធន៍ល្អៗខ្លះពីវេទិកាសាធារណៈនៅថ្នាក់សហគមន៍ ដូចជាវេទិកាដែលគាំទ្រដោយ NDI ក្នុងអំឡុងពេលបោះឆ្នោតឃុំ-សង្កាត់ ដែលក្នុងពេលនោះបានទាក់ទាញមនុស្សជាច្រើន ហើយគេបានចូលរួមយ៉ាងសកម្ម ។ ជាអកុសល គំនិតផ្តួចផ្តើមបែបនេះកំរនឹងមានរៀបចំណាស់ ហើយបើមាន ក៏មានតែនៅថ្នាក់ជាតិ ឬខេត្ត ជាជាងនៅថ្នាក់ស្រុក ឬឃុំដែលមានប្រជាពលរដ្ឋសាមញ្ញចូលរួមច្រើននោះ ។ យន្តការផ្សេងទៀតដែលមានលក្ខណៈចូលរួម ស៊ីជំរៅ និងផ្តោតការយកចិត្តទុកដាក់សំរាប់ក្រុមជាក់លាក់ណាមួយនោះ (ដូចជាការរៀបចំផែនការ ឬការរៀបចំថវិកាបែបចូលរួម គណៈវិនិច្ឆ័យរបស់ប្រជាពលរដ្ឋ សវនកម្មសង្គម ឬប័ណ្ណដាក់ពិន្ទុដោយសហគមន៍) ក៏មិនសូវមានការយកមកអនុវត្តដែរ ។ វេទិកាដែលមានប្រសិទ្ធិភាពសំរាប់ជំរុញអោយមានការពិភាក្សាគ្នាទៀងទាត់ និងជាលក្ខណៈប្រព័ន្ធរវាងអង្គការសង្គមស៊ីវិល និងតួអង្គនានាក្នុងជួររដ្ឋាភិបាលនោះ ក៏មិនសូវមានការរៀបចំដែរ ជាពិសេសនៅថ្នាក់ខេត្ត ។ ទាំងនៅខេត្តកំពង់ចាម និងខេត្តកំពង់ធំ ការប៉ុនប៉ងរៀបចំអោយមានការផ្លាស់ប្តូរព័ត៌មានប្រចាំខែរវាងអង្គការសង្គមស៊ីវិលនិងអភិបាលខេត្តកាន់តែស្ងប់ស្ងាត់បន្តិចម្តងៗ ហើយជាចុងក្រោយគឺលែងមានតែម្តង ។ យោងតាមការសំភាសន៍ "ការសំណេះសំណាល" បែបនេះត្រូវបានគេយល់ឃើញថាជាការជួបសំដែងការគួរសមប៉ុណ្ណោះ និងមិនមែនជាវេទិកាដើម្បីផ្លាស់ប្តូរព័ត៌មាន និង "ចរចារ" ប្រកបដោយអត្ថន័យឡើយ ។ នៅពេលដែលគ្មានកិច្ចពិភាក្សាប្រកបដោយអត្ថន័យជាប្រចាំនោះ ការប្រាស្រ័យទាក់ទងគ្នាម្តងម្កាលណាមួយនោះច្រើនតែធ្វើឡើងសំរាប់តែដោះស្រាយវិវាទ និងបញ្ហាដែលកើតឡើងយូរម្តងតែប៉ុណ្ណោះ ។

១៣០. នៅថ្នាក់ជាតិ មានការរៀបចំវេទិកាជាច្រើនដើម្បីពិភាក្សាពីគោលនយោបាយជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ដែលក្នុងនោះមានការចូលរួមរបស់អ្នកតំណាងមកពីបណ្តាញអង្គការក្រៅរដ្ឋាភិបាល (ដូចជា MediCam, NEP ឬ NGO Forum) ។ **កិច្ចប្រជុំ និងការពិគ្រោះយោបល់រវាងក្រសួង ម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល កើតមានកាន់តែច្រើនឡើងៗ ហើយក្នុងឱកាសនោះរដ្ឋាភិបាលធ្វើការបង្ហាញពីគោលបំណងនៃគោលនយោបាយ ពន្យល់ពីការសំរេចចិត្តរបស់ខ្លួនជាសាធារណៈ បង្ហាញនូវព័ត៌មានពាក់ព័ន្ធ និងកត់ត្រានូវក្តីព្រួយបារម្ភទាំងឡាយដែលអង្គការក្រៅរដ្ឋាភិបាល និង/ឬតួអង្គដទៃទៀតនៅក្នុងវិស័យឯកជនបានលើកឡើង ។** វេទិកាទាំងនេះបានបើកចំហនូវឱកាសបន្តិចម្តងៗ (យ៉ាងហោចណាស់នៅថ្នាក់ជាតិ) ដើម្បីអោយសង្គមស៊ីវិលបានចូលរួមក្នុងការពិភាក្សា និងការសំរេចចិត្ត ហើយបានផ្តល់ជាឱកាសសំរាប់ការពិភាក្សាគ្នាប្រកបដោយលក្ខណៈស្ថាបនាផងដែរ ។ តែទោះជាយ៉ាងណាក៏ដោយ ស្ថាប័នមិនមែនរដ្ឋមួយចំនួនដែលចូលរួមក្នុងវេទិកាទាំងនេះមានការសោកស្តាយ ដោយសារគ្មានការតាមដាននូវលទ្ធផលនៃវេទិកាទាំងនោះ ។ ឧទាហរណ៍ អ្នកចូលរួមនៅក្នុងវេទិការដ្ឋាភិបាលជាមួយវិស័យឯកជន ដែលធ្វើឡើងពីរដងក្នុងមួយឆ្នាំបានអោយដឹងថា រដ្ឋាភិបាល "ទទួលយក" នូវអនុសាសន៍ដែលស្នើឡើងនៅក្នុងកិច្ចប្រជុំ ប៉ុន្តែខកខានមិនបានអនុវត្តតាមអនុសាសន៍ទាំងនោះទេ ។ ប្រការដែលល្អគឺគប្បីមានលក្ខខ័ណ្ឌច្បាស់លាស់សំរាប់ការចូលរួមក្នុងព្រឹត្តិការណ៍បែបនេះ ដើម្បីការធានាថា រាល់ការព្រមព្រៀងគ្នាចំបងៗដែលជាលទ្ធផលពីវេទិកានោះនឹងត្រូវផ្សព្វផ្សាយជាសាធារណៈក្នុង "ប្រកាស" ផ្លូវការដើម្បីអោយមានការយកទៅអនុវត្តជាក់ស្តែង ។ ដូច្នេះការមានប្រព័ន្ធច្បាស់លាស់សំរាប់ឃ្លាំមើលការអនុវត្តន៍ គឺមានប្រយោជន៍ណាស់ ។ ការដែលសង្គមស៊ីវិលមានការចូលរួមក្នុងការពិគ្រោះយោបល់ និងការពិភាក្សាថ្នាក់ខ្ពស់ៗកាន់តែច្រើនឡើងៗនោះ មានន័យថាសង្គមស៊ីវិលក៏ត្រូវមានសមត្ថភាពខ្ពស់ និងចំណេះដឹងច្បាស់លាស់អំពីបញ្ហាអភិបាលកិច្ច រួមទាំងនីតិវិធីរដ្ឋបាល ច្បាប់ និងតុលាការផងដែរ ។ ប៉ុន្តែចំណុចនេះនៅតែជាបញ្ហាប្រឈមនៅឡើយសំរាប់អង្គការក្រៅរដ្ឋាភិបាលជាច្រើន ដែលហេតុដូច្នេះហើយពួកគេចាំបាច់ត្រូវបន្តរៀនសូត្រ និងកសាងសមត្ថភាពរបស់ខ្លួនជាប្រចាំដើម្បីអោយការចូលរួម និងការពិភាក្សាទទួលបានផ្លែផ្កាល្អ ។

## ២.ឃ.៥. អនុសាសន៍ និងសកម្មភាពដែលគួរអនុវត្ត

១៣១. ការស្រាវជ្រាវនេះបានរកឃើញថា ការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា និងការចូលរួមរបស់ប្រជាពលរដ្ឋប្រកបដោយអត្ថន័យនោះគឺនៅមានកំរិតតិចតួចនៅឡើយ ក៏ប៉ុន្តែក៏បានរកឃើញផងដែរថាមានឱកាសល្អៗជាច្រើនសំរាប់អភិវឌ្ឍនូវរូបភាពនៃការចូលរួមបែបនេះ ។ ការចូលរួមប្រកបដោយលក្ខណៈស្ថាបនាតំរូវអោយមាននូវបរិយាកាសគោលនយោបាយអំណោយផល (ផ្អែកលើការយល់ដឹងរួមអំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិល) ឆន្ទៈរបស់រដ្ឋាភិបាល និងសង្គមស៊ីវិលក្នុងការប្រាស្រ័យទាក់ទងគ្នាប្រកបដោយលក្ខណៈស្ថាបនា វត្តមាននៃយន្តការសំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋ និងសំរាប់ការទទួលខុសត្រូវ ព្រមទាំងសមត្ថភាព និងជំនាញសំរាប់ប្រើប្រាស់យន្តការទាំងនេះប្រកបដោយប្រសិទ្ធិភាព ។ ការស្រាវជ្រាវនេះបានរកឃើញនូវបញ្ហាប្រឈមផង និងឱកាសផងទាក់ទងទៅនឹងកត្តានីមួយៗទាំងនេះ ។

១៣២. អនុសាសន៍ចំនួនបីត្រូវបានស្នើឡើង ។ អនុសាសន៍ទី១ (សំរាប់តួអង្គនានាក្នុងជួររដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍) គឺ (១) **បង្កើត និងគាំទ្រអោយមាននូវបរិយាកាសគោលនយោបាយអំណោយផលមួយសំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល និងសំរាប់ការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា** ផ្អែកលើការយល់ដឹងរួមនិងច្បាស់លាស់អំពីសិទ្ធិ និងករណីយកិច្ច

របស់ភាគីនីមួយៗ ។ អនុសាសន៍ទី២ (សំរាប់អង្គការសង្គមស៊ីវិល និងម្ចាស់ជំនួយ ហើយជាប្រការល្អគឺគួរមានការគាំទ្រពីរដ្ឋាភិបាលផងដែរ) គឺ (២) **លើកកំពស់ និងគាំទ្រការប្រើប្រាស់នូវឧបករណ៍សំរាប់សំរបសំរួល និងការទទួលខុសត្រូវសង្គម ដើម្បីធ្វើអោយយន្តការសំរាប់ការពិភាក្សា និងការចូលរួមដែលមានស្រាប់ (ដូចជាកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណៈកម្មការទ្រទ្រង់សាលារៀន) កាន់តែមានប្រសិទ្ធិភាព** ។ អនុសាសន៍ទី៣គឺ (៣) **បង្កើតឱកាសនិងយន្តការថ្មីៗសំរាប់ការពិភាក្សា និង "ការចរចារ" ដោយផ្ទាល់ និងទៀងទាត់ រវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល (នៅគ្រប់កំរិតថ្នាក់)** ។

១៣៣. *<u>អនុសាសន៍ ឃ.១</u> - បង្កើត និងគាំទ្រអោយមាននូវបរិយាកាសគោលនយោបាយអំណោយផលមួយសំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល និងសំរាប់ការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា (សកម្មភាពតំរូវទៅខាងរាជរដ្ឋាភិបាល ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល និងការគាំទ្រពីដៃគូអភិវឌ្ឍន៍)* ។

ក) បង្កលក្ខណៈអោយតួអង្គសំខាន់ៗពីខាងរដ្ឋាភិបាល និងសង្គមស៊ីវិលបានជួបគ្នាដើម្បីស្វែងរកកុងសង់ស៊ីស (ការឯកភាពគ្នា) ទៅលើគោលការណ៍សំខាន់ៗនៃការទទួលខុសត្រូវសង្គម និងសិទ្ធិ ព្រមទាំងករណីយកិច្ចរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិលនិងតួអង្គនានាក្នុងរដ្ឋាភិបាល ។ ដំណើរការនេះគប្បីរៀបចំឡើង និងសំរបសំរួលដោយអន្តរការីមួយដែល "អព្យាក្រឹត" និងត្រូវបានគេទុកចិត្ត ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ។

ខ) ផ្អែកលើមូលដ្ឋាននៃគោលការណ៍ដែលបានឯកភាពនេះ បង្កើតក្រុមការងារពិសេសមួយ ដែលសមាសភាពរួមមាន "អ្នកមានស្នាដៃល្អ" ផ្នែកការទទួលខុសត្រូវសង្គម (មកពីខាងរដ្ឋាភិបាលនិងសង្គមស៊ីវិល) ដើម្បីលើកសំណើ និងអនុវត្តការកែទំរង់គោលនយោបាយ និងវិធានរបស់ស្ថាប័ន ក្នុងបំណងលើកកំពស់លទ្ធភាពទទួលបានព័តិមាន ការសំដែងមតិ ការរួបរួមជាសមាគម ការពិភាក្សាប្រកបដោយលក្ខណៈស្ថាបនា និងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការអភិបាលកិច្ច ។

គ) វិះរក និងបង្កើតយន្តការនានាសំរាប់ដោះស្រាយបញ្ហា ឬការតូញត្អែរ ឬការមិនឯកភាពធំៗណាមួយដែលតួអង្គនានាក្នុងសង្គមស៊ីវិលបានលើកឡើង ។ ឧទាហរណ៍ : គប្បីបង្កើតនូវការិយាល័យទំនាក់ទំនងរបស់អង្គការក្រៅរដ្ឋាភិបាលមួយនៅថ្នាក់ជាតិ ។ ឯនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាស្រុកនិងក្រុមប្រឹក្សាខេត្ត ដែលនឹងត្រូវបង្កើតឡើងក្នុងពេលឆាប់ៗស្របតាមច្បាប់អង្គការថ្មីនោះ គប្បីជាអ្នកទទួលភារកិច្ចនេះ ។

១៣៤. *<u>អនុសាសន៍ ឃ.២</u> - លើកកំពស់ និងគាំទ្រការប្រើប្រាស់នូវឧបករណ៍សំរាប់សំរបសំរួល និងការទទួលខុសត្រូវសង្គម ដើម្បីធ្វើអោយយន្តការសំរាប់ការពិភាក្សា និងការចូលរួមដែលមានស្រាប់ (ដូចជាកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណៈកម្មការទ្រទ្រង់សាលារៀន)កាន់តែមានប្រសិទ្ធិភាព។*

ក) លើកទឹកចិត្ត និងគាំទ្រអង្គការសហគមន៍ អង្គការសង្គមស៊ីវិល អោយបង្កើតឡើងនូវតួនាទីជា "ស្ពាន" ក្នុងនាមជាអ្នកសំរបសំរួល ឬអន្តរការីរវាងប្រជាពលរដ្ឋនិងអាជ្ញាធរ ដូចជាតាមរយៈការផ្តល់ការបណ្តុះបណ្តាល និងបង្រៀនប្រធានសហគមន៍ និងសង្គមស៊ីវិលនូវបច្ចេកទេសសំរបសំរួល និងការផ្សះផ្សារជាមូលដ្ឋាន ។

ខ) ផ្តល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពផ្នែកវិធីសាស្ត្រ និងឧបករណ៍នៃការទទួលខុសត្រូវសង្គម ។ បង្កើតនូវឱកាសដើម្បីអោយប្រតិបត្តិករនិងសកម្មជនបានរៀនសូត្រ កែសំរួល និងដកពិសោធន៍អនុវត្តនូវបណ្តាយុទ្ធសាស្ត្រនានានៃការទទួល

ខុសត្រូវសង្គម ដែលធ្លាប់ត្រូវបានសាកល្បង ដកពិសោធន៍ និងទទួលបានជោគជ័យទាំងនៅកម្ពុជានិងនៅបណ្តាប្រទេសដទៃក្នុងតំបន់អាស៊ី និងក្នុងសាកលលោក ជាពិសេសយុទ្ធសាស្ត្រទាំងឡាយណាដែលយកភស្តុតាងជាមូលដ្ឋាន ផ្តោតលើដំណោះស្រាយ (ជាជាងសំលឹងតែលើបញ្ហា) ។ ការអនុវត្តន៍សាកល្បងនេះគប្បីធ្វើឡើងដោយផ្អែកលើការពិភាក្សា ឬការប្រាស្រ័យទាក់ទងផ្ទាល់ និងដែលមានបំណងកសាងទំនុកចិត្តរវាងតួអង្គក្នុងរដ្ឋាភិបាល និងសង្គមស៊ីវិល ។ ម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិអាចរួមចំណែកដោយចែករំលែកនូវបទពិសោធន៍ដែលទទួលបានជោគជ័យពីប្រទេសផ្សេងៗទៀត [៤៨] ។ ការចែករំលែកនូវភស្តុតាងនៃជោគជ័យ និងអត្ថប្រយោជន៍នៃយុទ្ធសាស្ត្រទាំងនោះជាមួយប្រតិបត្តិករនៅក្នុងជួររដ្ឋាភិបាល ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀត គឺជារឿងសំខាន់ណាស់ ហើយគួរសង្កត់ធ្ងន់ទៅលើគុណសម្បត្តិជាក់ស្តែងនៃវិធីសាស្ត្រទាំងនោះ (ផ្នែកផ្តល់សេវា និងសុខុមាលភាព) ក៏ដូចជាគុណសម្បត្តិផ្នែកនយោបាយសំរាប់រដ្ឋាភិបាល (ដូចជាកំណើនជំនឿទុកចិត្ត និងប្រជាប្រិយភាពពីសាធារណៈជាដើម) ។

គ) ធ្វើអោយក្រុមប្រឹក្សាឃុំ-សង្កាត់ក្លាយជាវេទិកាដែលកាន់តែមានប្រសិទ្ធិភាពសំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋ ដោយការប្រើប្រាស់អ្នកសំរបសំរួលដែលជាភាគីទីបី ។ លើកទឹកចិត្ត និងគាំទ្រអោយប្រជាពលរដ្ឋចូលរួមក្នុងការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ជាមួយនឹងការត្រៀមខ្លួនបានល្អសំរាប់ការចូលរួមបែបនេះ (ដូចជាការជួបជុំគ្នាមុនពេលចូលប្រជុំ) និងប្រើប្រាស់ឧបករណ៍ និងបច្ចេកទេសនៃការទទួលខុសត្រូវសង្គម (ដូចជាការវាយតំលៃតាមបែបចូលរួមលើសេវាសាធារណៈ និងប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ ។ល។) ។ ការចាត់ចែងផ្សេងៗទៀតក៏ជាប្រការជួយលើកកំពស់ប្រសិទ្ធិភាពនៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ផងដែរ ក្នុងនោះមានដូចជាការផ្សព្វផ្សាយជាសាធារណៈនូវរបៀបវារៈប្រជុំអោយប្រជាពលរដ្ឋបានដឹង ការគោរពពេលវេលាដែលបានកំណត់ ការផ្លាស់ប្តូរទីកន្លែង (និងប្រធានបទ) នៃកិច្ចប្រជុំ ការលើកទឹកចិត្ត (និងផ្តល់ពេលវេលាសមស្រប) សំរាប់ការចូលរួមយោបល់របស់ប្រជាពលរដ្ឋ ការជ្រើសរើសទីកន្លែង និងពេលវេលាដែលសមស្របសំរាប់ប្រជាពលរដ្ឋចូលរួម និងការយកចិត្តទុកដាក់ទៅលើការរៀបចំកន្លែងអង្គុយដែល "ងាយស្រួលសំរាប់ចូលរួម" ។

ឃ) រិះរកវិធីធ្វើអោយគណៈកម្មការទ្រទ្រង់សាលារៀន (SSCs) ដែលមានស្រាប់ ក្លាយជាយន្តការដែលកាន់តែមានប្រសិទ្ធិភាពផ្នែកការទទួលខុសត្រូវសង្គម ដូចជាតាមរយៈការផ្តល់ការបណ្តុះបណ្តាល (និងការតាមដាន) ដល់សមាជិកសំខាន់ៗរបស់ SSCs ផ្នែកការសំរបសំរួល និងបច្ចេកទេសនៃការទទួលខុសត្រូវសង្គម ។ គាំទ្រកិច្ចខិតខំរបស់ SSCs ក្នុងការប្រើប្រាស់វិធីសាស្ត្រទទួលខុសត្រូវសង្គម (ដូចជា "ប័ណ្ណដាក់ពិន្ទុសាលារៀន" និងបច្ចេកទេសឃ្លាំមើលការចំណាយថវិកា) ព្រមទាំងរៀបចំវេទិកាសាធារណៈប្រចាំឆ្នាំ (ឬពីរដងក្នុងមួយឆ្នាំ) ដើម្បីបង្ហាញ និងពិភាក្សាអំពីថវិការបស់សាលារៀន *(សកម្មភាពតំរូវទៅខាងក្រសួងអប់រំ យុវជន និងកីឡា អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ដែលផ្តល់ជំនួយដល់SSCs)* ។

១៣៥. *<u>អនុសាសន៍ ឃ.៣</u>- បង្កើតឱកាសនិងយន្តការថ្មីៗសំរាប់ការពិភាក្សានិង "ការចរចារ" ដោយផ្ទាល់និងទៀងទាត់រវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល (នៅគ្រប់កំរិតថ្នាក់)*

[៤៨] ឧទាហរណ៍ នេះគឺជាគោលបំណងនៃ កម្មវិធីពង្រឹងសមត្ថភាពដើម្បីការទទួលខុសត្រូវសង្គម របស់ធនាគារពិភពលោក ហើយក៏ជាគោលបំណងរបស់សង្គមស៊ីវិល និងកម្មវិធីទីផ្សារដើម្បីកាត់បន្ថយភាពក្រីក្រ ដែលផ្តល់មូលនិធិដោយ DFID/DANIDA ដែរ ។

ក) លើកទឹកចិត្ត (ឬផ្តល់ការណែនាំ) ក្រុមប្រឹក្សាឃុំ-សង្កាត់អោយរៀបចំវេទិកាសាធារណៈអោយបានទៀងទាត់ ដែលក្នុងនោះប្រជាពលរដ្ឋមានឱកាសជួប បានសួរសំណួរ និងទទួលការឆ្លើយតបដោយផ្ទាល់ពីអ្នកតំណាងរបស់រដ្ឋាភិបាល (ដូចជាក្រុមប្រឹក្សាឃុំ-សង្កាត់ អ្នកគ្រប់គ្រងនិងបុគ្គលិកផ្នែកផ្តល់សេវាសាធារណៈ អភិបាលខេត្ត សមាជិកសភា និងអ្នកតំណាងរដ្ឋាភិបាលថ្នាក់ជាតិ) ។ មានការផ្តល់ជាអនុសាសន៍ថា ក្រុមប្រឹក្សាឃុំ-សង្កាត់គប្បីទទួលបានថវិកាដោយឡែកសំរាប់រៀបចំវេទិកាបែបនេះ និងសំរាប់កសាងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ដើម្បីគេអាចសំរបសំរួលវេទិកាទាំងនេះ ។ ការធ្វើបែបនេះគឺដើម្បីគេអាចឆ្លើយតបទៅនឹងការព្រួយបារម្ភ ការសាកសួររបស់ប្រជាពលរដ្ឋ និងការបញ្ជូន ឬណែនាំអោយប្រជាពលរដ្ឋបានស្គាល់ក្រុមប្រឹក្សាស្រុក និងខេត្ត (ដែលបង្កើតឡើងថ្មីៗ) នេះផងដែរ ។ វេទិកានីមួយៗអាចផ្តោតទៅលើបញ្ហាជាអាទិភាពជាក់លាក់ដែលជាក្តីបារម្ភរបស់ប្រជាពលរដ្ឋ (ដូចជាសុខភាព ការអប់រំ ការកាត់បន្ថយភាព ក្រីក្រ កសិកម្ម ដីធ្លី ព្រៃឈើ ជលផល ទឹក និងឧស្សាហកម្មនិស្សរណកម្ម) ឬផ្តោតលើក្រុមសង្គមជាក់លាក់ណាមួយ (ដូចជា ក្រុមស្ត្រី យុវជន កសិករ ជនពិការ...។ល។) ។ ប្រការដែលល្អ ទីកន្លែងសំរាប់រៀបចំព្រឹត្តិការណ៍ទាំងនេះគួរផ្លាស់ប្តូរពីភូមិមួយទៅភូមិមួយទៀត ហើយអង្គការសហគមន៍ និងអង្គការសង្គមស៊ីវិលគួរចូលរួមក្នុងការរៀបចំ សំរបសំរួល និងតាមដាន។ ក្រុមប្រឹក្សាឃុំ-សង្កាត់ គប្បីទទួលបានការលើកទឹកចិត្តឬគាំទ្រផងដែរ ដើម្បីគេអាចដកពិសោធន៍យន្តការនានា ដូចជាការបោះឆ្នោតប្រជាមតិ ការស្ទាបស្ទង់មតិ សវនាការសាធារណៈ គណៈវិនិច្ឆ័យរបស់ប្រជាពលរដ្ឋ ដើម្បីរកអោយឃើញនូវមតិយោបល់សេចក្តីត្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ *(សកម្មភាពតំរូវទៅខាងរដ្ឋាភិបាល ដោយមានកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល)* ។

ខ) រិះរក និងបង្កើតតួនាទីរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការធ្វើជាតំណាងអោយប្រជាពលរដ្ឋ និងពាំនាំក្តីបារម្ភរបស់ប្រជាពលរដ្ឋទៅជំរាបរដ្ឋាភិបាលថ្នាក់កណ្តាល និងជំរុញអោយរដ្ឋាភិបាលថ្នាក់កណ្តាលមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ ។ មានការផ្តល់អនុសាសន៍អោយមានការប្រើប្រាស់នូវយន្តការនានាដើម្បីអោយក្រុមប្រឹក្សាឃុំ-សង្កាត់ បង្ហាញនូវការពេញចិត្ត ឬមិនពេញចិត្តចំពោះសេវាសាធារណៈ ទៅមន្ទីរខេត្តដែលពាក់ព័ន្ធ និងដើម្បីអោយក្រសួងពាក់ព័ន្ធពិនិត្យពិច័យ និងបញ្ចូលនូវយោបល់របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ (និងអង្គការសហគមន៍ និងអង្គការសង្គមស៊ីវិល) ទៅក្នុងដំណើរការត្រួតពិនិត្យ និងវាយតំលៃរបស់ខ្លួន ។ បុគ្គលិកបំរើការនៅការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក (ដែលការិយាល័យបែបនេះនឹងមានចំនួនកាន់តែច្រើនឡើងនាពេលដ៏ខ្លីខាងមុខ) អាចជាជំនួយដ៏សំខាន់ក្នុងការសំរបសំរួលការងារនេះ *(សកម្មភាពតំរូវទៅខាងក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាឃុំ-សង្កាត់ អង្គការសង្គមស៊ីវិល ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក ដៃគូអភិវឌ្ឍន៍ អង្គការដែលគាំទ្រអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត)* ។

គ) ស្វែងរកលទ្ធភាពដើម្បីណែនាំអោយប្រើប្រាស់យន្តការដែលមានលក្ខណៈស្ថាប័ន សំរាប់ការចូលរួមយោបល់របស់ប្រជាពលរដ្ឋ ការឃ្លាំមើល និងការចរចារនៅក្នុងវិស័យនានាដែលជាប្រយោជន៍របស់សាធារណៈ ។ ឧទាហរណ៍ : ក្រុមប្រឹក្សាស្រុក និងខេត្តដែលបង្កើតឡើងក្នុងក្របខ័ណ្ឌច្បាប់អង្គការនោះ គួរមានមុខងារចាត់ចែងការចូលរួមយោបល់ និងការឃ្លាំមើលរបស់ប្រជាពលរដ្ឋ ។ អង្គការសង្គមស៊ីវិលគួរជួយបើកចំហនូវឱកាសសំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋអោយពេញលក្ខណៈនៅក្នុងក្រុមប្រឹក្សាដែលបង្កើតឡើងថ្មីៗនេះ តាមរយៈការស្នើឡើងនូវបញ្ញត្តិសមស្របសំរាប់បញ្ចូលទៅក្នុងច្បាប់នោះ ។ វេទិកាសាធារណៈប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាទាំងនេះក៏គួរពង្រឹងផងដែរនូវទំនាក់ទំនងរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ និងធានាថាអាជ្ញាធរកាន់តែមានការយល់ដឹងច្រើនអំពីតំរូវការ និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ ។ នៅឯថ្នាក់ជាតិ ក្រសួងសំខាន់ៗ

គួរបង្កើតនូវក្រុមប្រឹក្សាភិបាលមួយ (ដោយមានអ្នកតំណាងមកពីសង្គមស៊ីវិល និងវិស័យឯកជនជាសមាជិក) និងធានាអោយមានការពិគ្រោះយោបល់ជាលក្ខណៈប្រព័ន្ធទៅលើច្បាប់ ឬគោលនយោបាយចំបងៗ ។ សំខាន់ជាងនេះទៀត គប្បីប្រើប្រាស់យន្តការនានាដើម្បីធានាអោយមានការឃ្លាំមើលការគ្រប់គ្រងចំណូលសាធារណៈពីឧស្សាហកម្មនិស្សរណកម្ម (ដូចជាប្រេង ឧស្ម័ន និង រ៉ែ) ដោយចំហ និងប្រកបដោយប្រសិទ្ធិភាព ។ (*សកម្មភាពតំរូវទៅខាងរាជរដ្ឋាភិបាល*) ។

យ) ដើម្បីកសាងជំនឿទុកចិត្ត និងភាពកក់ក្តៅពីគ្នាទៅវិញទៅមក គប្បីបង្កើតអោយមានឱកាសបន្ថែមទៀត សំរាប់ការជួបគ្នាផ្ទាល់មុខរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ទាំងក្នុងបរិយាកាសផ្លូវការនិងមិនផ្លូវការ ។ រៀបចំអោយតួអង្គនានាក្នុងរដ្ឋាភិបាលបានចុះទស្សនកិច្ចស្វែងយល់ពីសកម្មភាព និងស្នាដៃរបស់អង្គការក្រៅរដ្ឋាភិបាលនៅតាមមូលដ្ឋាន អញ្ជើញអ្នកតំណាងរបស់សង្គមស៊ីវិល និងរដ្ឋាភិបាលអោយចូលរួមក្នុងវគ្គបណ្តុះបណ្តាលរួមគ្នា ទស្សនកិច្ចសិក្សា និងស្វែងយល់សកម្មភាពរបស់គ្នាទៅវិញទៅមក ណែនាំអោយមានយន្តការសំរាប់ចែករំលែកព័ត៌មានរវាងគ្នាអោយបានទៀងទាត់ (ឧទាហរណ៍ ការផ្តល់ជូនអោយគ្នាទៅវិញទៅមកជាលក្ខណៈប្រព័ន្ធនូវឯកសារ របាយការណ៍ និងការរីកចំរើនថ្មីៗរវាងអ្នកឯកទេសតាមវិស័យពីភាគីរដ្ឋាភិបាល និងសង្គមស៊ីវិល) លើកទឹកចិត្តអ្នកឯកទេសរបស់រដ្ឋាភិបាលអោយរៀបចំវគ្គបណ្តុះបណ្តាល ឬវគ្គសិក្សាសំរាប់អង្គការសង្គមស៊ីវិល (លើខ្លឹមសារច្បាប់ គោលនយោបាយ ថវិកា កម្មវិធី...។ល។) ហើយអ្នកឯកទេសរបស់សង្គមស៊ីវិលក៏ធ្វើដូច្នេះវិញសំរាប់មន្ត្រីរដ្ឋាភិបាលដែរ ។ លើកទឹកចិត្តអ្នកតំណាងរដ្ឋាភិបាលអោយចូលរួមអោយបានសកម្មក្នុងកិច្ចប្រជុំ និងសិក្ខាសាលាដែលផ្តួចផ្តើមដោយអង្គការសង្គមស៊ីវិល ។ ការផ្លាស់ប្តូរបុគ្គលិក ឬ"ការបញ្ជូន" បុគ្គលិករយៈពេលខ្លីរវាងមន្ទីររបស់រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលអាចជាវិធីមួយផ្សេងទៀតដែលប្រកបដោយភាពច្នៃប្រឌិត ដើម្បីកសាងការយោគយល់ និងទំនុកចិត្តគ្នារវាងសង្គមស៊ីវិល និងសមាជិកក្នុងរាជរដ្ឋាភិបាល (*សកម្មភាពតំរូវទៅខាងរដ្ឋាភិបាល និងសង្គមស៊ីវិល ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍*) ។

## ៣. ការពង្រឹងការទទួលខុសត្រូវសង្គមនៅកម្ពុជា

### ៣.ក. សេចក្តីសន្និដ្ឋាន

១៣៦. **ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងការលើកកំពស់ការទទួលខុសត្រូវរបស់រដ្ឋាភិបាលនៅកម្ពុជា គឺជាអាទិភាពមួយដ៏ចំបងបំផុត ។** ការមានការទទួលខុសត្រូវសាធារណៈដ៏រឹងមាំ គឺជាធាតុមិនអាចខ្វះបានក្នុងការសំរេចនូវទិសដៅរួមនៃអភិបាលកិច្ចល្អ ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធិភាព ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការផ្តល់អំណាចដល់ប្រជាពលរដ្ឋ ។ ក្រៅពីកិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្នដើម្បីពង្រឹងយន្តការទទួលខុសត្រូវនិងអភិបាលកិច្ច "ផ្ទៃក្នុង" (ជាយន្តការរបស់អ្នកផ្តល់សេវា) **វាជាការសំខាន់ខ្លាំងណាស់ក្នុងការលើកកំពស់ និងពង្រីកយន្តការទទួលខុសត្រូវសង្គមដោយអ្នក "ខាងក្រៅ" (យន្តការរបស់ភាគីទទួលសេវា) ។**

១៣៧. ទំនាក់ទំនងនិងការផ្សារភ្ជាប់រវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាលនៅមានភាពទន់ខ្សោយនៅឡើយ ហើយមានបញ្ហាប្រឈមជាច្រើនពាក់ព័ន្ធទៅនឹងកត្តានយោបាយ វប្បធម៌-សង្គម ប៉ុន្តែទន្ទឹមនឹងនេះក៏មានឱកាសល្អៗជាច្រើនផងដែរ ។ ការដកពិសោធន៍លើកដំបូងទៅលើវិធីសាស្រ្តនៃការទទួលខុសត្រូវសង្គម (ដូចជាការវិភាគដោយឯករាជ្យទៅលើគោលនយោបាយ ការងារថវិកាជាក់ស្តែង ការត្រួតពិនិត្យនិងវាយតំលៃដោយមានការចូលរួម ការតស៊ូមតិ និងការពិភាក្សារវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល) បានបង្ហាញនូវ**សក្តានុពលធំធេង**សំរាប់អនុវត្តការទទួលខុសត្រូវសង្គមផង និង**ភាពនៅមានកំរិត និងឧបសគ្គ**ផង ។ ការសិក្សានេះបានស្នើឡើងនូវអនុសាសន៍ជាច្រើនសំរាប់ភាគីពាក់ព័ន្ធដូចជារដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ។ អនុសាសន៍ទាំងនេះត្រូវបានស្នើឡើងក្នុងបំណងធ្វើអោយបរិយាកាសកាន់តែមានលក្ខណៈអំណោយផលថែមទៀត សំរាប់ការទទួលខុសត្រូវសង្គមនៅកម្ពុជា និងដើម្បីកសាងនូវសមត្ថភាព និងជំនាញដែលចាំបាច់ (ទាំងក្នុងរង្វង់សង្គមស៊ីវិលនិងរដ្ឋាភិបាល) ។ អនុសាសន៍ទាំងនេះក៏ស្នើឡើងដើម្បីពង្រីក និងធ្វើស្ថាប័ននីយកម្មនូវដែន ហើយនិងយន្តការសំរាប់ការពិភាក្សា និងការចរចាររវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល ។ របាយការណ៍នេះក៏បានសង្កត់ធ្ងន់ផងដែរអំពីកាលវេលាសំរាប់ជំរុញអោយមានវប្បធម៌នៃ "ការទទួលខុសត្រូវចំពោះថ្នាក់ក្រោម" នៅគ្រប់កំរិតថ្នាក់ ព្រមជាមួយនឹងការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយារបស់ភាគីពាក់ព័ន្ធសំខាន់ៗ ។ ឧទាហរណ៍ តួអង្គនានាក្នុងរដ្ឋាភិបាលត្រូវបានសាកសួរដេញដោលដើម្បីអោយមានភាពបើកចំហ អត់ធ្មត់ចំពោះការរិះគន់ និងទទួលយកនូវទស្សនៈផ្សេងពីទស្សនៈរបស់ខ្លួន ឯតួអង្គនានាក្នុងសង្គមស៊ីវិលត្រូវបានជំរុញអោយប្រកាន់យកនូវជំហរដែលមានលក្ខណៈស្ថាបនា និងផ្តោតការយកចិត្តទុកដាក់ច្រើនទៅលើដំណោះស្រាយ ប្រជាពលរដ្ឋត្រូវបានលើកទឹកចិត្តអោយមានការចូលរួមអោយបានសកម្ម ហើយម្ចាស់ជំនួយត្រូវបានលើកទឹកចិត្តអោយប្រើប្រាស់នូវបទពិសោធន៍អន្តរជាតិរបស់ខ្លួនដើម្បីគាំទ្រដល់កំណែទំរង់គោលនយោបាយ យន្តការ និងការអនុវត្តការទទួលខុសត្រូវសង្គមនៅកម្ពុជា ។

១៣៨. បើទោះបីក្រុមអ្នកស្រាវជ្រាវបានចាត់ទុកថា អនុសាសន៍ទាំងអស់នៅក្នុងរបាយការណ៍នេះមានសារៈសំខាន់ ក៏**សកម្មភាពខាងក្រោម (ជាសកម្មភាពដែលមានប្រសិទ្ធិភាពជាយុទ្ធសាស្រ្ត) ត្រូវបានស្នើឡើងជាអាទិភាពខ្ពស់ (ទាំងសំរាប់រយៈពេលខ្លី និងរយៈពេលវែង) ។ ការផ្តល់អាទិភាពលើសកម្មភាពទាំងនេះត្រូវបានចូលរួមធ្វើឡើងដោយក្រុមពាក់ព័ន្ធនានានៅក្នុងការសិក្សានេះ ។ អាទិភាពទាំងនោះ គឺសំរាប់ភាគីចំបងៗដែលពាក់ព័ន្ធក្នុងការសិក្សានេះ ដែលក្នុងនោះរួមមានរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ។**

## ៣.៦. សកម្មភាពជាអាទិភាព

### ៣.៦.១. សកម្មភាពអាទិភាពសំរាប់រាជរដ្ឋាភិបាលកម្ពុជា

*សំរាប់រយៈពេលខ្លី :*

១៣៩. *សកម្មភាពជាអាទិភាពទី១សំរាប់រាជរដ្ឋាភិបាល* - **ណែនាំ(និងគាំទ្រ) ក្រុមប្រឹក្សាឃុំ-សង្កាត់អោយរៀបចំជាវេទិកាសាធារណៈពីរដងក្នុងមួយឆ្នាំ ។** (អនុសាសន៍ ក.២, ខ.៣, និង ឃ.៣)

ការស្រាវជ្រាវនេះបង្ហាញថា ក្រុមប្រឹក្សាឃុំ-សង្កាត់មានសក្តានុពលយ៉ាងធំធេង (ប៉ុន្តែពុំទាន់អភិវឌ្ឍអោយបានប្រសើរ) សំរាប់រៀបចំវេទិកាដើម្បីការពិភាក្សារវាងប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលគួរណែនាំអោយមានការរៀបចំធ្វើវេទិកាសាធារណៈពីរដងក្នុងមួយឆ្នាំអោយបានទៀងទាត់នៅថ្នាក់ឃុំ-សង្កាត់ សំរាប់ជាឱកាសអោយប្រជាពលរដ្ឋបានចូលរួមជាមួយអាជ្ញាធររដ្ឋាភិបាល លើបញ្ហានានាដែលជាសេចក្តីព្រួយបារម្ភចំបងរបស់ពួកគេ ។

១៤០. *សកម្មភាពជាអាទិភាពទី២សំរាប់រាជរដ្ឋាភិបាល-* **ចែងជាបញ្ញត្តិអោយបានច្បាស់លាស់អំពីការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងក្រុមប្រឹក្សាស្រុកនិងក្រុមប្រឹក្សាខេត្តដែលទើបបង្កើតឡើងថ្មីៗ** (អនុសាសន៍ក.២, ខ.៣ និងឃ.៣)

នៅពេលបច្ចុប្បន្ននេះ មានឱកាសតិចតួចណាស់សំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ។ រាជរដ្ឋាភិបាលត្រូវបានលើកទឹកចិត្តអោយចេញជាប្រកាសមួយ ដែលមានចែងជាបញ្ញត្តិច្បាស់លាស់ ដើម្បីប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលអាចចូលរួមយ៉ាងពេញលក្ខណៈនៅក្នុងក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខេត្តដែលបង្កើតឡើងថ្មីៗ (បង្កើតឡើងអនុលោមទៅតាមច្បាប់អង្គការដែលទើបត្រូវបានអនុម័តនាពេលថ្មីៗនេះ) ។

*សំរាប់រយៈពេលវែង :*

១៤១. *សកម្មភាពជាអាទិភាពទី៣សំរាប់រាជរដ្ឋាភិបាល* - **ណែនាំសាលារៀន និងមណ្ឌលសុខភាព និងមន្ទីរពេទ្យទូទាំងប្រទេសអោយចែករំលែកព័ត៌មាន អំពីថវិកាជាសាធារណៈ** (អនុសាសន៍ ក.២)

ការស្រាវជ្រាវនេះបានរកឃើញថា ប្រជាពលរដ្ឋខ្វះលទ្ធភាពទទួលបានព័ត៌មានអំពីសេវាសាធារណៈជាមូលដ្ឋានដែលមានផលប៉ះពាល់ដោយផ្ទាល់ដល់សុខុមាលភាពរបស់ពួកគេ ។ ដើម្បីលើកកំពស់តម្លាភាព និងការទទួលខុសត្រូវសង្គម រាជរដ្ឋាភិបាលត្រូវបានលើកទឹកចិត្តអោយផ្តល់ជាសេចក្តីណែនាំដល់សាលារៀន និងមណ្ឌលសុខភាព និងមន្ទីរពេទ្យនៅទូទាំងប្រទេសអោយចែករំលែកព័ត៌មានអំពីថវិកាជាសាធារណៈ ដើម្បីអោយអ្នកប្រើប្រាស់សេវា ឬប្រជាពលរដ្ឋ បានដឹងអំពីការប្រើប្រាស់ថវិកាសាធារណៈ (និងធនធានដទៃទៀត) នៅកន្លែងទាំងនេះ និងអោយគេបានដឹងអំពីការប្រើប្រាស់ធនធានទាំងនោះ ។ ជាអនុសាសន៍ សំរង់ហិរញ្ញវត្ថុប្រចាំឆ្នាំគួរបិតផ្សាយជាសាធារណៈ និងបង្ហាញជូនក្នុងពេលមានវេទិកាសាធារណៈប្រចាំឆ្នាំ ។

១៤២. *សកម្មភាពជាអាទិភាពទី៤សំរាប់រាជរដ្ឋាភិបាល* - **បង្កើតក្រុមប្រឹក្សាភិបាលអន្តរក្រសួង** (អនុសាសន៍ ឃ.១ និង ឃ.៣)

វេទិកាទៀងទាត់សំរាប់ការចែករំលែកព័ត៌មានរវាងតួអង្គនានាក្នុងសង្គមស៊ីវិល និងរដ្ឋាភិបាលនៅពុំទាន់មាននៅឡើយទេ ។ ជាអនុសាសន៍ រាជរដ្ឋាភិបាលគួរស្នើ (ឬណែនាំ) អោយបណ្តាក្រសួងពាក់ព័ន្ធបង្កើតឡើងនូវក្រុមប្រឹក្សាភិបាលអចិន្ត្រៃយ៍មួយ (ដែល

សមាសភាពរួមមានតំណាង ឬទីប្រឹក្សាពាក់ព័ន្ធពីផ្នែកសង្គមស៊ីវិល ផ្នែកសិក្សាធិការ និងវិស័យឯកជន ។ល។) ក្រុមទាំងនេះគួរជួបប្រជុំគ្នាជាទៀងទាត់ (ឧទាហរណ៍ ប្រចាំត្រីមាស) អាស្រ័យទៅតាមលក្ខន្តិកៈច្បាស់លាស់របស់ខ្លួន ដើម្បីជាការរួមចំណែកដល់ការលើកឡើង និងពិភាក្សាអំពីបញ្ហាដែលជាក្តីបារម្ភចំបងៗរបស់សាធារណជន ផ្តល់យោបល់ទៅលើឯកសារសំខាន់ៗ និងសំរបសំរួលដំណើរការពិគ្រោះយោបល់ជាសាធារណៈទៅលើច្បាប់ ឬគោលនយោបាយថ្មីៗ ។

### ៣.ខ.២. សកម្មភាពជាអាទិភាពសំរាប់អង្គការសង្គមស៊ីវិល

*សំរាប់រយៈពេលខ្លី :*

១៤៣. *សកម្មភាពជាអាទិភាពទី១សំរាប់អង្គការសង្គមស៊ីវិល*— **ពង្រីកគំនិតផ្តួចផ្តើមផ្នែកចងក្រង និងពង្រឹងអំណាចនៅថ្នាក់សហគមន៍** (អនុសាសន៍ ខ.១ និង គ.១)

ការកសាងចំណេះដឹង ទំនុកចិត្ត និងអំណាចរបស់ប្រជាពលរដ្ឋសាមញ្ញៗ (រួមមាន ស្ត្រី យុវជន និងក្រុមដទៃទៀតដែលគេមិនសូវយកចិត្តទុកដាក់) គឺជាផ្នែកមួយដ៏សំខាន់នៃការទទួលខុសត្រូវសង្គម ។ កង្វះការផ្តល់អំណាចដល់ប្រជាពលរដ្ឋនៅតាមសហគមន៍ គឺជាមូលហេតុចំបងដែលធ្វើអោយការឧបត្ថម្ភពីម្ចាស់ជំនួយក្នុងទសវត្សរកន្លងមកពុំសូវទទួលបានជោគជ័យ ក្នុងការជំរុញនូវការទាមទារដ៏សកម្មអោយមានអភិបាលកិច្ចល្អ ។ កិច្ចខិតខំក្នុងការពង្រឹងភាពអង់អាច គប្បីធ្វើឡើងដោយផ្អែកលើបទពិសោធន៍ និងការរៀនសូត្រពីទំរង់នានា ដូចជាសមាគមកសិករដែលទទួលការគាំទ្រពីអង្គការសេដាក និងសមាគមសុខភាពភូមិរបស់ក្រុមអភិវឌ្ឍន៍ភូមិ ដែលមានបំណងដោះស្រាយសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ហើយដែលក្នុងខណៈជាមួយគ្នានោះបានជួយពង្រឹងការសំដែងមតិ និងឥទ្ធិពលនយោបាយរបស់ពួកគេផង ។

១៤៤. *សកម្មភាពជាអាទិភាពទី២សំរាប់អង្គការសង្គមស៊ីវិល*— **ណែនាំអោយអនុវត្តនូវការធ្វើរបាយការណ៍ និងប្រកាន់នូវតម្លាភាពចំពោះ "ថ្នាក់ក្រោម"** (អនុសាសន៍ គ.២)

ដើម្បីក្លាយខ្លួនជាភ្នាក់ងារធ្វើការផ្នែកទទួលខុសត្រូវសង្គមដ៏មានប្រសិទ្ធិភាព អង្គការសង្គមស៊ីវិលខ្លួនឯងត្រូវខិតខំធ្វើជាគំរូគេផ្នែកអភិបាលកិច្ចល្អនេះ តាមរយៈការកែលំអអភិបាលកិច្ចផ្ទៃក្នុង និងកែលំអប្រព័ន្ធតម្លាភាពរបស់ខ្លួន និងការទទួលខុសត្រូវចំពោះថ្នាក់ក្រោម ។ ទិដ្ឋភាពចំបងមួយនៃចំណុចនេះ គឺគេត្រូវខ្នះខ្នែងចែករំលែកព័ត៌មានអំពីកម្មវិធី និងថវិកាជាមួយអតិថិជន និងប្រជាពលរដ្ឋគោលដៅ រួចហើយលើកទឹកចិត្តពួកគេអោយចូលរួមឃ្លាំមើលអោយបានសកម្ម ។

*សំរាប់រយៈពេលវែង :*

១៤៥. *សកម្មភាពជាអាទិភាពទី៣សំរាប់អង្គការសង្គមស៊ីវិល* - **អភិវឌ្ឍជំនាញអំពីវិធីសាស្ត្រតស៊ូមតិបែបចូលរួមដែល "យកប្រជាពលរដ្ឋជាចំបង"** (អនុសាសន៍ ខ.១)

អង្គការសង្គមស៊ីវិលមានតួនាទីដ៏សំខាន់ក្នុងការផ្តល់អំណាចដល់ប្រជាពលរដ្ឋ អោយគេធ្វើសកម្មភាព និងតស៊ូមតិដោយខ្លួនឯង ។ សំរាប់អង្គការសង្គមស៊ីវិលកម្ពុជា ការកសាងសមត្ថភាព និងជំនាញអំពីវិធីសាស្ត្រតស៊ូមតិ និងការអភិវឌ្ឍន៍ដែលមានការចូលរួម និងយកប្រជាពលរដ្ឋជាចំបងនោះ ត្រូវបានចាត់ទុកថាជាកិច្ចការមានអាទិភាពខ្ពស់ ។

១៤៦. *សកម្មភាពជាអាទិភាពទី៤សំរាប់អង្គការសង្គមស៊ីវិល* - **បង្កើតឡើងនូវតួនាទីសំរបសំរួលសំរាប់ការពិភាក្សារវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល** (អនុសាសន៍ ឃ.២)

បទពិសោធន៍បង្ហាញថា ការពិភាក្សារវាងប្រជាពលរដ្ឋនិងរដ្ឋាភិបាលទទួលបានផលយ៉ាងធំធេងបើមានការសំរបសំរួលពីភាគីទីបី ។ អង្គការសង្គមស៊ីវិលដើរតួនាទីយ៉ាងសំខាន់ជា "ស្ពាន" រវាងប្រជាពលរដ្ឋ និងអាជ្ញាធររដ្ឋាភិបាល ហើយអង្គការទាំងនោះត្រូវបានលើកទឹកចិត្តអោយបង្កើតឡើង និងពង្រីកតួនាទីទាំងនេះជាអាទិភាពខ្ពស់ (ជាពិសេសនៅថ្នាក់មូលដ្ឋាន) ។

## ៣.ខ.៣. សកម្មភាពជាអាទិភាពសំរាប់ដៃគូអភិវឌ្ឍន៍

*សំរាប់រយៈពេលខ្លី :*

១៤៧. *សកម្មភាពជាអាទិភាពទី១សំរាប់ដៃគូអភិវឌ្ឍន៍* - **គាំទ្រការបណ្តុះបណ្តាល និងការហ្វឹកហ្វឺនដល់អ្នកដឹកនាំបច្ចុប្បន្ន និងអនាគតអ្នកដឹកនាំថ្នាក់មូលដ្ឋាន** (អនុសាសន៍ ខ.២)

សំរាប់ប្រជាពលរដ្ឋសាមញ្ញ អ្នកដឹកនាំសហគមន៍ និងអ្នកដឹកនាំថ្នាក់មូលដ្ឋាន បានដើរតួយ៉ាងសំខាន់ជាអ្នករៀបចំ អ្នកអប់រំ អ្នកគាំទ្រ និងអន្តរការី ។ ហេតុដូច្នេះហើយ ការវិនិយោគទៅលើសមត្ថភាព និងជំនាញរបស់អ្នកដឹកនាំនៅថ្នាក់មូលដ្ឋាននេះ ដើម្បីអោយគេផ្តល់ការឆ្លើយតប និងទទួលខុសត្រូវចំពោះថ្នាក់ក្រោមគឺជាអាទិភាពមួយ ។ ដៃគូអភិវឌ្ឍន៍គួរលើកកំពស់ការគាំទ្រដល់អង្គការសង្គមស៊ីវិល ដែលបច្ចុប្បន្នកំពុងផ្តល់ការបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំក្នុងមូលដ្ឋាន និងគាំទ្រការកសាងសមត្ថភាពនៅក្នុងផ្នែកនេះ ។

១៤៨. *សកម្មភាពជាអាទិភាពទី២របស់ដៃគូអភិវឌ្ឍន៍* - **ណែនាំអោយអនុវត្តនូវការធ្វើរបាយការណ៍ និងការប្រកាន់នូវតម្លាភាពចំពោះ "ថ្នាក់ក្រោម"** (អនុសាសន៍ គ.២)

ដៃគូអភិវឌ្ឍន៍ត្រូវបានលើកទឹកចិត្តអោយ "ធ្វើជាគំរូ"តាមរយៈការអនុវត្តនូវការទទួលខុសត្រូវសង្គមអោយមានលក្ខណៈជាប្រព័ន្ធទៅក្នុងប្រតិបត្តិការរបស់ខ្លួន ដូចជា (ការធានាថាប្រជាពលរដ្ឋត្រូវបានផ្តល់ជូននូវព័ត៌មានអំពីថវិកាដែលបានផ្តល់ និងការប្រើប្រាស់ថវិកាទាំងនោះ ជាពិសេសអោយអ្នកទាំងនោះបានចូលរួមត្រួតពិនិត្យ និងវាយតំលៃទៅលើសកម្មភាពនៃការចំណាយទាំងនោះ) ។ នៅពេលដែលបានក្លាយទៅជាគំរូផ្នែកតម្លាភាព និងការរាយការណ៍ ដៃគូអភិវឌ្ឍន៍មិនត្រឹមតែបានលើកកំពស់ការឃ្លាំមើលជាសាធារណៈចំពោះថវិកានិងកម្មវិធីផ្ទាល់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានជួយប្រជាពលរដ្ឋអោយមើលឃើញជាក់ស្តែងពីរូបភាពនៃការទទួលខុសត្រូវសង្គម ហើយនិងអាចធ្វើអោយប្រជាពលរដ្ឋមានការរំពឹងទុកអំពីតម្លាភាព និងការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលផងដែរ ។

*សំរាប់រយៈពេលវែង :*

១៤៩. *សកម្មភាពជាអាទិភាពទី៣របស់ដៃគូអភិវឌ្ឍន៍* - **ពង្រីកការគាំទ្រដល់គំនិតផ្តួចផ្តើមនៅថ្នាក់សហគមន៍** (អនុសាសន៍ ខ.១ និង គ.១)

ការគៀងគរចងក្រង និងការផ្តល់អំណាចដល់ប្រជាពលរដ្ឋមានសារៈសំខាន់ណាស់ ចំពោះការអភិវឌ្ឍន៍របស់សង្គមស៊ីវិល និងការទទួលខុសត្រូវសង្គម ។ រហូតមកដល់ពេលនេះ មានជំនួយពីដៃគូអភិវឌ្ឍន៍តែមួយចំណែកតូចប៉ុណ្ណោះដែលត្រូវបានផ្តល់ជូនដោយផ្ទាល់ដើម្បីគាំទ្រការអប់រំ ការចងក្រងនិងការផ្តល់អំណាចដល់ប្រជាពលរដ្ឋនៅថ្នាក់សហគមន៍ ។ ដៃគូអភិវឌ្ឍន៍គួរបង្កើនការឧបត្ថម្ភដល់អង្គការសង្គមស៊ីវិលទាំងឡាយដែលធ្វើការដោយផ្ទាល់នៅតាមសហគមន៍ និងលើកទឹកចិត្តព្រមទាំងគាំទ្រអង្គការសង្គមស៊ីវិលថ្នាក់ជាតិអោយប្រកាន់យកនូវវិធីសាស្ត្រធ្វើការពីថ្នាក់ក្រោមទៅថ្នាក់លើ និងផ្សារភ្ជាប់អោយមានប្រសិទ្ធិភាពជាមួយសហគមន៍ ។

១៥០. *សកម្មភាពជាអាទិភាពទី៤របស់ដៃគូអភិវឌ្ឍន៍* - **ធ្វើការតស៊ូមតិ និងគាំទ្រអោយមានបរិយាកាសគោលនយោបាយអំណោយផលបន្ថែមទៀតសំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិល** (អនុសាសន៍ ឃ.១)

លើកទឹកចិត្ត និងគាំទ្ររាជរដ្ឋាភិបាលកម្ពុជាអោយដាក់ចេញនូវគោលនយោបាយ និយ័តកម្ម និងគោលការណ៍ណែនាំ ដែលបង្កើតអោយមាននូវដែនសាធារណៈសំរាប់ការរួបរួមជាសមាគមរបស់ប្រជាពលរដ្ឋ ប្រកាន់យក និងការពារសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ រួចហើយដាក់ចេញនូវវិធានជាមូលដ្ឋានសំរាប់ការពិភាក្សាប្រកបដោយពេញលក្ខណៈរវាងប្រជាពលរដ្ឋនិងរដ្ឋាភិបាលហើយត្រូវចាត់ទុកថាការចូលរួម គឺជាតួនាទីអាទិភាពរបស់ដៃគូអភិវឌ្ឍន៍ ។

# ឯកសារយោង

ADB (1999), *A Study of NGOs: Cambodia*, Phnom Penh, Cambodia

Appleton, H. (2005), *Identifying Opportunities for Collaboration to Promote Transparency and Accountability in Cambodia*. For DFID, Phnom Penh

Aschmoneit, W. (June 2004), *Khmer Buddhist Self Help Organizations and Development Cooperation* In "Civil Society in Southeast Asia: Cambodia - Scope and Concepts of a Conference", Projektgruppe Sozialforschung e. V. Munich, Germany

Bou, S. and Salazar, L. (2005), Cambodia Grassroots Media Assessment for the Social Accountability (Citizens Partnerships for Better Governance) Framework. World Bank Back-to-Office Report.

Burke, A. & Nil V. (2005), *Options for increasing social accountability in Cambodia*. For DFID and The World Bank, Phnom Penh

CAS/TAF (2003), *Democracy in Cambodia: A survey of the Cambodian electorate*, The Asia Foundation, Phnom Penh

CAS/World Bank (2007*), Social Accountability Public Opinion Poll Findings*, World Bank, Phnom Penh

CAS/World Bank (2007a), *Social Accountability NGO Postal Survey Findings*, World Bank, Phnom Penh

CAS/World Bank (2007b), *Social Accountability Case Study Findings*, World Bank, Phnom Penh

CAS/World Bank (Oct. 2006), *Justice for the Poor? An Exploratory Study of Collective Grievances over Land and Local Governance in Cambodia*, Phnom Penh.

CDC (June 2006), *Report on Mapping Survey of NGO/Association Presence and Activity in Cambodia*, CDC-NRE, Supported by Danida, Phnom Penh, Cambodia

CDC (July 2005), *Report on Local Governance, Civil Society and Local Accountability: How Do Citizens Perceive and Interact with the Commune Councils?* Supported by Danida, Phnom Penh

Chandler, D. (1991), *The Tragedy of Cambodian History. Politics, War and Revolution since 1945*, New Haven: Yale University Press

*Civil Society in Southeast Asia: Cambodia - Scope and Concepts of a Conference* (Jun-04), Projektgruppe Sozialforschung e. V. Munich, Germany

Colletta, Nat J. & Cullen, M. (2000), The Nexus between Violent Conflict, Social Capital and Social Cohesion: Case Studies from Cambodia and B¤anda, Washington DC: The World Bank

Collins, W. A. (May 1999), *The UNDP/CARERE Local Planning Process: Reinforcing Civil Society - Case Studies from Battambang*, Center for Advanced Study (CAS) Phnom Penh, Cambodia

Collins, W. A. (Nov. 1998), *Grassroots Civil Society in Cambodia* Phnom Penh, Cambodia

Collins, W. A. (1997), *Dynamics of Dispute Resolution and Administration of Justice for Cambodian Villagers*, A Preliminary Assessment funded by USAID, Phnom Penh

Commune Council Support Project (2006), *CCSP Decentralization Awards for Outstanding Local Organizations in Local Governance: "Promoting Practical Initiatives that Make a Difference"*, Phnom Penh

Commune Council Support Project (2005), *Promoting Social Accountability in Rural Cambodia: The Citizens Rating Report*, Phnom Penh

COPCEL ?

Danida (July 2005), *Village Associations, Rural Peoples Livelihoods, Local Governance and NRM,* Council for Development of Cambodia Phnom Penh, Cambodia

Danida (Jul-05), *Local Government, Civil Society and Local Accountability: How Do Citizens Perceive and Interact with the Commune Councils?* Council for Development of Cambodia Phnom Penh, Cambodia

Freedom House (2006), Countries at the Crossroads: *Country Report – Cambodia* http://www.freedomhouse.org/inc/content/pubs/fiw/inc_country_detail.cfm?year=2006.html

Goetz, A.M. and Gaventa, J. (2001) *From Consultation to Influence: Bringing Citizen Voice and Client Focus into Service Delivery*, IDS Working Paper 138. Institute od Development Studies, Sussex University, Brighton, UK

Harris, V. (2006), *Cambodian Development Workers as Cultural Change Agents*, Nordic Institute of Asian Studies Copenhagen, Denmark

Heder, S. & Ledgeb¤ood, J. (1996), *Propaganda, Politics and Violence in Cambodia: Democratic Transition under United Nations Peace-Keeping*. Armonk, NY

Heinrich, V. & Malena, C. (2007) "The CIVICUS Civil Society Index" in V. Heinrich and L. Fioramonti (eds) *A Global Survey of Civil Society*, CIVICUS, Johanessburg.

Henke, R. & Kim N. (2005), *Commune Councils in Cambodia: A National Survey on their Functions and Performance, with a Special Focus on Conflict Resolution*, The Asia Foundation, Phnom Penh

Hughes C.and Öjendal, J. (2006), "Reassessing Tradition in Times of Political Change: Post-War Cambodia Reconsidered" In: *Journal of Southeast Asian Studies*, Vol.37, No.3, pp.415-420

Hughes, C. (2006), "The Politics of Gifts: Tradition and Regimentation in Contemporary Cambodia" In: *Journal of Southeast Asian Studies*, Vol.37, No.3, pp. 469-489

Hughes, C Conway T. (Jan. 2004), *Understanding Pro-Poor Political Change: The Policy Process, Cambodia*, Oversees Development Institute, London, UK

Hughes, C. (2003), *The Political Economy of Cambodia's Transition, 1991-2001*, London

Hughes, C. (2001) An Investigation of Conflict Management in Cambodian Villages. Centre for Peace and Development, Cambodia Development Resource Centre, Phnom Penh.

*Independent Study on Options for Future Donor Support to Decentralization and Deconcentration Contributing to Democratic Development in Cambodia*, GTZ Administration Reform and Decentralization Project (ARDP) & Ministry of Interior – The National Committee for Support to Communes/Sangkat, Phnom Penh

Kao Kim Hourn (1999), *Emerging Civil Society in Cambodia: Opportunities and Challenges*, Cambodian Institute for Cooperation and Peace (CICP), Phnom Penh, Cambodia

Khlok S. et al. (2003), *Margin to Mainstream. An Assessment of Community-based Organizations in Cambodia*, For World Bank Cambodia, Phnom Penh

Khus, T. (June 2004), *Cambodian Civil Society Movement* In "Civil Society in Southeast Asia: Cambodia - Scope and Concepts of a Conference", Projektgruppe Sozialforschung e. V Munich, Germany

Kim, S. Sovatha, A. (July 2005), *Decentralization: Can Civil Society Enhance Local Government's Accountability in Cambodia?* In "Cambodia Development Review", Volume 9, Issue 3, CDRI Phnom Penh, Cambodia

Kim, S. (June 2004), *Local Government Responsiveness: Can Building Civil Society Enhance Accountability in Cambodia's Political Context?* In "Civil Society in Southeast Asia: Cambodia - Scope and Concepts of a Conference", Projektgruppe Sozialforschung e. V. Munich, Germany

Kim, S. (Oct. 1999), The *Impact of Socioeconomic and Buddhist Life in Rural Cambodia on Development Sectors of NGOs and the Government*, Northern Illinois University, USA

Knight, K., Nareth, D. (2005), *Evaluation of the Participation of Village Network and Traditional Associations in the Commune Investment Planning Process in Kampong Thom*, GTZ Kampong Thom, Cambodia

Knowles, J. et al. (2007), *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review*, Phnom Penh: CDRI

Knowles, J. (July 2007), *Rural Investment for Local Governance: Assessment of Commune-Sangkats Fund Accountability Working Groups*, (Final Draft) Phnom Penh

Ledgeb¤ood, J. & Vijghen, J. (2002), “Decision Making in Rural Khmer Villages” in Ledgeb¤ood, J. (ed.), Cambodia Emerges from the Past: Eight Essays, Dekalb, pp.108-150

Luco, F. (2002), *Between a Tiger and a Crocodile: Management of Local Conflicts in Cambodia. An Anthropological Approach to Traditional and New Practices*, Phnom Penh: UNESCO

MacLean, L. (2006), *Cambodia Country Study Report*, Transparency International Berlin

Makin, J. (2006), *Cambodia: Women and Work in the Garment Industry*, ILO’s Better Factory Cambodia and The World Bank’s Justice for the Poor, Phnom Penh.

Malena, C. et al. (2007), *BUILDING THE DEMAND-SIDE OF GOOD GOVERNANCE: ENHANCING CONDITIONS FOR SOCIAL ACCOUNTABILITY IN GHANA*, CDD AND WORLD BANK, GHANA.

Malena, C. et al. (2004), *Social Accountability: An Introduction to the Concept and Emerging Practice*, Washington DC. The World Bank

Mansfield, C. March, L. Bounnath, S. (Jan. 2004), *Commune Councils and Civil Society: Promoting Decentralization through Partnerships*, Pact Cambodia Phnom Penh, Cambodia

Mansfield, C. MacLeod, K. (May 2002), *Advocacy in Cambodia: Increasing Democratic Space*, Pact Cambodia Phnom Penh, Cambodia

Marks, S. (1999), “Elusive Justice for the victims of the Khmer Rouge”, In: *Journal of International Affairs*, Vol.52, No. 2

Marston, J. (1997), *Cambodia 1991-94: Hierarchy, Neutrality and Etiquettes of Discourse*, PhD thesis, University of Washington

McNeil, M. and Mumvuma, T. (2006), *Demanding Good Governance: A Stocktaking of Social Accountability Initiatives by Civil Society in Anglophone Africa*, WBI Working Paper, Washington, D.C, World Bank Institute.

Meas N. (2006), *Challenges of Human Development in the Contemporary Social Process and Change – A Cambodian Perspective*, Working Paper for World Bank, Phnom Penh

Meas, N, Healy, J. (July 2003), *Towards Understanding Cambodian Villages Beyond War*, Sisters of St. Joseph, Sydney, Australia

NGO Forum on Cambodia (2007), Analysis of the Implementation of the 2007 Budget and the 2008 Budget Law, NGO Forum, Phnom Penh.

Nissen, Ch. (2005), *Living Under the Rule of Corruption: An Analysis of Everyday Forms of Corrupt Practices in Cambodia*, Report on Qualitative Research Component, Phnom Penh: CSD

Nissen, Ch. & Henke, R. (2005), *Corruption and Cambodian Households: Household Survey on Perceptions, Attitudes and Impact of Everyday Forms of Corrupt Practices in Cambodia*, Report on Quantitative Research Component, Phnom Penh: CSD/CAS

Ojendal, J and Kim, S. (2006), "Korob, Kaud, Klach: In Search of Agency in Rural Cambodia" In: *Journal of Southeast Asian Studies*, 37 (3), The National University of Singapore

O'Leary, M. P. (2006), *The Influence of Values on Development Practice: A Study of Cambodian Development Practitioners in Non-Governmental Organisations in Cambodia*, La Trobe University Melbourne, Australia

O'Leary, M. & Meas, N. (2001). *Learning for Transformation. A Study of the Relationship between Culture, Values, Experience and Development Practice in Cambodia*. Phnom Penh: Krom Akphiwat Phum.

Ovesen, J. Trankell, I.B. & Ojendal, J. (1996), *When Every Household is an Island: Social Organization and Power Structures in Rural Cambodia*, Uppsala Research Reports, Sweden: Uppsala University

Pellini, A. Ayres, D. (2006), *Community Participation in Local Governance in Cambodia: Learning from the Village Networks Approach*, Phnom Penh, Cambodia

Pellini, A. (2006), *Community Support to Schools: Exploring the Characteristics of Traditional Forms of Social Capital in Cambodia* In "Perspectives in Education" Vol.22, n.3, Phnom Penh, Cambodia

Pellini, A. & Ayres, D. (2005), Social *Capital and Village Governance: Experience with Village Networks*, A discussion paper, For GTZ Phnom Penh

Pellini, A. (August 2005), *Social Capital and Civil Society: Traditional Associations' Support to Education in Kampong Thom, Cambodia*, GTZ Phnom Penh, Cambodia

Pellini, A. (July 2005), *Traditional Forms of Social Capital in Cambodia and their Linkage with Local Development Processes* In "Cambodia Development Review", Volume 9, Issue 3, CDR Phnom Penh, Cambodia

Pellini, A. (June 2004), *Traditional Pagoda Associations and the Emergence of Civil Society in Cambodia*, GTZ Phnom Penh, Cambodia

Pellini, A. (June 2004), *Traditional Pagoda Associations and the Emergence of Civil Society in Cambodia* In "Civil Society in Southeast Asia: Cambodia - Scope and Concepts of a Conference", Projektgruppe Sozialforschung e. V. Munich, Germany

Peou S. (2004), *International Assistance for Institution Building in Post-Conflict Cambodia*, Netherlands Institute of International Relations 'Clingendael', Working Paper 26, in cooperation with CICP

Public Affairs Foundation, Sirker K. and Cosic, S. (2007), *Empowering the Marginalized: Case Studies of Social Accountability Initiatives in Asia, Washington, D.C., World Bank.*

*Report on the Conference on the Meaning of Community in Cambodia*, June 7-8, 1999, Working Group on Social Organization in Cambodia

Richmond, O. & Franks, J. (2007), "Liberal Hubris? Virtual Peace in Cambodia", In: *Security Dialogue*, Vol.38, No.1, pp.27-48

Royal Government of Cambodia (2006), *National Development Strategic Plan 2006-2010 for Growth, Employment, Equity and Efficiency to Reach Cambodia's Millennium Development Goals*, Approved by the Council of Ministers meeting 27 January 2006, Phnom Penh

Royal Government of Cambodia (2004), *Implementing the Rectangular Strategy and Development Assistance Need*, Prepared for the 2004 Consultative Group Meeting for Cambodia, Phnom Penh

Rusten, C. et al. (2004), *The Challenges of Decentralization Design in Cambodia*, Phnom Penh: CDRI

SIDA (Jan. 2006), *Civil Society and Uncivilized Politics: Trends and Roles of the Cambodian Civil Society and Possibilities for Sida Support*, The Eighth Report of the Sida Advisory Team on Democratic Governance in Cambodia, Phnom Penh, Cambodia

SIDA (March 2003), *Civil Society and Democracy in Cambodia: Changing Roles and Trends*, The Fifth Report of the Sida Advisory Team on Democratic Governance Phnom Penh, Cambodia

Slocomb, M. (2006), "The Nature and Role of Ideology in the Modern Cambodian State", In: *Journal of Southeast Asian Studies*, Vol.37, No.3, pp.375-395.

Transparency International (2006), *Cambodia Country Report*.

Un Kheang (2004), *Democratization without Consolidation: The Case of Cambodia, 1993-2004*, PhD thesis, Dekalb: Northern Illinois University

UNIFEM, WB, ADB, UNDP and DFID/UK.(2004) *A Fair Share for Women: Cambodia Gender Assessment*. Phnom Penh,

Vijghen, J. (April 2001), *Cambodian Human Rights and Democracy Organizations: Understanding NGOs*, Experts for Community Research Phnom Penh, Cambodia

Vijghen, J. (1997), *Non-Governmental Organizations in Cambodia anno 1997: Assessment of Capacity, Legal Framework and Co-operation*, ADB Phnom Penh, Cambodia

Wallgren, P. (Sept. 2005), *Forum Syd Study on Local Associations*, Forum Syd Phnom Penh, Cambodia

Wharton, D. (Dec. 2003), *Assessment and Identification of the Role and Potential of the Pagoda Committee (Pacoco) on Issues Related to Local Governance and Decentralization*, GTZ Phnom Penh, Cambodia

World Bank (Feb. 2006), Cambodia – Halving poverty by 2015? Poverty Assessment 2006, Prepared by the World Bank for the Consultative Group Meeting, Phnom Penh

World Bank (April 2005), Cambodia – Country Assistance Strategy of the World Bank Group 2005 – 2008, Partners in Development Assisting Cambodia to attain its Millennium Development Goals, Phnom Penh

World Bank (Dec. 2005), *Cambodia – Public Expenditure Tracking Survey (PETS) in Primary Education*, Report N. 34911-KH, East Asia and Pacific Region.

World Bank (Nov. 2004), *Cambodia at the Crossroads: Strengthening Accountability to Reduce Poverty*, Report No. 30636-KH, East Asia and the Pacific Region

Yonekura, Y, (1999), *The Emergence of Civil Society in Cambodia: Its Role in the Democratization Process*, University of Sussex, UK

Zepp, R. (2004), “The Aid Industry: A frank discussion of local and international NGOs” In: *Experiencing Cambodia*, unpublished paper, Phnom Penh, pp.65-78

# សទ្ទានុក្រម

**ការទទួលខុសត្រូវ** គឺជាកាតព្វកិច្ចរបស់អ្នកកាន់អំណាច (អ្នកកាន់អំណាចនយោបាយ ហិរញ្ញវត្ថុ ឬទំរង់អំណាចផ្សេងៗទៀត) ក្នុងការបំពេញករណីយកិច្ច និងឆ្លើយតបចំពោះសកម្មភាពរបស់ខ្លួន ។ អ្នកកាន់អំណាចទាំងនោះ អាចរួមមានមន្ត្រីរដ្ឋាភិបាល សាជីវកម្មឯកជន ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងអង្គការសង្គមស៊ីវិល ។

**ការផ្តល់អំណាចដល់ប្រជាពលរដ្ឋ** គឺជាការពង្រីកនូវទ្រព្យសម្បត្តិ និងសមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងការចូលរួម ចរចារ ជះឥទ្ធិពល គ្រប់គ្រង និងធ្វើអោយស្ថាប័នដែលមានឥទ្ធិពលលើជីវិតរបស់ពួកគេ មានការទទួលខុសត្រូវ ។

**ការចូលរួមរបស់ប្រជាពលរដ្ឋ** គឺជាដំណើរការដែលប្រជាពលរដ្ឋ និង/ឬ អង្គការសង្គមស៊ីវិលមានឥទ្ធិពល និងចូលរួមគ្រប់គ្រង លើការកំណត់អាទិភាព ការបង្កើតគោលនយោបាយ ការបែងចែកធនធាន និងលទ្ធភាពក្នុងការទទួលបានសំភារៈ និងសេវា សាធារណៈ ។

**ប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ** (CRCs) គឺជាការអង្កេតបែបចូលរួម ដែលប្រមូលយោបល់ពី*អ្នកប្រើប្រាស់* អំពីការផ្តល់សេវា សាធារណៈ ។ ប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ តែងធ្វើឡើងជាមួយនឹងការយកព័ត៌មានដោយប្រព័ន្ធផ្សព្វផ្សាយ និងការតស៊ូមតិរបស់សង្គមស៊ីវិល ដើម្បីទាមទារអោយមានការទទួលខុសត្រូវជាសាធារណៈ ។

**ការពាក់ព័ន្ធរបស់ប្រជាពលរដ្ឋ** គឺជាការចូលរួមរបស់អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋទូទៅតាមរយៈ ការប្រាស្រ័យទាក់ទង ដោយផ្ទាល់ និងដោយប្រយោលជាមួយរដ្ឋាភិបាល ស្ថាប័នពហុភាគី និងគ្រឹះស្ថានអាជីវកម្ម ដើម្បីមានឥទ្ធិពលទៅលើការសំរេចចិត្ត និងចែករំលែកការគ្រប់គ្រង លើការកំណត់អាទិភាព ការបង្កើតគោលនយោបាយ ការបែងចែកធនធាន និងលទ្ធភាពក្នុងការ ទទួលសំភារៈ និងសេវាសាធារណៈ ។

**សង្គមស៊ីវិល** គឺជាដែនសាធារណៈដែលនៅក្រៅរដ្ឋាភិបាល ទីផ្សារ និងគ្រួសារ ដែលប្រជាពលរដ្ឋ និងបណ្តាអង្គការក្រៅរដ្ឋាភិបាល ព្រមទាំងអង្គការមនុស្សធម៌ផ្សេងទៀត អាចប្រាស្រ័យទាក់ទងគ្នា សំដែងពីចំណាប់អារម្មណ៍ និងគុណតំលៃរបស់ខ្លួន និងខិតខំ ដើម្បីផលប្រយោជន៍រួម ។

**ប័ណ្ណដាក់ពិន្ទុរបស់សហគមន៍** (CSC) គឺជាឧបករណ៍ត្រួតពិនិត្យមួយរបស់សហគមន៍ ដែលប្រមែប្រមូលការយល់ឃើញរបស់អ្នក ប្រើប្រាស់អំពីគុណភាព ប្រសិទ្ធិភាព និងតម្លាភាព ។ ជាងនេះទៀត ដំណើរការដាក់ពិន្ទុដោយសហគមន៍នេះ រួមមានការជួបប្រជុំ ដោយផ្ទាល់ រវាងអ្នកផ្តល់សេវានិងសហគមន៍ ដែលការធ្វើបែបនេះនាំអោយមានការផ្តល់ព័ត៌មានត្រលប់ភ្លាមៗ ។ ដូច្នេះ នេះជា ឧបករណ៍ ដើម្បីទាមទារអោយមានការទទួលខុសត្រូវ និងការឆ្លើយតបពីអ្នកផ្តល់សេវាភ្លាម ហើយក៏ជាមធ្យោបាយសំរាប់ការ ផ្តល់អំណាចដល់ប្រជាពលរដ្ឋផងដែរ ។

**ការទទួលខុសត្រូវចំពោះថ្នាក់ក្រោម** សំដៅដល់ការទទួលខុសត្រូវរបស់អ្នកកាន់អំណាចក្នុងសង្គម (ដូចជារដ្ឋាភិបាល សាជីវកម្ម ឯកជន ម្ចាស់ជំនួយ ។ល។) ចំពោះអ្នកដែលមិនសូវមានអំណាច (ដូចជាប្រជាពលរដ្ឋសាមញ្ញ) ។ ការទទួលខុសត្រូវចំពោះថ្នាក់ក្រោម គឺជា គោលការណ៍ស្នូលនៃលទ្ធិប្រជាធិបតេយ្យ ។

**អភិបាលកិច្ចល្អ** គឺជាលទ្ធភាពរបស់រដ្ឋាភិបាល ក្នុងការ ១) ធានាអោយមានតម្លាភាពផ្នែកនយោបាយ និងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋគ្រប់រូប ២) ផ្តល់សេវាសាធារណៈដែលឆាប់រហ័ស និងប្រកបដោយប្រសិទ្ធិភាព ៣) លើកកំពស់សុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ និង ៤) បង្កើតនូវបរិយាកាសអនុគ្រោះមួយ សំរាប់ស្ថិរភាពនៃកំណើនសេដ្ឋកិច្ច ។

**ការវិភាគថវិកាដោយឯករាជ្យ (IBA)** គឺជាវាក្យស័ព្ទមួយដែលត្រូវបានប្រើប្រាស់ដើម្បីសំដៅដល់កិច្ចការវិភាគ និងការតស៊ូមតិរបស់សង្គមស៊ីវិល និងអង្គការឯករាជ្យដទៃទៀត ក្នុងបំណងធ្វើអោយការប្រើប្រាស់ថវិកាសាធារណៈកាន់តែមានតម្លាភាព និងក្នុងបំណងមានឥទ្ធិពលទៅលើការបែងចែកមូលនិធិសាធារណៈ ។ ការងារវិភាគថវិកាដោយឯករាជ្យ គៀងគរសាធារណៈមតិ តាមរយៈការបង្ហាញអំពីលក្ខណៈដែលបរិមាណថវិកានោះពាក់ព័ន្ធនឹងតំរូវការប្រចាំថ្ងៃ ។

**ការរៀបចំថវិកាដោយមានការចូលរួម** គឺជាយន្តការ ឬដំណើរការមួយដែលប្រជាពលរដ្ឋ និង/ឬ អង្គការសង្គមស៊ីវិល ចូលរួមដោយផ្ទាល់នៅក្នុងដំណាក់កាលផ្សេងៗនៃការរៀបចំថវិកា ការធ្វើសេចក្តីសំរេចចិត្ត និងការត្រួតពិនិត្យការប្រតិបត្តិថវិកា ។

**ការតាមដានការចំណាយដោយមានការចូលរួម** គឺជាយន្តការ ឬដំណើរការមួយដែលប្រជាពលរដ្ឋតាមដានលំហូរហិរញ្ញវត្ថុ និងទំនិញ តាមវដ្តនៃការចំណាយសាធារណៈ តាំងពីប្រភពដើមរហូតដល់គោលដៅនៃការបញ្ជូន ។

**ការត្រួតពិនិត្យ និងវាយតំលៃដោយមានការចូលរួម (PM&E)** គឺជាដំណើរការមួយដែលភាគីពាក់ព័ន្ធនៅកំរិតផ្សេងៗគ្នាចូលរួមនៅក្នុងការត្រួតពិនិត្យ ឬវាយតំលៃគំរោងកម្មវិធី ឬគោលនយោបាយជាក់លាក់ណាមួយ ហើយចែករំលែកការគ្រប់គ្រងទៅលើខ្លឹមសារ ដំណើរការ និងលទ្ធផលនៃសកម្មភាពត្រួតពិនិត្យ និងវាយតំលៃនោះ ព្រមទាំងចូលរួមក្នុងការកំណត់រក ឬចាត់វិធានការណ៍កែតំរូវរួមគ្នា ។

**ការរៀបចំគោលនយោបាយដោយមានការចូលរួម** គឺជាដំណើរការមួយដែលប្រជាពលរដ្ឋ និង/ឬអង្គការសង្គមស៊ីវិលចូលរួមដោយផ្ទាល់នៅក្នុងការរៀបចំគោលនយោបាយ និងផែនការសាធារណៈ ។

**ការទទួលខុសត្រូវសង្គម** សំដៅដល់បណ្តាសកម្មភាព និងយន្តការទាំងឡាយ (លើសពីលើការបោះឆ្នោត) ដែលប្រជាពលរដ្ឋ និងអង្គការរបស់ពួកគេអាចយកមកប្រើប្រាស់ ដើម្បីធ្វើអោយអ្នកកាន់អំណាចក្នុងសង្គម(ដូចជារដ្ឋាភិបាល) ផ្តល់ការទទួលខុសត្រូវ ។ ការទទួលខុសត្រូវសង្គមក៏សំដៅផងដែរដល់បណ្តាសកម្មភាពរបស់រដ្ឋាភិបាល សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងតួអង្គដទៃទៀតក្នុងសង្គម ដែលលើកកំពស់ ឬ សំរបសំរួលដល់កិច្ចខិតខំប្រឹងប្រែងបែបនេះរបស់ប្រជាពលរដ្ឋ ។

**សវនកម្មសង្គម** (ជួនកាលហៅថាគណនេយ្យសង្គម) គឺជាដំណើរការមួយដែលព័ត៌មានស្តីអំពីធនធាន (របស់គំរោង កម្មវិធី ឬអង្គការ) និងការប្រើប្រាស់ធនធានទាំងនោះត្រូវបានប្រមូល វិភាគ និងចែករំលែកជាសាធារណៈ ក្នុងរូបភាពដែលមានការចូលរួម ។ គោលគំនិតចំបងនៃសវនកម្មសង្គមគឺអំពីរបៀបប្រើប្រាស់ធនធានធៀបនឹងគោលបំណងសង្គម ។

**តម្លាភាព** គឺជាស្ថានភាពមួយដែលគោលបំណងរបស់គោលនយោបាយ ក្របខ័ណ្ឌផ្នែកច្បាប់ ផ្នែកស្ថាប័ន និងសេដ្ឋកិច្ចរបស់គោលនយោបាយ ការសំរេចចិត្ត និងសនិទានភាពគោលនយោបាយ ទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងគោលនយោបាយ ផ្នែករូបិយវត្ថុ និងហិរញ្ញវត្ថុ ព្រមទាំងការទទួលខុសត្រូវរបស់អង្គភាពរៀបចំគោលនយោបាយ ត្រូវបានផ្តល់ជូនដល់សាធារណជន តាមរបៀបមួយដែលអាចយល់បាន អាចរកបាន និងទាន់ពេលវេលា ។

**ការិយាល័យធនាគារពិភពលោកប្រចាំនៅកម្ពុជា**
**១១៣ មហាវិថីព្រះនរោត្តម**
**ទូរស័ព្ទ:** (៨៥៥ ២៣) ២១៧ ៣០៤
**ទូរសារ:** (៨៥៥ ២៣) ២១០ ៥០៤

**មណ្ឌលព័ត៌មានសាធារណៈ**
**៧០ មហាវិថីព្រះនរោត្តម**
**ទូរស័ព្ទ:** (៨៥៥ ២៣) ២១០ ៩២២
**ទូរសារ:** (៨៥៥ ២៣) ២១០ ៣៧៣

**វែបសាយ:** ជាភាសាខ្មែរ www.worldbank.org.kh
ជាភាសាអង់គ្លេស www.worldbank.org/kh